សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ខែមេសា ឆ្នាំ ២០១៦

# លីអាហូណា




## តើព្រះគម្ពីរត្រូវបានបកប្រែតាមរបៀបណា ? ទំព័រ ២០

ការស្គាល់សាវកថ្មីរបស់យើងគឺ អែលឌើរ រ៉ូណាល អេ រ៉ាសបាន ទំព័រ ១២

អ្នកផ្សព្វផ្សាយសាសនារៀមច្បង ៖ ត្រូវបានហៅឲ្យបម្រើ ទំព័រ ២៦

នៅពេលស្វាមីមានការលំបាកជាមួយនឹងការណ៍អាសគ្រាម ភរិយាត្រូវការការព្យាបាលផងដែរ ទំព័រ ៣៤

រៀនលេងទំនុកតម្កើងមួយបទក្នុងរយៈពេល១០នាទី ទំព័រ ៥៤



*« ដ្បិតមើលចុះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា ឱវង្សអ៊ីស្រាអែលអើយ យើងនឹងប្រៀបធៀបអ្នកទៅនឹងដើមអូលីវស្រុក ដែលបុរសម្នាក់បានយកមកដាំ ឲ្យជីជាតិនៅក្នុងចម្ការរបស់គាត់. . .*

*« . . .ហើយមានពរហើយ ព្រោះដោយអ្នករាល់គ្នាបានធ្វើការយ៉ាងព្យាយាមជាមួយនឹងយើងនៅក្នុងចម្ការនេះ ហើយបានកាន់តាមព្រះបញ្ញត្តិរបស់យើង ហើយបានផ្តល់ផ្លែធម្មជាតិដល់យើងទៀត ដើម្បីកុំឲ្យចម្ការយើងរលួយខូចទៀតឡើយ ឯមែកអាក្រក់ទាំងឡាយត្រូវបានកាត់បោះចោល ហើយមើលចុះអ្នករាល់គ្នានឹងមានសេចក្តីអំណរជាមួយនឹងយើង ដោយសារផ្លែឈើនៃចម្ការរបស់យើង » ។*

**យ៉ាកុប ៥:៣, ៧៥**

ដើមអូលីវ ត្រូវបានគេដាំដុះយ៉ាងច្រើនសន្ធឹកនៅពេញទូទាំងប្រទេសមេឌីទែរ៉ាណេ ហើយវាត្រូវបានគេនិយាយជាយូរលង់ណាស់មកហើយនៅក្នុងប្រវត្តិសាស្ត្រព្រះគម្ពីរ ចាប់តាំងពីសត្វព្រាបសបាននាំស្លឹកអូលីវមកឲ្យណូអេ រហូតដល់ការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅលើភ្នំអូលីវ រហូតទៅដល់រូបាធិស្ឋានរបស់យ៉ាកុបអំពីដើមអូលីវ ។

# លីអាហូណា ខែ មេសា ឆ្នាំ ២០១៦



៤

## សារលិខិត


**៤ សារលិខិតគណៈប្រធានទីមួយ: ការព្យាករ និង វិវរណៈផ្ទាល់ខ្លួន**
ដោយ ប្រធាន ហិនរី ប៊ី អាវរិង

**៧ សារលិខិតបង្រៀនសួរសុខទុក្ខ: បុត្រីនៃព្រះវរបិតាដ៏អស់កល្បជានិច្ចរបស់យើង**


## អត្ថបទពិសេសៗ


**១២ អែលឌើ រ៉ូណល អេ រ៉ាសបាន ៖ អ្នកដឹកនាំដ៏បប៉ិនប្រសប់ ឪពុកដ៏មានភក្តីភាព**
ដោយអែលឌើរ អិម រ័សុល បាឡឺដ
*ជាស្វាមី និង ឪពុកដែលពេញដោយក្តីស្រឡាញ់ អែលឌើ រ៉ូណល អេ រ៉ាសបាន បានអភិវឌ្ឍជំនាញនៃភាពជាអ្នកដឹកនាំអំពីការប្រឹក្សា អស់រយៈពេលជាច្រើនឆ្នាំ មកពីថ្នាក់ដឹកនាំជំនួញ និង ថ្នាក់ដឹកនាំបព្វជិតភាពដ៏ចំណាន ។*

**១៨ *តើគាត់* ជាប៊ីស្សពឬ ?**
ដោយ ផាទ្រីក ជេ ក្រូនិន ទី III
*ខ្ញុំបានយល់ពីមូលហេតុដែលនាងពុំអាចជឿថា ឥឡូវនេះខ្ញុំកំពុងបម្រើជាប៊ីស្សពហើយ ។ សាមសិបឆ្នាំមុនខ្ញុំគឺជាមនុស្សផ្សេងពីពេលឥឡូវនេះខ្លាំងណាស់ ។*


**នៅលើក្របមុខ**
គម្របមុខ និង ខាងក្នុងគម្របខាងក្រោយ ៖ រូបថតដោយ ឡេស នៀលសុន ខាងក្នុងគម្របខាងមុខ ៖ រូបថត © RayTango/Thinkstock ។


**២០ ការបកប្រែព្រះគម្ពីរ ៖ ឲ្យទៅជាភាសានៃដួងចិត្តរបស់យើង**
ដោយ អ័រ វ៉ាល ចនសុន
*ការអានព្រះគម្ពីរជាភាសារបស់យើងផ្ទាល់គឺដូចជាការត្រឡប់មកផ្ទះវិញខាងវិញ្ញាណ ។*

**២៦ ឱកាសនានានៃពួកអ្នកផ្សព្វផ្សាយសាសនាវៀមច្បង**
ដោយប្រធាន រ័សុល អិម ណិលសុន
*សូមអធិស្ឋានពីឱកាសនេះ ដើម្បីបង្កើតឱកាសដ៏អស្ចារ្យក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាវៀមច្បងរួមគ្នា ។*

**២៨ អ្នកផ្សព្វផ្សាយសាសនាវៀមច្បង ៖ មានគេត្រូវការ ត្រូវបានប្រទានពរ និង ត្រូវបានស្រឡាញ់**
ដោយ រីឆាត អិម. រ៉មនី
*គូស្វាមីភរិយារកឃើញថាការបម្រើបេសកកម្មគឺមានភាពកាន់តែអាចបត់បែនបាន ចំណាយតិច និង កាន់តែរីករាយជាងអ្វីដែលពួកគេបានគិតទៅទៀត ។*

**៣៤ នៅពេលដែលការណ៍អាសគ្រាមវាយប្រហារនៅក្នុងផ្ទះ — នោះទាំងភរិយា និង ស្វាមីត្រូវការការព្យាបាល**
ឈ្មោះត្រូវបានដកចេញ
*ប៊ីស្សពមួយរូបបានចែកចាយរបៀបដែលគាត់មិនត្រឹមតែបានជួយដល់ស្វាមីដែលមានការលំបាកជាមួយនឹងការណ៍អាសគ្រាមឡើយ ប៉ុន្តែថែមទាំងបានជួយដល់ភរិយា ដែលត្រូវការការព្យាបាលរបស់ព្រះអង្គសង្គ្រោះយ៉ាងច្រើនដូចគ្នាផងដែរ ។*

**៣៨ អ្នកយាមនៅលើប៉ម**
*ពង្រីកការយល់ដឹងរបស់អ្នកអំពីព្យាការីដោយការរៀនពីរបៀបដែលពួកលោកដូចជាអ្នកយាមនៅលើប៉ម ។*


## ផ្នែកនានា


**៨ ការគិតពិចារណា: តើយល់សេចក្តីណែនាំឬទេ ?**
ដោយ រ៉ុស ស៊ីវើរ

**៩ ការបម្រើនៅក្នុងសាសនាចក្រ: សូមអរគុណសម្រាប់ការបម្រើរបស់អ្នក**
ឈ្មោះត្រូវបានដកចេញ

**១០ ដំណឹងល្អពីបុរាណ: បព្វជិតភាព ៖ យុទ្ធាដ៏មាំមួន**
ដោយ អែលឌើរ អិល ថម ភែរី

**៤០ សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

**៨០ លុះត្រាជួបទៀត : ស្វែងរកអំណោយទានខាងវិញ្ញាណ**
ដោយប្រធាន ចច យ្ស ឃែណុន

## យុវមជ្ឈិមវ័យ


៤៨


**៤៤ ការទទួលស្គាល់ភាពក្លែងបន្លំរបស់សាតាំង**
ដោយ ដេនីស ស៊ី ហ្គូន
*តាមរយៈការរកមើលភាពខុសគ្នារវាងការកុហករបស់សាតាំង និង ការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ ជំនួសឲ្យការមើលពីភាពស្រដៀងគ្នា នោះយើងនឹងអាចទទួលស្គាល់ពីភាពក្លែងបន្លំរបស់សាតាំង ។*

**៤៨ ទំព័រយុវមជ្ឈិមវ័យ: ការវាស់វែងពីពរជ័យនៅក្នុងប្រទេសម៉ាដាហ្គាស្ការ**
ដោយ មីនឌី អាន សេលូ
*ទោះបីជាការរស់នៅក្នុងប្រទេសមួយដែលមានភាពលំបាកក្ដី សូឡូហ្វូ រ៉ាវែអូចោណា មានអារម្មណ៍ថាជីវិតរបស់គាត់គឺពោរពេញដោយពរជ័យ ។*




***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ ធ្វើតាមការជូនដំណឹងនេះ គឺ ធ្វើតាមព្យាការី ។***

## យុវវ័យ


**៥០ ស្មោះភាពខាងវិញ្ញាណ ៖ ការសង់កប៉ាល់មួយដែលមិនអាចលិចបាន**
ដោយ អែលឌើរ ឌេល ជី រេនឡាន់

**៥៤ រៀនលេងទំនុកតម្កើងមួយបទក្នុងរយៈពេល ១០នាទី !**
ដោយ ដានីយ៉ែល ខាធើរ

**៥៧ បានតាំងចិត្តដើម្បីឈប់**
ដោយ ហ្គេតជិន ប្លាកបើន
*ខ្ញុំនឹងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីឈប់លេងព្យាណូ ដូច្នេះនៅពេលឪពុកម្ដាយរបស់ខ្ញុំនិយាយថា ខ្ញុំអាចឈប់លេងបាន ប្រសិនបើខ្ញុំបានរៀនចេះទំនុកតម្កើងបាន៥០បទ នោះខ្ញុំបានចាប់ផ្ដើមលេងវា ។*

**៥៨ ការភ័យរន្ធត់ ភាពទុក្ខព្រួយ និង ផែនការរបស់ព្រះ**
ដោយ ប៉ោឡា កាជូពី
*ក្រឡេកទៅមើលពីបទពិសោធន៍នៃភាពហិចហោចដ៏ខ្លាំងបំផុតនៃជីវិតរបស់ខ្ញុំ ឥឡូវនេះខ្ញុំដឹងថា ព្រះវរបិតាសួគ៌បានគង់នៅជាមួយខ្ញុំគ្រប់ពេលវេលាទាំងអស់ ។*

**៦០ ទោះបីជាអ្នកអៀនខ្មាសក៏ដោយ**
ដោយ អែលឌើរ ចូសេ អេ តិក្សសៃរ៉ា
*សូមទុកចិត្តលើព្រះអម្ចាស់ ហើយទ្រង់នឹងប្រទានពរជ័យដល់អ្នក នៅក្នុងកិច្ចខិតខំរបស់អ្នក ដើម្បីចែកចាយដំណឹងល្អ ។*

**៦២ ទីកន្លែងរបស់យើង**

**៦៣ ប័ណ្ណប្រកាស: តើមើលទៅគួរឲ្យឆ្ងាញ់មែនទេ ?**

**៦៤ សំណួរ និង ចម្លើយ**
*ខ្ញុំត្រូវបានគេចំអកឲ្យនៅសាលារៀន ដោយសារខ្ញុំជាពួក អិល.ឌី.អេស. ។ ខ្ញុំដឹងថាខ្ញុំត្រូវការពារជំនឿរបស់ខ្ញុំ ប៉ុន្តែវាពិតជាពិបាកណាស់ ! តើខ្ញុំនឹងមានចិត្តក្លាហានគ្រប់គ្រាន់បានដោយរបៀបណា ?*


## កុមារ


៧៦


**៦៦ ចម្លើយមកពីសាវក: តើពួកសាវកធ្វើអ្វីខ្លះ ?**
ដោយអែលឌើរ ដាវីឌ អេ បែដណា

**៦៧ សេចក្ដីសុខសាន្តនៅក្នុងដួងចិត្តខ្ញុំ**
ដោយ ខារ៉ុល អេហ្វ ម៉ាកខន់ឃី
*នៅពេលខ្ញុំបានឃើញព្យាការី ហើយស្ដាប់លោកមានប្រសាសន៍ នោះខ្ញុំមានអារម្មណ៍នៃភាពសុខសាន្ត ។*

**៦៨ ទីបន្ទាល់របស់អ៊ីថាន**
ដោយ ឡារី ហិល្លី
*គ្រប់គ្នាទំនងជាមាននូវទីបន្ទាល់មួយលើកលែងតែអ៊ីថានប៉ុណ្ណោះ ។*

**៧០ ប្រាក់ពេសួសម្រាប់ព្រះវរបិតាសួគ៌**
ដោយ អែនជេឡា ផេណា ដាលី
*ដោយពុំមានប្រាក់នៅសល់ នោះអាណាឆ្ងល់ថា « តើយើងនឹងញុំាអ្វីនៅថ្ងៃស្អែក ? »*

**៧២ ការធ្វើតាមពួកព្យាការី និង ពួកសាវក**
ដោយ ជេណា កូហ្វ៊ង
*តើអ្នកអាចធ្វើតាមព្យាការីក្នុងខែនេះយ៉ាងដូចម្ដេច ?*

**៧៤ វីរបុរសក្នុងព្រះគម្ពីរមរមន: អាលម៉ាបានប្រែចិត្ត**

**៧៥ ខ្ញុំអាចអានព្រះគម្ពីរមរមន**

**៧៦ រឿងចេញពីព្រះគម្ពីរមរមន: អាលម៉ាជ្រមុជទឹកមនុស្សជាច្រើននាក់**

**៧៩ ទំព័រផាត់ពណ៌: ថ្ងៃឈប់សម្រាកជាថ្ងៃដ៏ពិសេសមួយ**

**ខែ មេសា ឆ្នាំ ២០១៦ ភាគទី ៤០ លេខ ៤**
**លីអាហូណា ១៣២៨៤**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម. រ័សុល បាឡឺដ, រ៉ូប៊ីត ឌី ហែល, ជេហ្វ្រី អ័រ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវ៉ែនសុន, ឌែល ជី រេនឡាន់

**អ្នកកែសម្រួល ៖** យ៉ូសែប ដបុលយូ. ស៊ីតាទី
**ជំនួយការអ្នកកែសម្រួល ៖** ជេមស៍ ប៊ី ម៉ាទីណូ, ខារ៉ូ អេហ្វ ម៉ាកខន់ឃី
**អ្នកប្រឹក្សា ៖** ប្រេន ខេ អាស្តុន, រ៉េនដល ឃេ បិនណ្ណិត, ក្រេក អេ ខារដុន, ឆារិល អេ អេសព្លិន, គ្រីស្តូហ្វែល ហ្គូលឌិន, ដូហ្គ្លាស ឌី ហូលមែស, ល៉េរី អរ ឡរិន, ខារ៉ូល អិម ស្ទេហ្វិន

**នាយកគ្រប់គ្រង ៖** ដេវីឌ ធី វ៉ើរ
**នាយកគ្រប់គ្រងប្រតិបត្តិការ ៖** វិនសិន អេ វ៉ូន
**នាយកគ្រប់គ្រងទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន
**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ វ៉ាល ចនសុន
**ជំនួយការការគ្រប់គ្រងផ្នែកកែសម្រួល ៖** រ៉ាយអិន ខា
**ជំនួយការបោះពុម្ព ៖** មេហ្គិន វើរហ្វូហ្វ
**និពន្ធ និងកែសម្រួលដោយ ៖** ប្រ៊ីតថានី ប៊ីតធី, ដេវីឌ ឌិកសុន, ដេវីដ អេ អែតវើត, ម៉ាថាយ ឌី ហ្វ៊ីតតុន, ឡារី ហ្វលើរ, ហ្គារែត អេច ហ្គាហ្វ, ឡារ៉ែន ផតទើរ ហ្គាន, ជីល ហាកឃីង, ឆាលឡូត ឡាកាំបាល់, ម៉ៃឃល អរ ម៉ូរីស, សាលី ចនសុន អូដេឃឹក, យ៉ូស្វេ ជេ ភឺគី, ចាន់ ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី អាន សេលូ, ប៉ុល វ៉ាន់ឌិន បើហ្គ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កុត នូដសិន
**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ថែដ អ័រ ភីធើរសុន
**រចនាប្លង់ដោយ ៖** ជីនិត អាន់ឌ្រូ, ហ្វេ ភី អាន់ត្រូស, មែនឌី បិនថ៍លី, ស៊ី ឃីមបឹល បុត, ថូម៉ាស ឆាល, ណាត ហ្គិនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្គិន, ស្កុត អិម មូ៉យ, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ នីកូល វ៉កឃិនហូស៍
**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលេត នេបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខន្នី បិវឡូប ប្រ៊ីច, ជូលី ប៊ឺដេត, ខេទី ដានខាន, ប្រេអិន ដ័បុលយូ ជីជី, ជិន្នីស ឌឺប៊ី, ជីន្នី ជេ និលសុន, ហ្គែល ធេត រ៉ាហ្វីធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្ទីវិន អ័រ គ្រីស្ទានសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬសាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុន្មាន គឺប្រែប្រួលទៅតាមភាសា ) ។

© 2016 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
April 2016 Vol. 15 No. 2. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# យោបល់នានាសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារបាន ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយ ។*



« **ទោះបីជាអ្នកខ្មាស់អៀនក៏ដោយ** » ទំព័រ ៦០ ៖ អ្នកអាចប្រើពេលវេលានៃរាត្រីជួបជុំក្រុមគ្រួសាររបស់ខ្លួនដើម្បីចែកចាយដំណឹងល្អ ! សូមពិភាក្សាជាមួយគ្រួសារពីក្ដីបារម្ភនានាដែលវាធ្វើឲ្យពិបាកដល់អ្នក ដើម្បីចែកចាយដំណឹងល្អ ។ អ្នកអាចអធិស្ឋានជាគ្រួសារថា ព្រះអម្ចាស់នឹងជួយអ្នកឲ្យទទួលអារម្មណ៍នៃការមានទំនុកចិត្តក្នុងការចែកចាយដំណឹងល្អ ហើយក្រោយមកអធិស្ឋានថាតើនរណាដែលអ្នកអាចអញ្ជើញឲ្យមកកាន់រាត្រីជួបជុំក្រុមគ្រួសារ ។ សូមគិតពីការអញ្ជើញសមាជិកម្នាក់ៗក្នុងគ្រួសារឲ្យថ្លែងទីបន្ទាល់អំឡុងពេលបង្រៀនមេរៀន ។ អ្នកអាចជ្រើសរើសបង្រៀនមេរៀនអំពីការស្ដារឡើងវិញ ឬ ផែនការនៃសេចក្ដីសង្គ្រោះ ។ សូមគិតពីការកត់ត្រាបទពិសោធន៍ និង អារម្មណ៍របស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។

## មានធនធានជាច្រើនទៀតនៅលើអ៊ិនធើរណែត

*លីអាហូណា* និង ធនធានផ្សេងៗទៀតរបស់សាសនាចក្រ មានជាច្រើនភាសានៅលើគេហទំព័រ **languages.lds.org** ។ សូមមើលគេហទំព័រ **facebook.com/liahona.magazine** ( ដែលមានជាភាសាអង់គ្លេស ភាសាព័រទុយហ្គាល់ និង ភាសាអេស្ប៉ាញ ) ដើម្បីរកសារលិខិតដ៏បំផុសគំនិតនានា គំនិតសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ និង ឯកសារដែលអ្នកអាចចែកចាយជាមួយមិត្តភក្តិ និង គ្រួសាររបស់អ្នក ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទនោះ ។*

*ការក្លែងបន្លំ, ៤៤, ៦៣*
*ការគោរពប្រតិបត្តិ, ៨, ៣៤, ៦២, ៧២*
*ការណ៍អាសគ្រាម, ៣៤*
*ការធ្វើឲ្យសកម្មឡើងវិញ, ១៨*
*ការបង្រៀន, ៧៥*
*ការបង្រៀនសួរសុខទុក្ខតាមផ្ទះ, ៩*
*ការបម្រើ, ៩, ២៦, ២៨, ៤១*
*ការប្រែចិត្ត, ១៨, ៧៤*
*ការប្រែចិត្តជឿ, ៤៣, ៥៨, ៧៥, ៧៦*
*ការហៅ, ១៨*
*ការអត់ទោស, ៣៤*
*ការអធិស្ឋាន, ៤១, ៦៤*
*កិច្ចការផ្សព្វផ្សាយសាសនា,២៦, ២៨, ៦០*
*ដង្វាយធួន, ៣៤*
*ដង្វាយមួយភាគក្នុងដប់, ៦២, ៧០*
*តន្ត្រី, ៥៤, ៥៧*
*ថ្ងៃឈប់សម្រាក, ៧៩*
*ទីបន្ទាល់, ៦៤, ៦៨*
*ទុក្ខព្រួយ, ៥៨*
*ទេពកោសល្យ, ៤០, ៥៤*
*និស្ស័យនៃព្រះ, ៧*
*ពិធីបុណ្យជ្រមុជទឹក, ៧៥, ៧៦*
*ពួកព្យាការី និង ពួកសាវក, ១០, ១២, ៦៦, ៦៧, ៧២*
*ព្រះគម្ពីរ, ២០*
*ព្រះគម្ពីរមរមន, ៤៣, ៤៤*
*ព្រះបញ្ញត្តិ, ៨, ៧២*
*ព្រះយេស៊ូវគ្រីស្ទ, ២០, ៣៤, ៤៣, ៥៨*
*ព្រះវិញ្ញាណបរិសុទ្ធ, ៤៤, ៥០*
*ភាពក្លាហាន, ៤៨, ៦៤*
*ភាពជាសិស្ស, ១២, ២៦*
*ភាពទៀងត្រង់, ៦២*
*វិរិណៈ, ៤, ១០, ២០, ៤១, ៤២, ៥០, ៧០, ៧២*
*សេចក្ដីជំនឿ, ៣៤, ៤៨, ៥៨, ៦០*
*សេចក្ដីសុខសាន្ត, ៥០, ៦៧*
*សេចក្ដីស្រឡាញ់, ៤០*
*អំណោយទានខាងវិញ្ញាណ, ៨០*



**ដោយប្រធាន**
**ហិនរី ប៊ី អាវរិង**
ទីប្រឹក្សាទីមួយក្នុង
គណៈប្រធានទីមួយ

# ការព្យាករ និង វិវរណៈផ្ទាល់ខ្លួន

សាសនាចក្រដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានស្ដារឡើងវិញនៅលើផែនដីសព្វថ្ងៃនេះ ។ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ តែងតែត្រូវបានដឹកនាំដោយព្យាការី និង សាវក ដែលកំពុងរស់នៅ ដោយទទួលការណែនាំជាបន្តបន្ទាប់មកពីឋានសួគ៌ ។

គំរូដ៏ទេវភាពនេះគឺមានភាពពិតដូចពីជំនាន់បុរាណដែរ ។ យើងរៀននៅក្នុងព្រះគម្ពីរប៊ីប ៖ « ពិតប្រាកដជាព្រះយេហូវ៉ាទ្រង់នឹងមិនធ្វើអ្វីដូច្នោះឡើយ លើកតែទ្រង់សម្ដែងឲ្យពួកហោរាជាអ្នកបម្រើទ្រង់ឃើញគំនិតលាក់កំបាំងរបស់ទ្រង់ផង » ( អេម៉ុស ៣:៧ ) ។

ព្រះបានមានព្រះបន្ទូលសារជាថ្មីម្ដងទៀតនៅជំនាន់របស់យើងនេះតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ។ ទ្រង់បានបើកសម្ដែងតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ នូវដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនៅក្នុងភាពពោរពេញរបស់វា ។ ទ្រង់បានស្ដារបព្វជិតភាពដ៏បរិសុទ្ធរបស់ទ្រង់ឡើងវិញ ជាមួយនឹងកូនសោរបស់វា ព្រមទាំងសិទ្ធិអំណាច និង មុខងារទាំងអស់នៃអំណាចដ៏ពិសិដ្ឋនៃបព្វជិតភាព ។

នៅក្នុងជំនាន់របស់យើង ព្យាការី និង សាវកនៅរស់ត្រូវបានប្រទាននូវសិទ្ធិអំណាចដើម្បី និយាយ បង្រៀន និង ដឹកនាំដោយប្រើសិទ្ធិអំណាចមកពីព្រះដ៏ជាព្រះវរបិតា និង ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ ព្រះអង្គសង្គ្រោះបានមានបន្ទូលទៅព្យាការីថា « អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ ហើយយើងពុំកែដោះសារខ្លួនឡើយ ហើយទោះជាផ្ទៃមេឃហើយផែនដី នឹងកន្លងបាត់ទៅក៏ដោយ គង់តែពាក្យរបស់យើងនឹងមិនកន្លងបាត់ដែរ ប៉ុន្តែពាក្យទាំងអស់នឹងបានសម្រេច ទោះជាដោយសំឡេងរបស់យើងផ្ទាល់ ឬក៏ដោយសំឡេងនៃពួកអ្នកបម្រើរបស់យើងក្ដី គឺដូចតែគ្នា » ( គ. និង ស. ១:៣៨ ) ។

នៅក្នុងសន្និសីទទូទៅពីរដងក្នុងមួយឆ្នាំ យើងមានពរដោយមានឱកាសស្ដាប់ព្រះបន្ទូលនៃព្រះអម្ចាស់ដល់ពួកយើងមកពីអ្នកបម្រើរបស់ទ្រង់ » ។ នោះគឺជាឯកសិទ្ធិមួយដែលមិនអាចកាត់ថ្លៃបានឡើយ ។ ប៉ុន្តែគុណតម្លៃនៃឱកាសនោះគឺអាស្រ័យទៅលើ ថាតើយើងទទួលព្រះបន្ទូលនោះក្រោមព្រះចេស្ដានៃព្រះវិញ្ញាណដដែលនោះដែលព្រះបន្ទូលទាំងនោះត្រូវបានប្រទានឲ្យដល់អ្នកបម្រើទាំងនោះ ( សូមមើល គ. និង ស. ៥០:១៩–២២ ) ។ គឺដូចជាពួកលោកដែលទទួលបាននូវសេចក្ដីណែនាំមកពីឋានសួគ៌ដែរ នោះយើងក៏ត្រូវទទួលវាបែបដូច្នោះដែរ ។ ហើយនោះវាតម្រូវពីយើងនូវការខិតខំខាងវិញ្ញាណដដែលនោះ ។

**« ចូរខិតខំសង្វាតរកវា »**

ច្រើនឆ្នាំកន្លងមកហើយ មានសមាជិកម្នាក់នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានសុំខ្ញុំឲ្យអានសុន្ទរកថាសន្និសីទមួយ ដែលលោកបានរៀបចំសម្រាប់សន្និសីទទូទៅ ។ ខ្ញុំគឺជាសមាជិកថ្មីម្នាក់នៃកូរ៉ុម ។ ខ្ញុំមានកិត្តិយសដោយទទួលបានការទុកចិត្តពីគាត់ថា ខ្ញុំអាចជួយគាត់រកព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលនឹងនាំឲ្យលោកថ្លែងឡើង ។ លោកបាននិយាយជាមួយខ្ញុំដោយស្នាមញញឹម « អូ៎ នេះគឺជាសុន្ទរកថាព្រាងលើកទី២២ហើយ » ។

ខ្ញុំបានចាំពីដំបូន្មានជាទីស្រឡាញ់ និង ស្រទន់របស់ប្រធាន ហារ៉ូល ប៊ី លី ( ឆ្នាំ ១៨៩៩–១៩៧៣ ) ដល់ខ្ញុំកាលពីមុនមក ដោយការសង្កត់ធ្ងន់យ៉ាងខ្លាំង ៖ « ហាល ប្រសិនបើអ្នកចង់ទទួលវិវរណៈ ចូរខិតខំសង្វាតរកវា » ។

ខ្ញុំបានអាន សញ្ជឹងគិត និង អធិស្ឋានលើសេចក្ដីព្រាងទី ២២នោះ ។ ខ្ញុំបានសិក្សាដោយអស់ពីសមត្ថភាពខ្ញុំក្រោមព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ នៅពេលសមាជិកកូរ៉ុមនោះបានចែកចាយសុន្ទរកថារបស់លោក នោះខ្ញុំបានបញ្ចប់ការខិតខំសង្វាតរបស់ខ្ញុំដើម្បីទទួលនូវសារលិខិតនោះ ។ ខ្ញុំពុំប្រាកដថា ខ្ញុំបានជួយអ្វីដល់គាត់ឡើយ ប៉ុន្តែខ្ញុំដឹងថាខ្ញុំត្រូវបានផ្លាស់ប្ដូរនៅពេលខ្ញុំស្ដាប់ឮសុន្ទរកថានោះបានថ្លែង ។ សារលិខិតបានចូលក្នុងដួងចិត្តខ្ញុំ លើសពីព្រះបន្ទូលដែលខ្ញុំធ្លាប់អាន និង



អ្វីដែលគាត់និយាយនោះទៅទៀត ។ ព្រះបន្ទូលនោះមានអត្ថន័យកាន់តែអស្ចារ្យជាងកាលដែលខ្ញុំអានសេចក្ដីព្រាងនោះទៅទៀត ។ ហើយសារលិខិតនោះ ហាក់បីដូចជាចង់និយាយអំពីខ្ញុំ វាត្រូវម៉ាច់នឹងតម្រូវការរបស់ខ្ញុំ ។

ពួកអ្នកបម្រើរបស់ព្រះបានតមអាហារ និង អធិស្ឋានដើម្បីទទួលសារលិខិត ដែលទ្រង់ប្រទានដល់ពួកគេឲ្យ ផ្ដល់ដល់អស់អ្នកដែលត្រូវការវិវរណៈ និង ការបំផុសគំនិត ។ អ្វីដែលខ្ញុំបានរៀនពីបទពិសោធន៍នោះ និង បទពិសោធន៍ផ្សេងៗទៀតស្រដៀងនេះដែរគឺថា ដើម្បីបានប្រយោជន៍ដ៏ធំមហិមាដែលមានមកពីការស្ដាប់ព្យាការី និង សាវកនៅរស់នោះយើងត្រូវខិតខំសង្វាតដោយខ្លួនយើងផ្ទាល់ដើម្បីទទួលវិវរណៈ ។

ព្រះអម្ចាស់ស្រឡាញ់មនុស្សគ្រប់គ្នា ដែលអាចឮសារលិខិតរបស់ទ្រង់ ហើយទ្រង់ស្គាល់ពីដួងចិត្ត និង កាលៈទេសៈរបស់បុគ្គលម្នាក់ៗ ។ ទ្រង់ស្គាល់ពីអ្វីដែលត្រឹមត្រូវ អ្វីដែលលើកទឹកចិត្ត និង អ្វីដែលសេចក្ដីពិតនៃដំណឹងល្អនឹងជួយបុគ្គលម្នាក់បានល្អបំផុត ដើម្បីជ្រើសរើសផ្លូវដើររបស់ខ្លួន ទៅតាមផ្លូវឆ្ពោះទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ។

ពេលខ្លះយើងដែលជាអ្នកស្ដាប់ និង អានសារលិខិតនៃសន្និសីទទូទៅក្រោយមកគិតថា « តើខ្ញុំចាំអ្វីបានល្អបំផុត ? » សេចក្ដីសង្ឃឹមរបស់ព្រះអម្ចាស់ចំពោះយើងម្នាក់ៗគឺថាចម្លើយរបស់យើងគឺ ៖ « ខ្ញុំនឹងមិនភ្លេចពីឱកាសនោះឡើយ គឺនៅពេលខ្ញុំទទួលអារម្មណ៍ពីសំឡេងនៃព្រះវិញ្ញាណនៅក្នុងគំនិត និង ដួងចិត្តរបស់ខ្ញុំ ដោយប្រាប់ខ្ញុំពីអ្វីដែលខ្ញុំអាចធ្វើដើម្បីគាប់ព្រះទ័យព្រះវរបិតាសួគ៌ និង ព្រះអង្គសង្គ្រោះរបស់ខ្ញុំ » ។

យើងអាចទទួលបានវិវរណៈផ្ទាល់ខ្លួននោះនៅពេលយើងស្ដាប់ព្យាការី និង សាវក ហើយនៅពេលយើងធ្វើវាដោយសេចក្ដីជំនឿដើម្បីទទួលវិវរណៈ នោះគឺដូចជាប្រធាន លីបានមានប្រសាសន៍ថាយើងអាចធ្វើវាបាន ។ ខ្ញុំដឹងថារឿងនោះពិតមកពីបទពិសោធន៍នេះ និង ដោយសាក្សីនៃព្រះវិញ្ញាណ ។ ■

## ការបង្រៀនចេញពីសារលិខិតនេះ

សូមគិតពីការអានរឿងរបស់ប្រធាន អាវរិង ឲ្យឮៗអំពីការសិក្សាសេចក្ដីព្រាងនៃសុន្ទរកថាសន្និសីទរបស់សមាជិកនៃកូរ៉ុមរបស់លោក ។ អ្នកក៏អាចនឹងសួរសំណួរថា « តើអ្វីខ្លះគឺជាតម្លៃនៃការទទួលវិវរណៈ ? » បន្ទាប់ពី ការពិភាក្សារបស់អ្នក អ្នកអាចអញ្ជើញអស់អ្នកដែលអ្នកសួរសុខទុក្ខ ឲ្យសញ្ជឹងគិត ហើយដាក់ផែនការ ដើម្បីទទួលសារលិខិតសន្និសីទទូទៅដែលនឹងមាននាពេលខាងមុខ « ក្រោមព្រះចេស្ដានៃព្រះវិញ្ញាណដដែលនោះ ដែលវិវរណៈនោះត្រូវបានប្រទានដល់អ្នកបម្រើ [ របស់ព្រះ ] » ។

រូបថត នៅក្នុងទីក្រុង ហេលស៊ីនគី ហ្វាំងឡង់ ដោយ គូកា ហ្វ្រីស្រម

## ព្រះវរបិតាសួគ៌បានមានបន្ទូលមកខ្ញុំតាមរយៈសុន្ទរកថាសន្និសីទ

ដោយ អានី ឡាឡេស្កា អាល់វេស ដេ ស៊ូស្សា

ខ្ញុំកំពុងមានចម្ងល់អំពីអ្វីដែលខ្ញុំគួរតែសិក្សានៅសាកលវិទ្យាល័យ ។ មនុស្សភាគច្រើនបាននិយាយមិនល្អអំពីវគ្គសិក្សាដែលខ្ញុំចង់រៀន ដូច្នោះខ្ញុំបានអធិស្ឋានដល់ព្រះអម្ចាស់ ដើម្បីដឹងថាទ្រង់យល់ស្របជាមួយនឹងការសម្រេចចិត្តរបស់ខ្ញុំដែរឬទេ ។

ចម្លើយរបស់ខ្ញុំបានកើតមាននៅថ្ងៃបន្ទាប់ ខណៈដែលខ្ញុំកំពុងអានសុន្ទរកថាសន្និសីទមួយនៅក្នុង *លីអាហូណា* ។ ខ្ញុំមានអារម្មណ៍ថា ទោះបីជាព្រះវរបិតាសួគ៌កំពុងប្រាប់ខ្ញុំថា ទ្រង់ពុំអាចជ្រើសរើសវាសម្រាប់ខ្ញុំក្ដី — នេះគឺជាការសម្រេចចិត្តមួយដែលខ្ញុំនឹងធ្វើវាដោយខ្លួនឯង ។ ខ្ញុំដឹងថាមិនថាខ្ញុំជ្រើសរើសរៀនអ្វីឡើយ ខ្ញុំនឹងត្រូវខំរៀនសូត្រយ៉ាងខ្លាំងដើម្បីទទួលបានជោគជ័យ ។



ខ្ញុំដឹងថា ខ្ញុំបានទទួលចម្លើយចំពោះការអធិស្ឋានរបស់ខ្ញុំ ។ ការបញ្ជាក់ពីព្រះវិញ្ញាណបរិសុទ្ធបានជួយខ្ញុំឲ្យធ្វើការសម្រេចចិត្ត ។ ខ្ញុំបានរៀនដើម្បីខិតខំឲ្យអស់ពីសមត្ថភាពរបស់ខ្លួន ហើយដឹងថាព្រះវរបិតាសួគ៌នឹងជួយខ្ញុំ ។

*អ្នកនិពន្ធរស់នៅសើរហ្គីប ប្រទេសប្រេស៊ីល ។*

ការរចនារូបថតដែលថតដោយតួសម្ដែង



## ធ្វើតាមព្យាការី

ព្យាការី និង សាវកនិយាយជំនួសព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ ពួកលោកបង្រៀនយើងពីរបៀបដើម្បីដើរតាមព្រះយេស៊ូវ ។ សូមដើរតាមផ្លូវនានា ដើម្បីទៅដល់អ្វីមួយចំនួន ដែលព្យាការី និង សាវកបានស្នើសុំឲ្យយើងធ្វើ ។





រូបគំនូរដោយ វ៉ល ឆាដវីក បាហ្គឡេ

*សូមសិក្សាឯកសារនេះប្រកបដោយការអធិស្ឋាន ហើយព្យាយាមស្វែងរកអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងអំពី « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » បង្កើនសេចក្ដីជំនឿរបស់អ្នកទៅលើព្រះ ហើយប្រទានពរដល់អ្នកទាំងឡាយដែលអ្នកថែទាំតាមរយៈការបង្រៀនសួរសុខទុក្ខយ៉ាងដូចម្ដេច ? សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ reliefsociety.lds.org ។*

# បុត្រីនៃព្រះវរបិតាដ៏អស់កល្បជានិច្ចរបស់យើង



ព្រះគម្ពីរបង្រៀនយើងថា « យើងរាល់គ្នាជាពូជព្រះហើយ » ( កិច្ចការ ១៧:២៩ ) ។ ព្រះបានហៅអិមម៉ា ស្ម៊ីធ ភរិយារបស់ព្យាការីយ៉ូសែប ស្ម៊ីធ ថាជា « បុត្រីរបស់យើង » ( គ. និង ស. ២៥:១ ) ។ ការប្រកាសដល់ក្រុមគ្រួសារ បង្រៀនយើងថាយើងម្នាក់ៗគឺជា « បុត្រី . . . សំណព្វប់ខាងវិញ្ញាណរបស់ព្រះបិតាមាតាសួគ៌ » ។[1]

ខារ៉ូល អិម ស្ទេហ្វិន ទីប្រឹក្សាទីមួយក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅមានប្រសាសន៍ថា « នៅក្នុងនគរនៃ [ ជីវិតមុនផែនដី ] យើងបានរៀនអំពីអត្តសញ្ញាណនៃភាពជាស្ត្រីដ៏អស់កល្បជានិច្ចរបស់យើង ។

« ដំណើរនៃជីវិតរមែងស្លាប់របស់យើងមកកាន់ផែនដីនេះពុំផ្លាស់ប្ដូរសេចក្ដីពិតទាំងនោះឡើយ » ។[2]

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា « ព្រះវរបិតារបស់អ្នកដែលគង់នៅស្ថានសួគ៌ ស្គាល់ឈ្មោះរបស់អ្នក និងស្គាល់ពីកាលៈទេសៈនានារបស់អ្នក » ។ « ទ្រង់ស្ដាប់ពុការអធិស្ឋានរបស់អ្នក ។ ទ្រង់ត្រាស់ដឹងអំពីសេចក្ដីសង្ឃឹម និង ក្ដីសុបិនរបស់អ្នក រួមទាំងសេចក្ដីភ័យខ្លាចព្រមទាំងការលំបាកនានារបស់អ្នក » ។[3]

ស៊ិស្ទើរ ស្ទេហ្វិន មានប្រសាសន៍ថា « យើងម្នាក់ៗជាសមាជិក និង មានចំណែកយ៉ាងសំខាន់ក្នុងក្រុមគ្រួសាររបស់ព្រះ ។ « ក្រុមគ្រួសារទាំងអស់នៅលើផែនដីខុសៗពីគ្នា ។ ហើយនៅពេលយើងព្យាយាមអស់ពីសមត្ថភាព ដើម្បីបង្កើតទំនៀមទម្លាប់គ្រួសារដ៏រឹងមាំ នោះសមាជិកភាពនៅក្នុងក្រុមគ្រួសាររបស់ព្រះគឺមិនអាស្រ័យទៅលើស្ថានភាពប្រភេទណាមួយ — ដូចជាស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពហិរញ្ញវត្ថុ ស្ថានភាពសង្គម ឬ ស្ថានភាពដែលយើងចេញផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមឡើយ » ។[4]

### *បទគម្ពីរបន្ថែម*

យេរេមា ១:៥; រ៉ូម ៨:១៦; គោលលទ្ធិ និង សេចក្ដីសញ្ញា ៧៦:២៣–២៤

### *សូមពិចារណាអំពីសំណួរនេះ*

តើការដឹងថា អ្នកជាបុត្រីរបស់ព្រះជះឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកយ៉ាងដូចម្ដេច ?

**កំណត់ចំណាំ**

១. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩ ។
២. ខារ៉ូល អិម ស្ទីហ្វិន « គ្រួសារគឺមកពីព្រះ » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១១ ។
៣. ជែហ្វ្រី អ័រ ហូឡិន « To Young Women » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ២៨ ។
៤. ខារ៉ូល អិម ស្ទីហ្វិន « គ្រួសារគឺមកពីព្រះ » ទំព័រ ១១ ។
៥. សូមមើលប្រធានបទដំណឹងល្អ « ដំណើររឿងនៃការនិមិត្តដំបូង » topics.lds.org។

**សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ**

### *ចេញពីប្រវត្តិសាស្ត្ររបស់យើង*

នៅក្នុងដំណើររឿងនៃការនិមិត្តដំបូង[5] ព្យាការីយ៉ូសែប ស្ម៊ីធបញ្ជាក់ពីសេចក្ដីពិតជាច្រើន — ដោយរួមមានថា ព្រះវរបិតាសួគ៌របស់យើងស្គាល់ឈ្មោះយើង ។

យ៉ូសែប វ័យក្មេងមានការលំបាកដើម្បីដឹងថាព្រះវិហារណាមួយត្រូវចូលរួម ហើយបានរកឃើញការណែនាំនៅក្នុងគម្ពីរយ៉ាកុប ១:៥ ។ យ៉ូសែប បានសម្រេចចិត្តថាលោកនឹងសួរដល់ព្រះ ។

នាព្រឹកមួយនៃនិទាឃរដូវក្នុងឆ្នាំ ១៨២០ លោកបានចូលទៅក្នុងព្រៃ ដើម្បីអធិស្ឋាន ប៉ុន្តែនៅមួយរំពេចនោះលោកត្រូវបានគ្របសង្កត់ដោយអំណាចខ្មៅងងឹតណាមួយ ។ ស្ដីអំពីរឿងនោះ លោកបានសរសេរ ៖

« នៅខណៈការភ្ញាក់ផ្អើលដ៏មហិមានេះ ស្រាប់តែខ្ញុំបានឃើញបង្គោលពន្លឺមួយនៅចំលើក្បាលខ្ញុំ មានរស្មីចែងចាំងលើសជាងសុរិយាទៅទៀតដែលចុះសន្សឹមៗមកចំលើរូបខ្ញុំ ។

« នៅពេលរស្មីនោះលេចមកមិនយូរប៉ុន្មាន ស្រាប់តែខ្ញុំបានឃើញថា ខ្ញុំបានរួចពីខ្មាំងសត្រូវដែលបានចងខ្ញុំទុក ។ កាលពន្លឺស្ថិតចំពីលើរូបខ្ញុំ ខ្ញុំបានឃើញតួអង្គពីរដែលមានរស្មី និង សិរីរុងរឿងដែលពុំអាចពណ៌នាបានឈរនៅអាកាសពីលើរូបខ្ញុំ ។ តួអង្គមួយមានព្រះបន្ទូលមកខ្ញុំ ដោយហៅខ្ញុំតាមឈ្មោះ ហើយចង្អុលទៅតួអង្គមួយទៀត ដោយមានព្រះបន្ទូលថា — *នេះជាព្រះរាជបុត្រាដ៏ស្ងួនភ្ងារបស់យើង ។ ចូរស្ដាប់ទ្រង់ចុះ !*» ( យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:១៦–១៧ ) ។

# តើយល់សេចក្ដីណែនាំឬទេ ?

ដោយ រ៉ុស សឺវើរ

*ការធ្វើដំណើរដោយជិះកង់ ធ្វើឲ្យខ្ញុំជឿអំពីតម្រូវការដើម្បីត្រួតពិនិត្យយ៉ាងជាប់លាប់លើផែនទីនៃដំណើរជីវិតរបស់យើងលើមាគ៌ារបស់ព្រះអម្ចាស់ ។*

ប៉ុន្មានឆ្នាំកន្លងមកហើយ ខ្ញុំបានធ្វើដំណើរដោយជិះកង់នៅក្នុងប្រទេសបារាំងជាមួយបងស្រីរបស់ខ្ញុំ គឺបងស្រីថ្លៃ និង កូនស្រីរបស់គាត់ ។ រៀងរាល់ព្រឹក យើងបានទទួលសេចក្ដីណែនាំលម្អិតបីសន្លឹក ប្រសិនបើធ្វើតាមដោយហ្មត់ចត់ នោះនឹងនាំយើងឲ្យទៅដល់គោលដៅរបស់យើងនៅថ្ងៃនោះ ។ ខណៈដែលយើងកំពុងជិះកង់កាត់ចម្ការទំពាំងបាយជូរ នោះសេចក្ដីណែនាំហាក់ដូចជាបង្គាប់ប្រាប់យើងឲ្យ « ទៅចំណាយ ៥០ ម៉ែត្រ ភាគខាងជើង បន្ទាប់មកបត់ឆ្វេង ហើយទៅចម្ងាយ ១០០ ម៉ែត្រទៀត » ។ ជារឿយៗ សេចក្ដីណែនាំប្រាប់យើងពីឈ្មោះស្លាកសញ្ញា និង ផ្លូវ ។

នាព្រឹកមួយ យើងបានជិះកង់តាមផ្លូវដ៏គួរឲ្យទាក់ទាញមួយ ប៉ុន្តែមិនយូរប៉ុន្មានយើងបានដឹងថា សេចក្ដីណែនាំរបស់យើងនោះពុំត្រូវនឹងតំបន់នោះឡើយ ។ ភ្លាមនោះយើងបានវង្វេងផ្លូវ ហើយយើងបានសម្រេចចិត្តដើម្បីត្រឡប់ទៅកាន់កន្លែងចាស់ដែលយើងស្គាល់ ជាកន្លែងដែលយើងនៅលើផ្លូវត្រូវវិញ ដើម្បីមើលថាយើងអាចទៅផ្លូវណាមួយ ។

ពិតណាស់ នៅពេលយើងទៅដល់ទីនោះ យើងបានឃើញស្លាកសញ្ញាផ្លូវតូចមួយ ដែលបានសរសេរនៅក្នុងសេចក្ដីណែនាំរបស់យើង ដែលយើងពុំបានចាប់អារម្មណ៍មើលវាសោះ ។ មិនយូរប៉ុន្មានយើងបាននៅលើផ្លូវរបស់យើងម្ដងទៀត ហើយជិះកង់តាមសេចក្ដីណែនាំនោះ ដែលធ្វើឲ្យយើងយល់ឥតខ្ចោះតែម្ដង ។

បទពិសោធន៍នេះបានក្លាយជារឿងប្រៀបប្រដូចទៅនឹងចម្លើយចំពោះសំណួរដ៏លំបាកមួយដែលខ្ញុំមាន ៖ ហេតុអ្វីនៅពេលមនុស្សម្នាក់ធ្លាប់មានទីបន្ទាល់អំពីដំណឹងល្អរួចហើយ ថាគាត់នឹងរវាតចិត្តចេញទៅវិញ ? វាបានប្រែជាច្បាស់ចំពោះខ្ញុំថា នៅពេលយើងបែរទៅផ្លូវខុស ( អំពើបាប ) ឬ ពុំធ្វើតាមព្រះបញ្ញត្តិរបស់ព្រះ នោះសេចក្ដីណែនាំ ( ព្រះបន្ទូលនៃព្រះ ) នឹងពុំមានន័យអ្វីឡើយ ។ ផែនទីដែលយើងមាន ពុំត្រូវនឹងតំបន់ដែលយើងនៅឡើយ ។ ប្រសិនបើយើងពុំបានវង្វេងចេញឆ្ងាយ នោះយើងអាចស្គាល់ថាកំហុសគឺជារបស់យើង ហើយថាយើងត្រូវតែត្រឡប់មកវិញ ( ប្រែចិត្ត ) ឬតាំងចិត្តជាថ្មីដើម្បីរស់នៅតាមអ្វីដែលព្រះបានបញ្ជាទៅកាន់កន្លែងណាដែលយើងដឹងថា យើងកំពុងដើរតាមផ្លូវត្រឹមត្រូវ ។

ជារឿយៗនៅពេលសេចក្ដីណែនាំនោះពុំត្រូវនឹងកន្លែងដែលយើងនៅ នោះយើងសង្ស័យពីសេចក្ដីណែនាំនោះ ។ ជំនួសឲ្យការត្រឡប់ក្រោយវិញ យើងបែរជាស្ដីបន្ទោសលើសេចក្ដីណែនាំនោះ ហើយក្រោយមកបដិសេធវាតែម្ដង ។ នៅទីបំផុត ដោយបានបោះបង់ចោលនូវទស្សនវិស័យនៃគោលដៅរបស់យើង នោះយើងបានវង្វេងរសាត់អណ្ដែតលើផ្លូវនានាដែលហាក់បីដូចជា បណ្ដោះអាសន្ន ដែលទាក់ទាញអារម្មណ៍យ៉ាងខ្លាំង ប៉ុន្តែនឹងមិននាំយើងទៅកន្លែងណាដែលយើងចង់ទៅនោះឡើយ ។

រៀងរាល់ថ្ងៃយើងមានឱកាសសិក្សាព្រះគម្ពីរ ។ ហើយរៀងរាល់ប្រាំមួយខែ យើងមានឱកាសដើម្បីស្ដាប់សន្និសីទទូទៅនៃសាសនាចក្រ ។ តើពេលវេលាទាំងនេះ មិនមែនជាពេលដែលយើងអាចពិនិត្យមើលផែនទីនៃផ្លូវរបស់យើង ហើយប្រាកដថាយើងកំពុងនៅលើផ្លូវដែលយើងត្រូវតែទៅទេឬអី ? នាគ្រាមួយ នៅពេលខ្ញុំបានស្ដាប់សន្និសីទ ជាមួយនឹងភាពមិនឥតខ្ចោះរបស់យើង នោះ ខ្ញុំមានអារម្មណ៍ថា យើងអាចដឹងថា យើងកំពុងនៅលើផ្លូវត្រូវ ប្រសិនបើសេចក្ដីណែនាំទាំងនេះកំពុងធ្វើឲ្យយើងយល់យ៉ាងខ្លាំង ។

ប្រសិនបើនៅពេលធ្វើតាមសេចក្ដីណែនាំត្រឹមត្រូវនឹងនាំយើងទៅដល់គោលដៅនៅក្នុងជីវិតនេះ នោះការសិក្សាព្រះគម្ពីរ និង ការស្ដាប់តាមដំបូន្មានរបស់ព្យាការីនៅរស់ អនុញ្ញាតឲ្យយើងពិនិត្យមើលដំណើរជីវិតរបស់យើង ហើយកែតម្រូវវា ប្រសិនបើវាត្រូវកែតម្រូវ ហើយនៅទីបំផុតយើងនឹងមកដល់ផ្ទះសេទ្បេស្ទាលរបស់យើង ។ ■

*អ្នកនិពន្ធដែលបានរស់នៅក្នុងរដ្ឋ ខូឡូរ៉ាដូ ស. រ. អា. បានទទួលមរណភាពកាលពីឆ្នាំមុន ។*

រូបគំនូរ ដោយ ចាអៀ ម៉ូលី



# សូមអរគុណសម្រាប់ការបម្រើរបស់អ្នក

ឈ្មោះត្រូវបានដកចេញ

*អ្នកគឺជាគំរូដ៏ល្អឥតខ្ចោះអំពីស្ត្រីទាំងនោះ ដែលចាប់តាំងពីសម័យនៃទីក្រុងណៅវូមក ដែលបានបម្រើគ្នាទៅវិញទៅមក តាមរយៈការបង្រៀនសួរសុខទុក្ខដោយសេចក្ដីស្រឡាញ់ និង ការបំផុសគំនិត ។*




ខ្ញុំពុំស្គាល់ឈ្មោះរបស់អ្នក អាយុរបស់អ្នក ឬ អ្វីផ្សេងទៀតពីអ្នកឡើយ ។ អ្វីដែលខ្ញុំដឹងនោះគឺថាអ្នកគឺជាគ្រូបង្រៀនសួរសុខទុក្ខរបស់ចូអាន ហើយខ្ញុំមានអំណរគុណចំពោះការបម្រើដ៏យកចិត្តទុកដាក់របស់អ្នកដោយអស់ពីដួងចិត្តរបស់ខ្ញុំ ។

ខ្ញុំដឹងថាការសួរសុខទុក្ខដល់បងប្អូនស្ត្រីមិនសូវសកម្មម្នាក់ដូចជាចូអាន ( ឈ្មោះត្រូវបានប្ដូរ ) ដែលជាកូនប្រសាស្រីរបស់ខ្ញុំ គឺមិនងាយស្រួលទេ ជាពិសេសនៅពេលនាងហាក់ដូចជាមិនសូវស្វាគមន៍អ្នកនោះ ។ ខ្ញុំសង្ស័យថានាងក៏មិនចង់ឲ្យអ្នកមកតាំងតែពីលើកដំបូងម្ល៉ េះ ។ ប៉ុន្តែចូអានបានប្រាប់ខ្ញុំថា អ្នកគឺជាមិត្តដ៏ពិតរបស់នាង បានឈោងចូលសួរសុខទុក្ខនាង ហើយទទួលអ្វីៗគ្រប់យ៉ាងដែលជាចរិតលក្ខណៈរបស់នាង ។

នៅអំឡុង ១៩ឆ្នាំនេះចាប់តាំងពី ចូអានបានរៀបការជាមួយកូនប្រុសរបស់ខ្ញុំ នេះគឺជាគ្រាដំបូងហើយដែលនាងបាននិយាយថាមានគ្រូបង្រៀនសួរសុខទុក្ខ ។ ថ្មីៗនេះនាងបានប្រាប់ខ្ញុំពីការសួរសុខទុក្ខយ៉ាងទៀងទាត់របស់អ្នក និង ពីរបៀបដែលអ្នកចេះគិតគូរ និងមានចិត្តទូលាយ ។ នាងបាននិយាយថាអ្នកបានជួយនាងជាច្រើនដង នៅពេលនាងឈឺ ហើយធ្លាប់ទាំងបានសុំដឹកជូនចៅស្រីរបស់ខ្ញុំទៅសកម្មភាពយុវនារីទៀតផង ។

អស់រយៈពេល១០ឆ្នាំកន្លងទៅនេះ ទាំងនាង កូនប្រុសខ្ញុំ និង គ្រួសាររបស់ពួកគេបានរស់នៅចម្ងាយរាប់រយគីឡូម៉ែត្រពីពួកយើង ។ ខ្ញុំបានអធិស្ឋានទូលសុំឲ្យមានមនុស្សផ្សេងទៀតដែលនឹងស្រឡាញ់ ហើយមើលថែពួកគេដូចខ្ញុំបានធ្វើ ហើយខ្ញុំបានទូលអង្វរទាំងទឹកភ្នែកដល់ព្រះវរបិតាសួគ៌ ថាសុំឲ្យអ្នកដទៃទៀតនឹងជួយពួកគេដូចដែលខ្ញុំជួយពួកគេប្រសិនបើពួកគេរស់នៅជិតខ្ញុំ ។ ចេញពីអ្វីដែលចូអានបាននិយាយ នោះអ្នកគឺជាចម្លើយចំពោះការអធិស្ឋានរបស់ខ្ញុំ ។

បើទោះជាចូអាន និង កូនប្រុសរបស់ខ្ញុំពុំគោរពតាមច្បាប់នៃពាក្យសំដីនៃប្រាជ្ញាវាងវៃ ហើយពុំចូលរួមសាសនាចក្រក្ដី ក៏ពួកគេនៅតែជាមនុស្សល្អ ហើយពួកគេស្រឡាញ់កូនៗរបស់ខ្លួនដែរ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកពុំបានមើលបំណាំពីការផឹកបារីរបស់ចូអានឡើយ ។ អ្នកពុំបានកាត់ទោសគាត់បើទោះជាគាត់មិនបានចូលរួមព្រះវិហារក្ដី ។ អ្នកបានព្យាយាមស្គាល់គាត់ ហើយដឹងថា គាត់គឺជាម្ដាយដ៏មានសេចក្ដីស្រឡាញ់ម្នាក់ ដែលចង់ឲ្យកូនស្រីរបស់ខ្លួនចូលរួមសាសនាចក្រ ហើយទទួលបាននូវទីបន្ទាល់ ។ ហើយនៅពេលចូអានទទួលការវះកាត់ អ្នកបានយកអាហារពេលល្ងាចមកឲ្យ ជាជាងមានមន្ទិលសង្ស័យថា នាងបាននាំបញ្ហាសុខភាពមួយចំនួននេះមកលើខ្លួនដោយសារតែខ្លួនឯងផ្ទាល់ឡើយ ។

ខ្ញុំមានអំណរគុណថា អ្នកគឺជាគំរូមួយសម្រាប់ចៅស្រីរបស់ខ្ញុំ ។ នាងអាចកោតសរសើរអ្នកថា ជាមនុស្សម្នាក់ ដែលខ្វល់ខ្វាយពីមនុស្សគ្រប់គ្នា ហើយខិតខំយ៉ាងខ្លាំងក្លាដើម្បីបង្ហាញការខ្វល់ខ្វាយដោយក្ដីស្រឡាញ់ ។ នាងបានប្រាប់ខ្ញុំថា នាថ្ងៃមួយនៅពេលអ្នកពុំបើកឡានមកនោះ អ្នកបានដើរជាងមួយគីឡូម៉ែត្រមកផ្ទះរបស់នាងជាមួយកូនតូចៗរបស់ខ្លួនដោយយកទាំងនំឃុកឃីមកផង ។

អ្នកបានប្រាប់នាងថា « ខ្ញុំបានគិតអំពីអ្នក និងម្ដាយរបស់អ្នក ហើយចង់ធ្វើអ្វីដែលល្អដល់ពួកអ្នក — គឺគ្រាន់តែដោយសារហេតុផលនេះឯង » ។

ខ្ញុំចង់ប្រាប់អ្នកថា ខ្ញុំមានអំណរគុណយ៉ាងខ្លាំងចំពោះការលះបង់របស់អ្នក ចំពោះការហៅរបស់អ្នកក្នុងនាមជាគ្រូបង្រៀនសួរសុខទុក្ខ ។ អ្នកគឺជាគំរូដ៏ល្អឥតខ្ចោះអំពីស្ត្រីទាំងនោះ ដែលចាប់តាំងពីសម័យនៃទីក្រុងណៅវូមក ដែលបានបម្រើគ្នាទៅវិញទៅមក តាមរយៈការបង្រៀនសួរសុខទុក្ខដោយសេចក្ដីស្រឡាញ់ និង ការបំផុសគំនិត ។ អ្នកបានបង្ហាញការបម្រើ និង សេចក្ដីស្រឡាញ់នោះតាមរយៈរបៀបដែលអ្នកបានសួរសុខទុក្ខដោយក្ដីស្រឡាញ់ដល់កូនប្រសាស្រីដែលអសកម្មរបស់ខ្ញុំ ។

សូមអរគុណ ។ ■

រូបថតនៃបណ្ណ និង ស្រោមសំបុត្រ © ISTOCK/THINKSTOCK



**ដោយ អែលឌើរ អិល ថម ភែរី ( ឆ្នាំ ១៩២២–២០១៥ )**
ក្នុងកូរ៉ុមនៃពួកសាវក ដប់ពីរនាក់

# បព្វជិតភាព ៖ យុថ្កាដ៏មាំមួន

*អត្ថបទនេះត្រូវបានរៀបចំដោយអែលឌើរ អិល ថម ភែរី នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ពីរថ្ងៃពីមុនមរណភាពរបស់លោក ដើម្បីចែកចាយដល់អ្នកកាន់បព្វជិតភាពវ័យក្មេង ។*

កម្លាំងដ៏មហិមានៅក្នុងជីវិតរបស់ខ្ញុំគឺជាបព្វជិតភាពនៃព្រះ ។ ខ្ញុំជឿថាវាគឺជាយុថ្កាដ៏មាំមួនសម្រាប់អ្នកដែលជាយុវវ័យនេះផងដែរ ។ ប៉ុន្តែដើម្បីឲ្យវាមានអំណាចនៅក្នុងជីវិតរបស់អ្នក នោះអ្នកចាំបាច់ត្រូវយល់ និង ប្រើប្រាស់វា ។

**បទពិសោធន៍ដំបូងៗជាមួយបព្វជិតភាព**

ខ្ញុំបានធំដឹងក្តីឡើងនៅក្នុងស្ថានភាពដ៏មនោរម្យមួយនៅក្នុងទីក្រុង លូហ្គែន រដ្ឋយូថាហ៍ ។ កាលវ័យកុមារ ខ្ញុំពុំចាំបាច់បារម្ភពីអាហារ ឬ ទីជម្រក ឬ ការអប់រំឡើយ ។ ប៉ុន្តែប្រហែលជាដោយសារជីវិតដ៏ស្រណុកបែបនេះ នោះខ្ញុំត្រូវតែធ្វើអ្វីមួយដែលខ្ញុំអាចតោងចាប់យ៉ាងជាប់ ដែលជាយុថ្កាចំពោះរូបខ្ញុំ ។

ចំពោះខ្ញុំយុថ្កានោះគឺជាបព្វជិតភាពនៃព្រះ ។ ខ្ញុំធ្លាប់នៅក្នុងស្ថានភាពអស្ចារ្យ កាលខ្ញុំកំពុងធំពេញវ័យ ។ ប៉ារបស់ខ្ញុំត្រូវបានហៅជាប៊ីស្សព កាលខ្ញុំអាយុបានមួយឆ្នាំ ហើយគាត់គឺជាប៊ីស្សពរបស់ខ្ញុំអស់រយៈពេល ១៩ឆ្នាំ ។ ការណែនាំក្នុងនាមជាឪពុក និងខាងវិញ្ញាណរបស់គាត់ បានជួយខ្ញុំយ៉ាងខ្លាំង ។

ខ្ញុំគិតថានោះ គឺជាមូលហេតុធំបំផុតដែលខ្ញុំអន្ទះសារចង់បានបព្វជិតភាពអើរ៉ុននៅថ្ងៃខួបកំណើតអាយុ ១២ឆ្នាំរបស់ខ្ញុំ ។ ខ្ញុំចាំពីថ្ងៃដ៏ពិសេសដែលឪពុករបស់ខ្ញុំដាក់ដៃគាត់លើក្បាលខ្ញុំ ហើយបានតែងតាំងខ្ញុំ ។ បន្ទាប់មក ខ្ញុំបានបន្តរីកចម្រើនជាបន្តបន្ទាប់នៅក្នុងតំណែងនៃបព្វជិតភាពអើរ៉ុន ហើយទទួលការបម្រើដែលខ្ញុំពេញចិត្តជាខ្លាំង ។

ការចែកសាក្រាម៉ង់គឺជារឿងមួយពិសេសណាស់សម្រាប់ខ្ញុំ ។ អ្នកអាចឃើញមនុស្សតាំងចិត្តរបស់ពួកគេ ដើម្បីធ្វើតាមព្រះអម្ចាស់ ហើយគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ នៅពេលពួកគេទទួលទាននិមិត្តរូបនៃព្រះកាយ និង ព្រះលោហិតរបស់ទ្រង់ ។

**ការរីកចម្រើននៅក្នុងការយល់ដឹងអំពីបព្វជិតភាព**

ខណៈដែលពេលវេលាបានរំកិលទៅមុខ ខ្ញុំបានបញ្ចប់វិទ្យាល័យ ហើយក្រោយមកបន្ទាប់ពីខ្ញុំរៀននៅមហាវិទ្យាល័យបានមួយឆ្នាំ ខ្ញុំត្រូវបានហៅឲ្យទៅបេសកកម្ម ។ ខ្ញុំរីករាយនឹងបេសកកម្មរបស់ខ្ញុំគ្រប់ពេល ហើយស្រឡាញ់ដៃគូរបស់ខ្ញុំ ។ មានដៃគូម្នាក់ដ៏ពិសេសដែលជាកម្លាំងដ៏រឹងមាំដល់ខ្ញុំ ។ ខ្ញុំបានរៀនច្រើនពីគាត់ នៅពេលយើងបំពេញទំនួលខុសត្រូវរបស់យើង ។

ដោយសារប្រទេសនោះស្ថិតនៅក្នុងសង្គ្រាមនៅពេលខ្ញុំបានត្រឡប់មកពីបេសកកម្មរបស់ខ្ញុំ នោះខ្ញុំបានចូលកងទ័ពម៉ារីនរបស់សហរដ្ឋ ។ នៅពេលសង្គ្រាមចប់ ខ្ញុំបានត្រឡប់ចូលរៀនមហាវិទ្យាល័យវិញ រៀបការ ហើយចាប់ផ្តើមមានគ្រួសារ ។ ដោយសារការផ្លាស់ប្តូរវិជ្ជាជីវៈជាបន្តបន្ទាប់បាននាំខ្ញុំទៅកាន់ទីកន្លែងជាច្រើននៅទូទាំងសហរដ្ឋ ជាកន្លែងដែលខ្ញុំបានរៀនយ៉ាងច្រើន នៅពេលខ្ញុំបានបម្រើនៅក្នុងការហៅនៃបព្វជិតភាពជាច្រើន ។ នៅទីបំផុតខ្ញុំបានប្តូរទៅរស់នៅទីក្រុង បូស្តុន រដ្ឋ ម៉ាស្សាឈូសេត ជាកន្លែងដែលខ្ញុំបានបម្រើជាប្រធានស្តេក ។ គឺនៅទីនោះហើយដែលខ្ញុំត្រូវបានហៅធ្វើជាជំនួយការនៃពួកដប់ពីរនាក់ ហើយ១៧ ខែក្រោយមក ក្លាយជាកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

**មេរៀនដែលបានរៀនក្នុងនាមជាសាវក**

តើខ្ញុំបានរៀនអ្វីខ្លះក្នុងនាមជាសមាជិកនៃកូរ៉ុមនៃពួកដប់ពីរនាក់ ?

ខ្ញុំបានរៀនថា មានអ្នកណែនាំ មានយុថ្កា និងការការពារនៅក្នុងបព្វជិតភាព ។

បព្វជិតភាពបានមានជាយូរមកហើយ ។ ពីមុនអ័ដាមមកលើផែនដី គាត់មាននូវបព្វជិតភាព ។ នៅពេលពូជពង្សរបស់អ័ដាមបានបែកខ្ញែករួមទាំងមានបព្វជិតភាព វាបានក្លាយជាការណ៍ចាំបាច់ដើម្បីរៀបចំរបៀបដែលបព្វជិតភាពត្រូវបានបម្រើ ។ ព្រះអម្ចាស់បានធ្វើការណ៍នេះ ដោយហៅអ័ប្រាហាំឲ្យធ្វើជាអធិបតីលើគ្រួសាររបស់គាត់នៃអ្នកកាន់បព្វជិតភាព ។ អង្គការនេះបានបន្តរហូតដល់





អ៊ីសាក យ៉ាកុប ដែលក្រោយមកបានប្ដូរឈ្មោះទៅជាអ៊ីស្រាអែលវិញ ។

ច្រើនសតវត្សរ៍ក្រោយមក កូនចៅរបស់អ៊ីស្រាអែលបានស្ថិតនៅក្នុងសេវកភាព ។ ព្រះអម្ចាស់បានបញ្ជូនម៉ូសេឲ្យទៅរំដោះពួកគេ ប៉ុន្តែនៅពេលគាត់បានធ្វើការណ៍នោះ ពួកគេបានបង្ហាញថាពួកគេជាប្រជាជនដែលពុំទាន់ត្រៀមខ្លួនរួចរាល់សម្រាប់បព្វជិតភាពមិលគីស្សាដែកនៅឡើយ ។ ដូច្នេះពួកគេត្រូវបានទុកឲ្យនៅតែមានបព្វជិតភាពអើរ៉ុន រហូតដល់ជំនាន់ព្រះអង្គសង្គ្រោះ ។

ខ្ញុំឃើញថាវាគួរឲ្យចាប់អារម្មណ៍ នូវអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើនាគ្រាដំបូង កាលទ្រង់បានចាប់ផ្ដើមការបម្រើរបស់ទ្រង់ ។ ទ្រង់បានរៀបចំបព្វជិតភាពមិលគីស្សាដែក ។ ទ្រង់បានហៅពួកសាវក ហើយបានបង្រៀនពួកគេអំពីក្រឹត្យវិន័យ និង របៀបនៃបព្វជិតភាព ។ ទ្រង់បានហៅពេត្រុសឲ្យធ្វើជាប្រធានសាវក ដោយបង្កើតខ្សែស្រឡាយនៃសិទ្ធិអំណាចនៅក្នុងសាសនាចក្ររបស់ទ្រង់ ។ នៅក្នុងជំនាន់នោះ និង ជំនាន់នេះ គឺព្រះយេស៊ូវគ្រីស្ទជាអង្គដែលជ្រើសរើសប្រធានសាវកឲ្យធ្វើជាអធិបតីលើសាសនាចក្រ ហើយគឺព្រះអង្គសង្គ្រោះដែលដឹកនាំលោកនៅក្នុងកាតព្វកិច្ចបព្វជិតភាពរបស់លោក ។

ដូច្នេះបព្វជិតភាពមាននូវខ្សែស្រឡាយផ្ទាល់មកពីអម្ចាស់ និង ព្រះអង្គសង្គ្រោះរបស់យើង តាមរយៈប្រធានសាវក ដល់សាវកដទៃ និង ដល់អ្នកកាន់បព្វជិតភាពផ្សេងទៀតនៅក្នុងសាសនាចក្រ ។ កូនសោនៃសិទ្ធិអំណាចត្រូវបានផ្ដល់ឲ្យដល់ពួកសាវក ហើយដរាបណាកូនសោទាំងនោះមាននៅលើផែនដី នោះយើងនឹងត្រូវបានដឹកនាំដោយព្រះអម្ចាស់ផ្ទាល់ ។ ការដឹកនាំដ៏ទេវភាពនេះការពារយើង ហើយធានាអះអាងដល់យើងថាសាសនាចក្រនេះនឹងមិនងាកចេញពីសេចក្ដីពិតឡើយ ។ វានឹងបន្តនៅជាប់លាប់ជានិច្ច ដោយសារវាពុំមែនត្រូវបានដឹកនាំដោយបុគ្គលនៅលើផែនដីនេះឡើយ ។ វាត្រូវបានដឹកនាំដោយព្រះអម្ចាស់ ។

**រៀនពីគោលលទ្ធិនានានៃបព្វជិតភាព**

ការទូន្មានដ៏អស្ចារ្យបំផុតដែលខ្ញុំមានសម្រាប់អ្នកដែលជាយុវជន នោះគឺត្រូវសិក្សាគោលលទ្ធិនានានៃបព្វជិតភាព យល់ដឹងពីអំណាច ដែលអ្នកមាននៅក្នុងការអនុវត្តបព្វជិតភាពរបស់អ្នក ហើយរៀនពីរបៀបដែលវាអាចប្រទានពរដល់ជីវិតរបស់អ្នក និង ជីវិតរបស់មនុស្សដទៃទៀត ។

ខ្ញុំសន្យាថា ប្រសិនបើអ្នកនឹងរៀនពីគោលលទ្ធិនានានៃបព្វជិតភាព ហើយបំពេញកាតព្វកិច្ចបព្វជិតភាពរបស់អ្នក នោះបព្វជិតភាពនឹងក្លាយជាយុថ្កាដ៏មាំមួន ដែលនឹងរក្សាសុវត្ថិភាពខាងវិញ្ញាណរបស់អ្នក ហើយនាំអ្នកឲ្យមានសេចក្ដីអំណរដ៏អស្ចារ្យ ។ ចូរធ្វើជាកូរ៉ុមបព្វជិតភាពមួយដ៏ពិត ។ ចូរឈោងទៅជួយដល់មិត្តភក្តិ ហើយនាំពួកគេឲ្យមកកូរ៉ុមរបស់អ្នក ។ សូមបង្កើតភាពជាបងប្អូនប្រុសនៅក្នុងកូរ៉ុមរបស់អ្នក ដែលនឹងក្លាយទៅជាគ្រឹះដ៏អចិន្ត្រៃយ៍សម្រាប់ជីវិតរបស់អ្នក ។ ■

# អែលឌើរ រ៉ូណល អេ រ៉ាសបាន ៖

## អ្នកដឹកនាំដ៏ប៉ិនប្រសប់ ឪពុកដ៏មានភក្ដីភាព

**ដោយអែលឌើរ អិម រ័សុល បាឡឹង**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់



រ៉ុន រ៉ាសបាន ពុំដែលមានមន្ទិលសង្ស័យថា លោកនឹងបម្រើបេសកកម្មពេញម៉ោងឡើយ ។ សំណួរតែមួយគត់ដែលក្មេងអាយុ ១៩ ឆ្នាំមានពេលកំពុងបើកការហៅបម្រើបេសកកម្មនោះគឺ *ទីកន្លែងណា* ដែលលោកនឹងទៅបម្រើ ។

« ឪពុកខ្ញុំបានបម្រើបេសកកម្មនៅប្រទេសអាល្លឺម៉ង់ ។ បងប្រុសរបស់ខ្ញុំបានបម្រើបេសកកម្មនៅប្រទេសអាល្លឺម៉ង់ ។ អនាគតបងថ្លៃប្រុសរបស់ខ្ញុំបានបម្រើបេសកកម្មនៅប្រទេសអាល្លឺម៉ង់ » ។ លោកបានមានប្រសាសន៍ថា « ខ្ញុំបានគិតថា ខ្ញុំនឹងទៅប្រទេសអាល្លឺម៉ង់ដែរហើយ » ។

ប៉ុន្ដែព្រះអម្ចាស់មានផែនការផ្សេងទៀត ។ រ៉ុនត្រូវបានហៅបម្រើបេសកកម្មទៅសហរដ្ឋភាគខាងកើតជំនួសវិញដែលមានទីស្នាក់ការនៅទីក្រុង នូវ យ៉ោក ស.រ.អា. ។ ដោយការខកចិត្ដ លោកបានកាន់ក្រដាសហៅបម្រើរបស់ខ្លួនចូលទៅបន្ទប់ដេក លុតជង្គង់ក្បែរគ្រែ អធិស្ឋាន បើកព្រះគម្ពីររបស់គាត់ដោយព្រាវៗ ហើយបានចាប់ផ្ដើមអានវា ៖

« មើលចុះ និង មើលន៏ យើងមានមនុស្សជាច្រើននៅកន្លែងនេះ គឺនៅភូមិភាគជុំវិញ ហើយទ្វារដ៏មានផលប្រយោជន៍នឹងត្រូវបានបើកចំហ នៅភូមិភាគជុំវិញនៅ *ដែនដីនៃទិសខាងកើតនេះ ។*

« ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់បានទុកឲ្យអ្នកមកឯទីនេះ ដ្បិតដោយហេតុនេះហើយ ទើបបានចាំបាច់សម្រាប់សេចក្ដីសង្គ្រោះ នៃព្រលឹងទាំងឡាយ » (គ. និង ស. ១០០:៣–៤ការសង្កត់ធ្ងន់ត្រូវបានបន្ថែម ) ។

រំពេចនោះ ព្រះវិញ្ញាណបរិសុទ្ធបានបញ្ជាក់ដល់រ៉ុនថា ការហៅរបស់លោកទៅបេសកកម្មស្ដេកភាគខាងកើតគឺពុំមែនជាកំហុសឆ្គងឡើយ ។

លោកបានរំឭកថា « ខ្ញុំបានប្រែពីការខកចិត្តទៅជាការមាននូវការបញ្ជាក់លើកដំបូងរបស់ខ្ញុំពីព្រះគម្ពីរជាច្រើន ដែលថាវាគឺជាទីតាំងដែលព្រះអម្ចាស់មានព្រះទ័យចង់ឲ្យខ្ញុំទៅនោះ ជាបទពិសោធន៍នៃការផ្លាស់ប្ដូរជីវិតខាងវិញ្ញាណដ៏អស្ចារ្យសម្រាប់ខ្ញុំ » ។

បេសកកម្មរបស់លោកទៅកាន់សហរដ្ឋភាគខាងកើត គឺជាការហៅដំបូងនៃការហៅជាច្រើនរបស់សាសនាចក្រ ដែលតម្រូវឲ្យលោកធ្វើដំណើរទៅកន្លែងជាច្រើនដែលលោកមិនធ្លាប់រំពឹងថានឹងទៅ ។ ហើយការហៅនិមួយៗ—គ្រូបង្រៀន ប៊ីស្សព ទីប្រឹក្សាជាន់ខ្ពស់ ប្រធានបេសកកម្ម សមាជិកនៃពួកចិតសិបនាក់ រៀមច្បងនៃគណៈប្រធាននៃពួកចិតសិបនាក់ និង សាវក

ខាងលើខាងស្ដាំ ៖ អែលឌើរ រ៉ូណល អេ រ៉ាសបាន កាលជាប្រធានបេសកកម្មនៅក្នុងទីក្រុង នូវ យ៉ោក ក្នុងឆ្នាំ ១៩៩៨ ។ នៅឆ្វាយខាងស្ដាំ ៖ អែលឌើរ រ៉ាសបានជាមួយបងស្រីរបស់លោក ណាន់ស៊ី ស្ដីនល័រម្ដាយ នឹងបងប្រុស រ័សុល និង ណៃល ។ ខាងស្ដាំ ៖ ជាមួយនឹងម្ដាយរបស់លោកកាលអាយុប្រាំពីរឆ្នាំ ។

របស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ—អែលឌើរ រ៉ូណល អេ រ៉ាសបាន បានទទួលយកតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ហើយបន្តពឹងផ្អែកលើព្រះវិញ្ញាណរបស់ទ្រង់ នៅពេលលោកបម្រើដល់កូនចៅរបស់ព្រះ ។

« រ៉ុនពុំដែលឲ្យម៉ាក់ និង ប៉ាឈរ ឬ អង្គុយក្បែរគ្នាដោយគ្មានលោកនៅចន្លោះពួកគាត់ឡើយ » ។

រ៉ុនគឺពិតជាក្មេងល្អម្នាក់ ប៉ុន្តែលោកសារភាពថាលោកក៏រប៉ិលរប៉ូចផងដែរ ។







លោកនិយាយថា « គ្រូបង្រៀន [ ថ្នាក់អង្គការបឋមសិក្សា ] ប្រធានអង្គការបឋមសិក្សាស្តេករបស់ខ្ញុំបានមកជួបម្តាយខ្ញុំពីរបីដង ហើយមានប្រសាសន៍ថា ‹ រ៉ុននី រ៉ាសបានគឺជាក្មេងចចេសណាស់ ប៉ុន្តែពួកគាត់មិនដែលបោះបង់ក្នុងការជួយខ្ញុំឡើយ ។ ពួកគេបង្ហាញសេចក្តីស្រឡាញ់យ៉ាងអស្ចារ្យដល់ខ្ញុំ ហើយអញ្ជើញខ្ញុំឲ្យត្រឡប់មកថ្នាក់វិញជានិច្ច » ។[២]

## កើតមកពីឪពុកម្តាយល្អ

នៅក្នុងសុន្ទរកថាលើកដំបូងក្នុងនាមជាសាវករបស់ព្រះយេស៊ូវគ្រីស្ទ អែលឌើរ រ៉ាសបាន បានបង្ហាញពីអំណរគុណដ៏អស់ពីដួងចិត្តចំពោះបុព្វការីជនរបស់លោក ។ លោកមានប្រសាសន៍ថា « ខ្ញុំបានកើតមកពីឪពុកម្តាយល្អ នៅក្នុងដំណឹងល្អហើយពួកគាត់កើតមកពីឪពុកម្តាយល្អទាំងប្រាំមួយជំនាន់ដែរ » ។[១]

ម្តាយរបស់លោក វើដា អែនឌើរសុន រ៉ាសបាន គឺជាអ្នកដឹកនាំម្នាក់ដែលមានសេចក្តីស្រឡាញ់ ដែលបានអប់រំឲ្យរ៉ុនស្រឡាញ់ព្រះគម្ពីរតាំងពីក្មេង ។ ឪពុករបស់លោក រ៉ូឡុន ហាគីន រ៉ាសបាន គឺជាអ្នកកាន់បព្វជិតភាពដ៏ស្មោះត្រង់ ដែលធ្វើជាគំរូអំពីគុណធម៌នៃការឧស្សាហ៍ព្យាយាមក្នុងការងារ ។

កើតនៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ១៩៥១ នៅក្នុងទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ស.រ.អា. រ៉ូណល អេ ( អែនឌើរសុន ) រ៉ាសបាន គឺជាកូនទោលនៅក្នុងគ្រួសារលោក ។ ឪពុកម្តាយរបស់លោកគឺធ្លាប់បានរៀបការ ហើយធ្លាប់លែងលះរៀងៗខ្លួនពីមុនពួកគេរៀបការជាមួយគ្នា ហើយរ៉ុនបានចិញ្ចឹមឲ្យបានធំឡើងក្រោមការថែទាំជាមួយនឹងបងប្រុសពីរនាក់ និងបងស្រីម្នាក់ ។

បងស្រីរបស់លោក ណានសី ស្ដីនល័រ បាននិយាយថា « លោកមានបុគ្គលិកលក្ខណៈរបស់ឪពុកម្តាយយើង ដូច្នេះយើងទាំងអស់គ្នាស្រឡាញ់គាត់ » ។

កុមារភាពរបស់រ៉ុនបានផ្តោតយកចិត្តទុកដាក់លើសាសនាចក្រ—ការប្រជុំវួដ ពិធីជប់លៀងក្នុងវួដ បរិភោគអាហារនៅវួដ និង ក្រុមកីឡាវួដ ។ នៅពេលលោកទំនេរពីសាលាប្រជុំវួដ ខុតតុនវ៉ូត ទីមួយ នោះលោកធ្វើការងារផ្សេងៗ ធ្វើសកម្មភាពនានានៃក្រុមកាយឫទ្ធិ ព្រមទាំងចំណាយពេលជាមួយមិត្តភក្តិ ។ នៅក្នុងផ្ទះ ពេលវេលារបស់គ្រួសារបានផ្តោតចិត្តទុកដាក់លើព្រះគម្ពីរ ល្បែងកម្សាន្ត និង កិច្ចការផ្ទះ ។



លោកនិយាយថា « ឪពុករបស់ខ្ញុំបានបង្រៀនខ្ញុំពីអត្ថន័យនៃការងារតាមរយៈគំរូរបស់គាត់ ។ ម្តាយរបស់ខ្ញុំបានបង្រៀនខ្ញុំអំពីការងារតាមរយៈការផ្តល់ការងារឲ្យខ្ញុំធ្វើ » ។

ឪពុករបស់រ៉ុនបើកឡានដឹកនំប៉័ង គាត់ត្រូវក្រោកឡើងម៉ោង៤ព្រឹករាល់ថ្ងៃ ហើយត្រឡប់មកផ្ទះវិញយប់ជ្រៅរាល់យប់ ។ ម្តាយរបស់លោកនៅផ្ទះចិញ្ចឹមកូនៗ ជួយរកប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារដោយការធ្វើ និង លក់តុក្កតាកូនក្រមុំព័រសីឡែន ។

រ៉ុន មានសមត្ថភាពជាអ្នកដឹកនាំពីធម្មជាតិ ផ្ទេរសិទ្ធិ និង សម្រេចកិច្ចការនានា—ដែលវាបានជួយគាត់យ៉ាងល្អនៅក្នុងទំនួលខុសត្រូវក្នុងការងារអាជីព និង ខាងសាសនារបស់លោក—គឺមានប្រយោជន៍ដល់លោកតាំងពីក្មេង ។

បងស្រីរបស់លោកចាំថា « រ៉ុនត្រូវបានចាត់ឲ្យកាត់ស្មៅ » ប៉ុន្តែ រ៉ុន បានធ្វើដូចជាម៉ាក ធ្វាន ថម សរយើរដែរ គឺអាចបញ្ចុះបញ្ចូលមិត្តភក្តិរបស់គាត់ឲ្យមកជួយលោក ។

រូបថតបានទទួលសិទ្ធិអនុញ្ញាត ពីគ្រួសាររ៉ាសបាន លើកលែងតែបានកត់សម្គាល់ ។







តាំងពីរៀបអាពាហ៍ពិពាហ៍មក អែលឌើរ និង ស៊ិស្ទើរ រ៉ាសបានបាន ដាក់ព្រះអម្ចាស់ជាត្រីមុខជានិច្ច ។ បានរៀបអាពិហ៏ពិពាហ៍នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ១៩៧៣ ( ខាងក្រោម ) ទីបំផុតពួកគេត្រូវបានប្រទានពរឲ្យ មានកូនស្រីបួននាក់ និង កូនប្រុសម្នាក់ ( ខាងលើ ) ។ នៅទំព័រម្ខាងទៀត ៖ ចូន ហាន់ស្មែន ស៊ីញ៉័រ អតីតដៃគូ ជំនួញរបស់អែលឌើរ រ៉ាសបាន និង គ្រូ ណែនាំ ហៅអែលឌើរ រ៉ាសបានថាជា « អ្នកដឹកនាំដ៏ប៉ិនប្រសព្វ ដែលមាន ភក្ដីភាពយ៉ាងខ្លាំង » ។

ណាន‌ស៊ីនិយាយថា « ពេលខ្ញុំមើលទៅវាលស្មៅ នោះខ្ញុំនឹងឃើញមិត្តភក្តិស្និទស្នាលរបស់គាត់កាត់ស្មៅជំនួសគាត់វិញ » ។ « សប្តាហ៍ក្រោយមកមិត្តភក្តិម្នាក់ផ្សេងទៀតរបស់គាត់បានមកកាត់ស្មៅ ។ គាត់គ្រាន់តែអង្គុយនៅវាលហាលខាងមុខ ហើយសើច និង និយាយកំប្លែងជាមួយពួកគេ នៅពេលពួកគេបានធ្វើកិច្ចការរបស់គាត់ » ។

ឪពុកម្តាយរបស់រ៉ុនមានបញ្ហាហិរញ្ញវត្ថុ ប៉ុន្តែក្រុមគ្រួសារនេះមានដំណឹងល្អ ។ រ៉ុននិយាយថា « យើងពុំដែលមានប្រាក់ច្រើនឡើយ ប៉ុន្តែវាពុំដែលប៉ះពាល់ដល់សុភមង្គលរបស់ខ្ញុំឡើយ » ។

**មិត្តភក្តិ និង ថ្នាក់ដឹកនាំដ៏ជាទីទុកចិត្ត**

ដោយបានចម្រើនវ័យធំឡើង នោះរ៉ុនត្រូវបានប្រទានពរដោយមានមិត្តភក្តិល្អៗ និង មានថ្នាក់ដឹកនាំបព្វជិតភាពដែលជាទីទុកចិត្ត រួមមានប្រធានស្តេករបស់គាត់ដែលបម្រើអស់រយៈ ១៤ឆ្នាំ កាលគាត់នៅពីក្មេង—ជែមស៍ អ៊ី ហ្វោស្ត ( ឆ្នាំ ១៩២០–២០០៧ ) ដែលក្រោយមកបានបម្រើនៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ និង នៅក្នុងគណៈប្រធានទីមួយ ។ គ្រួសាររបស់រ៉ុនរីករាយនឹងមិត្តភាពយ៉ាងស្និទស្នាលជាមួយប្រធាន ហ្វោស្ត និង គ្រួសាររបស់លោក ។ លោកមានប្រសាសន៍ថា « ប្រធានហ្វោស្តតែងហៅខ្ញុំថាជាក្មេងនៅ ខុតតុនវ៉ូត ដោយសារលោកបានជួយចិញ្ចឹមបីបាច់ខ្ញុំ » ។

រ៉ុនគ្មានពេលវេលាសម្រាប់លេងកីឡានៅសាលាឡើយកាលគាត់រៀននៅវិទ្យាល័យ ដោយសារគាត់មានការងារមួយជាប់ជានិច្ច ប៉ុន្តែគាត់បានឆ្លៀតពេលសម្រាប់មិត្តភាពដ៏ស្មោះស្ម័គ្រដែលមានជាយូរអង្វែងនៅក្នុងជីវិតនេះ។

មិត្តភក្តិកាលនៅកុមារភាពរបស់លោកឈ្មោះ ក្រេក ម៉ាកឃ្លារីបាននិយាយថា « ខ្ញុំសរសើររ៉ុនជានិច្ច ចំពោះបុគ្គលិកលក្ខណៈរបស់គាត់ ប៉ុន្តែគាត់មិនល្អឥតខ្ចោះនោះទេ » ។ គាត់បានបន្ថែមទាំងញញឹមទៀតថា « ខ្ញុំបានប្រាប់គាត់ថា ប្រសិនបើគាត់ឡើងឋានសួគ៌ នោះខ្ញុំក៏នឹងបានឡើងឋានសួគ៌ផងដែរ ដោយសារយើងបានធ្វើកិច្ចការទាំងនោះដូចគ្នាពេលយើងចម្រើនវ័យធំឡើង » ។

រ៉ុនបានទៅបម្រើបេសកកម្មនៅដើមឆ្នាំ ១៩៧០ ប៉ុន្តែ ក្រេកកំពុងពិចារណាពីការពន្យាពេលដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនា រហូតដល់រដូវស្លឹកឈើជ្រុះបន្ទាប់ ។ នោះគឺជាពេលដែលរ៉ុនបានទូរសព្ទទៅគាត់ពីបេសកកម្មរបស់ខ្លួន ។

បងប្រុស ម៉ាកឃ្លារីនិយាយថា « ខ្ញុំពុំដឹងពីរបៀបដែលលោកបានទទួលការអនុញ្ញាតដើម្បីទូរសព្ទមកឡើយ ប៉ុន្តែលោកបានស្តីប្រដៅខ្ញុំចំពោះការមិនរំភើបចិត្តក្នុងការចេញបេសកកម្មរបស់ខ្ញុំភ្លាមៗនោះ ។ ពិតណាស់ ខ្ញុំមិនបានពន្យាពេលទេ » ។

រ៉ុនបានប្រាប់ថា បេសកកម្មរបស់លោកគឺជាបទពិសោធន៍មួយយ៉ាង « អស្ចារ្យបំផុត » ។ លោកនិយាយថា « ព្រះអម្ចាស់បានប្រទានពរដល់ខ្ញុំនូវបទពិសោធន៍ និង ជំរុញសេចក្តីជំនឿដ៏អស្ចារ្យជាច្រើន ។ បេសកកម្មរបស់ខ្ញុំបានជះឥទ្ធិពលយ៉ាងធំធេងចំពោះជីវិតខាងវិញ្ញាណរបស់ខ្ញុំ » ។

ផ្នែកមួយនៃបេសកកម្មរបស់រ៉ុនបានបម្រើនៅក្នុងកោះប៊ើរមូដា ។ ប្រធានបេសកកម្មរបស់លោក ហារ៉ូត នីហ្វែ វីលគីនសុន បញ្ជូនតែ « អ្នកផ្សព្វផ្សាយសាសនាណាដែលគោរពប្រតិបត្តិឥតលំអៀង » ទៅទីនោះ ដោយសារគាត់អាចទៅជួបពួកគេយូរៗម្តងតែប៉ុណ្ណោះ ។

រ៉ុននិយាយថា « យើងនៅតែឯង

ប៉ុន្តែប្រធានបេសកកម្មពុំមានការព្រួយបារម្ភអំពីយើងឡើយ ។ យើងបានបំពេញកាតព្វកិច្ចរបស់យើង » ។

**« យុវនារីដ៏មានឧត្តមគតិ » នៃក្លឹបខៃលតា ហ្វី**

បន្ទាប់ពីចប់បេសកកម្មរបស់ខ្លួននៅឆ្នាំ ១៩៧២ នោះរ៉ុនរកបានការងារមួយ ហើយបានចុះឈ្មោះចូលរៀននៅសាកលវិទ្យាល័យយូថាហ៍នៅរដ្ឋស្លឹកឈើជ្រុះនោះហើយបានចូលរួមក្នុងក្លឹប ខៃលតា ហ្វី កាប៉ា ក្លឹបមហាវិទ្យាល័យសម្រាប់អ្នកត្រឡប់ពីបេសកកម្មវិញ ។ នៅក្នុងសកម្មភាពសង្គមនៃក្លឹបមហាវិទ្យាល័យនោះ គាត់កត់សម្គាល់ឃើញយុវនារីដ៏ស្រស់ម្នាក់ដែលមានឈ្មោះថា មេឡានី ធ្វីឆែល ។ មេឡានីគឺជា « យុវនារីដ៏មានឧត្តមគតិ » ម្នាក់នៅក្នុងក្លឹបខៃលតា ហ្វី ដែលបានជួយដល់សកម្មភាពបម្រើនានារបស់ក្លឹបមហាវិទ្យាល័យ ។

មេឡានីក៏ដូចជារ៉ុនផងដែរគឺជាកូនដែលកើតមកពីក្រុមគ្រួសារនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ឪពុករបស់គាត់គឺជាមេបញ្ជាការទាហាន ហើយម្ដាយរបស់គាត់ពុំដែលឲ្យការប្ដូរទីលំនៅជាញឹកញាប់របស់គ្រួសារខ្លួន ក្លាយជាការដោះសារចំពោះការខកខានទៅព្រះវិហារឡើយ ។

មេឡានីបានមានចិត្តរំភើបចំពោះសេចក្ដីសប្បុរស សុជីវធម៌ និង ចំណេះដឹងអំពីដំណឹងល្អរបស់រ៉ុនខ្លាំងណាស់ ។ « ខ្ញុំបាននិយាយប្រាប់ខ្លួនឯងថា ‹ លោកគឺជាបុរសដ៏អស្ចារ្យម្នាក់ ហើយវាគ្មានបញ្ហាទេ ប្រសិនបើខ្ញុំមិនមានឱកាសដើរលេងជាគូជាមួយលោកនោះ ។ ខ្ញុំគ្រាន់តែចង់ធ្វើជាមិត្តជិតស្និទរបស់លោកប៉ុណ្ណោះ › » ។

នៅពេលទំនាក់ទំនងរបស់ពួកគេរីកចម្រើន នោះព្រះវិញ្ញាណបានបញ្ជាក់ក្នុងអារម្មណ៍របស់នាងអំពីរ៉ុន និង ការប្ដេជ្ញាចិត្តរបស់លោកចំពោះព្រះអម្ចាស់ ។ មិនយូរប៉ុន្មាន មិត្តភាពរបស់ពួកគេបានក្លាយទៅជាស្នេហាដែលមេឡានីហៅថា « ដំណើររឿងស្នេហាដ៏អណ្ដែតអណ្ដូង » ។

អែលឌើរ រ៉ាសបានមានប្រសាសន៍ថានាងគឺជាដៃគូដ៏ល្អឥតខ្ចោះ ។ « មេឡានីមានភក្ដីភាព និង មរតកនៅក្នុងដំណឹងល្អដូចជាខ្ញុំផងដែរ ។ យើងបានក្លាយជាមិត្តិភក្តិជិតស្និទនឹងគ្នា ហើយនោះគឺជាពេលដែលខ្ញុំបានសុំនាងរៀបការ » ។

ពួកគេបានរៀបការនៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ១៩៧៣ ក្នុងព្រះវិហារបរិសុទ្ធសលត៍លេក ។ លោកមានប្រសាសន៍ថា « ចាប់តាំងពីនោះមកលោកបានមានដៃគូដ៏អស់កល្បដែលមិនគិតពីខ្លួនឯង. . .បានជួយខ្ញុំឲ្យប្រែកាន់តែដូចជាសិស្សរបស់ព្រះយេស៊ូគ្រីស្ទ ។ ក្ដីស្រឡាញ់ និង ការបម្រើរបស់នាង និង កូនៗ៥នាក់របស់យើង ព្រមទាំងភរិយា និង ស្វាមីរបស់ពួកគេ និង ចៅៗទាំង២៤នាក់របស់យើង គាំទ្រដល់ខ្ញុំ » ។[៣]

**« តោះយើងទៅ »**

អំឡុងពេលកំពុងបម្រើជាប្រធានកូរ៉ុមអែលឌើរនៅក្នុងវួដនៃនិស្សិតដែលបានរៀបការរួចរបស់លោក នោះរ៉ុនបានស្គាល់ ចូន ហាន់ស្វែន ស៊ីញ៉រ អ្នកផ្ដល់ដំបូន្មានក្រុមប្រឹក្សាវួដ ។ មិនយូរប៉ុន្មាន ចូនមានការកោតសរសើរចំពោះរបៀបដែលរ៉ុនបានដឹកនាំកូរ៉ុម ។

អែលឌើរ ហាន់ស្វែន ដែលបានបម្រើជាពួកចិតសិបនាក់ប្រចាំតំបន់ពីឆ្នាំ ១៩៩៦ ដល់ ២០១១ បានមានប្រសាសន៍ថា « លោកមានទេពកោសល្យនៃភាពជាអ្នកដឹកនាំ និង រៀបចំរចនាសម្ព័ន្ធយ៉ាងអស្ចារ្យ ។ ខ្ញុំបានគិតថាវាមិនមែនជារឿងធម្មតាទេ ដែលយុវជនម្នាក់ដែលនៅរៀនមហាវិទ្យាល័យអាចដឹកនាំកូរ៉ុមបានយ៉ាងល្អបែបនោះ » ។

អស់រយៈពេលជាច្រើនខែ ចូនបានមើលឃើញថារ៉ុនបានប្ដូរពីការគិតទៅជាសកម្មភាព នៅពេលលោកបំពេញកាតព្វកិច្ចបព្វជិតភាព ។ នៅពេលមានការរើសបុគ្គលិកជាន់ខ្ពស់ផ្នែកទីផ្សារនៅក្រុមហ៊ុនរបស់ចូន—ដែលនឹងក្លាយជាសាជីវកម្មគីមីហាន់ស្វែន—គាត់បានសម្រេចចិត្តថា រ៉ុនមានជំនាញនានាដែលគាត់ចង់បាន ហើយហៅគាត់ឲ្យធ្វើការងារនោះ ។ មុខងារនោះបានចាប់ផ្ដើមនៅសប្ដាហ៍បន្ទាប់នៅរដ្ឋអូហៃអូ ស.រ.អា. ។

រ៉ុនបានរំឭកថា « ខ្ញុំបានប្រាប់មេឡានីថា ‹ បងនឹងមិនឈប់រៀន ហើយផ្លាស់ទីលំនៅឡើយ › ។ បងខិតខំពេញមួយជីវិតរបស់បងដើម្បីបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ ហើយនៅទីបំផុតបងជិតបានសម្រេចគោលដៅហើយ » ។

មេឡានីបានរំឭករ៉ុនថា ការស្វែងរកការងារល្អនេះហើយគឺជាមូលហេតុដែលលោកត្រូវសិក្សា ។

នាងបានសួរថា « តើបងបារម្ភពីរឿងអ្វី ? អូនចេះពីរបៀបរៀបចំអីវ៉ាន់ ហើយផ្លាស់ទីលំនៅ ។ អូនបានធ្វើវាពេញមួយជីវិតរបស់អូនហើយ ។ អូននឹងអនុញ្ញាតឲ្យបងទូរសព្ទទៅម្ដាយរបស់បងរាល់យប់ ។ តោះយើងទៅ » ។



ចូន មានទំនុកចិត្តលើរ៉ុនគឺជារឿងត្រឹមត្រូវណាស់ ។ ក្រោមការគ្រប់គ្រងរបស់ចូន នោះរ៉ុនបានរីកចម្រើនយ៉ាងលឿននៅក្នុងក្រុមហ៊ុន ក្លាយជាប្រធានក្រុមហ៊ុន និង ជាប្រធានប្រតិបត្តិនៅក្នុងឆ្នាំ ១៩៨៦ ។ លោកបានធ្វើដំណើរជាច្រើនកន្លែងដើម្បីបំពេញការងារក្រុមហ៊ុន—ទាំងក្នុង និង ក្រៅស្រុក ។ បើទោះបីជាមានកាលវិភាគរវល់ក្ដី រ៉ុនបានព្យាយាមមកផ្ទះវិញចុងសប្ដាហ៍ ។ ហើយនៅពេលលោកធ្វើដំណើរ យូរៗម្ដងលោកបានយកសមាជិកគ្រួសារខ្លួនទៅជាមួយលោក ។

មេឡានី និយាយថា « នៅពេលលោកនៅផ្ទះ លោកពិតជាធ្វើឲ្យកូនៗមានអារម្មណ៍យ៉ាងពិសេស និង ពេញដោយក្ដីស្រឡាញ់ » ។ លោកបានចូលរួមសកម្មភាពនានា និង កម្មវិធីកីឡារបស់កូនៗតាមពេលវេលាដែលអំណោយផលឲ្យ ។ ជេនេសា ម៉ាកហ្វើសុន ជាកូនស្រីម្នាក់ក្នុងចំណោមកូនបួននាក់ របស់គូស្វាមីភរិយាមួយគូនេះ បាននិយាយថា កាតព្វកិច្ចសាសនានៅថ្ងៃអាទិត្យរបស់ឪពុកនាង គឺត្រូវអង្គុយបែកពីក្រុមគ្រួសារអំឡុងពេលប្រជុំសាសនាចក្រជានិច្ច ។

នាងនិយាយថា « យើងនឹងដណ្ដើមគ្នាអង្គុយក្បែរលោកនៅព្រះវិហារ ព្រោះលោកកម្រមានវត្តមាននៅទីនោះណាស់ ។ ខ្ញុំចាំពេលខ្ញុំចាប់ដៃលោក ហើយគិតខ្លួនខ្ញុំថា ‹ ប្រសិនបើខ្ញុំអាចរៀនប្រែក្លាយដូចជាលោក នោះខ្ញុំនឹងនៅលើផ្លូវត្រឹមត្រូវ






ហើយនឹងប្រែក្លាយកាន់តែដូចជាព្រះអង្គសង្គ្រោះ › ។ លោកគឺជាវីរបុរសរបស់ខ្ញុំជានិច្ច » ។

គ្រីស្ទានកូនប្រុសរបស់គូស្វាមីភរិយានេះ រំឭកពីអនុស្សាវរីយ៍នៃ « ពេលវេលារបស់ឪពុក និង កូនប្រុស » ។ គាត់និយាយថា មិត្តភាពជាមួយអ្នកដទៃជារឿងបណ្ដោះអាសន្ន ព្រោះគ្រួសារពួកយើងឧស្សាហ៍ប្ដូរទីលំនៅ « ប៉ុន្តែឪពុករបស់ខ្ញុំគឺជាមិត្តភក្តិដ៏ជិតស្និទ្ធរបស់ខ្ញុំជានិច្ច »—ទោះបីពេលខ្លះគាត់គឺជាគូប្រកួតប្រជែងម្នាក់ក្ដី ។

មិនថាការស៊ុតបាល់បោះជាមួយគ្រីស្ទានការលេងល្បែងកម្សាន្តជាមួយកូនស្រីគាត់ ឬ ស្នូចត្រីជាមួយគ្រួសារ និង មិត្តភក្តិរបស់ខ្លួនឡើយ រ៉ុនតែងតែឈ្នះ ។

គ្រីស្ទាននិយាយថា « អំឡុងពេលយើងធំឡើង គឺគាត់ពុំអនុញ្ញាត *ឲ្យនរណាម្នាក់* ឈ្នះគាត់ឡើយ ។ យើងត្រូវតែប្រឹងប្រែងដើម្បីទទួលជ័យជំនះ ប៉ុន្តែវាធ្វើឲ្យយើងកាន់តែប្រសើរឡើង ។ ហើយប្រពៃណីនេះបន្តរហូតដល់ចៅៗជាទីស្រឡាញ់របស់លោកដែរ » ។

អស់ជាពេលជាច្រើនឆ្នាំ គ្រួសាររបស់រ៉ុនអាចឃើញយ៉ាងច្បាស់ពីរបៀបដែលការបម្រើនៅក្នុងសាសនាចក្របានតម្កើងសមត្ថភាពរបស់លោក ដើម្បីបង្ហាញសេចក្ដីស្រឡាញ់ និង ការអាណិតអាសូរ ដើម្បីបង្ហាញអារម្មណ៍នៃព្រះវិញ្ញាណ ហើយបំផុសគំនិតរបស់មនុស្សដទៃទៀតឲ្យធ្វើកិច្ចការនានាឲ្យអស់ពីសមត្ថភាពរបស់ខ្លួន ។ បន្ទាប់ពីកំណើតចៅប្រុសរបស់រ៉ុន និង មេឡានី ឈ្មោះផាសតុន កើតមក គ្រួសារនេះបានពឹងផ្អែកទាំងស្រុងលើកម្លាំងខាងវិញ្ញាណ និង ការគាំទ្ររបស់រ៉ុន ។

ផាសតុន មានជំងឺតំណពូជដ៏កម្រពីកំណើត គាត់ត្រូវរងការឈឺចាប់ព្រោះបញ្ហាសុខភាពជាច្រើន ដែលជាការសាកល្បងចំពោះគ្រួសារគាត់ទាំងខាងរូបកាយ សតិអារម្មណ៍ និង ខាងវិញ្ញាណ ។ អែលឌើរ រ៉ាសបានបានហៅដំណើរការនេះ បន្ទាប់ពីកំណើតរបស់ផាសតុនថា « ជាការសាកល្បងដ៏ពិបាកមួយដើម្បីរៀនមេរៀនពិសេសៗ ដែលទាក់ទងនឹងភាពអស់កល្បរបស់ពួកគេ » ។[4]



អំឡុងពេលបីឆ្នាំយ៉ាងខ្លីនៃជីវិតរបស់ផាសតុន—ជាពេលដែលមានសំណួរជាច្រើនតែមានចម្លើយតិចតួច—អែលឌើរ រ៉ាសបាន បានឈរជាបង្គោលខាងវិញ្ញាណ ដោយដឹកនាំគ្រួសាររបស់លោកឲ្យខិតកាន់តែជិតព្រះចេស្ដានៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

ជាមួយនឹងការប្រកាសនៃការហៅបម្រើថ្មីរបស់លោក សមាជិកគ្រួសារ និង មិត្តភក្តិជាច្រើនគ្មានការភ្ញាក់ផ្អើលឡើយ ។ គ្រីស្ទាននិយាយថា « ពួកយើងទាំងអស់គ្នាដែលស្គាល់លោកច្បាស់ បានលើកដៃយ៉ាងខ្ពស់ នៅពេលគាត់ត្រូវបានគាំទ្រជាសាវក » ។

**« ទូលបង្គំនឹងទៅបម្រើ »**

នៅក្នុងឆ្នាំ ១៩៩៦ ពេលលោកមានអាយុ ៤៥ឆ្នាំ ជាពេលដែលរ៉ុនមានភាពជោគជ័យក្នុងវិជ្ជាជីវៈ នោះគាត់ត្រូវបានហៅឲ្យបម្រើជាប្រធានបេសកកម្មនៃបេសកកម្ម នូវ យ៉ោក នូវយ៉ោកខាងជើង ។ ដូចជាពួកសាវកពីបុរាណដែរ លោក « បានទុកសំណាញ់ [ របស់គាត់ ] ចោល » (ម៉ាថាយ ៤:២០) ។

អែលឌើរ រ៉ាសបានមានប្រសាសន៍ថា « ការទទួលយកការហៅបម្រើគឺគ្រាន់តែមួយពព្រិចភ្នែកប៉ុណ្ណោះ » ។ លោកបានមានប្រសាសន៍ទៅកាន់ព្រះអម្ចាស់ថា « ព្រះអម្ចាស់ចង់ឲ្យទូលបង្គំទៅបម្រើ នោះទូលបង្គំនឹងទៅបម្រើ » ។

អំឡុងពេលបម្រើរ៉ុនបានប្រើមេរៀនដ៏អស្ចារ្យដែលលោកបាន




ខាងឆ្វេងខាងលើ ៖ អែលឌើរ និង ស៊ិស្ទើរ រ៉ាសបានជាមួយសមាជិកសាសនាចក្រនៅ នូវ ឌេលី ប្រទេសឥណ្ឌា នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៥ ។ ខាងលើ ៖ អែលឌើរ និង ស៊ិស្ទើរ រ៉ាសបាន អំឡុងពេលការបម្រើរបស់លោកជាប្រធានបេសកកម្មនៅទីក្រុង នូវ យ៉ោក ឆ្នាំ ១៩៩៦-៩៩ ជាមួយចៅប្រុសរបស់ពួកលោកឈ្មោះ ផាសតុន ដែលបានជួយគ្រួសារនេះរៀនអំពី « មេរៀនពិសេសៗដែលមានទំនាក់ទំនងនឹងភាពអស់កល្បជានិច្ច » និង នៅក្នុងកម្មវិធីបញ្ចុះបឋមសិលានៅព្រះវិហារបរិសុទ្ធសាក្រាម៉ង់តូ កាលីហ្វូញ៉ា ។

រៀនពីបទពិសោធន៍នៃជីវិតរបស់លោកគឺ ៖ « មនុស្សមានសារៈសំខាន់ជាងអ្វីៗផ្សេងទៀត » ។[៥] ជាមួយនឹងចំណេះដឹងនោះ ព្រមទាំងទេពកោសល្យដែលលោកបានអភិវឌ្ឍ នោះលោកបានត្រៀមខ្លួនរួចរាល់ដើម្បីចាប់ផ្ដើមបម្រើពេញម៉ោងនៅក្នុងនគររបស់ព្រះអម្ចាស់ ។

រ៉ុន និង មេឡានីបានបម្រើកិច្ចការផ្សព្វផ្សាយសាសនានៅក្នុងទីក្រុង នូវ យ៉ោក ដោយមានទាំងឧបសគ្គ និង ក្ដីរំភើប ។ បន្ទាប់មក រ៉ុនបានផ្ទេរទំនួលខុសត្រូវដល់អ្នកផ្សព្វផ្សាយសាសនា—បំផុសឲ្យពួកគេមានភក្ដីភាព និង ការបង្រៀន ស្ថាបនា និង លើកស្ទួយពួកគេក្នុងកិច្ចការនោះ ។

នៅក្នុងឆ្នាំ ២០០០ ប្រាំបីខែបន្ទាប់ពីរ៉ុន និង មេឡានីបានបញ្ចប់បេសកកម្មរបស់ពួកគេ នោះរ៉ុនត្រូវបានហៅបម្រើជាពួកចិតសិបនាក់ ដែលលោកមានការរៀបចំបទពិសោធន៍ និង ទេពកោសល្យជាច្រើនដែលបានប្រទានពរដល់សាសនាចក្រ ។ ក្នុងនាមជាសមាជិកនៃពួកចិតសិបនាក់ នោះលោកបានបម្រើជាទីប្រឹក្សានៅក្នុងគណៈប្រធានតំបន់អឺរ៉ុបកណ្ដាល ដោយជួយគ្រប់គ្រងប្រទេសទាំង ៣៩ ។ ទោះបីជាលោកបានចប់ពីមហាវិទ្យាល័យជាង ៤០ឆ្នាំក្ដី លោកនៅតែបន្តធ្វើជាសិស្សដ៏ឧស្សាហ៍ ស្វាគមន៍ដល់ការបង្ហាត់បង្រៀនជាបន្តបន្ទាប់ពីពួកបងប្អូនប្រុសច្បងនៅពេលលោកបានគ្រប់គ្រងតំបន់ខាងលិចនៃអាមេរិកខាងជើងភាគពាយព្យ និង តំបន់ទាំងបីនៅយូថាហ៍ លោកបានបម្រើជានាយកប្រតិបត្តិនៃ ការិយាល័យព្រះវិហារបរិសុទ្ធ ហើយបានបម្រើនៅក្នុងគណៈប្រធាននៃពួកចិតសិប ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយពួកដប់ពីរនាក់ ។

ថ្មីៗនេះ អែលឌើរ រ៉ាសបានបានថ្លែងថា « វាជាកិត្តិយស និង ឯកសិទ្ធិដ៏អស្ចារ្យអ្វីម្ល៉េះសម្រាប់ខ្ញុំ ដើម្បីធ្វើជាមនុស្សដ៏តូចបំផុតនៅក្នុងចំណោមពួកដប់ពីរនាក់ ហើយរៀនពីពួកលោកគ្រប់ជំហាន និង គ្រប់ឱកាសទាំងអស់ » ។[៦]

### « អ្វីដែលពួកលោកបានដឹង នោះខ្ញុំដឹង »

មានគំនូរពីរផ្ទាំងព្យួរនៅជញ្ជាំងនៃការិយាល័យរបស់អែលឌើរ រ៉ាសបាន ។ គំនូរមួយគឺអំពីអ្នកផ្សព្វផ្សាយសាសនានៃពួកមរមនបង្រៀនគ្រួសារមួយនៅប្រទេសដាណឺម៉ាកនៅក្នុងទសវត្សឆ្នាំ ១៨៥០ ។ គំនូរទីពីរគឺអំពីអ្នកផ្សព្វផ្សាយសាសនាជំនាន់មុនឈ្មោះ ដាន ចូនស៍ ផ្សព្វផ្សាយឈរនៅលើអណ្ដូងទឹកនៅលើកោះនៃចក្រភពអង់គ្លេស ។ រូបគំនូរ ( ខាងស្ដាំខាងលើ ) រំឭកអែលឌើរ រ៉ាសបាន អំពីបុព្វការីជនរបស់លោកផ្ទាល់ ។

លោកបានថ្លែងទីបន្ទាល់ថា « អ្នកត្រួសត្រាយទាំងនេះបានលះបង់អ្វីៗទាំងអស់សម្រាប់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយបន្សល់ទុកនូវកេរដំណែលសម្រាប់កូនចៅរបស់ពួកគាត់ឲ្យដើរតាម » ។[៧] អ្វីដែលជំរុញឲ្យបុព្វការីជនរបស់អែលឌើរ រ៉ាសបានបន្តឆ្ពោះទៅមុខទោះមានទុក្ខលំបាកវេទនា និង ការបៀតបៀន និង អ្វីដែលធ្វើឲ្យលោកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះការហៅបម្រើថ្មីរបស់លោក ៖ គឺចំណេះដឹង និង សាក្សីដ៏ពិតរបស់ព្រះអម្ចាស់ និង កិច្ចការរបស់ទ្រង់ ។

លោកបានមានប្រសាសន៍ថា « ខ្ញុំមានកិច្ចការជាច្រើនដែលត្រូវរៀននៅក្នុងការហៅបម្រើថ្មីរបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍រាបទាបណាស់ចំពោះការបម្រើនេះ ។ ប៉ុន្តែលក្ខណៈពិសេសមួយនៃការហៅបម្រើរបស់ខ្ញុំដែលខ្ញុំអាចធ្វើបាន ។ គឺខ្ញុំអាចថ្លែងទីបន្ទាល់អំពីព្រះនាមនៃព្រះគ្រីស្ទ នៅទូទាំងពិភពលោក › (គ. និង ស. ១០៧:២៣) ។ ទ្រង់មានព្រះជន្មរស់ ! »[៨]





ក្នុងនាមជាចៅទួតនៃពួកអ្នកត្រួសត្រាយ នោះលោកបន្ថែមថា ៖ « អ្វីដែលពួកលោកបានទទួលអារម្មណ៍ នោះខ្ញុំក៏បានទទួលអារម្មណ៍នោះផងដែរ ។ អ្វីដែលពួកលោកបានដឹង នោះខ្ញុំក៏បានដឹង » ។[៩]

ហើយអ្វីដែលពួកគេបានរំពឹងទុកសម្រាប់កូនចៅជំនាន់ក្រោយរបស់ពួកគេគឺបានសម្ដែងឲ្យឃើញនៅក្នុងជីវិត ការបង្រៀន និង ការបម្រើរបស់អែលឌើរ រ៉ូណល អេ រ៉ាសបាន ដែលកំពុងធ្វើតាមគំរូរបស់ពួកគេ និង គោរពកេរដំណែលរបស់ពួកគេនៅពេលលោកបានបោះជំហានឆ្ពោះទៅមុខ ក្នុងនាមជាសាក្សីពិសេសម្នាក់របស់ព្រះអម្ចាស់ ។ ■

កំណត់ចំណាំ
១. រ៉ូណល អេ រ៉ាសបាន « I Stand All Amazed » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៨៩ ។
២. រ៉ូណល អេ រ៉ាសបាន « Friend to Friend: Golden Nuggets » *Friend* ខែ តុលា ឆ្នាំ ២០០២ ទំព័រ ៨ ។
៣. រ៉ូណល អេ រ៉ាសបាន « I Stand All Amazed » ទំព័រ ៨៩ ។
៤. រ៉ូណល អេ រ៉ាសបាន « Special Lessons » *Liahona* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៨០ ។
៥. រ៉ូណល អេ រ៉ាសបាន សន្និសីទសារព័ត៌មាន ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១៥ ។
៦. រ៉ូណល អេ រ៉ាសបាន testimony, Priesthood និង Family Department devotional ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៥ ។
៧. រ៉ូណល អេ រ៉ាសបាន « I Stand All Amazed » ទំព័រ ៨៩ ។
៨. រ៉ូណល អេ រ៉ាសបាន ទីបន្ទាល់ ។
៩. រ៉ូណល អេ រ៉ាសបាន Pioneer Day address, Tabernacle ទីក្រុង សលត៍ លេក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧ ។

ខាងឆ្វេងខាងលើបំផុត ៖ រូបថតដោយ វីនឌី ឃីលើរ ខាងស្ដាំ ៖ អ្នកផ្សព្វផ្សាយសាសនាមរមនទាំងនោះនាំទៅក្នុងប្រទេសដាណឺម៉ាក ដោយ អាណុល ហ្វ្រីប៊ើក ( ដោយមានការអនុញ្ញាតពី ក្រីស្ទីន ដាសហ្គ្នារ ឆ្នាំ ១៨៥៦ ) ដាន ចូនស៍ ព្រោះនៅក្នុងទីក្រុង វេល ដោយ ខ្លាក ឃេលី វ្រៃត



*ដោយសារខ្ញុំមិនសូវសកម្មអស់ជាច្រើនឆ្នាំមកហើយ សមាជិកម្នាក់ដែលស្គាល់ខ្ញុំ ពុំអាចជឿថាខ្ញុំត្រូវបានហៅឲ្យធ្វើជាប៊ីស្សពឡើយ ។*

**ដោយ ផាទ្រីក ដេ ក្រូនិន ទី III**

អំឡុងពេលប្រជុំគណៈកម្មការប្រតិបត្តិបព្វជិតភាព អ្នកផ្សាយសាសនាពេញម៉ោងរបស់យើងបានរាយការណ៍ពីការជួបសមាជិកម្នាក់ដែលកំណត់ត្រារបស់ខ្លួនមិននៅក្នុងវួដឡើយ ។ ភ្លាមនោះខ្ញុំបានស្គាល់ឈ្មោះនោះភ្លាម ហើយបាននិយាយថា នាងនិង ខ្ញុំធ្លាប់បាននៅវួដជាមួយគ្នាកាលពីច្រើនឆ្នាំមុន ។

អ្នកផ្សព្វផ្សាយសាសនាម្នាក់និយាយថា « មែនហើយ ប៊ីស្សព នាងបាននិយាយថា ហើយហាក់ដូចជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងថាអ្នកក្លាយជាប៊ីស្សពឬ » ។

ខ្ញុំបានសួរពួកគេថា « តើនាងបាននិយាយអ្វីខ្លះ ? »

ពួកគេនិយាយថា នាងមើលទៅដូចជាភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយនិយាយថា «*តើគាត់* ជាប៊ីស្សពឬ ? »

ខ្ញុំបានសើច ហើយពន្យល់ថាបងស្រីម្នាក់នេះបានស្គាល់ខ្ញុំ ថាជាមនុស្សផ្សេងពីនេះយ៉ាងខ្លាំងកាលពី៣០ឆ្នាំមុន ។

ក្រោយមកនៅពេលខ្ញុំបានគិតពីព្រឹត្តិការណ៍នោះមក ខ្ញុំបានគិតអំពីការផ្លាស់ប្តូរដ៏ច្រើននៅក្នុងជីវិតរបស់ខ្ញុំអំឡុងពេល៣០ ឆ្នាំជាងដែលគ្រួសារខ្ញុំ និង ខ្ញុំបានក្លាយជាសមាជិក ។ ខ្ញុំបានស្គាល់សមាជិកជាច្រើននៅក្នុងវួដរបស់យើងអស់រយៈពេល២០ឆ្នាំមកហើយ ហើយបានបម្រើជាប្រធានសាខា និង ប៊ីស្សព ប៉ុន្តែគ្មានសមាជិកទាំងនេះណាមួយបានស្គាល់ខ្ញុំកាលពី ៣០ឆ្នាំមុនឡើយ ។ ទោះបីជាខ្ញុំបានចែកចាយម្តងម្កាលពីព្រឹត្តិការណ៍នានាកាលពីអតីតកាលរបស់ខ្ញុំ ដើម្បីបង្រៀនអំពីការប្រែចិត្ត និង ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទក្តី ក៏សមាជិកវួដភាគច្រើនពុំដឹងថាមាននូវការផ្លាស់ប្តូរខ្លាំងប៉ុណ្ណាឡើយនៅក្នុងដំណើរជីវិតក្នុងសាសនាចក្ររបស់ខ្ញុំ ។

គ្រួសារខ្ញុំ និង ខ្ញុំត្រូវបាននាំឲ្យស្គាល់សាសនាចក្រនេះក្នុងខែ ឧសភា ឆ្នាំ ១៩៧៩ ហើយខ្ញុំបានដឹងភ្លាមថា ទីនេះហើយគឺជាកន្លែងដែលត្រឹមត្រូវសម្រាប់យើង ។ យើងបានជ្រមុជទឹកនៅខែមិថុនា ហើយនៅពេលដំបូងយើងទាំងអស់គ្នាសកម្ម ប៉ុន្តែមិនយូរប៉ុន្មានក្រោយមក ខ្ញុំបានឈប់ចូលរួមព្រះវិហារ ហើយបានត្រឡប់ទៅរកទម្លាប់ចាស់របស់ខ្ញុំវិញ ។ ខ្ញុំពុំដែលមានមន្ទិលសង្ស័យអំពីភាពពិតដ៏ពោរពេញនៃដំណឹងល្អ និង ការស្តារឡើងវិញឡើយ ប៉ុន្តែខ្ញុំពុំបានគិតថា ខ្ញុំពុំមានសមត្ថភាពគ្រប់គ្រាន់ដើម្បីក្លាយជាសមាជិកសាសនាចក្រល្អឡើយ ។

នៅឆ្នាំ ១៩៨២ ដោយសារខ្ញុំបន្តសេពគ្រឿងស្រវឹង នោះភរិយារបស់ខ្ញុំ ដែលពុំធ្លាប់ធ្លាក់ជំនឿរបស់គាត់នោះ បានរៀបចំក្រដាសស្នាមសុំលែងលះខ្ញុំ ។ កាលនោះគ្រួសាររបស់ខ្ញុំកំពុងរស់នៅក្នុងទីក្រុង អូក្លាហូម៉ា ស.រ.អា. ប៉ុន្តែខ្ញុំបានត្រឡប់ទៅរដ្ឋអិលលីណោយ ស.រ.អា. វិញ ជាកន្លែងដែលខ្ញុំត្រូវបានចិញ្ចឹមឲ្យធំឡើង ។ ខ្ញុំបានធ្លាក់ខ្លួនដល់ចំណុចមួយដែលធ្វើឲ្យខ្ញុំហៀបនឹងបាត់បង់អ្វីមួយ ដែលពិតជាមានតម្លៃបំផុតចំពោះខ្ញុំ ៖ គឺគ្រួសារខ្ញុំ ។

ខ្ញុំបានចាប់ផ្តើមអធិស្ឋានដោយលុតជង្គង់ទាំងព្រឹក ទាំងយប់ដល់ព្រះ ដែលជាអង្គដែលខ្ញុំពុំប្រាកដថានៅមានទ្រង់ទៀតនោះ ឬ ប្រសិនបើមានទ្រង់មែន ខ្ញុំគិតថាទ្រង់បានភ្លេចខ្ញុំយូរហើយ ។ ប៉ុន្តែខ្ញុំបានអធិស្ឋានដោយស្មោះត្រង់អស់រយៈពេលបីខែ ។ នាព្រឹកព្រលឹមមួយ ខណៈដែលខ្ញុំកំពុងអធិស្ឋានដោយអស់ពីចិត្ត នោះអារម្មណ៍ធូរស្បើយយ៉ាងខ្លាំងមួយបានមានក្នុងខ្លួនខ្ញុំ ហើយខ្ញុំបានដឹងថាព្រះមានព្រះជន្មរស់នៅ ថាទ្រង់បានស្គាល់ខ្ញុំ ហើយថាទ្រង់ស្រឡាញ់ខ្ញុំ ។ ហើយខ្ញុំក៏ដឹងផងដែរថាខ្ញុំនឹងមិនប៉ះគ្រឿងស្រវឹងសូម្បីតែមួយតំណក់ទៀតឡើយ ។

នៅល្ងាចនោះ ភរិយារបស់ខ្ញុំបានទូរសព្ទមកខ្ញុំ ដើម្បីប្រាប់ឲ្យខ្ញុំដឹងថា នាងនឹងផ្ញើឯកសារលែងលះមកឲ្យខ្ញុំចុះហត្ថលេខា ។ អំឡុងពេលនិយាយគ្នានោះ នាងបាននិយាយថា « មានអ្វីមួយប្លែកយ៉ាងខ្លាំងអំពីបង ។ អូនមិនជឿថាបងនឹងផឹកស្រា

# តើគាត់

## ជាប៊ីស្សពឬ ?



ម្ដងទៀតឡើយ ហើយអូននឹងហែកក្រដាសស្នាមទាំងនេះចោល » ។ យើងបានជួបជុំគ្នាវិញ ហើយពីរឆ្នាំក្រោយមក នាងបានបង្កើតកូនប្រុសទីបីរបស់យើង ។

បុគ្គលម្នាក់អាចស្មានថាខ្ញុំនឹងត្រឡប់ទៅសកម្មទាំងស្រុងវិញនៅក្នុងសាសនាចក្រ ប៉ុន្តែខ្ញុំជាមនុស្សរឹងរូសម្នាក់ ។ ខ្ញុំបានត្រឡប់ទៅវិញ ហើយបានទទួលការហៅជាអ្នកណែនាំកូរ៉ុមអែលឌើរ ។ ប៉ុន្តែមិនយូរប៉ុន្មានខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍ថានៅទន់ខ្សោយក្នុងការបង្រៀន ហើយបានធ្លាក់ខ្លួនអសកម្មម្ដងទៀត ។

នៅក្នុងឆ្នាំ ១៩៩១ យើងបានប្ដូរទៅនៅសាខាតូចមួយ ។ បួនប្រាំខែពីមុនកូនប្រុសពៅរបស់យើងអាយុ ៨ឆ្នាំ ភរិយារបស់ខ្ញុំ ដែលជាប្រធានបឋមសិក្សា បានសួរគាត់ថា តើគាត់ចង់ឲ្យនរណាជ្រមុជទឹកឲ្យគាត់ ។ មែនហើយ គាត់ចង់ឲ្យឪពុករបស់ខ្លួនធ្វើពិធីបរិសុទ្ធនោះ ។ ភរិយារបស់ខ្ញុំបានប្រាប់គាត់ថាប្រហែលជាវាមិនអាចកើតឡើងបានទេ ។ គាត់ពុំទទួលយកចម្លើយនោះឡើយ ហើយបានចាប់ផ្ដើមកិច្ចការនៃការធ្វើឲ្យឪពុករបស់គាត់សកម្មឡើងវិញ ។ គាត់មិនបង្អង់ពេលឡើយ ហើយមិនយូរប៉ុន្មាន ខ្ញុំបានឃើញថាខ្ញុំបម្រើជាប្រធានក្រុមកាយរិទ្ធ ហើយក្រោយមកខ្ញុំបានជ្រមុជទឹក និងបញ្ជាក់ដល់កូនប្រុសរបស់ខ្ញុំ ។

ប្រាំបីខែបន្ទាប់ពីខ្ញុំសកម្មគឺជាពេលវេលាដ៏រីករាយ ។ យើងបានផ្សារភ្ជាប់ជាគ្រួសារនៅក្នុងព្រះវិហារបរិសុទ្ធឈីកាហ្គោ អិលលីណោយ ហើយខ្ញុំត្រូវបានហៅបម្រើជាអ្នកណែនាំកូរ៉ុមអែលឌើរម្ដងទៀត លើកនេះខ្ញុំពុំបានបោះបង់វាទៀតឡើយ ។ ក្រោយមកខ្ញុំត្រូវបានហៅជាទីប្រឹក្សានៅក្នុងគណៈប្រធានសាខា ហើយប្រាំខែក្រោយមក ខ្ញុំត្រូវបានហៅបម្រើជាប្រធានសាខា ។ ប្រហែលជាមួយខែ បន្ទាប់ពីការបម្រើរបស់ខ្ញុំ នោះខ្ញុំបានចាំពីការគិតថា «*តើខ្ញុំ* ជាប្រធានសាខាឬ ? »

ខ្ញុំបានប្រាប់ពួកបរិសុទ្ធដែលមានការលំបាកៗ ជាច្រើនឆ្នាំថា ប្រសិនបើខ្ញុំអាចរីកចម្រើននៅក្នុងដំណឹងល្អ មនុស្សគ្រប់គ្នាអាចធ្វើវាបានផងដែរ ។ វាគឺជាការយល់ដឹងនូវអំណាចពិតនៃព្រះអង្គសង្គ្រោះ និង ដង្វាយធួនរបស់ទ្រង់ ហើយបោះជំហានទៅមុខដើម្បីមកកាន់ទ្រង់ ។

ខ្ញុំនឹងមានអំណរគុណជារៀងរហូតដល់ភរិយា និង កូនៗរបស់ខ្ញុំ និងដល់គ្រូបង្រៀនតាមផ្ទះ អ្នកដឹកនាំកូរ៉ុមអែលឌើរ ប៊ីស្សព និង ពួកបរិសុទ្ធដ៏ស្មោះត្រង់ផ្សេងទៀត ដែលបានធ្វើជាគំរូល្អអស្ចារ្យសម្រាប់ខ្ញុំ ។ វាគឺជាឯកសិទ្ធមួយដើម្បីបម្រើព្រះអម្ចាស់ និង ពួកបរិសុទ្ធក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ ។ ជីវិតរបស់ខ្ញុំបានពរយ៉ាងលើសលប់លើសពីអ្វីៗទាំងអស់ដែលខ្ញុំអាចស្រមៃគិត ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ អិលលីណោយ ស.រ.អា ។*

រូបគំនូរដោយ ម៉ាក ស្មីធ © ២០១៦

# ការបកប្រែព្រះគម្ពីរ ៖ ឲ្យទៅជា ភាសា នៃដួងចិត្តរបស់យើង

អស់អ្នកដែលជាប់ទាក់ទិនក្នុងការបកប្រែព្រះគម្ពីរពីភាសាអង់គ្លេសទៅជាភាសាដទៃទៀតស្គាល់នូវបទពិសោធន៍នេះ ។ បទពិសោធន៍នេះកើតឡើងម្ដងហើយម្ដងទៀត ។

យុវវ័យសាសន៍អាមេនីម្នាក់កាន់ព្រះគម្ពីរមរមនក្នុងដៃ ដែលទើបនឹងបានបកប្រែថ្មីៗនេះជាភាសារបស់ខ្លួនបានដើរសំដៅមករកសមាជិកម្នាក់នៃក្រុមដែលបានធ្វើការបកប្រែនោះ ។ គាត់ពោលថា « សូមអរគុណ » ។ « ខ្ញុំបានអានព្រះគម្ពីរមរមនជាភាសាអង់គ្លេស ។ « ខ្ញុំបានអានព្រះគម្ពីរមរមនជាភាសារុស្ស៊ី ។ ខ្ញុំបានអានវាជាភាសាអ៊ុយក្រែន ។ ខ្ញុំយល់វាពុំច្បាស់លាស់ឡើយ រហូតដល់ពេលដែលខ្ញុំអាចអានវាជាភាសាអាមេនីទើបខ្ញុំយល់ ។ ពេលខ្ញុំអានវាជាភាសាអាមេនី ធ្វើឲ្យខ្ញុំយល់តែម្ដង ។ វាគឺដូចជាត្រឡប់មកផ្ទះវិញអញ្ចឹង ។

**ការត្រឡប់មកផ្ទះវិញ**

ប្រសិនបើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺជាផ្ទះខាងវិញ្ញាណរបស់យើង នោះវាគឺការត្រឹមត្រូវហើយដែលវាផ្ដល់អារម្មណ៍នៃការលួងលោម និង ភាពស្និទ្ធស្នាលនេះ ។ នៅផ្ទះយើងសម្រាក ។ យើងចិញ្ចឹមបីបាច់ខ្លួនយើង ។ យើងនិយាយជាមួយមនុស្សជាទីស្រឡាញ់របស់យើងជាភាសាដែលបានបង្រៀនយើងដោយម្ដាយរបស់យើង ។ នេះគឺជាភាសានៃដួងចិត្តរបស់យើង ហើយដោយសារតែដួងចិត្តគឺអ្វីដែលដំណឹងល្អត្រូវតែឆ្ពោះទៅដល់នោះការសិក្សាព្រះគម្ពីរជាភាសានៃដួងចិត្តរបស់យើងគឺមានសារៈសំខាន់ណាស់ ។

គោលលទ្ធិ និងសេចក្ដីសញ្ញាប្រាប់ថាការណ៍នេះគឺពិត ។ នៅក្នុងគម្ពីរនោះ ព្រះអម្ចាស់បើកសម្ដែងថា តាមរយៈកូនសោបព្វជិតភាពដែលកាន់ដោយគណៈប្រធានទីមួយ « ព្រះពាហុនៃព្រះអម្ចាស់នឹងសម្ដែងក្នុងព្រះចេស្ដា



**បទពិសោធន៍រាប់មិនអស់បង្ហាញពីព្រះហស្តរបស់ព្រះអម្ចាស់នៅក្នុងកិច្ចការបកប្រែព្រះគម្ពីររបស់ទ្រង់ ។**

**ដោយ អ៊ែរ វ៉ាល ចនសុន**
ទស្សនាវដ្ដីសាសនាចក្រ



រូបថតនៃទំព័ររបស់ព្រះគម្ពីរមរមនជាភាសាជប៉ុន ព័រទុយហ្គាយ និង អាល្លឺម៉ង់ ដោយ ឡូរ៉ា សឺឍ *DESERET NEWS*






*ព្រះគម្ពីរបានរំជួលដួងចិត្តកាន់តែខ្លាំងក្លានៅពេលអានវាជាភាសាកំណើតរបស់យើងផ្ទាល់ – ជាភាសានៃដួងចិត្តរបស់យើង ។*

*ព្រះគម្ពីរមរមនបញ្ចប់ទាំងស្រុងត្រូវបានបោះពុម្ពជា៨៩ភាសា ហើយការបកប្រែជម្រើសត្រូវបានបកប្រែជា ២១ភាសាផ្សេងទៀត ។*

នូវការបរិវត្តន៍ដល់ពួកសាសន៍ទាំងឡាយ . . . អំពីដំណឹងល្អនៃសេចក្ដីសង្គ្រោះរបស់ពួកគេ ។

« ដ្បិតនៅថ្ងៃនោះ ហេតុការណ៍នឹងកើតឡើងថា មនុស្សគ្រប់រូបនឹងឮភាពពោរពេញនៃដំណឹងល្អ ដោយនូវពាក្យសម្ដីរបស់ខ្លួន និង ដោយនូវភាសារបស់ខ្លួន តាមរយៈពួកអ្នកដែលត្រូវបានតែងតាំងចំពោះអំណាចនេះ ដោយសារការចាត់ចែងនៃព្រះដ៏ជាជំនួយ ដែលបានសណ្ឋិតមកលើពួកគេសម្រាប់វិវរណៈនៃព្រះយេស៊ូវគ្រីស្ទ » ( គ. និង ស. ៩០:១០–១១ ) ។

ជីម ជេវែល ដែលបានធ្វើការនៅក្រុមបកប្រែព្រះគម្ពីរនៅឯទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ ប្រាប់រឿងមួយអំពីរបៀបដែលបទគម្ពីរអាចផ្ដល់នូវអារម្មណ៍ជិតស្និទដូចជានៅក្នុងគេហដ្ឋាន នៅពេលវាបានបកប្រែជាភាសានៃដួងចិត្ត ៖

« នៅក្នុងការបកប្រែព្រះគម្ពីរមរមនជាភាសាសេសូតូ ជាភាសាដែលគេនិយាយនៅប្រជាជាតិអាហ្វ្រិកនៃប្រទេសឡេសូតូ នោះយើងត្រូវការរកមនុស្សម្នាក់ជួយយើងវាយតម្លៃលើកិច្ចការនៃក្រុមបកប្រែនោះ ។ ប្រធានគម្រោង ឡារី ហ៊្វីលី បានរកឃើញសមាជិកម្នាក់នៃសាសនាចក្រមកពីប្រទេស ឡេសូតូ ដែលជានិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យរដ្ឋយូថាហ៍ ។ នៅក្នុងប្រទេស ឡេសូតូ ការអប់រំត្រូវបានប្រើប្រាស់ភាសាអង់គ្លេស ដូច្នេះស្ត្រីរូបនេះ និងកូនៗរបស់គាត់បានសិក្សាភាសាអង់គ្លេសតាំងពីថ្នាក់ទីមួយម្ល៉េះ ប៉ុន្តែពួកគេនៅតែនិយាយគ្នាជាភាសាសេសូតូនៅក្នុងផ្ទះ ។

« គាត់បានយល់ព្រមធ្វើកិច្ចការបកប្រែនេះ ។ ការវាយតម្លៃរបស់គាត់អំពីជំពូកនានាដែលយើងបានផ្ញើឲ្យគាត់ពិតជាមានប្រយោជន៍ណាស់ ។ យើងតែងតែផ្ញើសំណួរជាក់លាក់នានា ដែលទាក់ទងនឹងវាក្យស័ព្ទ និង សំណង់ប្រយោគភាសា ដែលគាត់បានផ្ដល់មតិយ៉ាងមានប្រយោជន៍ ។ ទោះជាយ៉ាងណាក៏ដោយ យើងកត់សម្គាល់ថា គាត់បានគូសពណ៌លឿងចំណាំលើខគម្ពីរជាច្រើន ដែលពុំទាក់ទងនឹងសំណួររបស់យើងសោះ ។ នៅពេលយើងបានសួរគាត់អំពីខគម្ពីរដែលបានគូសចំណាំទាំងនោះ គាត់បាននិយាយ ៖ ‹ អូ៎ ខគម្ពីរទាំងនោះវាធ្វើខ្ញុំរំជួលចិត្តយ៉ាងខ្លាំង ដែលខ្ញុំពុំធ្លាប់យល់ច្បាស់ជាភាសាអង់គ្លេស ។ ខ្ញុំបានគូសចំណាំវា ប្រយោជន៍ឲ្យខ្ញុំអាចចែកចាយវាជាមួយកូនៗរបស់ខ្ញុំ › » ។

**គំរូនៃការបកប្រែព្រះគម្ពីរ**

ការបកប្រែព្រះគម្ពីរប៊ីប គឺជាដំណើររឿងមួយដ៏យូរលង់ និង គួរឲ្យចាប់អារម្មណ៍ ដោយចាប់ផ្ដើមជាមួយនឹងការបកប្រែនៃផ្នែកនានានៃគម្ពីរសញ្ញាចាស់មកពីភាសាហេព្រើរទៅជាភាសាក្រិក ។ ក្រោយមកព្រះគម្ពីរប៊ីបបានបកប្រែពីភាសាក្រិក ទៅ ជាភាសាឡាតាំង ហើយចេញពីភាសាឡាតាំង ហេព្រើរ និង ភាសាក្រិកទៅជាភាសាអង់គ្លេស និង ទៅជាភាសាជាច្រើនផ្សេងៗទៀត ។[១] ជាលទ្ធផល សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ពុំបានបកប្រែព្រះគម្ពីរប៊ីបទៅជាភាសាផ្សេងៗឡើយ ប៉ុន្តែបានប្រើគម្ពីរប៊ីបដែលបានទទួលយករួចទៅហើយ ដោយពួកគ្រីស្ទានដែលនិយាយភាសាទាំងនោះ ។[២]

« ដ្បិតហេតុការណ៍នឹងកើតឡើងថា . . . មនុស្សគ្រប់រូបនឹងឮភាពពោរពេញនៃដំណឹងល្អ ដោយនូវពាក្យសម្ដីរបស់ខ្លួន និង ដោយនូវភាសារបស់ខ្លួន តាមរយៈពួកអ្នកដែលត្រូវបានតែងតាំងចំពោះអំណាចនេះ » ( គ. និង ស. ៩០:១១ ) ។





# ដំណើរការបកប្រែព្រះគម្ពីរ

1

## អនុមតិឲ្យបកប្រែ

- ការបកប្រែព្រះគម្ពីរត្រូវបានស្នើសុំដោយគណៈប្រធានតំបន់ នៅពេលសមាជិកនៃសាសនាចក្រ ដែលនិយាយភាសានោះកើនឡើង ហើយនៅពេលឯកសារគ្រឹះនៃសាសនាចក្រត្រូវបានបកប្រែទៅជាភាសានោះ ។
- ការស្នើសុំត្រូវបានពិនិត្យមើលដោយគណៈកម្មការនៃទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ ដែលរួមមានសមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ និងគណៈប្រធានទីមួយ ។

2

## ដំណាក់កាលនៃការបកប្រែ

ដំណាក់កាលដំបូង ៖

- ការបកប្រែព្រះគម្ពីរបរិសុទ្ធដែលមានរួចត្រូវបានជ្រើសរើសសម្រាប់ការប្រើប្រាស់របស់សាសនាចក្រ ។
- *ឯកសារសំខាន់ត្រូវបកប្រែមុនគេ ៖ មូលដ្ឋានគ្រឹះនៃដំណឹងល្អ* ( រួមមានគោលលទ្ធិគ្រឹះ ព្រមទាំងឈ្មោះសាសនាចក្រ ការអធិស្ឋានសាក្រាម៉ង់ ការអធិស្ឋានបុណ្យជ្រមុជទឹក និង មាត្រានៃសេចក្ដីជំនឿ ) *កូនសៀវភៅទីបន្ទាល់នៃព្យាការីយ៉ូសែប ស្ម៊ីធ* និង គេហទំព័រ LDS.org ។
- សុន្ទរកថាសន្និសីទទូទៅអាចត្រូវបានបកប្រែជាភាសានានា ។

ដំណាក់កាលទី ១ ៖

- ព្រះគម្ពីរមរមន ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា និងព្រះគម្ពីរមុក្ដាដ៏មានតម្លៃមហិមា ។ ( កិច្ចការនេះប្រហែលជា ១០ឆ្នាំ ។ )
- អត្ថបទមូលដ្ឋានគ្រឹះដូចជា « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » « ព្រះគ្រីស្ទដ៏មានព្រះជន្មរស់ ៖ ទីបន្ទាល់នៃពួកសាវក » ទំនុកតម្កើងដែលបានជ្រើសរើស និង *ប្រកាសដំណឹងល្អរបស់យើង* ។

ដូច្នោះហើយកិច្ចការបកប្រែព្រះគម្ពីរភាគច្រើនដែលសាសនាចក្រធ្វើនោះគឺព្រះគម្ពីរមរមន ( គឺជាគម្ពីរដែលត្រូវបកប្រែជាចម្បង ) ព្រះគម្ពីរគោលលទ្ធិ និង សេចក្ដីសញ្ញា និង ព្រះគម្ពីរមុក្ដាដ៏មានតម្លៃមហិមា ។ ភាសានានានៃព្រះគម្ពីរទាំងនេះត្រូវបានបកប្រែមកពីភាសាអង់គ្លេស ជាភាសាដែលព្យាការី យ៉ូសែប ស្ម៊ីធ បានបើកសម្ដែងឡើងនៅក្នុងនោះ ជាភាសានៃដួងចិត្តរបស់លោក ។ ដំណើរការដែលត្រូវបានប្រើប្រាស់ដើម្បីបកប្រែព្រះគម្ពីរទៅជាភាសានានាក្រៅពីភាសាអង់គ្លេស គួរតែត្រូវបានធ្វើឲ្យដឹងដល់សិស្សនានានៃប្រវត្តិសាសនាចក្រ ។ វាដូចគ្នាបេះបិទទៅនឹងដំណើរការដែលព្យាការីបានប្រើដើម្បីបកប្រែព្រះគម្ពីរមរមនទៅជាភាសាអង់គ្លេស ។

យ៉ូសែប ស្ម៊ីធគឺជាក្មេងម្នាក់ដែលរាបសា ជាកសិករដែលពុំមានការអប់រំច្រើនឡើយ ។ ប៉ុន្តែលោកមានគុណសម្បត្តិ និង សក្ដានុពលដែលព្រះអម្ចាស់ត្រូវការចំពោះកិច្ចការនេះដែលចាំបាច់ត្រូវតែបានសម្រេច ។ ពិតណាស់ យ៉ូសែប និងគ្រួសាររបស់លោកត្រូវបានរៀបចំ ហើយដាក់ពួកគេនៅទីនោះដើម្បីធ្វើកិច្ចការនេះតែម្ដង ។[៣]

យ៉ូសែបក៏បានទទួលជំនួយ — ពីព្រះ និង មនុស្សនានា — នៅក្នុងការបកប្រែកំណត់ត្រារបស់សាសន៍នីហ្វៃ ។ ទេវតាម៉ូរ៉ូណៃបានជួបយ៉ូសែប រាល់ឆ្នាំអស់រយៈពេលបួនឆ្នាំ ពីមុនអនុញ្ញាតឲ្យគាត់ទៅយកកំណត់ត្រានោះ ។ យើងពុំដឹងច្បាស់ទាំងអស់ឡើយថា ម៉ូរ៉ូណៃបានបង្រៀនអ្វីខ្លះដល់ព្យាការី ប៉ុន្តែការមកជួបរបស់ទ្រង់ហាក់បីដូចជាបានរៀបចំគាត់ខាងវិញ្ញាណ និងសតិអារម្មណ៍សម្រាប់កិច្ចការនានានាពេលខាងមុខ ។[៤]

ព្រះអម្ចាស់ក៏បានរៀបចំ « អ្នកបកប្រែ » ពីមុនគ្រានោះមកដល់ ដែលជាមធ្យោបាយដើម្បីបកប្រែភាសាដែលបាត់បង់ ។ ដោយបានពិពណ៌នាថាជាត្បូងថ្លាពីរដុំនៅក្នុងស៊ុមប្រាក់ របស់ទាំងនេះ និង ឧបករណ៍ស្រដៀងនេះត្រូវបានហៅថាជាត្បូងអ្នកមើលឆុត បានជួយព្យាការីបកប្រែកំណត់ត្រារបស់សាសន៍នីហ្វៃទៅជាភាសាអង់គ្លេស ។ ព្យាការីពុំបានរៀបរាប់អ្វីលម្អិតពីដំណើរការនេះឡើយ លោកបានថ្លែងយ៉ាងសាមញ្ញថា លោកបានបកប្រែគម្ពីរមរមនតាមរយៈ « អំណោយទាន និង ព្រះចេស្ដានៃព្រះ » ។[៥]

ក្រៅពី ជំនួយមកពីព្រះដែលលោកបានទទួល យ៉ូសែបមានមនុស្សជួយនៅក្នុងនាមជាអ្នកចម្លងដែលបានកត់ចម្លងជាឯកសារ ដែលក្រោយមកមានមនុស្សផ្សេងទៀតបានរៀបចំ បោះពុម្ព បង់ថ្លៃឲ្យ និងចែកចាយវាទៅកាន់ពិភពលោក ។

ស្រដៀងនឹងការរៀបចំ និង ជំនួយដែលយ៉ូសែបបានទទួលនៅក្នុងកិច្ចការបកប្រែរបស់លោក នោះអស់អ្នកដែលបានទទួលភារៈកិច្ចឲ្យធ្វើកិច្ចការនៃការបកប្រែព្រះគម្ពីរសព្វថ្ងៃនេះ ត្រូវបានរៀបចំដោយព្រះអម្ចាស់ ហើយបានទទួលជំនួយនៅក្នុងកិច្ចការរបស់ពួកគេ — ទាំងមកពីព្រះ និង មនុស្ស ។

**កិច្ចការនៃវិវរណៈ**

ដំណើរការដ៏លំបាកនៃការបកប្រែជះឥទ្ធិពលដោយកម្លាំងខាងវិញ្ញាណ ដែលអាចរៀបរាប់បានថាជា « វិវរណៈដោយក្រុមប្រឹក្សា » ។ មនុស្សពីរ ឬ បី នាក់ដែលបានជ្រើសរើសធ្វើជាអ្នកបកប្រែធ្វើការជាមួយមនុស្សផ្សេងទៀតនៅក្នុងការធ្វើកិច្ចការនេះ ។ ពួកគេមានប្រធាននៅទីស្នាក់ការកណ្ដាលនៃសាសនាចក្រ អ្នកត្រួតពិនិត្យនៅក្នុងមូលដ្ឋាន វាក្យស័ព្ទសម្រាប់ជាឯកសារយោង[៦] សេចក្ដីណែនាំបកប្រែ កម្មវិធីកុំព្យូទ័រ និង ការគាំទ្រពីបព្វជិតភាព រហូតដល់គណៈប្រធានទីមួយ ។ ( សូមមើលតារាងដែលភ្ជាប់មក ) ។ នៅពេលគណៈប្រធានផ្ដល់ការអនុមិតចុងក្រោយនៃការបកប្រែ នោះកិច្ចការនោះនឹងត្រូវរៀបចំ បោះពុម្ព និង ចែកចាយ ។ ដោយត្រូវបានរៀបចំជាទ្រមង់នពន្ត នោះវាក៏ត្រូវបានបោះពុម្ពផ្សាយលើ LDS.org ហើយមាននៅក្នុងកម្មវិធី Gospel Library ។

កិច្ចសហប្រតិបត្តិការរួមគ្នានេះគឺមានគោលបំណង និង ការបំផុសគំនិត ។ វាពាក់ព័ន្ធនឹងការផ្ដោតចិត្ត



ដោយស្មោះត្រង់ចំពោះគុណភាពនៃមាតិកា និង គុណភាពនៃការរៀបចំដែលមាននៅក្នុងកិច្ចការនោះ ។ ការបកប្រែគឺត្រូវបានត្រួតពិនិត្យជាច្រើនកម្រិត ជាពិសេសកម្រិតនៃថ្នាក់ដឹកនាំបព្វជិតភាពដែលស្វែងរកការអនុមតិពីព្រះអម្ចាស់ ។ មានតែបន្ទាប់ពីការអនុមតិនោះប៉ុណ្ណោះ ទើបការបកប្រែបានប្រព្រឹត្តិទៅបាន ។ ខណៈដែលពុំមានកម្រិតជាក់លាក់ពីវិវរណៈនៅក្នុងរបៀបដែលព្យាការី យ៉ូសែប ស្ម៊ីធបានបកប្រែព្រះគម្ពីរមរមន នោះដំណើរការនេះគឺត្រូវបានដឹកនាំយ៉ាងច្បាស់ដោយព្រះអម្ចាស់ — តាមរយៈអំណោយទានរបស់ទ្រង់ និង ព្រះចេស្ដារបស់ទ្រង់ ។

នេះពុំមានន័យថា ការបកប្រែនឹងល្អឥតខ្ចោះឡើយនៅពេលការបកប្រែដំបូងបានចប់ ។ ជារឿយៗការពិនិត្យមើលឡើងវិញជាច្រើនដងនាពេលខាងមុខដោយអស់អ្នកដែលសិក្សាព្រះគម្ពីរ ផ្ដល់យោបល់កែលម្អលើវេយ្យករណ៍ និង វាក្យស័ព្ទ ឬ រកឃើញកំហុសនៃការរៀបចំ ឬ ការប្រកបពាក្យ ។ កម្រមានការផ្លាស់ប្ដូរភាពច្បាស់លាស់នៃគោលលទ្ធិណាស់ ។ នៅពេលមានការផ្លាស់ប្ដូរ គឺវាត្រូវធ្វើឡើងក្រោមការណែនាំពីគណៈប្រធានទីមួយ ។

**ធនធានពីព្រះអម្ចាស់**

ព្រះអម្ចាស់គាំទ្រកិច្ចការបកប្រែនេះតាមរបៀបផ្សេងៗផងដែរ ។ ជាទូទៅមានការរាយការណ៍ដោយក្រុមបកប្រែនៅទីស្នាក់ការកណ្ដាលនៃសាសនាចក្រ នៅពេលមានតម្រូវការណាមួយនោះព្រះអម្ចាស់ប្រទានជំនួយឲ្យ ។

ឧទាហរណ៍មួយនៃឧទាហរណ៍ជាច្រើន មានការត្រូវការអ្នកបកប្រែម្នាក់សម្រាប់ការបកប្រែ និងថតសំឡេងឯកសារសាសនាចក្រជាភាសាម៉ម ( ដែលជាខ្សែស្រឡាយនៃភាសាម៉ាយ៉ានដែលគេនិយាយនៅក្នុងប្រទេស ក្វាតេម៉ាឡា ។ ក្នុងចំណោមអ្នកផ្សព្វផ្សាយសាសនាដំបូងគេដែលត្រូវបានហៅទៅប្រទេសក្វាតេម៉ាឡាគឺជាអែលឌើរម្នាក់ ដែលជីតារបស់គាត់និយាយភាសាម៉ម ។ អ្នកផ្សព្វផ្សាយសាសនារូបនេះត្រូវបានចិញ្ចឹមបីបាច់នៅក្នុងទីក្រុង ហើយនិយាយតែភាសាអេស្ប៉ាញប៉ុណ្ណោះ ។ ប៉ុន្តែរៀងរាល់យប់ជីតារបស់គាត់មករកគាត់ក្នុងក្ដីសុបិន ហើយបង្រៀនភាសាម៉មដល់គាត់ ។ អែលឌើរវ័យក្មេងម្នាក់នេះក្លាយជាអ្នកបកប្រែភាសាម៉មដ៏សំខាន់នៅក្នុងសាសនាចក្រ ។

ជារឿយៗ កិច្ចការបកប្រែនេះត្រូវបានធ្វើឡើងដោយការពលិកម្មផ្ទាល់ខ្លួនយ៉ាងអស្ចារ្យ ។ ដោយអាស្រ័យលើស្ថានភាពនៃហិរញ្ញវត្ថុ នោះអ្នកបកប្រែមួយចំនួនបានបរិច្ចាគការបម្រើរបស់ពួកគេ និង អ្នកខ្លះទៀតបានទទួលកម្រៃ ប្រយោជន៍ឲ្យពួកគេអាចលះបង់ពេលវេលាខ្លួនចំពោះការបកប្រែ ។

បុរសម្នាក់ដែលបានក្លាយជាអ្នកបកប្រែភាសាអ៊ើឌូ បានប្រែចិត្តជឿលើសាសនាចក្រនៅក្នុងប្រទេសបាគីស្ថានអំឡុងពេលធ្វើជាគ្រូបង្រៀន ។ ដោយសារលទ្ធផលនៃការប្រែចិត្តជឿរបស់គាត់ នោះគាត់បានបាត់បង់ការងារខ្លួន គាត់បានបាត់បង់ផ្ទះសម្បែង ដែលសាលាគាត់បង្រៀននោះបានផ្ដល់ដល់គាត់ ហើយគាត់បានបាត់បង់សាលារៀនរបស់កូនៗគាត់ផងដែរ ។ ប្រធានបកប្រែសាសនាចក្រម្នាក់ បានទៅជួបគាត់សម្រាប់ការបម្រើជាអ្នកបកប្រែ ហើយបានផ្ដល់ដល់គាត់នូវប្រាក់កម្រៃសមរម្យ ។ បន្ទាប់ពីធ្វើការជាអ្នកបកប្រែបានពីរបីខែមក បុរសម្នាក់នេះបានជួបជាមួយប្រធាននោះ ហើយស្នើសុំដោយអឹមអៀនប្រសិនបើប្រធាននោះនឹងទិញប៊ិចថ្មីមួយឲ្យគាត់ ។ ដោយសារប៊ិចដែលគាត់កំពុងប្រើនោះបានអស់ទឹកទៅហើយ ។ ក្រោយមកប្រធាននោះបានឃើញ និង កែកំហុសក្នុងកិច្ចការ ដែលអ្នកបកប្រែបានធ្វើ ដែលជាលទ្ធផលអ្នកបកប្រែរូបនោះទទួលបានកម្រៃតិចជាងអ្វីដែលគាត់ត្រូវទទួលបាន ។

ប៉ុន្តែដូចជាព្រះអម្ចាស់បានប្រទានពរដល់យ៉ូសែប ស្ម៊ីធ នៅក្នុងរបៀបមួយដែលធ្វើឲ្យលោកបំពេញកិច្ចការរបស់ខ្លួន នោះព្រះអម្ចាស់ប្រទានពរដល់អ្នកបកប្រែរបស់ទ្រង់ ។ ឧទាហរណ៍ អ្នកបកប្រែម្នាក់នៃ

ដំណាក់កាលទី ២ ៖

- ឯកសារផ្សេងៗជាច្រើនទៀតអាចត្រូវបានស្នើសុំដូចជាទស្សនាវដ្ដី *លីអាហូណា* សៀវភៅសិក្សាថ្នាក់វិទ្យាស្ថាន និង ថ្នាក់សិក្ខាសាលា សៀវភៅសិក្សាសម្រាប់ការណែនាំថ្ងៃអាទិត្យ ទំនុកតម្កើង និង ចម្រៀងកុមារ ឯកសារព្រះវិហារបរិសុទ្ធ និង ពង្សប្រវត្តិ និង ការបកប្រែសម្រាប់ការចាក់ផ្សាយសម្រាប់ស្ដេក និង តំបន់ ។

**ក្រុមការងារដ៏សំខាន់**

ក្រុមបកប្រែ ៖

- សមាជិកដែលសក្ដិសមចូលព្រះវិហារបរិសុទ្ធពីរ ឬ បីនាក់ដែលមានភាពចាស់ទុំល្មមនៅក្នុងដំណឹងល្អ ។
- ដោយបានធ្វើតាមសេចក្ដីណែនាំនៃការបកប្រែមួយខគម្ពីរម្ដងៗវចនានុក្រម និង ធ្វើតាមប្រធានបកប្រែនៃទីស្នាក់ការកណ្ដាលរបស់សាសនាចក្រ ។

ត្រួតពិនិត្យពីគណៈកម្មការបព្វជិតភាព ៖

- បុរស និង ស្ត្រីដែលមានគ្នាពីបីទៅប្រាំនាក់ដែលជាអ្នកដឹកនាំសាសនាចក្រនៅក្នុងតំបន់ ។
- ត្រូវ បានហៅ ហើយញែកចេញដើម្បីជួយពិនិត្យមើលការបកប្រែ ដើម្បីឲ្យមានភាពច្បាស់លាស់នៃការអាន និង គោលលទ្ធិត្រឹមត្រូវ ។
- ការប្ដូរពាក្យពុំធ្វើឡើងឡើយ រហូតដល់គណៈកម្មការយល់ស្របជាឯកច្ឆន្ទ ហើយការផ្លាស់ប្ដូរនោះវាត្រូវគ្នាជាមួយនឹងសេចក្ដីណែនាំនៃការបកប្រែ ។

ការពិនិត្យពីសមាជិក ៖

- សមាជិកសាសនាចក្រក្នុងមូលដ្ឋានក៏ពិនិត្យមើលពីការបកប្រែផងដែរ ។
- ពួកគេផ្ដល់នូវមតិកែលម្អលើភាពច្បាស់លាស់ និង ភាពសមរម្យរបស់ពាក្យពេចន៍ ។
- ភាពច្បាស់លាស់នៃការបកប្រែធានាថាព្រះវិញ្ញាណបរិសុទ្ធអាចថ្លែងជាសាក្សីពីសេចក្ដីពិតនៃការបង្រៀន ។

*ដំណើរការបកប្រែព្រះគម្ពីរវាទាក់ទងទាំងការប្រើខួរក្បាលគិត និង ដួងចិត្ត ព្រមទាំងជំនាញខាងសតិអារម្មណ៍ និង ការយល់ដឹងខាងវិញ្ញាណ ។*

ព្រះគម្ពីរភាសាឡាវៀនគឺជាមេធាវីដែលបានសិក្សាច្បាប់នៅក្នុងប្រទេស រុស្ស៊ី ជាកន្លែងដែលគាត់បានប្រែចិត្តជឿលើដំណឹងល្អដែលបានស្ដារឡើងវិញ ។ បានត្រឡប់ទៅប្រទេសឡេតូនីវិញ គាត់បានបង្កើតអាជីវកម្មរបស់ខ្លួន ។ លោកក៏បានបម្រើជាប្រធានសាខាផងដែរ ។ គាត់មានភាពមមាញឹកណាស់ ប៉ុន្តែសាសនាចក្រត្រូវការគាត់ និង ជំនាញរបស់គាត់ជាមួយនឹងភាសាអង់គ្លេស ។

គាត់បានសុំពេលដើម្បីអធិស្ឋានអំពីការស្នើសុំនោះ ដោយសារការទទួលយកកិច្ចការនោះ ដូចដែលគាត់បានប្រាប់ដល់អ្នកតំណាងសាសនាចក្រថា « ដូចជាដកអាហារចេញពីមាត់កូនៗរបស់ខ្ញុំអញ្ចឹង » ។ បន្ទាប់ពីអធិស្ឋាន គាត់បានសម្រេចចិត្តទទួលយកកិច្ចការនេះ ប៉ុន្តែបានទូលសុំព្រះអម្ចាស់ឲ្យប្រទានពរដល់គាត់ នូវមធ្យោបាយដើម្បីធ្វើនូវកិច្ចការលំបាក កិច្ចការដែលទាមទារខាងវិញ្ញាណ កិច្ចការដែលត្រូវការពេលច្រើន ។

គាត់បានចាប់ផ្ដើមទៅការិយាល័យច្បាប់របស់គាត់មួយម៉ោងមុនម៉ោងធ្វើការរៀងរាល់ថ្ងៃ ហើយបានប្រើម៉ោងនោះដើម្បីបកប្រែព្រះគម្ពីរមរមន ។ គាត់បានបញ្ចប់កិច្ចការនោះយ៉ាងលឿនក្នុងរយៈពេលប្រាំឆ្នាំ ។ ពិតណាស់ នេះជាការបកប្រែមួយដ៏លឿនបំផុត ក្រៅពីយ៉ូសែបដែលបានបកប្រែព្រះគម្ពីរមរមនប្រមាណជា៦០ថ្ងៃប៉ុណ្ណោះ ។

**នៅក្នុងកិច្ចការនៃការបកប្រែព្រះគម្ពីររបស់ព្រះអម្ចាស់ វាសបញ្ជាក់ឲ្យឃើញច្បាស់ថានេះគឺជាកិច្ចការរបស់ទ្រង់ ។ ទ្រង់រៀបចំមនុស្សជាមួយនឹងឧបករណ៍នានាដែលពួកគេត្រូវការដើម្បីពន្លឿនកិច្ចការនេះ ហើយទ្រង់បំផុសគំនិត និង ប្រទានពរពួកគេនៅពេលធ្វើកិច្ចការទាំងនេះ ។**



មានបទពិសោធន៍ជាច្រើនដែលអាចទាក់ទងនឹងការបង្ហាញថា ព្រះហស្តរបស់ព្រះអម្ចាស់នៅក្នុងកិច្ចការបកប្រែព្រះគម្ពីររបស់ទ្រង់ ។ បទពិសោធន៍ទាំងអស់ប្រកាសយ៉ាងច្បាស់ថា នេះគឺជាកិច្ចការរបស់ទ្រង់ ហើយថាទ្រង់ខ្វល់ខ្វាយយ៉ាងខ្លាំងអំពីកិច្ចការនេះ ។ ទ្រង់រៀបចំមនុស្សឲ្យធ្វើកិច្ចការនេះ ។ ទ្រង់រៀបចំឧបករណ៍នានាដែលពួកគេត្រូវការដើម្បីពន្លឿនកិច្ចការនេះ ។ ហើយទ្រង់បំផុសគំនិត និង ប្រទានពរដល់ពួកគេនៅពេលពួកគេធ្វើកិច្ចការនេះ ។

ជាលទ្ធផល ពិភពលោកបានរីកចម្រើនតាមរយៈព្រះបន្ទូលរបស់ព្រះ ដោយប្រទានដល់កូនចៅរបស់ទ្រង់ជាភាសានៃដួងចិត្ត ។ ■

**កំណត់ចំណាំ**

១. សូមមើលផ្នែកទីប្រាំបីនៃ « How the Bible Came to Be » ដោយ ឡៃណែត អេច រីត បានបោះពុម្ពនៅក្នុង *Ensign* នៅចន្លោះខែ មករា និង ខែ កញ្ញា ឆ្នាំ ១៩៨២ ។
២. សូមមើលឧទាហរណ៍ « Church Edition of Spanish Bible Now Published » mormonnewsroom.org។
៣. សូមមើល ម៉ាថាយ អេស ហូឡិន « The Path to Palmyra » *Liahona* ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ១៤–១៩ ។
៤. សូមមើល ខេន ភី ចាកសុន « Moroni's Message to Joseph Smith » *Ensign* ខែ សីហា ឆ្នាំ ១៩៩០ ទំព័រ ១២–១៦ ។
៥. យ៉ូសែប ស្ម៊ីធ នៅក្នុងបុព្វកថានៃព្រះគម្ពីរមរមន ។ សម្រាប់ការពិពណ៌នាបន្ថែមអំពីការបកប្រែព្រះគម្ពីរមរមនរបស់យ៉ូសែប ស្ម៊ីធ សូមមើលប្រធានបទដំណឹងល្អ « Book of Mormon Translation » topics.lds.org។
៦. វាក្យស័ព្ទផ្ដល់និយមន័យដល់គ្រប់ពាក្យនៅក្នុងព្រះគម្ពីរជាភាសាអង់គ្លេស ប្រយោជន៍ឲ្យអ្នកបកប្រែអាចយល់ពីអត្ថន័យនៃពាក្យនានាបានកាន់តែប្រសើរឡើង ។ ជារឿយៗ ពាក្យនានាមានអត្ថន័យច្រើនជាងមួយ ដូច្នេះអ្នកបកប្រែត្រូវតែពឹងផ្អែកលើបរិបទការបំផុសគំនិត និង កិច្ចការជាក្រុមដើម្បីស្វែងរកដំណោះស្រាយត្រឹមត្រូវ ។ យូរៗម្ដង សំណួរអំពីអត្ថន័យនៃពាក្យត្រូវបានដោះស្រាយតែតាមរយៈគណៈប្រធានទីមួយប៉ុណ្ណោះ ។



ដោយប្រធាន
រ័សុល អិម ណិលសុន
ប្រធានកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

# ឱកាសនានាសម្រាប់ ពួកអ្នកផ្សព្វផ្សាយសាសនារៀមច្បង

*របៀបមួយដ៏ល្អបំផុតសម្រាប់គូស្វាមីភរិយាដើម្បីមានអនុស្សាវរីយ៍ដ៏អស្ចារ្យនោះគឺការបម្រើបេសកកម្មជាមួយគ្នា ។*

នៅពេលមិត្តភក្តិរបស់យើងដែលមានអាយុ ៦០ ឬ ៧០ ឆ្នាំភ្លេចភ្លាំងអ្វីមួយ នោះយើងតែងភ្លាត់មាត់និយាយលេងថា « ចាស់ហើយ » ។ ប៉ុន្តែខ្ញុំចង់ពិភាក្សាពីភាពវ័យចំណាស់មួយបែបផ្សេងទៀត — គឺឱកាសមួយដ៏សែនមានន័យ ដែលអនុស្សាវរីយ៍នោះនឹងនៅជិតជាប់ជារៀងរហូត ។ វាគឺជាឱកាសដែលពួកអ្នកផ្សព្វផ្សាយសាសនារៀមច្បងដឹងថា ពួកគេកំពុងធ្វើកិច្ចការដែលព្រះអម្ចាស់ពិតជាមានព្រះទ័យចង់ឲ្យពួកគេធ្វើ ។ នៅក្នុងអនុស្សាវរីយ៍បែបនោះ ពួកគេទទួលស្គាល់ថា ៖

- ពួកគេមានបទពិសោធន៍ក្នុងជីវិតដើម្បីចែកចាយ និង មានទេពកោសល្យជំនាញ ព្រមទាំងការយល់ដឹងអំពីដំណឹងល្អ ដែលពួកគេអាចប្រើដើម្បីប្រទានពរដល់មនុស្សដទៃ ។
- គំរូរបស់ពួកគេគឺជាពរជ័យចំពោះកូនៗ និង ចៅៗរបស់ពួកគេ ។
- នៅពេលពួកគេបម្រើ នោះពួកគេកំពុងធ្វើឲ្យមានមិត្តភាពយូរអង្វែងហើយ ។
- អាពាហ៍ពិពាហ៍របស់ពួកគេកាន់តែរីកចម្រើនខ្លាំងឡើងរាល់ថ្ងៃ ។
- ការបម្រើនៅក្នុងព្រះនាមទ្រង់គឺគួរជាទីរីករាយណាស់ ។

### ឱកាសនានានៅក្នុងការបង្កើតអនុស្សាវរីយ៍

ឱមិត្តចំណាស់ៗរបស់ខ្ញុំអើយ អ្នកគប្បីព្យាយាមទទួលបទពិសោធន៍នៃឱកាសបែបនោះ ។ សូមគិតពីរឿងដែលអែលឌើរ ជែហ្វ្រី អ័រ ហូឡិនក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានរៀបរាប់អំពីអ្វីដែលអ្នកផ្សព្វផ្សាយសាសនាស្វាមីភរិយាមួយគូបម្រើនៅប្រទេសឈីលីបានធ្វើ ។ ឪពុកម្ដាយរបស់អែលឌើរវ័យក្មេងម្នាក់បានទទួលមរណភាព ។ ប្រធានបេសកកម្មនៅឆ្ងាយ ដែលពុំអាចឲ្យគាត់មកជួបអ្នកផ្សព្វផ្សាយសាសនានោះភ្លាមៗបានឡើយ ។

អែលឌើរ ហូឡិនមានប្រសាសន៍ថា « ប៉ុន្តែមានអ្នកផ្សព្វផ្សាយសាសនារៀមច្បងដ៏ចិត្តល្អ [ មានភាពចាស់ទុំ ] ដែលបម្រើនៅក្នុងតំបន់នោះ » ។ « ពួកគេបានមក ហើយអង្គុយជាមួយអ្នកផ្សព្វផ្សាយសាសនារូបនោះ ហើយបានយកចិត្តទុកដាក់ដោយក្តីស្រឡាញ់ និងបានលួងលោមគាត់រហូតដល់ប្រធានបេសកកម្មអាចទាក់ទងមកគាត់ដោយផ្ទាល់ ។ យើងមានអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងយ៉ាងអស្ចារ្យនៅក្នុងបេសកកម្មរបស់យើង ប៉ុន្តែគ្មានអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងណាម្នាក់អាចលួងលោមដល់អែលឌើរនោះ ដូចអ្នកផ្សព្វផ្សាយសាសនាស្វាមីភរិយានោះអាចធ្វើបានឡើយ » ។[1]

ជំនាញរបស់ពួកគេនៅគ្រានោះគឺសាមញ្ញបង្ហាញសេចក្ដីអាណិតអាសូរនៅចំគ្រាដ៏ចាំបាច់នោះ ។ ពួកគេពុំខ្វល់ខ្វាយពីការនិយាយភាសាផ្សេងក្រៅពីភាសានៃសេចក្ដីស្រឡាញ់ដូចជាព្រះគ្រីស្ទឡើយ ។ ពួកគេពុំបាច់ព្រួយបារម្ភពីការភ្លេចថ្ងៃខួបកំណើតចៅ ឬ ការប្រសិទ្ធពរទារកឡើយ បើទោះបីជាព្រឹត្តិការណ៍ទាំងនោះសំខាន់យ៉ាងណាក្តី ។ ពួកគេខ្វល់ខ្វាយពីកន្លែងដែលព្រះអម្ចាស់អាចប្រើពួកគេឲ្យទៅដើម្បីប្រទានពរដល់ជីវិតនៃកូនចៅរបស់ទ្រង់ ។ ហើយដោយសារពួកគេមាននូវឆន្ទៈបែបនេះ នោះទ្រង់អាចឲ្យពួកគេតំណាងទ្រង់បាន ។

### ការបម្រើគឺងាយស្រួលណាស់

សេចក្តពិតគឺថា គ្មានអ្នកផ្សព្វផ្សាយសាសនារៀមច្បងណាឃើញថាវាមានភាពងាយស្រួលដើម្បីចាកចេញពីផ្ទះឡើយ ។ ទោះបីជាយ៉ូសែប ស្ម៊ីធ ព្រិកហាំ យ៉ង់ យ៉ូហាន ថេលើរ ឬ វិលហ្វូឌ វូឌដ្រុព្វក្ដ ។ ពួកគេមានកូន និង ចៅៗផងដែរ ហើយពួកគេស្រឡាញ់ក្រុមគ្រួសាររបស់ខ្លួន គឺដូចជាពួកយើងអញ្ចឹងដែរ ។ ប៉ុន្តែពួកគេក៏ស្រឡាញ់ព្រះអម្ចាស់ ហើយចង់បម្រើទ្រង់ ។ ថ្ងៃណាមួយ យើងអាចជួបអ្នកខ្លាំងពូកែទាំងនេះដែលជួយស្ថាបនាសម័យកាន់កាប់ត្រួតត្រានេះ ។ នៅពេលយើងធ្វើដូច្នេះ នោះយើងនឹងរីករាយថា យើងពុំគេចវេសខ្លួនយើងពីការបម្រើ នៅពេលយើងគួរតែបម្រើនោះឡើយ ។

អ្នកខ្លះអាចចង់បម្រើខណៈដែលកំពុងរស់នៅឯផ្ទះខ្លួន ។ បន្ទាប់ពីមានជំងឺដាច់សរសៃឈាមខួរក្បាល ដែលធ្វើឲ្យអាសេ ស្កុម៉ាឆើរ ណែលសិន ( ពុំជាប់សាច់ឈាមខ្ញុំ

ទេ ) បានពិការត្រូវជិះលើរទេះរុញ នោះគាត់បារម្ភថាបំណងប្រាថ្នាក្នុងជីវិតរបស់គាត់ទៅបេសកកម្មជាមួយស្វាមីខ្លួន ដុន នឹងពុំអាចសម្រេចបានឡើយ ។ ក្រោយមកអ្នកជិតខាងម្នាក់បានជជែកជាមួយពួកគេអំពីបេសកកម្មសេវាកម្មសាសនាចក្រនៅឃ្លាំងរបស់ប៊ីស្សព ។ ដោយមានការលើកទឹកចិត្តនោះពួកគេបាននិយាយជាមួយអ្នកគ្រប់គ្រងអគារ បានបំពេញសំណុំបែបបទរបស់ខ្លួន ហើយត្រូវបានហៅបម្រើរយៈពេលពីរថ្ងៃក្នុងមួយសប្ដាហ៍នៅឃ្លាំងក្បែរផ្ទះរបស់ខ្លួន ។

អាសេ ណែលសិននិយាយថា « វាងាយស្រួលណាស់ដោយគ្រាន់តែដេកគិតថា ‹ អ៊ូ គេមិនត្រូវការខ្ញុំទៀតឡើយ › » ។ « ប៉ុន្តែឥឡូវខ្ញុំមានអារម្មណ៍ថាមានគេ *ត្រូវការ* ខ្ញុំ ។ ហើយនោះគឺជាទីបន្ទាល់មួយសម្រាប់ខ្ញុំ » ។



*អ្នកផ្សព្វផ្សាយសាសនាប្ដីប្រពន្ធមួយគូនៅក្នុងទីក្រុង សេអ៊ូល ប្រទេសកូរ៉េខាងត្បូង ពេញចិត្តនឹងបទពិសោធន៍ដ៏រីករាយនៃការបម្រើជាមួយគ្នា ។*

**ពិតជាមានគេត្រូវការអ្នកខ្លាំងណាស់**

ប្រសិនបើអ្នកត្រូវបានល្បួងឲ្យគិតថាពុំមានគេត្រូវការអ្នក នោះសូមឲ្យខ្ញុំបញ្ជាក់សារជាថ្មីជាមួយអ្នកថាគឺ មានគេត្រូវការអ្នក ។ គ្មានប្រធានបេសកកម្មនៅក្នុងសាសនាចក្រណា ដែលពុំចង់បានអ្នកផ្សព្វផ្សាយសាសនាគូស្វាមីភរិយាបន្ថែមទៀតដើម្បីបម្រើនៅក្នុងបេសកកម្មរបស់ខ្លួនឡើយ ។ ពួកអ្នកផ្សព្វផ្សាយសាសនារៀមច្បងពង្រឹងដល់អែលឌើរ និង ស៊ីស្ទើរវ័យក្មេង ។ ពួកគេផ្ដល់ការគាំទ្រ ដែលជួយមនុស្សដទៃឲ្យបម្រើកាន់តែប្រសើរឡើងនៅក្នុងទំនួលខុសត្រូវរបស់ខ្លួន ។ ហើយតើអ្នកអាចស្រមៃទៅមើលថា វាសំខាន់ប៉ុណ្ណា ដែលអ្នកដឹកនាំដែលទើបតែក្លាយជាសមាជិកបានពីរបីឆ្នាំ មានទំនាក់ទំនងយ៉ាងងាយស្រួលជាមួយនឹងសមាជិកសាសនាចក្រដែលបទពិសោធន៍យូរមកហើយនោះ ? ជារឿយៗអ្នកផ្សព្វផ្សាយសាសនារៀមច្បងគឺជាចម្លើយចំពោះការអធិស្ឋានរបស់ប៊ីស្សព និង ប្រធានសាខា ។

យើងសូមលើកទឹកចិត្តដល់ប្រធានបេសកកម្ម ព្យាយាមឲ្យអ្នកផ្សព្វផ្សាយសាសនារៀមច្បងបម្រើ ដើម្បីបំពេញទៅតាមតម្រូវការនៅក្នុងបេសកកម្មរបស់ខ្លួន ។ ប៊ីស្សពគួរតែព្យាយាមរកគូស្វាមីភរិយាដែលអាចទៅបម្រើបាន ។ គេហទំព័រ LDS.org មានរៀបរាប់ពីឱកាសជាច្រើនសម្រាប់អ្នកផ្សព្វផ្សាយសាសនារៀមច្បង ។ ប៉ុន្តែសំខាន់ជាងគេបំផុតនោះ គូស្វាមីភរិយាអាចលុតជង្គង់របស់ខ្លួនចុះ ហើយទូលសួរដល់ព្រះវរបិតា ប្រសិនបើនេះគឺជាពេលត្រឹមត្រូវសម្រាប់ខ្លួន ដើម្បីបម្រើបេសកកម្មជាមួយគ្នា ។ តម្រូវការមួយនៃតម្រូវការទាំងអស់នោះគឺ *បំណងប្រាថ្នា* ដើម្បីបម្រើអាចជាតម្រូវការសំខាន់បំផុត ( សូមមើល គ. និង ស. ៤:៣ ) ។

នៅពេលខ្ញុំកោតសរសើរអំពីកិច្ចការរបស់អ្នកផ្សព្វផ្សាយសាសនារៀមច្បង នោះខ្ញុំទទួលស្គាល់ថា មានពួកគេជាច្រើនចង់បម្រើ ប៉ុន្តែពួកគេពុំអាចធ្វើបាន ។ ការរារាំងនោះគឺដោយសារតែអាយុ ឬ សុខភាពទ្រុឌទ្រោម ក៏ដូចជាតម្រូវការចាំបាច់នានានៃសមាជិកគ្រួសារខ្លួន ។ នៅពេលបំណងប្រាថ្នានេះមានខ្លាំងក្លានៅក្នុងចិត្ត ប៉ុន្តែនៅតែមានដែនកំណត់បែបនេះ នោះមនុស្សដទៃអាចធ្វើកិច្ចការនេះជំនួសអ្នកបាន ហើយអ្នកអាចបរិច្ចាគថវិកាដ៏ចាំបាច់នោះ ។

គូស្វាមីភរិយាអើយ មិនថាអ្នកជានរណា ឬ នៅទីណាឡើយ សូមអធិស្ឋានអំពីឱកាសនេះដើម្បីបង្កើតឱកាសដ៏អស្ចារ្យធ្វើជាអ្នកផ្សព្វផ្សាយសាសនារៀមច្បងជាមួយគ្នា ។ ព្រះវរបិតាសួគ៌នឹងជួយអ្នកឲ្យដឹងពីអ្វីដែលអ្នកអាចធ្វើ ។ ■

**កំណត់ចំណាំ**

១. ជែហ្វ្រី អ័រ ហូឡិន នៅក្នុងយ៉ូសែប វ៉កឃើរ « Elder Jeffrey Holland: LDS Church Desperately Needs More Senior Missionaries » *Deseret News,* ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ ទំព័រ ៣ ។



















*ខាងលើ ៖ អ្នកផ្សព្វផ្សាយសាសនាវៀមច្បង ម៉ម្ម៉ូស ជួបជាទៀងទាត់ជាមួយប្រធាន រ៉ូប៊ីនសុន ដើម្បីពិភាក្សាពីរបៀបដើម្បីប្រើទេពកោសល្យរបស់ខ្លួន នៅពេលពួកគេបម្រើអ្នកដទៃ ។ ខាងលើ ៖ អ្នកផ្សព្វផ្សាយសាសនាវ័យក្មេងនៅមជ្ឈមណ្ឌលបំពាក់បំប៉ននៅក្នុង អាក្រា ហ្គាណា និយាយថា ដោយមានការគាំទ្រពីអែលឌើរ និង ស៊ិស្ទើរ ម៉ម្ម៉ូស គឺដូចជាការមានម្ដាយ និង ឪពុកទីពីរបម្រើជាមួយពួកគេ ។*










## នៅផ្ទះ ឬ ឆ្ងាយពីផ្ទះ

*ការបម្រើនៅផ្ទះ ឬឆ្ងាយពីផ្ទះក្ដី អ្នកផ្សព្វផ្សាយសាសនាវៀមច្បង « មកហើយជួយ » នៅក្នុងវួដ និង សាខា ការិយាល័យបេសកកម្ម មជ្ឈមណ្ឌលអ្នកទស្សនា ព្រះវិហារបរិសុទ្ធ បេសកកម្មនៅក្នុងទីក្រុង ការចាត់តាំងខាងវេជ្ជសាស្ត្រ មជ្ឈមណ្ឌលធនធានការងារ កម្មវិធីភាពខ្លួនទីពឹងខ្លួន កម្មវិធីជាសះស្បើយពីការញៀន ពង្សប្រវត្តិ រក្សាកំណត់ត្រា ប្រព័ន្ធអប់រំសាសនាចក្រ កិច្ចការសាធារណៈ សេវាកម្មជំនួយមនុស្សធម៌ និង មានជាច្រើនទៀត ។ ហើយត្រូវការអ្នកផ្សព្វផ្សាយសាសនាវៀមច្បងជាច្រើនបន្ថែមទៀត ។*











# អ្នកផ្សព្វផ្សាយសាសនារៀមច្បង ៖

## មានគេត្រូវការ ត្រូវបានប្រទានពរ និង ត្រូវបានស្រឡាញ់

*ការបម្រើជាអ្នកផ្សព្វផ្សាយសាសនាគូស្វាមីភរិយា កាន់តែអាចបត់បែនបាន ចំណាយតិច និង ជាបទពិសោធន៍ដ៏សែនរីករាយ ជាងអ្វីដែលអ្នកគិតទៅទៀត ។*

**ដោយ វីធាត អិម រ៉មនី**
ទស្សនាវដ្ដីសាសនាចក្រ

« តើអ្នកអាចមក ហើយជួយបានទេ ? »

វាគឺជាសំណួរមួយដែលហ្គើរ៉ល និង ឡូណា ម៉មរ៉ូស មកពី វ៉ាស៊ីនតោន ស.រ.អា. បានឆ្លើយកាលពីលើកមុន ។ ពួកគេបានឆ្លើយថា បាន នៅពេលអតីតប៊ីស្សពរបស់ខ្លួន ដែលឥឡូវជាប្រធានបេសកកម្ម បានស្នើសុំប្រសិនបើពួកគេអាចបម្រើជាមួយគាត់នៅវ៉េស អ៊ីនឌី ។ ពួកគេបានឆ្លើយថា បានម្ដងទៀតនៅពេលប្រធានស្ដេករបស់ពួកគេបានហៅពួកគេឲ្យបំពេញការបម្រើបេសកកម្មមួយនៅទីស្នាក់ការកណ្ដាលរបស់សាសនាចក្រនៅទីក្រុង សលត៍ លេក រដ្ឋយូថាហ៍ ស.រ.អា.ដោយធ្វើការជាមួយកុំព្យូទ័រ និង ធនធានមនុស្ស ។

នៅពេលអតីតប៊ីស្សព និង ប្រធានបេសកកម្មរបស់ពួកគេឈ្មោះ រីត រ៉ូប៊ីនសុន បានហៅពួកគេជាថ្មីម្ដងទៀត ដែលលើកនេះឲ្យបម្រើជាប្រធាននៃមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនានៅ អាក្រា ហ្គាណា គាត់បានសុំប្រសិនបើស្វាមីភរិយាឈ្មោះម៉មរ៉ូសនេះនឹងជួយបម្រើសារជាថ្មីម្ដងទៀត ។

អែលឌើរ ម៉មរ៉ូសនិយាយថា « យើងបានដឹងថាយើងអាចទុកចិត្តលើព្រះអម្ចាស់ » ។ « ដូច្នេះយើងបានសម្រេចចិត្តដើម្បីទុកចិត្តទ្រង់ម្ដងទៀត » ។ ពួកគេបានឆ្លើយថា បាន ដោយបានបំពេញទម្រង់បែបបទ ទទួលការហៅរបស់ខ្លួន ហើយមិនយូរប៉ុន្មានបានទៅដល់ប្រទេសហ្គាណា ។

### ការបម្រើជាអ្នកផ្សព្វផ្សាយសាសនារៀមច្បង

បទពិសោធន៍របស់គូស្វាមីភរិយាម៉មរ៉ូស បង្ហាញពីគោលការណ៍មួយចំនួនអំពីការបម្រើបេសកកម្មជាអ្នកផ្សព្វផ្សាយសាសនារៀមច្បង ដែលពុំអាចយល់បានទាំងស្រុងឡើយ ៖

- *បេសកកម្មមានពីរបែប ៖* ( ១ ) ប្រធានសាសនាចក្រហៅអ្នកផ្សព្វផ្សាយសាសនារៀមច្បង ឲ្យបម្រើទោះបីជានៅផ្ទះខ្លួនផ្ទាល់ ឬ ទៅឆ្ងាយពីផ្ទះក្ដី ។ ( ២ ) ប្រធានស្ដេកហៅអ្នកផ្សាយសាសនារៀមច្បងផ្នែកសេវាកម្មសាសនាចក្រ ដើម្បីបំពេញតម្រូវការក្នុងមូលដ្ឋាន ឬ ក្នុងតំបន់ក្រៅម៉ោង ចាប់ពី៨ ម៉ោងទៅដល់ ៣២ម៉ោងក្នុងមួយសប្ដាហ៍ ។ ជាទូទៅពួកគេរស់នៅ និង បម្រើនៅក្នុងមូលដ្ឋាន ប៉ុន្តែពេលខ្លះ អាចបម្រើនៅឆ្ងាយពីផ្ទះ ។
- *ប្រធានបេសកកម្មត្រូវបានលើកទឹកចិត្តឲ្យស្វែងរកអ្នកផ្សព្វផ្សាយសាសនារៀមច្បង ដែលអាចបំពេញនូវសេចក្ដីត្រូវការនៅក្នុងបេសកកម្មរបស់ខ្លួន ហើយអ្នកផ្សព្វផ្សាយសាសនារៀមច្បងអាចបង្ហាញពីចំណូលចិត្តរបស់ខ្លួន ។* អែលឌើរ ដៃប្រ៊ី អ៊័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា « យើងពុំបាននិយាយថាគូស្វាមីភរិយាអាចរើសយក និង ជ្រើសរើសការចាត់តាំងបម្រើបេសកកម្មរបស់ខ្លួនដោយខ្លួនឯងបានឡើយ » ។ « ការហៅគឺនៅតែជាការហៅ ។ . . . [ ប៉ុន្តែ ] យើងនិយាយពីអ្នកផ្សាយសាសនារៀមច្បងរបស់យើងអំពីចំណូលចិត្តនៃការបម្រើរបស់ពួកគេ ហើយគ្រប់ការពិចារណាទាំងអស់ត្រូវបានផ្ដល់ឲ្យ ដើម្បីឲ្យពួកគេបម្រើនៅកន្លែង និង របៀបដែលពួកគេចង់បម្រើ » ។[១]
- *ប្រធានបេសកកម្មប្រឹក្សាជាមួយគូស្វាមីភរិយានោះអំពីរបៀបដ៏ល្អបំផុតដើម្បីប្រើជំនាញ និង សមត្ថភាពរបស់ពួកគេ ។* ប្រធានរ៉ូប៊ីនសុនមានប្រសាសន៍ថា « ដើម្បីមានបទពិសោធន៍កាន់តែមានន័យខ្លាំងបំផុតក្នុងនាមជាអ្នកផ្សាយសាសនារៀមច្បង នោះ អ្នកត្រូវតែមានឱកាសដើម្បីធ្វើការទាំងនៅក្នុងតំបន់ ដែលអ្នកចង់បម្រើ និង កន្លែងដែលអ្នកមានកម្រិតជំនាញមួយដែលធ្វើឲ្យអ្នកមានអារម្មណ៍ថាមានគុណសម្បត្តិជាច្រើនដើម្បីផ្ដល់ឲ្យ » ។



**ចូរត្រៀមខ្លួនអ្នកឲ្យចេរាល់ជានិច្ច**

« យើងត្រូវការអ្នកផ្សព្វផ្សាយសាសនារៀបចំឡងជាច្រើនថែមទៀត ។ . . .ចូរត្រៀមខ្លួនអ្នកឲ្យចេរាល់ជានិច្ច ។ . . . មានពេលវេលាតិចតួចនៅក្នុងជីវិតអ្នក នៅពេលអ្នកនឹងរីករាយ [ យ៉ាងខ្លាំង ] នូវវិញ្ញាណដ៏ផ្អែមល្ហែម និង គួរជាទីពេញចិត្តដែលកើតមកពី [ ការបម្រើ ] ជាមួយគ្នានៅក្នុងកិច្ចការរបស់លោកចៅហ្វាយ » ។

ប្រធាន ថូម៉ាស អេស ម៉នសុន « As We Meet Together Again » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៦ ។





ឧទាហរណ៍ ប្រធានរ៉ូប៊ីនសុនបានដឹងថា អែលឌើរម៉ម៉ូសនិយាយភាសាបារាំង ពិតជាមានប្រយោជន៍ណាស់ ដោយសារជនជាតិអាហ្វ្រិកជាច្រើននិយាយភាសាបារាំង ។ ប្រធានរ៉ូប៊ីនសុនមានប្រសាសន៍ថា « ខ្ញុំបានស្រមៃឃើញថាគាត់កំពុងតែចុះប្រឡូកក្នុងកិច្ចការនៃការធ្វើដំណើរ និង ធ្វើទិដ្ឋាការសម្រាប់អ្នកផ្សព្វផ្សាយសាសនា » ។ « ប៉ុន្តែនៅពេលដែលគាត់បានមកដល់ពីនេះ ខ្ញុំមានអារម្មណ៍ថា នោះពុំមែនជាចំណាប់អារម្មណ៍ពិតប្រាកដរបស់គាត់ឡើយ ។ ដូច្នេះខ្ញុំបានអញ្ជើញគាត់ឲ្យប្រើជំនាញកុំព្យូទ័ររបស់គាត់ ។ គាត់បានជួយយើងអស់ជាច្រើនម៉ោង » ។ អែលឌើរ ម៉ម៉ូស ក៏ជួយអ្នកផ្សព្វផ្សាយសាសនាផងដែរ ជាពិសេសអ្នកផ្សព្វផ្សាយសាសនានិយាយភាសាបារាំងរៀបចំឈ្មោះ និង ធ្វើកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់គ្រួសាររបស់ពួកគេ ។ ស៊ីស្ទើរ ម៉ម៉ូស ជាជំនួយការពេទ្យ ត្រូវបានចាត់ឲ្យធ្វើការជាមួយវេជ្ជបណ្ឌិត និង គិលានុបដ្ឋានិយកាបេសកកម្ម ។

### ទ្រង់រៀបចំផ្លូវ

ដូចជាគូស្វាមីភរិយាម៉ម៉ូសផងដែរ នោះគូស្វាមីភរិយាដទៃផ្សេងទៀតឃើញថា នៅពេលយើងទុកចិត្តលើព្រះអម្ចាស់ នោះទ្រង់រៀបចំផ្លូវដល់យើង ។ នោះគឺជាអ្វីដែលបានកើតឡើងចំពោះអាលវិន និង កូរ៉ាស្សូន រីតាមកពីការីត ខារីត នៅក្នុងប្រទេសហ្វីលីពីន ។

អែលឌើរ រីតា ពន្យល់ថា « ពីរឆ្នាំពីមុនការសម្រេចចិត្តរបស់យើង ដើម្បីបម្រើ នោះយើងបានចាប់ផ្ដើមរៀបចំផែនការយ៉ាងម៉ត់ចត់ សម្រាប់ជំនួញគ្រួសាររបស់យើង » ។ « កូនប្រុសស្រីរបស់យើងបានបញ្ចប់មហាវិទ្យាល័យ ហើយអាចធ្វើកិច្ចការជំនួសពួកយើង ប៉ុន្តែយើងបានឆ្ងល់ថា តើនរណានឹងដោះស្រាយបញ្ហាជំនួញ និង ប្រតិកម្មដែលអតិថិជនមានចំពោះផែនការរបស់យើង ។

ស៊ិស្ទើរ រីតាក៏ព្រួយបារម្ភពីការទៅចោលម្ដាយចាស់ជរារបស់គាត់ផងដែរ ។ គាត់និយាយថា « ខ្ញុំភ័យខ្លាចថាយើងអាចបាត់បង់គាត់ អំឡុងពេលដែលយើងចេញទៅឆ្ងាយនោះ » ។ « ខ្ញុំក៏បានមានអារម្មណ៍ទន់ខ្សោយ ចំពោះការអញ្ជើញឲ្យបង្រៀនដំណឹងល្អផងដែរ » ។

ពួកគេបានប្រឹក្សាជាមួយប៊ីស្សពរបស់ខ្លួន និង ជាមួយគូស្វាមីភរិយាមួយគូដែលទើបតែបានបម្រើថ្មីៗនៅ ដាវ៉ៅ ។ ស៊ីស្ទើរ រីតា និយាយថា « ពួកគេទាំងអស់គ្នាបានថ្លែងទីបន្ទាល់យ៉ាងរឹងមាំថាព្រះអម្ចាស់នឹងដឹកនាំគូស្វាមីភរិយានិមួយៗ ឲ្យដឹងពីរបៀបដើម្បីដោះស្រាយកិច្ចការនៅឯផ្ទះខ្លួន ក្រុមគ្រួសារ និង ថវិកាសម្រាប់បេសកកម្មរបស់ខ្លួន » ។

អែលឌើរ រីតា និយាយថា « នៅពេលយើងស្វែងរកការណែនាំ នោះក្ដីបារម្ភរបស់យើងត្រូវបានដោះស្រាយ — អាជីវកម្មរបស់យើងបានលូតលាស់ទៅមុខយ៉ាងល្អទោះបីជាមានឧបសគ្គក្ដី អតិថិជនរបស់យើងបង្ហាញសេចក្ដីអំណរ និងការគាំទ្រ ហើយគ្រួសាររបស់យើងបានខិតកាន់តែជិតព្រះនៅក្នុងការថែទាំដល់ម្ដាយរបស់យើងដែលឈឺ ។ យើងបានចាប់ផ្ដើមយល់ថាព្រះអម្ចាស់ពិតជានឹងជួយយើង » ។

ឥឡូវនេះគូស្វាមីភរិយារីតាបម្រើជាសមាជិក និង គាំទ្រថ្នាក់ដឹកនាំនៅក្នុងបេសកកម្មហ្វីលីពីន កាហ្គាយ៉ាន ឌឺ អូរ៉ូ ។

### មានអ្វីជាច្រើនដែលអ្នក *អាច* ធ្វើបាន

គូស្វាមីភរិយាមួយចំនួនឆ្ងល់អំពីដែនកំណត់នៃបញ្ហាខាងសាច់ឈាម ប៉ុន្តែខែស និងជែននីលីន ម៉ាអើមែន មកពីរដ្ឋ យូថាហ៍ ស.រ.អ. ពុំមានមន្ទិលសង្ស័យពីបញ្ហានោះឡើយ ។ ជាច្រើនឆ្នាំកន្លងទៅ បួនខែបន្ទាប់ពីពួកគេបានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ឡូស អាន់ជើឡែសកាលីហ្វូញ៉ា នោះខែសត្រូវបានកេណ្ឌទៅធ្វើទាហាន ហើយបញ្ជូនទៅកាន់សមរភូមិ ។ ជាអ្នកដឹកនាំក្រុមទ័ពអាកាសនោះគាត់ដើរនាំមុខគេនៅមុខទាហានដទៃ នៅពេលពេលចម្ការមីនបានផ្ទុះឡើង ។ គាត់បានកំបុតជើងទាំងពីររបស់ខ្លួន ។ នៅពេលគាត់ត្រឡប់ទៅផ្ទះវិញ នោះ ជែននីលីនបានស្ទុះយ៉ាងលឿនទៅគ្រាគាត់ ។

ខែសនិយាយថា « ខ្ញុំបានដឹងថាខ្ញុំពុំព្រួយបារម្ភអ្វីឡើយ ដោយសារយើងមានអាពាហ៍ពិពាហ៍អស់កល្បជានិច្ចហើយ » ។ ភរិយារបស់ខ្ញុំបានគាំទ្រខ្ញុំរហូតមក ។ គាត់នៅតែគាំទ្រខ្ញុំរៀងរាល់ថ្ងៃ » ។

នៅពេលស៊ីស្ទើរ ម៉ាអើមែនបានចូលនិវត្តន៍ ពួកគេបានសម្រេចចិត្តបម្រើបេសកកម្ម ។ ប៉ុន្តែតើការកំបុតជើងទាំងគូរបស់អែលឌើរ ម៉ាអើមែនអាចជាបញ្ហាឬទេ ? គាត់និយាយថា « តែងតែមានរឿងជាច្រើនដែលខ្ញុំ *ពុំអាច* ធ្វើវាបាន ប៉ុន្តែក៏មានរឿងជាច្រើនទៀតដែលខ្ញុំ *អាច* ធ្វើបាន នោះយើងបានដឹងថានឹងមានកន្លែងមួយសម្រាប់យើង » ។

អំឡុងពេលបំពេញទម្រង់បែបបទរបស់ខ្លួន គាត់បានគូសសញ្ញាកែងលើប្រអប់មួយដែលបញ្ជាក់ថាគាត់បានបម្រើនៅក្នុងជួរកងទ័ព ។ មិនយូរប៉ុន្មាន ពួកគេបានទទួលការហៅមួយមកពីសម្ព័ន្ធយោធាសាសនាចក្រ ។ « ខ្ញុំមានអត្តសញ្ញាណប័ណ្ណមួយដែលអនុញ្ញាតឲ្យយើងចូលក្នុងបន្ទាយទាហាន ដូច្នេះពួកគេបានស្នើសុំការអនុញ្ញាតពីយើងដើម្បីណែនាំយើងសម្រាប់សម្ព័ន្ធយោធាបេសកកម្ម » ។

គូស្វាមីភរិយាត្រូវបានហៅឲ្យបម្រើនៅឯបន្ទាយទាហាននៅក្នុងរដ្ឋ ខារ៉ូលីណាខាងជើង ស.រ.អា. ។ អែលឌើរ ម៉ៅអើមែនរំឭក ៖ « សញ្ញានៅឯទ្វារចូលដាក់ថា ‹ បន្ទាយប្រាក គេហដ្ឋាននៃទាហានអាកាស › ។ នៅពេលអ្នកយាមបានស្វាគមន៍យើងដោយបាវចនាទ័ពអាកាស ‹ តាំងពីដើមទីរហូតដល់ចប់ ! › នោះវាគឺជាលើកដំបូងហើយដែលខ្ញុំបានស្តាប់ឮពាក្យនោះអស់ពេលជាច្រើនឆ្នាំមកហើយ ។ ខ្ញុំមានអារម្មណ៍កក់ក្តៅ បើទោះបីជាខ្ញុំពុំធ្លាប់ទៅបន្ទាយប្រាកក្តី ។ ខ្ញុំដឹងថាបេសកកម្មរបស់យើងគឺត្រូវនឹងយើងម៉ាច់តែម្តង ហើយថាព្រះអម្ចាស់មានព្រះទ័យគិតគូរពីខ្ញុំ » ។

ស៊ីស្ទើរ ម៉ៅអើមែននិយាយថា « យើងបានបង្រៀនមេរៀនអំពីការប្រែជាមានភាពខ្លួនទីពឹងខ្លួន និង ភាពរឹងមាំ ព្រមទាំងអំពីការពង្រឹងដល់អាពាហ៍ពិពាហ៍ » ។ « ដំបូងយើងពុំចង់ចែកចាយរឿងរបស់យើងឡើយ ប៉ុន្តែយើងបានឃើញថាការចែកចាយពីវាបានធ្វើឲ្យមានការផ្លាស់ប្តូរ ។ ពួកទាហាន និង ប្តីប្រពន្ធរបស់ពួកគេធ្លាប់បានបម្រើនៅក្នុងប្រទេសប្រេស៊ីលកាលពីនៅក្មេងក្តី ក៏គាត់ពុំសូវចេះភាសាព័រទុយហ្គាល់ច្រើនទៀតឡើយ ។ ហើយស៊ីស្ទើររ៉ូមរ៉េលពុំចេះភាសាព័រទុយហ្គាល់សោះ ។ ប៉ុន្តែដោយការសិក្សា និង ការខិតខំបានជួយឲ្យជំនាញភាសាព័រទុយហ្គាល់របស់អែលឌើរ រ៉ូមរ៉េលត្រឡប់ទៅរកភាពដើមវិញ ហើយភាសាព័រទុយហ្គាល់របស់ស៊ីស្ទើររ៉ូមរ៉េលវិញក៏រីកចម្រើនផងដែរ ។ ពួកគេក៏ចេះលេងហ្គីតា អូគូឡេឡេបានប្រសើរផងដែរ ។

ស៊ីស្ទើរ រ៉ូមរ៉េលនិយាយថា « ខ្ញុំពុំបានមានគម្រោងយកវាទៅជាមួយខ្ញុំឡើយ ប៉ុន្តែអែលឌើរ រ៉ូមរ៉េលត្រូវបានបំផុសគំនិតឲ្យយកវាទៅ ហើយវាពិតជាអស្ចារ្យណាស់ដែលឃើញពីអ្វីដែលបានកើតឡើង » ។ នៅពេលយើងបង្រៀនសាសនាគន់ការី ហើយធ្វើកិច្ចការដើម្បីឲ្យសកម្មឡើងវិញ ព្រមទាំងការរាប់អានវាសប្បាយណាស់ដើម្បីលេងហ្គីតានោះដើម្បីឲ្យមនុស្សច្រៀងទំនុកតម្កើង ។



ដោយយកឈ្នះលើបញ្ហាខាងហិរញ្ញវត្ថុ នោះអែលឌើរ និង ស៊ីស្ទើរ រីតាបម្រើនៅក្នុងប្រទេសរបស់ខ្លួនគឺប្រទេសហ្វីលីពីន ។



សម្រាប់អែលឌើរ និង ស៊ីស្ទើរ ម៉ៅអើមែន បម្រើនៅក្នុងសម្ព័ន្ធយោធាគឺត្រូវម៉ាច់នឹងពួកគាត់តែម្តង ។ ពួកគេនិយាយថា « វាដូចជាការត្រឡប់មកផ្ទះវិញអញ្ចឹង » ។



ដោយត្រូវបានបំផុសឲ្យយកហ្គីតាអូគូឡេឡេ នោះអែលឌើរ និង ស៊ីស្ទើររ៉ូមរ៉េលប្រើវាដើម្បីចែកចាយភាសាសាកលនៃតន្ត្រី នៅពេលពួកគេទៅសួរសុខទុក្ខនៅតាមផ្ទះ និង ច្រៀងទំនុកតម្កើង ។

បានមើលមកយើង ហើយនិយាយថា ‹ ប្រសិនបើអ្នកអាចធ្វើវាបាន នោះយើងក៏អាចធ្វើវាបានផងដែរ › » ។

គូស្វាមីភរិយាម៉ៅអើមែន មាននូវបទពិសោធន៍វិជ្ជមានបែបនោះនៅ ខារ៉ូលីណាខាងជើង ដែលពួកគេត្រូវបានស្នើសុំឲ្យបម្រើជាថ្មីម្តងទៀត ។ សព្វថ្ងៃនេះពួកគេធ្វើដំណើរប្រហែល ៦៤គីឡូម៉ែត្រពីផ្ទះរបស់ខ្លួននៅទីក្រុង អូរិមទៅទីក្រុង សតល៍ លេកពីរដងក្នុងមួយសប្តាហ៍ដើម្បីបម្រើនៅក្នុងការិយាល័យសម្ព័ន្ធយោធាសាសនាចក្រ ។ ពួកគាត់ក៏បង្រៀនអ្នកផ្សព្វផ្សាយសាសនាវៀមច្បងនៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនានៅទីក្រុង ប្រូវ៉ូ ជាកន្លែងដែលពួកគេឃើញថា ក្រុមនិមួយៗ រួមទាំងបុគ្គលម្នាក់បានយកឈ្នះលើឧបសគ្គនានាដើម្បីបម្រើ ។

### ភាសានៃសាកលលោក

ដោយបានហៅឲ្យបម្រើនៅបេសកកម្មប្រេស៊ីល ឃ្វីអាបា នោះរ៉ានឌី និង លូអេលែន រ៉ូមរ៉េលមកពីយូថាហ៍មានការព្រួយបារម្ភ ។ ទោះបីជាអែលឌើរ រ៉ូមរ៉េលយើងរៀនភាសានោះ ហើយទំនុកតម្កើងបាននាំមកនូវព្រះវិញ្ញាណដ៏អស្ចារ្យជាមួយពួកគេ » ។

ទោះបីជាជំនាញភាសាព័រទុយហ្គាល់របស់នាងនៅតែកំពុងអភិវឌ្ឍក្តី គាត់បានច្រៀងយ៉ាងរលូន ។ គាត់និយាយថា « តន្ត្រីនាំឲ្យមនុស្សជួបជុំគ្នា » ។ « ទោះបីជាខ្ញុំពុំអាចយល់អ្វីគ្រប់យ៉ាងដែលពួកគេនិយាយអំឡុងពេលជួបគ្នាក្តី ក៏នៅពេលច្រៀងពួកយើងបានយល់គ្នា » ។ ដោយបានអញ្ជើញឲ្យនិយាយនៅក្នុងថ្នាក់អំពីបុណ្យជាតិរបស់អាមេរិកគឺបុណ្យថ្លែងអំណរគុណ នោះអ្នកផ្សព្វផ្សាយសាសនាវៀមច្បង រ៉ូមរ៉េលបានច្រៀងទំនុកតម្កើងនៃការថ្លែងអំណរគុណ — ដោយលេងហ្គីតាអូគូឡេឡេ ។ ហើយស៊ីស្ទើររ៉ូមរ៉េលក៏ប្រើឧបករណ៍សាមញ្ញបន្ថែមមួយដែល គឺព្យាណូដើម្បីច្រៀងទំនុកតម្កើងនៅព្រះវិហារ ។

ចុះភាសាព័រទុយហ្គាល់វិញ ? គាត់និយាយថា « ទោះបីជាអ្នកមិនចេះស្ទាត់ក្តី ការរៀនតែពីរបីពាក្យនឹងជួយហើយ » ។ « ការនិយាយតែពាក្យសាមញ្ញដូចជាសួស្តី និង ការស្វាគមន៍មនុស្សនឹងមានឥទ្ធិពលយ៉ាងខ្លាំង ។ ចូរឲ្យ

ពួកគេដឹងថាអ្នកកំពុងរៀនវា ។ សូមរៀនតាមសម្រួល ហើយពឹងផ្អែកលើព្រះវិញ្ញាណ » ។ ពិតមែនហើយ ព្រះវិញ្ញាណគឺជាភាសាមួយផ្សេងទៀតដែលមនុស្សគ្រប់គ្នាអាចចេះ ។

**ការបម្រើនៅផ្ទះ**

ប៉ុល និង ម៉ា ជីន លេវីស មកពីរដ្ឋយូថាហ៍ បានបម្រើបេសកកម្មបីដងហើយ ( ព្រះវិហារបរិសុទ្ធប៉ាល់ម៉ៃរ៉ា នូវយ៉ោក ព្រះវិហារបរិសុទ្ធហុងកុង ប្រទេសចិន និង នៅក្រូអាតស៊ើរបៀន និង ស្លូវេនី ជាមួយថ្នាក់សិក្ខាសាលា និង វិទ្យាស្ថានសាសនា ) ។ ពួកគេបានរៀបចំបម្រើបេសកកម្មមួយទៀត ទទួលពិធីបរិសុទ្ធ ហើយទៅព្រះវិហារបរិសុទ្ធគឺជាពរជ័យអស្ចារ្យមួយ » ។

អែលឌើរ លេវីសនិយាយថា « មានអ្នកផ្សាយសាសនារៀមច្បងជាច្រើន នៅពេលពួកគេគិតអំពីការបម្រើបេសកកម្ម នោះពួកគេបារម្ភពីអ្វីដែលពួកគេនឹងធ្វើនៅផ្ទះរបស់ខ្លួន និង ឡានរបស់ខ្លួន ឬអ្វីៗដែលពួកគេនឹងនឹកដល់គ្រួសាររបស់ពួកគេ » ។ « យើងអាចរស់នៅក្នុងផ្ទះរបស់យើង ហើយបើកឡានរបស់យើងផ្ទាល់ ។ យើងត្រូវបានលើកទឹកចិត្តឲ្យទៅសកម្មភាពរាត្រីជួបជុំក្រុមគ្រួសារ ដរាបណាកម្មវិធីនោះមិនប៉ះពាល់ដល់ទំនួលខុសត្រូវរបស់អ្នកផ្សព្វផ្សាយសាសនា ។ ហើយយើងក៏បាននៅទីនេះរហូតដល់ចៅរបស់យើងម្នាក់កើតផងដែរ » ។



*ដោយបម្រើនៅឯផ្ទះ នោះអែលឌើរ និង ស៊ីស្ទើរលេវីស រីករាយនឹងស្គាល់អ្នកផ្សព្វផ្សាយសាសនា និង សមាជិកនៅក្នុងស្តេករបស់ខ្លួន ។*



*អែលឌើរ និង ស៊ីស្ទើរ សូរ៉េនសិន ឲ្យថ្មតូចៗដល់កូនក្មេងនៅក្នុងកោះយុក ដើម្បីរំឭកពួកគេឲ្យបន្ត « រឹងមាំនៅក្នុងព្រះគ្រីស្ទ » ។*

នៅពេលប្រធានស្តេករបស់ពួកគេបានសុំ « តើអ្នកមានបំណងដើម្បីបម្រើនៅក្នុងស្តេកខ្លួនផ្ទាល់ ដើម្បីគាំទ្រដល់បេសកកម្មដែលអ្នកកំពុងរស់នៅនេះទេ ? »

ស៊ិស្ទើរ លេវីសនិយាយថា « យើងជាអ្នកចំណូលថ្មីនៅទីនេះ ដូច្នេះវាគឺជាឱកាសដ៏អស្ចារ្យ » ។ « យើងបម្រើជាមួយអែលឌើរ និង ស៊ីស្ទើរវ័យក្មេង ដែលមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយប្រធានបេសកកម្ម ទៅប្រជុំមណ្ឌល និង តំបន់ ហើយធ្វើការជាមួយអ្នកដឹកនាំបេសកកម្មវួដ » ។ ពួកគេក៏ទៅសួរសុខទុក្ខសាសនាគន់ការី និង អស់អ្នកដែលមិនសូវសកម្ម ។

ស៊ិស្ទើរ លេវីសនិយាយថា « យើងបានជួបមនុស្សអស្ចារ្យជាច្រើន យើងនឹងពុំធ្លាប់ស្គាល់ រួមទាំងមនុស្សមួយចំនួនទៀត ដែលបានអសកម្ម ។ ឃើញពួកគេត្រឡប់មកវិញ

**ពរជ័យដល់គ្រួសារ**

ម្យ៉ាងវិញទៀត ជីល និង ខេន សូរ៉េនសិន ដែលមកពីស្តេកជាមួយគ្នា បាននិយាយពីរបៀបដ៏ល្អបំផុតដើម្បីពង្រឹងគ្រួសារខ្លួនដែលបានបម្រើនៅឆ្ងាយពីផ្ទះខ្លួន ។ ស៊ិស្ទើរ សូរ៉េនសិននិយាយថា « ការដោះសារមួយដ៏ធំដែលស្វាមីភរិយាបានធ្វើនោះ គឺ ថាខ្លួនបដិសេធពុំទៅបេសកកម្មនោះដោយសារមានចៅ កូនរៀបការមានបញ្ហា កូនស្រីនឹងមានគ៌រ ឪពុកម្តាយចាស់ — អ្នកនឹងមានរឿងដោះសារគ្រប់បែបយ៉ាង ។ គ្រួសារគឺជាអាទិភាព ហើយអ្នកនឹកពួកគេរៀងរាល់ថ្ងៃ ។ ប៉ុន្តែការទៅបេសកកម្មគឺជាកាបញ្ជូននូវសារលិខិតដ៏មានអនុភាព ថាកិច្ចការអ្នកផ្សព្វផ្សាយសាសនាក៏សំខាន់ផងដែរ ។

ក្រៅពីនោះ អែលឌើរ សូរ៉េនសិនបានកត់សម្គាល់គឺថា « ឥឡូវនេះមានរបៀបជាច្រើនដើម្បីបន្តទាក់ទងគ្នា ដែលអ្នកអាចប្រើវាបានគ្រប់ពេល » ។



**« ខ្ញុំនឹងធ្វើដែលទ្រង់ឲ្យខ្ញុំធ្វើ »**

« នៅពេលខ្ញុំគិតពីតម្រូវការដ៏ច្រើននៃអ្នកផ្សព្វផ្សាយសាសនារៀមច្បង នោះខ្ញុំតែងគិតអំពីទំនុកតម្កើងដ៏គួរឲ្យពេញចិត្ត ‹ ខ្ញុំ › នឹងទៅដែលទ្រង់ឲ្យខ្ញុំទៅ › ( *ទំនុកតម្កើង* លេខ ១៦៨ ) និង សារលិខិតរបស់បទនេះ គឺ ‹ ខ្ញុំ › នឹងធ្វើដែលទ្រង់ឲ្យខ្ញុំធ្វើ › » ។

អែលឌើរ ដាល្លិន អេក អូកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។



**ត្រូវការអ្នកផ្សព្វផ្សាយសាសនារៀមច្បង**

« សារលិខិតរបស់យើងចំពោះអ្នកទាំងអស់គ្នាដែលជាគូស្វាមីភរិយាដ៏ចាស់ទុំរបស់យើងគឺសាមញ្ញ ៖ យើងត្រូវការពួកអ្នកយ៉ាងខ្លាំង ។ យើងកំពុងធ្វើអ្វីគ្រប់យ៉ាងដែលយើងអាចធ្វើបានដើម្បីធ្វើឲ្យមានភាពងាយស្រួលដល់អ្នកឲ្យទៅបេសកកម្ម ។ . . . វាដល់ពេលហើយ ដើម្បីឲ្យអ្នកទៅបម្រើ ។ មានមនុស្សជាច្រើនដែលត្រូវការអ្នក ។ សូម — ទៅបម្រើបេសកកម្មចុះ » ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមពួកសាវកដប់ពីរនាក់ *Deseret News* ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ ។

ដំណើរជីវិតជាអ្នកផ្សព្វផ្សាយសាសនារបស់គូស្វាមីភរិយា ស្វ៉ែនសិនបាន ចាប់ផ្ដើមកាលពីបីឆ្នាំកន្លងទៅ នៅពេលប៊ីស្សពរបស់ពួកគេបានសុំពួកគេឲ្យ ធ្វើជាម្ចាស់កម្មវិធីប្រជុំពិសេស សម្រាប់គូស្វាមីភរិយាដែលបម្រុងនឹងបម្រើជា អ្នកផ្សព្វផ្សាយសាសនា ។ ស៊ីស្ទើរ ស្វ៉ែនសិននិយាយថា « បន្ទាប់ពីនិយាយ ពីការបម្រើនោះជាទៀងទាត់មក ពួកយើងត្រូវទៅបេសកកម្មដោយខ្លួនឯង ! » ពួកគេ បានទទួលការហៅឲ្យបម្រើនៅក្នុងក្រុមកោះឃុក ដែលជីដូនជីតារបស់ជីលបានបម្រើ កាលពី៥០ឆ្នាំមុន ។

សព្វថ្ងៃនេះ ក្នុងចំណោមកិច្ចការផ្សេងទៀត នោះពួកគេត្រូវបានសុំឲ្យបង្រៀនថ្នាក់ ព្រះគម្ពីរប៊ីបនៅក្នុងសាលា ។

អែលឌើរ ស្វ៉ែនសិននិយាយថា « យើងបានជជែកគ្នាអំពីព្រះគ្រីស្ទគឺជា សិលា » ។ « យើងឲ្យថ្មតូចៗទៅសិស្ស ហើយលើកទឹកចិត្តពួកគេឲ្យបន្ដរឹងមាំ



*នៅជុំវិញពិភពលោក គូស្វាមីភរិយានិយាយថា ក្រៅពីការជួយដល់អ្នកដទៃ ការបម្រើជាមួយគ្នាពង្រឹង អាពាហ៍ពិពាហ៍របស់ពួកគេ ហើយនាំពួកគេឲ្យខិតកាន់តែជិតនឹងព្រះវរបិតាសួគ៌ ។*

នៅលើព្រះគ្រីស្ទ ។ ឥឡូវនេះ ទីណាក៏ដោយដែលយើងទៅគេនិយាយថា ‹ ថ្មរឹងមាំៗ ! › នៅពេលពួកគេឃើញយើង » ។

### មកហើយជួយ

ប្រសិនបើអ្នកគិតបម្រុងទៅបេសកកម្មពេញម៉ោង ឬបេសកកម្មសេវាកម្ម សាសនាចក្រ នោះពួកអ្នកផ្សព្វផ្សាយសាសនារៀមច្បងទាំងនេះ នឹងសួរអ្នកនូវ សំណួរដូចដែលប្រធាន រ៉ូប៊ីនសុន បានសួរ ហ្គើរ៉ល និង ឡូណា ម៉ម៉ូស ៖ « តើ អ្នកអាចមក ហើយជួយបានទេ ? » ហើយពួកគេនឹងប្រាប់អ្នកថា មិនថាអ្នកចូលរួម សកម្មប៉ុណ្ណាក៏ដោយ ការសន្យានេះគឺពិត ៖ អ្នកគឺសំខាន់ អ្នកអាចរួមចំណែក ហើយ អ្នកនឹងត្រូវបានប្រទានពរ និង ត្រូវបានស្រឡាញ់ ។ ■

កំណត់ចំណាំ

១. « អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ៖ LDS Church Desperately Needs More Senior Missionaries » *Deseret News* ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ deseretnews.com។

## របៀបជាច្រើនដើម្បីបម្រើ

សូមមើលឱកាសថ្មីៗ ស្ដាប់ពីអស់អ្នកដែលកំពុងបម្រើ បច្ចុប្បន្ននេះ ហើយស្វែងរកចម្លើយចំពោះសំណួរដែលមាននៅ lds.org/callings/missionary ។

## កាន់តែមានភាពងាយស្រួល

គោលការណ៍បត់បែនដែលសម្រួលឲ្យគូស្វាមីភរិយាទៅបម្រើ ។

- អ្នកផ្សព្វផ្សាយសាសនាសេវាកម្មសាសនាចក្រ អាចនៅផ្ទះ ហើយ បម្រើក្នុងមូលដ្ឋាន ។
- គូស្វាមីភរិយាអាចបម្រើរយៈពេល ៦ខែ, ១២ខែ, ១៨ខែ ឬ ២៣ខែ បាន ។ ពួកគេអាចបម្រើនៅក្រៅប្រទេសសម្រាប់រយៈពេលតិចជាង ១៨ខែ ប្រសិនបើពួកគេបង់ថ្លៃធ្វើដំណើរ ។
- គូស្វាមីភរិយា ដែលបង់ថ្លៃដោយខ្លួនឯង អាចចំណាយពេលឈប់ សម្រាកពី ៧ ថ្ងៃទៅ ១០ថ្ងៃដើម្បីត្រឡប់ទៅផ្ទះចូលរួមកម្មវិធី សំខាន់របស់គ្រួសារបាន ។
- មានការកំណត់លើតម្លៃផ្ទះ ។ គូស្វាមីភរិយាពុំចំណាយច្រើនទៀត ឡើយលើចំនួនកំណត់មួយសម្រាប់ថ្លៃផ្ទះ រួមមានការជួលផ្ទះ ថ្លៃ ទឹកភ្លើង និង ថ្លៃគ្រឿងសង្ហារិម ។
- ផ្ទះនឹងមានសុវត្ថិភាព ហើយមានផាសុខភាព ។ បេសកកម្ម ឬ តំបន់ការិយាល័យផ្ដល់ផ្ទះដែលស្អាត មានគ្រឿងសង្ហារិមសមរម្យ និង តម្លៃធូរថ្លៃ។
- កាលវិភាគនានាមានភាពតិចជាងមុន ។ គូស្វាមីភរិយាពុំរំពឹងឲ្យធ្វើ តាមកាលវិភាគដូចគ្នានឹងកាលវិភាគម៉ោងធ្វើការ និង សកម្មភាព ដូចជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងឡើយ ។
- ការទាក់ទងមកគ្រួសារគឺអនុញ្ញាតបានញឹកញាប់ ។ គូស្វាមីភរិយា អាចទាក់ទងទៅគ្រួសារខ្លួន កាន់តែញឹកញាប់ជាងអ្នកផ្សព្វផ្សាយ សាសនាវ័យក្មេង ។



# នៅពេលដែល ការណ៍អាសគ្រាមវាយប្រហារនៅក្នុងផ្ទះ — នោះទាំងភរិយា និង ស្វាមី ត្រូវការការព្យាបាល

*ខ្ញុំបានឃើញដោយផ្ទាល់ពីព្រះចេស្ដារបស់ព្រះអង្គសង្គ្រោះក្នុងការព្យាបាលអាចកើតឡើងដល់ភរិយាព្រមទាំងស្វាមី នៅពេលស្វាមីមានឧបសគ្គជាមួយនឹងការណ៍អាសគ្រាម ។*



ការបទេរូបថតដែលថតដោយតួសម្ដែង

ឈ្មោះត្រូវបានដកចេញ

អំឡុងពេលប្រាំមួយខែដំបូងរបស់ខ្ញុំក្នុងនាមជាប៊ីស្សព មានគូស្វាមីភរិយាមួយចំនួននៅក្នុងវួដរបស់ខ្ញុំ បានមកជួបខ្ញុំដោយមានទំនុកចិត្ត ប្រាប់ខ្ញុំពីការលំបាករបស់ស្វាមីដែលមានបញ្ហាជាមួយការណ៍អាសគ្រាម ។ នៅក្នុងករណីមួយចំនួន ភរិយាមានភាពស្មុគស្មាញអំពីក្ដីតក់ស្លុតដោយបានដឹងពីការបំផ្លាញយ៉ាងសម្ងាត់នោះ មនុស្សខ្លះទៀតបានដឹងពីវាអស់ពេលជាច្រើនខែ ឬឆ្នាំមកហើយ ។

ខ្ញុំមានអារម្មណ៍អាណិតអាសូរដល់គូស្វាមីភរិយាទាំងនោះ ហើយមានអារម្មណ៍ពីព្រះចេស្ដាប្រោសលោះរបស់ព្រះអង្គសង្គ្រោះ នៅពេលខ្ញុំបានប្រឹក្សាជាទៀងទាត់ និងដោយប្រុងប្រយ័ត្នជាមួយនឹងបងប្អូនប្រុសម្នាក់ៗដើម្បីជួយពួកគេឲ្យ « រលាស់ច្រវ៉ាក់ . . . ដែលចងក្រៀក [ ពួកគេ ] ចោល » ( នីហ្វៃទី ២ ៩:៤៥ ) ។

ទោះជាយ៉ាងណាក្ដី ប្រហែលជាការចាក់ស្រោចព្រះវិញ្ញាណដ៏ច្រើនមហិមាបានកើតឡើង នៅពេលខ្ញុំបានជួបភរិយារបស់ពួកគេ ។ ខ្ញុំបានឃើញថា អំឡុងពេលដែលមុខរបួសមួយចំនួននៅថ្មីថ្មោង ហើយស្នាមរបួសចាស់ៗផ្សេងទៀតពីការធ្លាប់បានធ្វើបែបនេះអស់រយៈពេលជាច្រើនក្នុងអតីតកាល នោះបងប្អូនស្រីទាំងនេះបានស៊ូទ្រាំដោយក្ដីឈឺចាប់ខាងវិញ្ញាណយ៉ាងខ្លាំង ដែលបណ្ដាលមកពីសំណួរដូចជា « តើខ្ញុំបានធ្វើអ្វីខ្លះដែលបណ្ដាលឲ្យគាត់ពុំចាប់អារម្មណ៍មកលើរូបខ្ញុំ ? » ឬ « ហេតុអ្វីគាត់ចង់ស្រម៉ៃពីខ្លួនគាត់ជាមួយអ្នកផ្សេងទៀតជាជាងជាមួយខ្ញុំដូច្នេះ ? »

ដោយសារតែស្វាមីនោះបានប្រព្រឹត្តិអំពើរំលង វាងាយស្រួលសម្រាប់ប៊ីស្សពដើម្បីមានអារម្មណ៍ថា ស្វាមីភាគច្រើនត្រូវការចូលទៅរកកូនសោដើម្បីបើកសោយកព្រះចេស្ដាព្យាបាលរបស់ព្រះអង្គសង្គ្រោះ ប៉ុន្តែខ្ញុំបានរៀនដឹងថា ភរិយាគួរតែត្រូវបានព្យាបាលពីក្ដីឈឺចាប់ និង របួសគ្រាំគ្រាខាងក្នុងចិត្តឲ្យច្រើនដូចជាស្វាមីត្រូវការការព្យាបាលពីអំពើបាប និង ចំណង់ដែលអត់ទ្រាំពុំបាន ។

នៅក្នុងការថ្លែងទៅដល់ពួកសាសន៍នីហ្វៃ ព្យាការីយ៉ាកុបបានកាត់ទោសដល់បុរសចំពោះទង្វើដែលពុំស្មោះត្រង់របស់ពួកគេចំពោះភរិយាខ្លួន « ដែលភាគច្រើន [ មាន ] អារម្មណ៍ទន់ភ្លន់ និង បរិសុទ្ធ និង ចិត្តទោរទន់នៅចំពោះព្រះ គឺជាការណ៍ដែលសព្វព្រះហឫទ័យដល់ព្រះ » ( យ៉ាកុប ២:៧ ) ។ លោកបានបន្តថា ៖ « អ្នកបានធ្វើឲ្យភរិយាដ៏ទន់ភ្លន់របស់អ្នកខូចចិត្ត . . . ព្រោះតែគំរូដ៏អាក្រក់របស់អ្នកនៅចំពោះពួកគេ ហើយសំឡេងដង្ហក់នៃបេះដូងគេ បានឮ ឡើងទៅដល់ព្រះទាស់នឹងអ្នក » ( យ៉ាកុប ២:៣៥ ) ។ ខ្ញុំបានឃើញពីសំឡេងដង្ហក់ទាំងនេះដោយផ្ទាល់ ។ ជារឿយៗវាពុំកើតឡើងមកតែពីអារម្មណ៍ដ៏ឈឺចាប់ខ្លាំងរបស់ភរិយាទាំងនោះអំពីការក្បត់ដែលបានបណ្ដាលមកពីការពាក់ព័ន្ធនឹងការណ៍អាសគ្រាមរបស់ស្វាមីខ្លួនឡើយ ប៉ុន្តែវាក៏បណ្ដាលមកពីពាក្យសម្ដីបន្ទាបបន្ថោក និង អាកប្បកិរិយាឈ្លើយដែលបង្ហាញជាញឹកញាប់ ដែលជាលទ្ធផលនៃការលំបាកនៅក្នុងខ្លួនពួកបុរសទាំងនោះ ។ តាមពិតវាជារឿងទូទៅទៅហើយ ដែលបុរសម្នាក់ទម្លាប់ស្ដីបន្ទោសដល់ភរិយាខ្លួនថាមកពីនាងទើបគាត់មានអាកប្បកិរិយាបែបនោះ ដោយលើកយកទង្វើនានាដែលនាងបានធ្វើ ឬពុំបានធ្វើ ។ គួរឲ្យស្ដាយណាស់ វាក៏ជារឿងសាមញ្ញទៅហើយសម្រាប់ភរិយាដែលចាប់ផ្ដើមយកមកពិចារណា ហើយជឿលើការចោទប្រកាន់ទាំងនោះ ។

គូស្វាមីភរិយាមួយគូបែបដូច្នេះបានអង្គុយនៅក្នុងការិយាល័យរបស់ខ្ញុំ គឺក្រោយថ្ងៃដែលស្វាមីរបស់គាត់បានសារភាពពីទម្លាប់នៃការណ៍អាសគ្រាមខ្លួន ដែលបានរុកគុនគាត់តាំងពីនៅយុវវ័យ ។ ខណៈកំពុងតែអង្គុយស្ដាប់មេរៀនថ្នាក់សមាគមសង្គ្រោះ

ដោយផ្អែកលើសុន្ទរកថាសន្និសីទទូទៅខែមេសា ឆ្នាំ ២០១៨របស់ស៊ីស្ទើរ លីនដា អេស រីវេស « ការការពារពីរូបអាសគ្រាម — ផ្ទះដែលផ្តោតលើព្រះគ្រីស្ទ » ភរិយារូបនេះចាប់ផ្តើមទទួលស្គាល់ពីអាកប្បកិរិយាទិតៀនរបស់ស្វាមីនាងចំពោះរូបនាងអំពីទំនោរជាច្រើនដែលគ្រូបង្រៀនបានពិពណ៌នា ។ បន្ទាប់ពីមេរៀនចប់ នាងបានទៅជួបស្វាមីរបស់ខ្លួនដើម្បីសួរសំណួរ ហើយគាត់បានសារភាពពីការណ៍អាថ៌កំបាំងថាគាត់បានលាក់បាំងវាយូរយារណាស់មកហើយ ។ ការខូចចិត្តដែលនាងគិតទុកនោះឥឡូវនេះកាន់តែធ្វើឲ្យនាងកើតទុក្ខធ្ងន់ឡើងដោយសារតែការថ្នាំងថ្នាក់ចិត្តដ៏យ៉ាងខ្លាំងនោះ ។ អំឡុងពេលលើកដំបូងដែលពួកគេជួបខ្ញុំ នោះពួកគេមានការលំបាកដើម្បីមើលឃើញថាអាពាហ៍ពិពាហ៍របស់គួរតែបន្តទៅមុខទៀតឬអត់ ។ ខ្ញុំបានធានាជាមួយនឹងពួកគេថា នឹងមាននូវសេចក្តីសង្ឃឹម ខ្ញុំបានផ្តល់ការទូន្មានមួយចំនួនដំបូង ហើយក្រោយមកអញ្ជើញពួកគេឲ្យត្រឡប់មកវិញ ព្រមទាំងជួបជាមួយខ្ញុំម្នាក់ម្តង ។

ដោយមានការអធិស្ឋានដ៏ស្មោះត្រង់ដែលខ្ញុំបានអធិស្ឋាន នៅក្នុងការរៀបចំសម្រាប់ការជួបទាំងនោះ ខ្ញុំក៏ពិនិត្យសើរើឡើងវិញពីយោបល់ដែលបានផ្តល់ឲ្យនៅក្នុង Ministering Resources លើគេហទំព័រ LDS.org ជាពិសេស



### របៀបដែលអ្នកដឹកនាំបព្វជិតភាពអាចជួយ

នៅពេលដែលថ្នាក់ដឹកនាំជួយដល់គូស្វាមីភរិយាដែលជាសមាជិក កំពុងមានបញ្ហាជាមួយនឹងការណ៍អាសគ្រាម នោះកិច្ចខិតខំរបស់ពួកគេដើម្បីប្រាកដថា គូស្វាមីភរិយាទាំងនេះមានអារម្មណ៍ស្តាប់តាម និង យល់គឺសំខាន់ដូចនឹងការទូន្មានដែលពួកគេអាចផ្តល់ឲ្យបាន ។ សូមពិចារណាពីយោបល់ដូចតទៅនេះមកពីធនធានការបម្រើ ( ministering.lds.org ) ៖

- ជួបគ្នាជាទៀងទាត់ ហើយផ្តល់ការគាំទ្រ ។
- សង្កត់ធ្ងន់លើសមត្ថភាពរបស់ព្រះអង្គសង្គ្រោះដើម្បីប្រទាននូវការព្យាបាលផ្ទាល់ខ្លួនដល់គូស្វាមីភរិយាដែលមានបញ្ហានឹងការណ៍អាសគ្រាម ( សូមមើល អាលម៉ា ៧:១១ និង ម៉ាថាយ ១១:២៨–៣០ ) ។
- នៅពេលសមរម្យ សូមអញ្ជើញបុគ្គលម្នាក់ឲ្យគិតពីការចូលរួមក្នុងការប្រជុំក្រុមគាំទ្រ តាមរយៈកម្មវិធីជាសះស្បើយលើការញៀន ឬ ក្រុមគាំទ្រស្រដៀងគ្នានេះ ។
- ជួយគូស្វាមីភរិយាឲ្យយល់ថា ពួកគេអាចទទួលបានការបំផុសគំនិតផ្ទាល់ខ្លួន ដើម្បីដឹងពីរបៀបកំណត់ព្រំដែនច្បាស់លាស់អំពីទំនាក់ទំនង និង នៅក្នុងផ្ទះ ។
- ជួយគូស្វាមីភរិយាឲ្យស្វែងរកមិត្តភក្តិ ឬ សមាជិកគ្រួសារម្នាក់ ដែលខ្លួនទុកចិត្ត ដែលអាចផ្តល់ការគាំទ្រយ៉ាងមានអត្ថន័យជាបន្តបន្ទាប់ ។
- ជួយបុគ្គលម្នាក់ៗដែលមានបញ្ហានឹងការណ៍អាសគ្រាម ឲ្យមានទំនួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ហើយគាំទ្រគូស្វាមីភរិយារបស់ខ្លួន ។
- គិតពីការបញ្ជូនគូស្វាមីភរិយាដែលមានបញ្ហានឹងការណ៍អាសគ្រាមទៅកាន់អ្នកមានជំនាញវិជ្ជាជីវៈឲ្យជួយ ឬ ផ្តល់ការប្រឹក្សា ។ ស្វែងរកធនធាននានាក្នុងមូលដ្ឋានដែលមានសេវាកម្មនេះ ដែលត្រូវគ្នានឹងគោលការណ៍នៃដំណឹងល្អ ។





*ខាងក្រោម ៖ យើងមានភាពតក់ស្លុតពេលនាងដឹងពីឧបសគ្គរបស់ស្វាមីនាងជាមួយការណ៍អាសគ្រាម ប៉ុន្តែនាងបានមានសេចក្ដីសង្ឃឹម ហើយបានព្យាបាលតាមរយៈព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ ។*

នៅក្នុងធនធានសម្រាប់ការគាំទ្រស្វាមីភរិយាដែលមានបញ្ហាជាមួយការណ៍អាសគ្រាម ខ្ញុំបានអានចំណុចខាងក្រោម ៖ « សូមបង្ហាញសេចក្ដីស្រឡាញ់ និង កង្វល់របស់អ្នកចំពោះពួកនាងម្នាក់ៗ ព្រមទាំងស្វាមីរបស់នាងផងដែរ ។ សូមបញ្ជាក់ឲ្យច្បាស់ថានាងពុំមានទំនួលខុសត្រូវចំពោះបញ្ហាការណ៍អាសគ្រាមរបស់ស្វាមីនាង ឬ អាកប្បកិរិយាអាក្រក់ ហើយពុំត្រូវបានរំពឹងឲ្យស៊ូទ្រាំចំពោះអាកប្បកិរិយារំលោភបំពាននេះឡើយ » ។

នៅពេលខ្ញុំបានជួបស្ត្រីរូបនេះ ខ្ញុំបានស្ដាប់ ហើយធ្វើតាមការទូន្មាននេះ ហើយបានបន្ថែមការធានាអះអាងថា ទង្វើរបស់ស្វាមីនាងគឺពុំមែនមកពីនាងឡើយ ពុំមែនជាអ្វីដែលនាងបានធ្វើ ឬ ពុំបានធ្វើឡើយ ប៉ុន្តែផ្ទុយទៅវិញគឺមកពីទំនាស់ផ្ទៃក្នុងផ្ទាល់ខ្លួនរបស់គាត់វិញទេតើ ។ ខ្ញុំបានមើលពីអារម្មណ៍ធូរស្បើយ និង ការលួងចិត្តដែលមានចំពោះនាង នៅពេលនាងយល់ពាក្យទាំងនេះ ហើយទទួលអារម្មណ៍ពីការបញ្ជាក់របស់ព្រះវិញ្ញាណថាពាក្យទាំងនេះគឺពិត ។ នៅចុងបញ្ចប់នៃការសម្ភាសនោះ គាត់បានសុំ ប្រសិនបើខ្ញុំនឹងផ្ដល់ការប្រសិទ្ធពរបព្វជិតភាពដល់គាត់ ។ ខ្ញុំបានដឹងថា ខ្ញុំគឺជាមនុស្សម្នាក់គត់ដែលនាងអាចងាកមករកសម្រាប់ការប្រសិទ្ធពរបែបនោះ នៅពេលនាងសុំឲ្យរក្សាស្ថានភាពរបស់នាងជាការសម្ងាត់ពីគ្រួសារ និង មិត្តភក្តិ ។

ដើម្បីជួយក្នុងដំណើរការការព្យាបាល ខ្ញុំបានអញ្ជើញស្វាមីនោះឲ្យចូលមកក្រុមជាសះស្បើយលើការញៀននៃពួកបរិសុទ្ធថ្ងៃចុងក្រោយក្នុងមូលដ្ឋាន ហើយខ្ញុំបានលើកទឹកចិត្តភរិយាគាត់ឲ្យចូលរួមក្រុមនោះផងដែរសម្រាប់ស្វាមី និង សមាជិកគ្រួសារ ។ គាត់បានប្រាប់ខ្ញុំពីការលួងលោមដែលគាត់បានមានពីការប្រជុំជាមួយបងប្អូនស្រីផ្សេងទៀត ដែលយល់ពីការរងទុក្ខរបស់ខ្លួន និង សេចក្ដីសង្ឃឹមដែលនាងបានទទួល ដែលឃើញគូស្វាមីភរិយានានាដែលបានឆ្លងកាត់ការសាកល្បងដូចគ្នានេះហើយបានយកឈ្នះវាជាមួយគ្នា ។

ប៉ុន្មានខែក្រោយបន្ទាប់ពីការជួបលើកទីមួយជាមួយគូស្វាមីភរិយានេះបានកន្លងផុតទៅ នោះក្ដីស្រឡាញ់ និង ការខ្វល់ខ្វាយរបស់ខ្ញុំចំពោះពួកគេបានកើនឡើងដោយសារតែទំនាក់ទំនងជាច្រើនដែលយើងមានជាមួយគ្នា ។ អំឡុងពេលដែលខ្ញុំទទួលស្គាល់ថា ការបន្តដំណើរលើផ្លូវរបស់ពួកគេនឹងមិនបន្តទៅមុខបានដោយគ្មានឧបសគ្គ នោះវាគឺជាសេចក្ដីអំណរសម្រាប់ខ្ញុំដើម្បីដឹងថាពីមួយខែទៅមួយខែទៀតស្វាមីនោះបានទប់អារម្មណ៍របស់ខ្លួនពីតណ្ហា និង ការណ៍អាសគ្រាម ហើយមើលឃើញពីតម្លៃ និង ទំនុកចិត្តរបស់ភរិយាខ្លួន ដែលឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់ ។

នៅក្នុងការសម្ភាសថ្មីៗនេះជាមួយពួកគេ ភាពតានតឹងផ្លូវចិត្ត និង ដំណក់ទឹកភ្នែកកាលពីជួបលើកដំបូងនោះត្រូវបានជំនួសដោយស្នាមញញឹម និងសើចសប្បាយវិញ ។ ប៉ុន្តែប្រហែលជាលទ្ធផលដ៏ធំមហិមាដែលសង្ឃឹមចង់បាននោះ — គឺសេចក្ដីសង្ឃឹមថា ពុំគ្រាន់តែអាពាហ៍ពិពាហ៍របស់ពួកគេបន្តទៅមុខទៀតឡើយ ប៉ុន្តែថាវាថែមទាំងមាននូវសក្ដានុពលដែលនឹងក្លាយទៅជាអ្វីដែលល្អស្រស់ត្រកាល និង តម្កើងឡើង ។

ជាអកុសលខ្ញុំទទួលស្គាល់ថា ពុំមែនគូស្វាមីភរិយាគ្រប់គូនឹងមានបទពិសោធន៍ដែលមានលទ្ធផលល្អបែបនេះទេ ។ អាពាហ៍ពិពាហ៍មួយចំនួនអាចបរាជ័យ នៅពេលអ្នកដែលមានបញ្ហាជាមួយការណ៍អាសគ្រាមបដិសេធធ្វើការកែលម្អ ។ ប៉ុន្តែដោយពុំគិតពីផ្លូវដែលស្វាមីបានជ្រើសរើសឡើយ នោះខ្ញុំបានដឹងថាការទូន្មានឲ្យបម្រើដល់ភរិយាគឺជាការបំផុសគំនិតមួយ ។ ខ្ញុំសង្ឃឹមថា គ្មានបងប្អូនស្រីណានៅក្នុងស្ថានភាពនេះនឹងមានអារម្មណ៍ថានាងត្រូវបានគេមើលរំលង វិនិច្ឆ័យខុស ឬ ពុំយល់ចិត្តពីប៊ីស្សពរបស់ខ្លួនឡើយ ។ ការបម្រើរបស់ប៊ីស្សពគឺជាគន្លឹះមួយដែលព្រះចេស្ដារបស់ព្រះអង្គសង្គ្រោះត្រូវបានបើកបង្ហាញ ដើម្បីព្យាបាលដួងចិត្តបុគ្គលម្នាក់យ៉ាងពេញលេញ — គឺដល់អស់អ្នក « ដែលត្រូវបានចាក់ទំលុះឲ្យមានរបួសយ៉ាងជ្រៅ » ( យ៉ាកុប ២:៣៥ ) ។ ■



**ទូន្មាន និង លួងលោមដល់គូស្វាមីភរិយា**

« ក្នុងនាមជាអ្នកដឹកនាំ យើងបារម្ភខ្លាំងអំពីស្វាមីភរិយា និងក្រុមគ្រួសារនៃអ្នកដែលរងទុក្ខដោយសារការញៀននៃការណ៍អាសគ្រាម ។ អែលឌើរ រីឆាដ ជី ស្កត បានអង្វរ ៖ ‹ ប្រសិនបើអ្នកផ្ទាល់គ្មានអំពើបាបធ្ងន់ធ្ងរទេ នោះសូមកុំចាំបាច់រងទុក្ខដោយព្រោះលទ្ធផលនៃអំពើបាបអ្នកដទៃឡើយ ។ . . . អ្នកអាចមានអារម្មណ៍ក្ដីមេត្តាករុណា ។ . . . តែអ្នកពុំគួរយកមកដាក់លើខ្លួនឯងនូវអារម្មណ៍នៃការទទួលខុសត្រូវសម្រាប់ទង្វើនោះឡើយ › ។ ចូរដឹងថាអ្នកមិននៅម្នាក់ឯងឡើយ ។ មានជំនួយ ។ មាននូវការប្រជុំពីការជាសះស្បើយពីការញៀនសម្រាប់ស្វាមីភរិយា ដែលមានទាំងការប្រជុំតាមទូរសព្ទ ដែលអនុញ្ញាតឲ្យស្វាមីភរិយាទូរសព្ទមកការប្រជុំនោះ ហើយចូលរួមពីផ្ទះខ្លួនផ្ទាល់ » ។

**លីនដា អេស រីវ៍ ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ « ការការពារពីការណ៍អាសគ្រាម — ផ្ទះដែលផ្ដោតលើព្រះគ្រីស្ទ » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ១៦ ។**

# អ្នកយាម
# នៅលើប៉ម

« ឱក្រុងយេរូសាឡិមអើយ យើងបានដាក់ពួកយាមល្បាតនៅលើកំផែងឯង ហើយ គេនឹងមិននៅមាត់ស្ងៀម ទោះយប់ឬថ្ងៃផង ឯងរាល់គ្នាដែលជាអ្នករំឭកព្រះយេហូវ៉ាអើយ កុំឲ្យនៅស្ងៀមឡើយ » ។
អេសាយ ៦២:៦

**អ្នកយាម**

អ្នកយាមគឺជាឆ្មាំដែលត្រូវបានដាក់នៅកំផែងជញ្ជាំង ឬ លើប៉ម ដើម្បីឃ្លាំចាំមើល និង ព្រមានប្រាប់ទុកជាមុននូវគ្រោះថ្នាក់ដែលនឹងកើតឡើងមកពីចម្ងាយ ។ ពួកគេត្រូវបានជួលឲ្យធ្វើការដើម្បីការពារទីក្រុង ព្រមទាំងចម្ការទំពាំងបាយជូរ ទីវាលនានា ឬ វាលចិញ្ចឹមសត្វ ។



**ប្រភេទនៃប៉ម**

**ប៉មនៅជញ្ជាំងទីក្រុង** ជាទូទៅត្រូវបានសង់ឡើងនៅទ្វារច្រកចូល ឬ នៅត្រង់ទ្វារជ្រុងៗ ( សូមមើល របាក្សត្រទី ២ ២៦:៩ ) ។ ទាំងប៉មដែលនៅច្រកទ្វារ និង នៅទ្វារជ្រុងផ្ដល់នូវទីតាំងដើម្បីមើលពីគ្រោះថ្នាក់ដែលកើតមានឡើង ហើយការពារការវាយប្រហារពីសត្រូវ ( សូមមើល របាក្សត្រទី ២ ២៦:១៥ ) ។

**ប៉មនៅបន្ទាយ ឬ ប្រាសាទ** ជាទូទៅជាសំណង់នៅដាច់តែឯងដែលបានសង់លើទីទួលខ្ពស់ ឬ ទីតាំងផ្សេងៗដែលបានរៀបចំ ។ ពេលខ្លះវាគឺជាទីតាំងដែលមានទំហំធំល្មម ធ្វើជាទីជម្រកចុងក្រោយ សម្រាប់ប្រជាជនទូទាំងទីក្រុង នៅពេលដែលពួកគេកំពុងត្រូវបានវាយប្រហារ ( សូមមើល ពួកចៅហ្វាយ ៩:៤៦–៥២ ) ។

**ប៉មនៅក្នុងចម្ការទំពាំងបាយជូរ ទីវាល ឬ វាលចិញ្ចឹមសត្វ** គឺជាសំណង់តូចៗដែលសង់ឡើងដើម្បីជួយការពារគ្រាប់ពូជ និង ហ្វូងសត្វពីចោរលួច និង សត្វព្រៃ ( សូមមើល របាក្សត្រទី ២ ២៦:១០; អេសាយ ៥:២; ២៧:៣ ) ។ ជារឿយៗ នៅជាន់ក្រោមនៃប៉មនេះ គឺជាបន្ទប់មួយដើម្បីដាក់សម្ភារផ្សេងៗ ។



**អ្នកយាមនៅលើប៉ម ៖**

**មាននូវការយល់ឃើញដែលខ្ពង់ខ្ពស់ ។** នៅពេលអ្នកបម្រើរបស់ព្រះត្រូវបានហៅ និង ផ្ដល់សិទ្ធិអំណាច នោះព្យាការីត្រូវបានញែកចេញពីពិភពលោក ពួកលោកខិតចូលកាន់តែជិតទ្រង់ ហើយពួកលោកត្រូវបានអនុញ្ញាតឲ្យមើលឃើញនូវអ្វីៗជាច្រើនមកពីឋានសួគ៌ ។

**មើលឃើញពីអ្វីៗដែលមនុស្សទាំងអស់មើលពុំឃើញ ។** « អ្នកមើលឆុតអាចដឹងអំពីការណ៍ទាំងឡាយដែលកន្លងមកហើយ និង ការណ៍ទាំងឡាយដែលនឹងកើតឡើងនៅពេលខាងមុខផង ហើយដោយសារប្រដាប់បកប្រែទាំងនេះ ទើបគ្រប់ការណ៍ទាំងអស់ត្រូវបានបើកឲ្យឃើញ ឬ និយាយម្យ៉ាងទៀតថា ការណ៍សម្ងាត់ទាំងឡាយនឹងត្រូវបានសម្ដែងឲ្យដឹង ហើយការណ៍លាក់កំបាំងទាំងឡាយនឹងត្រូវបានចេញមកឯពន្លឺ ហើយការណ៍ទាំងឡាយដែលគ្មានគេដឹង នោះក៏នឹងត្រូវបានធ្វើឲ្យដឹង ដោយសារវត្ថុទាំងនោះ ហើយការណ៍ទាំងឡាយក៏នឹងត្រូវធ្វើឲ្យដឹងដោយសារវត្ថុទាំងនោះដែរ បើពុំនោះសោតទេ នឹងពុំមាននរណាអាចដឹងបានឡើយ » ( ម៉ូសាយ ៨:១៧ ) ។

**មានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ។** ព្យាការីមាននូវទំនួលខុសត្រូវយ៉ាងហ្មត់ចត់ដើម្បី ព្រមានយើងពីគ្រោះថ្នាក់ដែលនឹងកើតឡើង ហើយពួកលោកនឹងបន្តធ្វើការណ៍នេះដោយពុំគិតពីមតិ ឬ និន្នាការរបស់សាធារណជននៅក្នុងសង្គមឡើយ ។

**ព្រមានអំពីអ្វីៗទាំងអស់ដែលវាពុំទាន់កើតឡើង ។** « ព្យាការីប្រកាសបដិសេធអំពើបាបទាំងស្រុង ហើយទាយទុកជាមុនពីផលវិបាករបស់វា ។ លោកគឺជាអ្នកផ្សាយអំពីសេចក្ដីសុចរិត ។ ម្ដងម្កាល ពួកព្យាការីអាចនឹងត្រូវបានបំផុសគំនិតឲ្យទាយទុកជាមុនអំពី អនាគតកាលសម្រាប់ជាប្រយោជន៍ដល់មនុស្សលោក » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ព្យាការី » lds.org/scriptures/gs ) ។

**ផ្ដល់នូវសុវត្ថិភាព និង ការការពារ ។** តាមរយៈការស្ដាប់តាមការព្រមានរបស់ព្យាការី នោះយើងអាចមានសុវត្ថិភាព ហើយចៀសវាងពីគ្រោះថ្នាក់ដែលអាចធ្លាក់មកលើយើង ម្នាក់ៗ ឬ ទាំងអស់គ្នា ប្រសិនបើយើងពុំស្ដាប់តាម ។ ■





### កាតព្វកិច្ចដើម្បីមើលថែ

« អស់ជាច្រើនសតវត្សរ៍ ព្យាការីបានបំពេញកាតព្វកិច្ចរបស់ពួកលោក ពេលពួកលោកព្រមានមនុស្សពីគ្រោះថ្នាក់ទាំងឡាយមុនវាកើតឡើង ។ ពួកសាវករបស់ព្រះអម្ចាស់មានកាតព្វកិច្ច ដើម្បីមើលថែព្រមាន និង ឈោងជួយដល់អស់អ្នកដែល កំពុងស្វែងរកចម្លើយចំពោះសំណួរក្នុងជីវិត » ។

**អែលឌើរ អែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « God Is at the Helm »** ***Liahona,*** **ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ២៥ ។**

## រឿងពិតពីព្រះគម្ពីរបរិសុទ្ធ



នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពេលខ្លះព្រះអម្ចាស់បានប្រៀបធៀបប៉មទៅនឹងបន្ទាយ ឬ ប្រាសាទថាជាទីជម្រក ( សូមមើល ទំនុកតម្កើង ១៨:២; ៦១:៣; សុភាសិត ១៨:១០; សាំយូអែលទី ២ ២២:៣ ) ហើយពេលខ្លះព្យាការីត្រូវបានប្រៀបធៀបថាជាពួកអ្នកយាមល្បាត ( សូមមើល អេសាយ ៦២:៦; យេរេមា ៦:១៧; អេសេគាល ៣:១៧; ៣៣:៧; ហូសេ ៩:៨; ម៉ាឡាគី ៧:៤ ) ។

« យើងបានតាំងឯងឲ្យជាអ្នកយាម ដល់ពូជពង្សអ៊ីស្រាអែល ដូច្នេះ ត្រូវឲ្យឯងស្ដាប់ពាក្យពីមាត់យើង រួចទៅប្រាមប្រាប់គេឲ្យយើងផង » ( អេសេគាល ៣:១៧ សូមមើលផងដែរ អេសេគាល ៣៣:១–៧ ) ។

រូបថតប៉មផ្នែកខាងក្រោយ © ISTOCK/THINKSTOCK; [illegible]

# ឱកាសលើកទីពីរ

លើកទីមួយ ដែលខ្ញុំបានជួបគាត់ ខ្ញុំកំពុងកាន់វីយូឡុង ។

គាត់បានដើរដោយអូសជើងមកជិតខ្ញុំ ខណៈដែលខ្ញុំកំពុងដើរទៅបន្ទប់អាហារ ដោយស្ពាយប្រអប់វីយូឡុងរបស់ខ្ញុំ ។

គាត់បាននិយាយថា « វីយូឡុង » ពេលគាត់ដើរសំដៅមករកខ្ញុំ ។

ខ្ញុំនិយាយថា « មែនហើយ » ។

ខ្ញុំពុំធ្លាប់និយាយជាមួយនរណាម្នាក់ដែលពិការ ហើយពុំដឹងពីអ្វីដែលត្រូវនិយាយទៀតឡើយ ។ គាត់បានដើរតាមខ្ញុំទៅតុខ្ញុំ ហើយបានអង្គុយក្បែរខ្ញុំ ដោយចង្អុលទៅប្រអប់វីយូឡុងរបស់ខ្ញុំ ។

គាត់បាននិយាយថា « វីយូឡុង » សារជាថ្មីម្តងទៀត ។

ខ្ញុំបានបើកប្រអប់វាឡើង ហើយគាត់មានការរំភើបយ៉ាងខ្លាំង ។ គាត់បានទាញខ្សែវីយូឡុងដោយធ្ងន់ដៃ ។ ខ្ញុំបានភ័យ នៅពេលខ្ញុំស្រមៃគិតថាខ្សែមួយបានដាច់ចេញពីវីយូឡុងរបស់ខ្ញុំ ហើយខ្ញុំបានបិទប្រអប់វាភ្លាម ។ គាត់បានឱបខ្ញុំពីមុនគាត់ចាកចេញទៅ ។

**វិល្លាមបាននិយាយថា « វីយូឡុង » ពេលគាត់ដើរសំដៅមករកខ្ញុំ ។**



ខ្ញុំបានឃើញគាត់ជារឿយៗបន្ទាប់ពីពេលនោះ ។

នៅពេលណាដែលគាត់ឃើញខ្ញុំ គាត់បានកាន់ស្មារបស់ខ្ញុំ និង គាត់ថើបក្បាលរបស់ខ្ញុំ ។

ពេញឆ្នាំសិក្សានៅវិទ្យាល័យ ខ្ញុំព្យាយាមគេចពីគាត់រហូត នៅពេលខ្ញុំឃើញគាត់ដើរមក ។ នៅពេលគាត់ឃើញខ្ញុំ គាត់បានឱបខ្ញុំយ៉ាងណែន ហើយថើបខ្ញុំដោយប្រទ្បេកប្រទ្បាក់ ខ្ញុំទ្រាំបានតែពីរបីនាទីប៉ុណ្ណោះដោយញញឹមទាំងបង្ខំចិត្ត ហើយដើរចេញទៅយ៉ាងលឿនដោយពុំនិយាយអ្វីមួយម៉ាត់ឡើយ ។

ខ្ញុំរអ៊ូរហ៊ុមៗថា « អ៊ូអត់ទេ » នៅពេលខ្ញុំបានឃើញគាត់នៅការប្រគុំតន្ត្រីចុងក្រោយរបស់ខ្ញុំនៅវិទ្យាល័យ ។ បន្ទាប់ពីការប្រគុំតន្ត្រីចប់ គាត់បានដើរយឺតៗមករកខ្ញុំពេលខ្ញុំបានឈរជាមួយមិត្តខ្ញុំនៅក្រៅសាលប្រជុំ ។

មិត្តភក្តិរបស់ខ្ញុំឈរសម្លឹងឱបដៃមើលនៅពេលគាត់បានដើរឡើងមកខ្ញុំដោយទាំងញញឹមញញ៉ែម លាតដៃរបស់គាត់ឱបខ្ញុំ ។

« វិល្លាម !!! »

ខ្ញុំបានងាកទៅមើល ហើយឃើញស្ត្រីម្នាក់រត់ត្រឹកៗមកកាន់យើង ។

នាងនិយាយថា « សូមទោស » ដោយតោងដៃគាត់ ។ « វិល្លាមចូលចិត្តវីយូឡុង ។ គាត់បានអង្វរខ្ញុំឲ្យនាំគាត់មកការប្រគុំតន្ត្រីនារាត្រីនេះ ។ តោះយើងទៅកូនសម្លាញ់ » ។

ចាប់តាំងពីនោះមក ខ្ញុំភ្ញាក់ខ្លួនថាខ្ញុំមិនធ្លាប់ដែលស្គាល់ឈ្មោះរបស់គាត់ឡើយ ។ ខ្ញុំបានជួបវិល្លាមពីរឆ្នាំមុន ប៉ុន្តែបានចំណាយពេលច្រើនគេចចេញពីគាត់ ដែលខ្ញុំពុំបានព្យាយាមស្គាល់គាត់ឡើយ ។ នៅពេលខ្ញុំសម្លឹងមើលគាត់ និង ម្តាយរបស់គាត់ដើរចេញទៅ ខ្ញុំមានអារម្មណ៍អាម៉ាស់យ៉ាងខ្លាំង ។

ច្រើនឆ្នាំក្រោយមក បន្ទាប់ពីខ្ញុំបានរៀបការ ខ្ញុំបានបង្កើតកូនប្រុសតូចដ៏ស្អាតមួយដែលមានជំងឺគ្រាសគន្លងដែលយើងបានដាក់ឈ្មោះថា ស្តែនស៊ើរ ។ ជារឿយៗខ្ញុំបានគិតពីវិល្លាមនៅពេលខ្ញុំមើលកូនប្រុសរបស់ខ្ញុំ ហើយខ្ញុំឆ្ងល់ថា ប្រសិនបើស្តែនស៊ើរនឹងមានបទពិសោធន៍ស្រដៀងនេះដែរឬអត់ ។ តើមនុស្សជាច្រើននឹងគេចចេញពីគាត់ដោយសារតែគាត់ថើប ឬ ឱបខ្លាំងៗ ឬច្រើនពេកដែរឬអត់ ? តើក្មេងអាយុស្របាលគ្នានឹងរូបគេពុំមានអារម្មណ៍សុខស្រួលជាមួយនឹងភាពពិការរបស់គាត់ឬអត់ ?

កាលស្តែនស៊ើរអាយុបួនឆ្នាំ ខ្ញុំបានយកគាត់ទៅមន្ទីរពេទ្យក្នុងមូលដ្ឋានមួយតាមការណាត់ជួប ។ នៅពេលខ្ញុំយកគាត់ចេញពីឡាន នោះខ្ញុំបានឃើញមនុស្សពីរនាក់ចេញពីមន្ទីរពេទ្យ ។ មិនគួរឲ្យជឿសោះថា ខ្ញុំដឹងថានោះគឺជាវិល្លាម និង ម្តាយរបស់គាត់ ។

« វិល្លាម !!! » ខ្ញុំបានស្រែកហៅនៅពេលយើងដើរនៅជិតគ្នា ខ្ញុំមានក្តីរំភើបយ៉ាងខ្លាំង ។

« សួស្តី ! » គាត់ដើរយឺតៗកាត់ចំណតឡានដោយមានស្នាមញញឹមយ៉ាងធំ ។ គាត់បានចាប់ដៃខ្ញុំ ហើយរលាក់ដៃដោយក្តីអំណរ ។

« ប្អូនសុខសប្បាយទេ ? » ខ្ញុំបានសួរគាត់ ។

គាត់និយាយថា « វីយូឡុង » ដោយក្តីរំភើបដែលអាចឃើញក្នុងកែវភ្នែកគាត់ ។

*វីយូឡុង*។ គាត់ក៏ចងចាំខ្ញុំផងដែរ ។ « មែនហើយ » ខ្ញុំបាននិយាយទាំងញញឹម ព្រមទាំងយំផងដែរថា « ខ្ញុំបានលេងវីយូឡុង » ។

នៅពេលយើងនិយាយគ្នា នោះ ដួងចិត្តខ្ញុំបានអធិស្ឋានខ្សឹបៗក្នុងចិត្តចំពោះសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់នៃព្រះវរបិតាដែលពេញដោយក្តីស្រឡាញ់គង់នៅឋានសួគ៌ ដែលដឹងថាខ្ញុំចង់ជួបវិល្លាមម្តងទៀតខ្លាំងប៉ុណ្ណា ។ ខ្ញុំមានអំណរគុណថាព្រះបានឃើញខ្ញុំ — ជាម្តាយវ័យក្មេងដ៏លំបាកដែលមានកង្វល់ជាមួយនឹងបញ្ហាសុខភាពរបស់កូនខ្លួន ហើយព្រួយបារម្ភពីអនាគតរបស់កូនៗ — ហើយប្រទានបទពិសោធន៍នេះដល់ខ្ញុំ ដែលរំឭកខ្ញុំថា ទ្រង់ស្គាល់ពួកយើង ។ ■

ខាយលី ប៊ិលវីន នៅរដ្ឋអារីស្សូណា ស.រ.អា.

រូបគំនូរដោយ អេលែន ហ្វានស៍



ខ្ញុំបានឮស្ត្រីនោះដាក់កាក់ប្រាក់ដែលហាក់បីដូចជាច្រើនណាស់លើតុគិតលុយដើម្បីបង់ថ្លៃទំនិញ ។

# ចូរទៅជួយនាងទៅ

ខ្ញុំបានឈរតម្រង់ជួរនៅស្ថានីយលក់សាំង ។ នៅពីមុខខ្ញុំ មានម្ដាយម្នាក់ដែលមានកូនតូចពីរនាក់សុំលុយ ៣ដុល្លារដែលមានតម្លៃស្មើនឹងទិញសាំង និងការ៉េមវ៉ាន់នីឡាពីរដុំ ។

ពេលក្រឡេកមើលដំបូង ខ្ញុំអាចឃើញថាពួកគេនៅតូចៗណាស់ ។ កូនក្មេងនោះពុំពាក់ស្បែកជើងឡើយ ហើយពាក់សម្លៀកបំពាក់រហែករយ៉េរយ៉ៃ ។

ខ្ញុំបានឮស្ត្រីនោះដាក់កាក់ប្រាក់ដែលហាក់បីដូចជាច្រើនណាស់លើតុគិតលុយដើម្បីបង់ថ្លៃទំនិញ ។

បន្ទាប់ពីបង់ថ្លៃសាំងខ្ញុំរួច ខ្ញុំបានដើរចេញទៅ ហើយបានក្រឡេកមើលឡានរបស់ម្ដាយរូបនោះ ។ ឡាននោះគឺជាឡានស៊េរីចាស់ដែលទំនងជាពុំអាចធ្វើដំណើរបានឆ្ងាយដោយប្រើសាំងតែបីដុល្លារនោះបានឡើយ ។

ខ្ញុំមានអារម្មណ៍ក្ដួលអាណិតម្ដាយនៃកូនពីរនាក់នោះ ប៉ុន្តែខ្ញុំបានចាប់ផ្ដើមបញ្ឆេះម៉ូតូខ្ញុំ ហើយចេញដំណើរទៅ ។

មិនយូរប៉ុន្មានក្រោយពីខ្ញុំជិះតាមផ្លូវមក មានសំឡេងមួយប្រាប់ខ្ញុំថា ៖ « ចូរទៅជួយនាងទៅ » ។ ការបំផុសគំនិតនោះបានកើតឡើងពីរដង ។

ខ្ញុំគ្រវីក្បាលរបស់ខ្ញុំ ដោយគិតថានាងប្រហែលជាចេញទៅបាត់ហើយ ។ តើខ្ញុំនឹងនិយាយទៅកាន់នាងតាមរបៀបណាទៅ ?

សំឡេងនោះបានកើតឡើងយ៉ាងច្បាស់ជាលើកទីបី ៖ « ចូរទៅជួយនាងទៅ ! »

ខ្ញុំបានត្រឡប់ទៅស្ថានីយលក់សាំងវិញ ដោយព្យាយាមរកមើលថាតើខ្ញុំនឹងនិយាយថាម៉េច ប្រសិនបើនាងនៅទីនោះ ។

នៅពេលទៅដល់ ខ្ញុំបានឃើញថាទ្វារឡានរបស់នាងបើក ។ នាងអង្គុយនៅកៅអីតែកុង ហើយកូនតូចពីរនាក់របស់នាងកំពុងញ៉ាំការ៉េមរបស់ខ្លួននៅកៅអីក្រោយ ។

ខ្ញុំបានអធិស្ឋានយ៉ាងខ្លីទូលសួរដល់ព្រះវរបិតាសួគ៌ពីអ្វីដែលខ្ញុំគួរនិយាយ ។ សំឡេងដដែរនោះបាននិយាយមកកាន់ខ្ញុំ « ណែនាំខ្លួនអ្នកឲ្យនាងស្គាល់ ហើយសុំនាងជួយ » ។ ខ្ញុំបានដើរទៅរកឡានរបស់នាង ហើយបានណែនាំខ្លួនខ្ញុំដល់នាង ។ ខ្ញុំបានប្រាប់នាងថា ខ្ញុំមានអារម្មណ៍បំផុស ដើម្បីសួរនាងប្រសិនបើនាងត្រូវការជំនួយ ។

នាងបានចាប់ផ្ដើមយំ ហើយនិយាយថា « ខ្ញុំទើបតែបានបញ្ចប់ការអធិស្ឋានទៅព្រះយេស៊ូវ ដោយសុំឲ្យទ្រង់បញ្ជូននរណាម្នាក់មកជួយខ្ញុំ » ។

ព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានរបស់នាង ។ ខ្ញុំបានចេញប្រាក់ចាក់សាំងឲ្យពេញដល់នាង ហើយបានឲ្យលេខទូរសព្ទរបស់បុរសម្នាក់នៅក្នុងក្រុមអែលឌើររបស់យើងដែលបម្រើនៅគ្រានោះ ។ ខ្ញុំពុំដឹងថាមានអ្វីកើតឡើងជាមួយម្ដាយវ័យក្មេងនេះនៅពេលក្រោយទៀតឡើយ ប៉ុន្តែខ្ញុំមានអំណរគុណដែលខ្ញុំបានធ្វើតាមការបំផុសគំនិតដើម្បីជួយនាង ។ ■

ថូម៉ាស រ៉ូប៊ីនសុន រដ្ឋកាលីហ្វូញ៉ា ស.រ.អា.

រូបគំនូរដោយ ស្ទេន ហ្វែលស៍

# ចូរកុំបាញ់ឡើយ !

ប៉ុប និងខ្ញុំបានអង្គុយនៅក្នុងឡានប៉ូលីសរបស់យើង កំពុងរង់ចាំសញ្ញាឲ្យរំកិលឡានទៅមុខទៀត ។ យើងបានចាប់ផ្ដើមការយាមល្បាតរបស់យើងរយៈពេលពីរម៉ោងមុន បន្ទាប់ពីការជូនដំណឹងដល់ឡានដែលបាននិយាយនោះនៅក្នុងវិទ្យុទាក់ទងប៉ូលីសដែលមានសញ្ញាព្រមាន ។

ការព្រមាននោះបានប្រាប់ថា « មានអំពើចោរកម្មមួយកំពុងកើតឡើង » ។ « មានចោរពីរនាក់ ហើយទាំងពីរនាក់មានកាំភ្លើង ។ មានគេឃើញពួកវានៅក្នុងឡានពណ៌ទឹកក្រូចមួយ ។ សាក្សីនិយាយថា ចោរទាំងនោះសាហាវណាស់ ហើយមិនញញើតនឹងបាញ់សម្លាប់មនុស្សឡើយ » ។

អំពើចោរកម្មបែបនេះទើបតែកើតនៅក្នុងតំបន់នោះ ប៉ុន្តែទោះបីជាមានកិច្ចខិតខំខ្នះខ្នែងដោយអស់ពីសមត្ថភាពរបស់យើងក្ដី ក៏ចោរទាំងនោះនៅតែគេចខ្លួនបានម្ដងហើយម្ដងទៀត ។ ខ្ញុំបានឈប់គិតពីរឿងនោះភ្លាមពេលខ្ញុំបានឃើញមនុស្សពីរនាក់ ចេញមកពីផ្ទះមួយនៅផ្លូវដ៏ងងឹតឈឹង ហើយឡើងជិះឡានពណ៌ទឹកក្រូចនោះ ។ ឥឡូវនេះពួកគេបើកឡាននៅលើផ្លូវដដែលជាមួយយើងដែរ ។

ខ្ញុំបាននិយាយតាមវិទ្យុទាក់ទងថា « ខ្ញុំសុំកងកម្លាំងជំនួយបន្ថែមទៀត » ។ « ជនសង្ស័យកំពុងបើកឡានពួកវាទៅទិសខាងជើងចេញពីទីតាំងរបស់យើងហើយ » ។

រូបគំនូរដោយ អេរីលេន ហ្គានស៍



ដោយសារស្ថានភាពដ៏តានតឹងនោះ ខ្ញុំបានឮសំឡេងមួយ ។ វាជាសំឡេងស្ងប់ស្ងាត់ ប៉ុន្តែពោរពេញដោយអំណាច និង ព្រះចេស្ដា ៖ « ចូរកុំបាញ់ ឡើយ ! »

កងជំនួយបន្ថែមរបស់យើង ដែលជាប៉ូលីសពុំពាក់ឯកសណ្ឋាន និង ពុំបើកឡានប៉ូលីសនោះ បានបើកឡានចេញទៅ ខណៈដែលបប និង ខ្ញុំបានបើកតាមពីក្រោយ ។ បន្ទាប់ពីរថយន្តទាំងបីគ្រឿងរបស់យើងបានបើកនៅលើស្ពាន នោះកងជំនួយរបស់យើងបានឈប់ឡានភ្លាមនៅលើស្ពានពីមុខឡានពណ៌ទឹកក្រូចនោះ ហើយយើងចតឡាននៅពីក្រោយឡាននោះដោយឃាំងឡានរបស់ជនសង្ស័យនោះ ។ ភ្លាមនោះ ឡានទឹកក្រូចបានឈប់ហើយ មនុស្សទាំងពីរនាក់នៅក្នុងឡាននោះ បានក្រាបចុះលាក់ខ្លួន ។

« ចុះចេញពីឡាន ហើយដាក់ដៃលើក្បាល ! » ខ្ញុំបានបញ្ជាបែបនេះបន្ទាប់ពីខ្ញុំចុះពីឡាន ។ គ្មាននរណាម្នាក់ឆ្លើយតបឡើយ ។

ដោយរៀបនឹងបាញ់កាំភ្លើង នោះខ្ញុំបានបញ្ជាម្ដងទៀតថា « ចុះចេញពីឡាន ហើយដាក់ដៃលើក្បាល ! » ។ ចូរធ្វើឥឡូវភ្លាម ! »

ភ្លាមនោះអ្នកបើកឡានបានក្រោកមក ហើយងាកមករកខ្ញុំ ។ ខ្ញុំអាចឃើញដែកភ្លឺចាំងព្រាកៗនៅក្នុងដៃគាត់ ។

ការបំពាក់បំប៉នរបស់ខ្ញុំ និង ការយល់ដឹងទូទៅរបស់ប៉ូលីស បានប្រាប់ខ្ញុំថា ខ្ញុំធ្វើបែបនេះដើម្បីការពារជីវិតរបស់ខ្ញុំ ។ ប៉ុន្តែដោយសារស្ថានភាពដ៏តានតឹងនោះ ខ្ញុំបានឮសំឡេងមួយ ។ វាជាសំឡេងស្ងប់ស្ងាត់ ប៉ុន្តែពោរពេញដោយអំណាច និង ព្រះចេស្ដា ៖ « ចូរកុំបាញ់ ! »

ខ្ញុំបានរំពឹងថានឹងបាញ់ក្នុងគ្រាណាមួយ ប៉ុន្តែខ្ញុំរង់ចាំមនុស្សនៅក្នុងឡាននោះជាអ្នកបាញ់មុនសិន ។ ផ្ទុយទៅវិញ អ្នកបើកឡាន បានលើកដៃរបស់ខ្លួន ហើយដាក់ខ្ពស់ផុតពីក្បាល ដែលមានអ្វីដូចជាកាំភ្លើង ហើយបានទម្លាក់ដៃរបស់គាត់ដាក់លើភ្លៅរបស់ខ្លួន ។

« នៅឲ្យស្ងៀម ! » ខ្ញុំបាននិយាយ ពេលខ្ញុំរត់ទៅកាន់ឡាន ។ « នៅឲ្យស្ងៀម ! »

ពេលនោះគឺដូចជារឿងនៅក្នុងទូរទស្សន៍អញ្ចឹង — រហូតដល់ខ្ញុំបានដឹងថា មនុស្សដែលនៅក្នុងឡាននោះគឺជាយុវនារីពីររូបដែលមានការភិតភ័យយ៉ាងខ្លាំង ។ អ្វីដែលខ្ញុំបានគិត គឺថា ជាកាំភ្លើងនោះគឺគ្រាន់តែជាក្បាលខ្សែក្រវ៉ាត់សុវត្ថិភាពទេ ។

ក្រោយមកយើងបានដឹងថា យុវនារីនោះ កំពុងយកឡានទៅសងមិត្តប្រុសរបស់ខ្លួនវិញ ។ ពួកនាងពុំដឹងថាពួកគេជាមនុស្សបែបណាឡើយ ។

« ខ្ញុំគិតថាអ្នកនឹងត្រូវបាញ់សម្លាប់ហើយ ខាល ! » បបបានប្រាប់ខ្ញុំពេលក្រោយមក ។ « ខ្ញុំស្ទើរតែបាញ់កាំភ្លើងទៅហើយ ។ ខ្ញុំពុំដឹងថា ហេតុអ្វីខ្ញុំពុំបាញ់នោះឡើយ » ។

ប៉ូលីសសើបអង្កេតទាំងពីរដែលពុំជិះឡានប៉ូសីលនោះបាននិយាយដូចគ្នា ទោះបីជាពុំមានឮសំឡេងនោះ ប៉ុន្តែខ្ញុំស្ដាប់ឮ ។ ខ្ញុំដឹងថាមានតែព្រះចេស្ដានៃស្ថានសួគ៌ អាចសង្គ្រោះយុវនារីទាំងពីរនោះពីសេចក្ដីស្លាប់ ហើយជួយមន្ត្រីប៉ូលីសទាំងបួនពីការធ្វើកំហុសដ៏អកុសល ។ បទពិសោធន៍នេះបានធ្វើឲ្យខ្ញុំមានចំណេះដឹងពិតប្រាកដថា ព្រះវរបិតាសួគ៌របស់យើងអាច និង ធ្វើអន្តរាគមន៍ចំពោះសេចក្ដីជំនឿរបស់យើង ។ ■

ឈ្មោះត្រូវបានដកចេញ

# ចូរបង្រៀនពួកគេឲ្យអានព្រះគម្ពីរមរមន

អំឡុងពេលបម្រើរបស់យើងនៅក្នុងបេសកកម្មជេនីវ៉ា ស្វីស ខ្ញុំត្រូវ បានហៅ ហើយញែកចេញធ្វើជាប្រធានសាខា ហើយភរិយារបស់ខ្ញុំត្រូវបានហៅជាប្រធានសមាគមសង្គ្រោះ ។ ដោយធ្វើការជាមួយគ្នាអស់ពីកម្លាំងរបស់យើង ដើម្បីដោះស្រាយការលំបាកនៅក្នុងសាខា ។ ទោះបីជាសាខានេះបានរៀបចំនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ក៏សាខានេះពុំឃើញមានពិធីបុណ្យជ្រមុជទឹកអស់ជាច្រើនឆ្នាំ ហើយក៏ពុំបានបញ្ជូនអ្នកផ្សព្វផ្សាយសាសនាណាទៅបេសកកម្មឡើយអស់រយៈពេល ១៥ឆ្នាំ ។

វាសរបញ្ជាក់ឲ្យឃើញថា យើងត្រូវការជំនួយរបស់ព្រះអម្ចាស់ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាលំបាកលំបិនជាច្រើនដែលសាខាបានជួប ។ បន្ទាប់ពីខ្ញុំបានអធិស្ឋានអំពីឧបសគ្គនានារបស់សាខា នោះព្រះវិញ្ញាណនៃព្រះអម្ចាស់បានមានបន្ទូលមកខ្ញុំថា « ចូរបង្រៀនសមាជិកឲ្យអានព្រះគម្ពីរមរមន ហើយអ្នកនឹងមានជោគជ័យ » ។

ភ្លាមនោះយើងបានធ្វើផែនការដើម្បីតាំងចិត្តសមាជិកទាំងអស់ឲ្យចាប់ផ្ដើមអានព្រះគម្ពីរមរមន ។

លទ្ធផលដែលទទួលបានគឺអស្ចារ្យណាស់ ។ ភាពសុខសាន្ត និង ព្រះវិញ្ញាណបានត្រឡប់មកកាន់សាខាវិញ ។ មានគ្រួសារថ្មីៗបានចូលរួមសាសនាចក្រ ។ ដោយបានជំរុញពីបំណងរបស់ខ្លួនដើម្បីបម្រើ នោះយុវជនម្នាក់បានចេញបម្រើបេសកកម្ម ។ អ្នករៀបអាពាហ៍ពិពាហ៍ដែលមានបញ្ហាមួយចំនួនត្រូវបានពង្រឹង ហើយគ្រួសារប្រែកាន់តែស្និទ្ធស្នាលនឹងគ្នា ។ សាខានេះបន្តរីកចម្រើនមកដល់សព្វថ្ងៃនេះ ។

យើង និង សមាជិកសាខាបានធ្វើជាសាក្សីចំពោះខ្លួនយើង នូវព្រះចេស្ដាដ៏មានអព្ភូតហេតុនៃព្រះគម្ពីរមរមន ។ វាពិតជាសិលាគន្លឹះនៃសាសនារបស់យើង និង ពីទីបន្ទាល់របស់យើងអំពីដំណឹងល្អ និង អំពីព្រះយេស៊ូវគ្រីស្ទ ។ យើងស្រឡាញ់វាអស់ពីដួងចិត្តរបស់យើង ។ វាគឺជាប្រភពនៃចំណេះដឹងដែលគ្មានទីបញ្ចប់ និង ពុំប្រែប្រួល ។

បទពិសោធន៍នេះបានបង្រៀនយើងថា ព្រះគម្ពីរមរមនគឺពិតជាមធ្យោបាយដ៏ពិត ដើម្បីជួយបងប្អូនប្រុសស្រីរបស់យើង ឲ្យដកចេញនូវស្រមោលនៃភាពងងឹតខាងវិញ្ញាណដែលគ្របដណ្ដប់លើផែនដីនេះ ។ ព្រះគម្ពីរនេះនាំមកនូវភាពសុខសាន្ត ក្ដីអំណរ សុភមង្គល ហើយមានបំណងប្រាថ្នាកាន់តែខ្លាំង ដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ។ ■

អ៊ីមីលៀន រីអូស ហ្គូបេក កាណាដា

# ការទទួលស្គាល់ ភាពក្លែងបន្លំរបស់សាតាំង

ដោយ ដេនីស ស៊ី ហ្គូន

ខ្ញុំបានដាក់ក្រដាសប្រាក់ពីរបីដុល្លារទៅក្នុងកាបូបលុយខ្ញុំនៅហាងលក់គ្រឿងទេស នៅពេលដែលមានក្រដាសប្រាក់មួយសន្លឹកដូចជាចម្លែក ។ ខ្ញុំបានគិតថាពណ៌បៃតងគឺ មានពណ៌ស្រាលជាងក្រដាសផ្សេងទៀត ដូច្នោះខ្ញុំបានពិនិត្យមើលយ៉ាងជិតភ្នែក ។ ក្រោយមកខ្ញុំបានកត់សម្គាល់ឃើញរូបរបស់ប្រធាន ចច វ៉ាស៊ីនតោនហាក់បីដូចជាមិនច្បាស់សោះ ។ សូម្បីតែក្រដាសទៀតសោតក៏មានអារម្មណ៍ថាពុំត្រូវទ្បើយ ។ វាក្លែងក្លាយ ! ស្មៀននោះបានប្តូរវាយកក្រដាសប្រាក់ពិត ហើយដាក់ក្រដាសប្រាក់ក្លែងក្លាយនោះទៅក្នុងហាងម្ចាស់នោះវិញ ។

ខ្ញុំបានគិតយ៉ាងច្រើនអំពីក្រដាសប្រាក់ក្លែងក្លាយនោះតាំងពីនោះមក ។ ខ្ញុំឆ្ងល់ថាមិនដឹងជាក្រដាសប្រាក់នេះបានដំណើរការយូរប៉ុន្មានមកហើយទេ ហើយមិនដឹងថាមានមនុស្សប៉ុន្មាននាក់ដែលត្រូវបានបោកបញ្ឆោតអស់ជាច្រើនឆ្នាំមកនេះ ។ តាមពិតទៅ ដោយខ្ញុំពុំបានយកចិត្តទុកដាក់ ខ្ញុំក៏ប្រហែលជាត្រូវបានបោកបញ្ឆោតផងដែរ ។ ប៉ុន្តែដោយការប្រៀបធៀបវានឹងក្រដាសប្រាក់ពិត ហើយផ្តោតលើភាពខុសគ្នាជំនួសឲ្យភាពស្រដៀងគ្នា នោះខ្ញុំអាចប្រាប់ថាវាពិតជាក្លែងក្លាយមែន ។

ព្រះគម្ពីរមរមនមានឧទាហរណ៍ជាច្រើនពីការក្លែងបន្លំខាងវិញ្ញាណ ដែលបានធ្វើតាមវិធីសាស្រ្តរបស់សាតាំង ដូចជាការកុហក និង ការបោកបញ្ឆោតមនុស្សដទៃដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ។ តាមរយៈការសិក្សាពីល្បិចកល និង ស្នៀតរបស់វា នោះយើងចាប់ផ្តើមកត់សម្គាល់ឃើញពីកំហុស និងបញ្ហារបស់វា តាមរបៀបមួយដោយអង្កេតយ៉ាងហ្មត់ចត់ ដើម្បីកត់សម្គាល់ពីភាពខុសគ្នារវាងក្រដាសប្រាក់ពិត និង ក្រដាសប្រាក់ក្លែងក្លាយ ។ កាលណាយើងកាន់តែអង្កេតមើលពីភាពខុសគ្នា នោះយើងរៀបចំខ្លួនបានកាន់តែប្រសើរ ដើម្បីឃើញពីអ្នកក្លែងបន្លំសព្វថ្ងៃនេះ ហើយទប់ទល់នឹងការកុហករបស់វា ។

## ការប្រមូលព័ត៌មានពីភាពក្លែងបន្លំរបស់សាតាំង

សាតាំងព្យាយាមដឹកនាំយើងឲ្យទៅជាប់ចំណងនៃភាពក្លែងបន្លំខាងវិញ្ញាណផ្ទាល់របស់វា ហើយប្រសិនបើយើងពុំប្រុងប្រយ័ត្នទេនោះ យើងនឹងត្រូវបានបោកបញ្ឆោត ។ ប្រធាន យ៉ូសែប អែហ្វ ស៊្មីធ ( ឆ្នាំ ១៨៣៨–១៩១៨ ) បានព្រមាន ៖ « សាតាំងគឺជាអ្នកក្លែងខ្លួនយ៉ាងជំនាញ ហើយដោយសារសេចក្តីពិតនៃដំណឹងល្អដ៏អស្ចារ្យត្រូវបានប្រទានដល់ពិភពលោកយ៉ាងច្រើនជាបន្តបន្ទាប់ នោះវាបាចពង្រាយប្រាក់កាក់ក្លែងបន្លំនៃគោលលទ្ធិក្លែងក្លាយ ។ សូមមានការប្រុងប្រយ័ត្នចំពោះក្រដាសប្រាក់ក្លែងក្លាយនោះ អ្នកនឹងពុំអាចចាយវាបានទ្បើយ ប៉ុន្តែវាធ្វើឲ្យខកចិត្ត មានទុក្ខព្រួយ និង ស្លាប់ខាងវិញ្ញាណ » ។[១]

**នៅពេលយើងជួបប្រទះនឹងការក្លែងបន្លំខាងវិញ្ញាណ នោះព្រះគម្ពីរមរមនអាចជួយយើងឲ្យកំណត់ថាអ្វីពិត និង អ្វីដែលក្លែងក្លាយ ។**

ការការពារដ៏ល្អបំផុតដែលយើងមានដើម្បីទប់ទល់នឹងការបោកបញ្ឆោតដោយការក្លែងបន្លំរបស់សាតាំងគឺត្រូវស្គាល់សេចក្តីពិតនៃដំណឹងល្អឲ្យបានច្រើនតាមដែលអាចធ្វើបាន ។ ដរាបណាយើងស្គាល់សេចក្តីពិតកាន់តែជាក់ច្បាស់ នោះវាកាន់តែងាយស្រួលដើម្បីកត់សម្គាល់ពីភាពខុសគ្នា នៅពេលសាតាំងបង្ហាញយើងនូវភាពក្លែងបន្លំរបស់វា ។ ដូច្នេះនៅពេលវាធ្វើដូច្នេះ យើងត្រូវស្វែងរកមើលភាពខុសគ្នា ពុំមែនភាពស្រដៀងគ្នាទ្បើយ គឺធ្វើដូចជាខ្ញុំបានធ្វើជាមួយនឹងក្រដាសប្រាក់

រូបថតមកពី ISTOCK/THINKSTOCK



ដុល្លាររបស់ខ្ញុំដែរ ដោយសារថាទីណាមានការកុហក ទីនោះនឹងត្រូវបានបើកសម្តែងជានិច្ច ។

ប្រធាន អ៊ែសរ៉ា ថាហ្វ បែ៊នសឹន ( ឆ្នាំ ១៨៩៩–១៩៩៤ ) បានបង្រៀន ៖ « ព្រះគម្ពីរមរមនបង្ហាញឲ្យឃើញនូវមារសត្រូវរបស់ព្រះគ្រីស្ទ ។ . . .ជាមួយនឹងព្រះតម្រិះដឹងមុនដ៏ឥតព្រំដែនរបស់ទ្រង់ ព្រះបានធ្វើឲ្យព្រះគម្ពីរមរមន លេចចេញជារូបរាងឡើង ដើម្បីឲ្យយើងអាចឃើញកំហុស ហើយយល់ដឹងពីរបៀបតយុទ្ធនឹងគំនិតនៃការអប់រំ នយោបាយ សាសនា និងទស្សនៈវិជ្ជាដែលខុសឆ្គងនាសម័យយើងនេះ » ។[២]

យើងកំពុងតែធ្វើសង្គ្រាមជាមួយនឹងសាតាំងសព្វថ្ងៃនេះ ។ យើងក៏ដូចជាកងទ័ពដទៃទៀតដែរ យើងត្រូវតែដឹងពីផែនការរបស់មារសត្រូវ ។ ជាឧទាហរណ៍ ការដឹងពីពេលវេលា និង ទីកន្លែងដែលមារសត្រូវរបស់យើងនឹងវាយប្រហារយើង គឺជាព័ត៌មានដ៏មានតម្លៃបំផុត ។ ហេតុដូច្នោះហើយមូលហេតុនៃលក្ខខណ្ឌតម្រូវឲ្យទទួលបាននូវព័ត៌មានបែបនេះនោះ ត្រូវបានហៅថា « ការប្រមូលព័ត៌មាន » ។ ដើម្បីស្គាល់ពីសត្រូវរបស់យើង គឺមានន័យថាមានភាពវៃឆ្លាតជាងសត្រូវយើង ។ ព្រះគម្ពីរមរមនអាចជួយយើងឲ្យ « ប្រមូលព័ត៌មាន » អំពីយុទ្ធសាស្ត្រក្លែងបន្លំរបស់សាតាំង ។

### ពាក្យសម្តីបញ្ចោរគឺជាភាពក្លែងបន្លំ

នៅក្នុងព្រះគម្ពីរមរមន ភាពក្លែងបន្លំជាងពាក់កណ្តាលត្រូវបានប្រើជាពាក្យសម្តីបញ្ចោរ និង អំណាចផ្ទាល់ខ្លួនដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន ។ ឧទាហរណ៍ សេរេម « មានតំរិះដ៏ឥតខ្ចោះអំពីភាសារបស់ប្រជាជន ហេតុដូច្នោះហើយ ទើបគាត់អាចបញ្ចោរ ហើយរកកលល្បិចនៃសម្តីជាច្រើនដោយអំណាចនៃអារក្ស » ( យ៉ាកុប ៧:៤ ) ។ ពួកសង្ឃទុច្ចរិតរបស់ស្តេចណូអេបាននិយាយ « សម្តីផ្អែមល្ហែមឥតប្រយោជន៍ និង សម្តីបញ្ចើចបញ្ចើ » ( ម៉ូសាយ ១១:៧ ) ដែលធ្វើឲ្យមនុស្សធ្លាក់ខ្លួនចំពោះ

ការថ្វាយបង្គំបដិមាករ និង អំពើទុច្ចរិតផ្សេងៗទៀត ។ កូរីហូបានសម្រេចនូវជោគជ័យស្រដៀងគ្នានៅជំនាន់របស់លោក « ដោយបង្វែរចិត្តមនុស្សជាច្រើនចេញ » ( អាលម៉ា ៣០:១៨ ) ។ ទាំងអាម៉ាលិកាយ និង កាឌីអានតុន បានប្រើសមត្ថភាពបញ្ជោររបស់វាដើម្បីបង្កើតកងទ័ពទុច្ចរិតឲ្យដើរតាមវា ( សូមមើល អាលម៉ា ៤៦:១០; ហេលេមិន ២:៤ ) ។

ការណ៍នេះពុំមែនចៃដន្យទេ ។ ពាក្យបញ្ជោរគឺគ្មានអត្ថន័យ ពុំស្មោះសរ ពុំពិត និង បំផ្លើស ។ នីហ្វៃបានព្រមានដល់អស់អ្នកដែល « បង្រៀនតាមរបៀបនេះ គឺជាគោលលទ្ធិក្លែងក្លាយ ឥតខ្លឹមសារ ហើយឥតប្រយោជន៍ ហើយនឹងអួតនៅក្នុងចិត្តរបស់ខ្លួន ហើយនឹងលាក់គំនិតខ្លួនពីព្រះអម្ចាស់ ហើយកិច្ចការរបស់ពួកគេនឹងនៅក្នុងទីងងឹត » ( នីហ្វៃទី ២ ២៨:៩ ) ។

ជារឿយៗពាក្យបញ្ជោរត្រូវបានប្រើដើម្បីបោកបញ្ឆោត វាតែងតែមានការជំរុញចិត្តយ៉ាងអាថ៌កំបាំង ឬ មានផែនការលាក់កំបាំង ។ ពាក្យបញ្ជោរគឺការនិយាយហួសពីអ្វីដែលត្រូវនិយាយ ហើយវាទាក់ទាញឲ្យមាននូវការអួតអាត និង អំនួតរបស់មនុស្សខាងសាច់ឈាម ។ ប៉ុន្តែព្យាការីរបស់ព្រះអម្ចាស់ប្រាប់យើងយ៉ាងសេចក្ដីពិតសាមញ្ញ ប៉ុន្តែសំខាន់ដែលយើង *ត្រូវតែ* ដឹង ។

ពាក្យបញ្ជោរគឺជាភាសាដែលសាតាំងនិយាយ ។ ប្រធាន ជេមស៍ អ៊ី ហ្វោស្ត ( ឆ្នាំ ១៩២០–២០០៧ ) ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយបានពន្យល់ ៖ « ជារឿយៗសំឡេង [ របស់សាតាំង ] ពិតជាមានហេតុផល ហើយសារលិខិតរបស់វាងាយនឹងបង្ហាញថាត្រូវយ៉ាងខ្លាំង ។ វាគួរឲ្យទាក់ទាញ ជាសំឡេងដោយឧបាយកលដែលធ្វើឲ្យចិត្តរីករាយ ។ វាមិនមែនជាសំឡេងខ្លាំង ឬ ពុំរីករាយឡើយ ។ គ្មាននរណាម្នាក់ស្ដាប់តាមសំឡេងសាតាំងឡើយ ប្រសិនបើវាជាសំឡេងដែលឮខ្លាំង ឬ ពុំរីករាយនោះ » ។[៣]



*« [ សំឡេងរបស់សាតាំង ] គួរឲ្យទាក់ទាញ ជាសំឡេងដោយឧបាយកលដែលធ្វើឲ្យចិត្តរីករាយ ។ . . . គ្មាននរណាម្នាក់ស្ដាប់តាមសំឡេងសាតាំងឡើយ ប្រសិនបើវាជាសំឡេងដែលឮខ្លាំង ឬ ពុំរីករាយនោះ » ។*

នៅពេលពិភពលោកនេះបង្ហាញដល់យើងនូវគំនិតទស្សនវិទ្យា ឬ យោបល់ដែលហាក់បីដូចជាទាក់ទាញដែលនាំឲ្យមាននូវការអួតអាង ឬ មោទនភាព ឬ សំឡេងសាមញ្ញនោះហាក់បីដូចជាពិត នោះវាគឺជាការព្រមានមួយដល់យើងភ្លាម ។ សូមចាត់ទុកគំនិតទាំងនោះថាជាការក្លែងបន្លំ ។ សូមប្រៀបធៀបវាជាមួយនឹងសេចក្ដីពិតដែលបង្រៀនដោយព្យាការីរបស់ព្រះអម្ចាស់ ។ សូមរកមើលភាពខុសគ្នានានា ពុំមែនភាពស្រដៀងគ្នាឡើយ ហើយគំនិតក្លែងបន្លំនោះនឹងលេចចេញជាក់ស្ដែងតែម្ដង ។

## នីហូរ — អ្នកក្លែងបន្លំដ៏មានប្រជាប្រិយ

នីហូរបានប្រើយុទ្ធសាស្ត្រនៃពាក្យបញ្ជោររបស់សាតាំងដោយសេរី ។ ចូរពិនិត្យមើលគាត់ជាគំរូមួយអំពីអ្នកក្លែងបន្លំខាងវិញ្ញាណ ។ នីហូរ ជាអ្នកដែលមានគោលលទ្ធិហាក់បីដូចទទួលស្គាល់ថាមានព្រះអង្គសង្គ្រោះមួយអង្គ គឺជាអ្នកផ្សព្វផ្សាយដ៏មានប្រជាប្រិយ និង ឥទ្ធិពលនៅក្នុងចំណោមសាសន៍នីហ្វៃ ។ នីហូរបានបង្កើតអ្នកតាមខ្លួនជាច្រើនដោយបង្រៀនថា « មនុស្សទាំងអស់ត្រូវតែបានសង្គ្រោះនៅថ្ងៃចុងក្រោយ » ហើយ « មានជីវិតដ៏នៅអស់កល្បជានិច្ច » ( អាលម៉ា ១:៤ ) ។

តើយើងអាចឃើញទេថា ហេតុអ្វីសារលិខិតរបស់នីហូរគួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំងដូច្នេះ ? គាត់កំពុងបង្រៀនអំពីព្រះដែលងាយស្រួល និង ព្រះដែលសម្រាកលំហែកាយ — ជាព្រះមួយអង្គ ដែលដោយសារទ្រង់ស្រឡាញ់មនុស្សគ្រប់គ្នា នោះទ្រង់នឹងសង្គ្រោះពួកគេ ដោយមិនគិតពីអ្វីឡើយ ។ ដូច្នេះចូរទៅចុះ ហើយធ្វើនូវអ្វីៗដែលអ្នកចង់ធ្វើ ដោយសារអ្វីៗទាំងអស់គឺល្អទាំងអស់ ។ វាជាមនោគមដ៏ទាក់ទាញចិត្ត ដែលទាក់យកចិត្តមនុស្សជាច្រើននៅជំនាន់របស់នីហូរ ( សូមមើល អាលម៉ា ១:៥ ) ក៏ដូចជាមនុស្សជាច្រើននាជំនាន់សព្វថ្ងៃនេះផងដែរ ។ សំបុត្រឥតគិតថ្លៃមួយទៅកាន់ឋានសួគ៌គឺជាអ្វីមួយដែលមនុស្សហាក់បីដូចជាចង់បាន ។

ដូច្នេះតើមានបញ្ហាអ្វីជាមួយនឹងសារលិខិតរបស់នីហូរនោះ ? ចូរមើលចំណុចសំខាន់នៃសេចក្ដីសំអាងរបស់គាត់ម្ដងទៀត ៖

- ព្រះបានបង្កើតមនុស្សទាំងអស់ — ពិត ។
- ព្រះស្រឡាញ់មនុស្សទាំងអស់ — ពិត ។
- យើងពុំគួរភ័យខ្លាចព្រះឡើយ — ពិត ។
- យើងគួរតែរីករាយជាមួយនឹងគំនិតនៃសេចក្ដីសង្គ្រោះ — ពិត ។

ហេតុដូច្នោះហើយ មានចំណុចស្រដៀងគ្នាជាច្រើនរវាងអ្វីដែលនីហូរបានបង្រៀន ជាមួយនឹងសេចក្ដីពិតនៃដំណឹងល្អ ។ ប៉ុន្តែសូមចាំថា — គឺដូចទៅនឹងក្រដាសប្រាក់ក្លែងក្លាយនោះដែរ យើងត្រូវតែរកមើលភាពខុសគ្នា ពុំមែនភាពស្រដៀងគ្នាឡើយ ។ ដូច្នេះចូរមើលចំណុចបង្រៀនចុងក្រោយរបស់នីហូរ ៖

- ព្រះនឹងប្រទានជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្សគ្រប់រូប — ខុស !

ឥឡូវ នេះគឺជាភាពខុសគ្នាសំខាន់មួយដែលប្រាប់យើងថា នីហូរគឺជាអ្នកក្លែងបន្លំខាងវិញ្ញាណ ។ សេចក្ដីសង្គ្រោះពីសេចក្ដីស្លាប់ខាងរូបកាយ *គឺ* ត្រូវបានធានាថាមានចំពោះមនុស្សទាំងអស់ ប៉ុន្តែសេចក្ដីសង្គ្រោះនៃសេចក្ដីស្លាប់ខាងវិញ្ញាណគឺមានលក្ខខណ្ឌលើឆន្ទៈនៃការប្រែចិត្តរបស់យើង ។ ប្រសិនបើយើងប្រែចិត្ត នោះយើងអាចទទួលជីវិតដ៏នៅអស់កល្បជានិច្ច ( សូមមើល យ៉ាកុប ៦:១១ ) ។ ប៉ុន្តែជីវិតអស់កល្បជានិច្ចពុំមែនផ្ដល់ឲ្យដោយសេរីឡើយ ។

### គេឌាន និង អាលម៉ាបានស្គាល់អ្នកក្លែងបន្លំ

ទង្វើទុច្ចរិតរបស់នីហូរត្រូវបានបើកបង្ហាញនៅពេលដែលគាត់បានជួបជាមួយគេឌាន ដែលជាគ្រូបង្រៀនសុចរិតម្នាក់នៅក្នុងសាសនាចក្ររបស់ព្រះ ។ គេឌានបានតទល់នឹងស្ដេចណូអេយ៉ាងក្លាហានអស់ជាច្រើនឆ្នាំមុន ហើយហេតុដូច្នោះហើយមានបទពិសោធន៍ជាមួយនឹងអ្នកក្លែងបន្លំខាងវិញ្ញាណ ( សូមមើល ម៉ូសាយ ១៩:៤–៨ ) ។ នីហូរ « បានចាប់ផ្ដើមប្រកែកជាមួយបុរសនោះយ៉ាងខ្លាំង ដើម្បីគាត់អាចដឹកនាំមនុស្សនៃសាសនាចក្រឲ្យវង្វេងផ្លូវ ប៉ុន្តែបុរសនោះ [ គេឌាន ] បានតទល់នឹងគាត់ ដោយព្រមានដាស់តឿនគាត់ដោយព្រះបន្ទូលទាំងឡាយនៃព្រះ » ( អាលម៉ា ១:៧ ) ។ គេឌានបានដឹងថានីហូរគឺជាអ្នកក្លែងបន្លំ ។ ក្រោយពីភាពពិតរបស់នីហូរត្រូវបានបើកបង្ហាញនោះវាប្រើយុទ្ធសាស្ត្រមួយទៀតរបស់សាតាំងគឺ — ឃាតកម្ម ។ ប៉ុន្តែសេចក្ដីស្លាប់របស់គេឌាននោះពុំអត់ប្រយោជន៍ឡើយ ។ មនុស្សបាននាំយកអ្នកក្លែងបន្លំនីហូរទៅមុខអាលម៉ាដើម្បីកាត់ទោស ។

អាលម៉ាបានដឹងថា នីហូរពុំគ្រាន់តែមានកំហុសខាងឧបាយកលផ្ទែកសង្ឃហើយធ្វើឃាតកម្មឡើយ ប៉ុន្តែប្រសិនបើពុំបានការពារវាទេនោះ ឧបាយកលផ្ទែកសង្ឃនៅក្នុងចំណោមប្រជាជន « នឹងបញ្ជាក់នូវការបំផ្លិចបំផ្លាញរបស់គេទាំងស្រុង » ( អាលម៉ា ១:១២ ) ។ ដូច្នេះនីហូរត្រូវបានកាត់ទោសឲ្យស្លាប់ ហើយរងទុក្ខដោយ « ការស្លាប់ដោយថោកទាប » ( អាលម៉ា ១:១៥ ) ។

គេឌាន និង អាលម៉ាគឺជាគំរូសម្រាប់យើង ។ នៅពេលយើងមានព្រះវិញ្ញាណគង់នៅជាមួយយើង នោះយើងនឹងឃើញ ហើយស្ដាប់ឮ « រឿងទាំងឡាយតាមដែលនឹងមាននៅពេលខាងមុខ » ( យ៉ាកុប ៤:១៣ ) ។ យើងនឹងស្គាល់ផែនការ និង គ្រោងការណ៍ក្លែងបន្លំរបស់សាតាំង « ដោយដឹងគ៏រះដ៏ឥតខ្ចោះ ហាក់បីដូចជាពន្លឺថ្ងៃពីយប់ងងឹត » ( ម៉ូរ៉ូណៃ ៧:១៥ ) ។

មារសត្រូវ « ក្លែងបន្លំ » របស់យើងគឺមានភាពឆ្លាតវៃ ប៉ុន្តែដូចជាគេឌាន និង អាលម៉ា នោះយើងអាចក្លាយជាអ្នកឆ្លាតជាងវា ។ គឺដូចដែលខ្ញុំបានចាប់ផ្ដើមដឹងបន្តិចម្ដងៗពីភាពខុសគ្នារវាងការប្រៀបធៀបក្រដាសប្រាក់ដុល្លាររបស់ខ្ញុំដែរ នោះយើងអាចរៀនអង្កេតមើល ទាំងប្រើគំនិត និង វិញ្ញាណរបស់យើងដោយសន្សឹមៗដើម្បីស្គាល់ភាពខុសគ្នារវាងសេចក្ដីពិត និង ការកុហក ។ នៅពេលយើងធ្វើដូច្នោះ នោះយើងនឹងស្គាល់អ្នកក្លែងបន្លំ ហើយទប់ទល់នឹងការកុហករបស់វា ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



**សាតាំងផ្សាយការកុហក**

« សាតាំងជាមារសត្រូវរបស់យើងចង់ឲ្យយើងបរាជ័យ ។ វាផ្សាយការកុហក ដែលជាផ្នែកនៃកិច្ចខិតខំរបស់វាដើម្បីបំផ្លាញជំនឿរបស់យើង ។ វាឲ្យយោបល់ដ៏ប៉ិនប្រសប់ថា អ្នកមានមន្ទិលសង្ស័យ អ្នកចេះសួរមនុស្សទុទិដ្ឋិនិយម គឺជាមនុស្សជឿនលឿន និង មានបញ្ញា ខណៈដែលអ្នកដទៃមានជំនឿទៅលើព្រះ និងអព្ភូតហេតុរបស់ទ្រង់ គឺជាមនុស្សខ្វះគតិ ខ្វាក់ ឬត្រូវគេលាងខួរក្បាលទៅវិញ ។ សាតាំងនឹងគាំទ្រថា វាឡូយណាស់ដើម្បីសង្ស័យអំពីអំណោយទានខាងវិញ្ញាណ និង ការបង្រៀនរបស់ពួកព្យាការីពិត » ។

ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ « **Be Not Afraid, Only Believe** » ***Liahona,*** ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៧៨ ។

កំណត់ចំណាំ

1. យ៉ូសែប អេហ្វ ស្ម៊ីធ, *Gospel Doctrine,* ការបោះពុម្ពទី ៥ ( ឆ្នាំ ១៩៣៩ ) ទំព័រ ៣៧៦ ។
2. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ Ezra Taft Benson* ( ឆ្នាំ ២០១៤ ) ទំព័រ ១៣២ ។
3. ជេមស៍ អ៊ី ហ្វោស្ដ « The Forces That Will Save Us » *Liahona,* ខែ មករា ឆ្នាំ ២០០៧ ទំព័រ ៤ ។

# ការរស់នៅដោយពរជ័យនៅក្នុងប្រទេស ម៉ាដាហ្គាស្ការ



ដោយ មីនឌី អាន សេលូ
ទស្សនាវដ្ដីសាសនាចក្រ

> **ទោះបីជាមាននូវស្ថានភាពនយោបាយតានតឹង និងសេដ្ឋកិច្ចយ៉ាប់យ៉ឺននៅក្នុងប្រទេសនេះក្ដី សូឡូហ្វូពឹងផ្អែកលើពរជ័យនានាដែលកើតឡើងតាមរយៈការរស់នៅតាមដំណឹងល្អ ។**

បន្ទាប់ពីភរិយារបស់ខ្លួនបានរងទុក្ខដោយការខកចិត្តពីការរលូតកូនអំឡុងពេលមានផ្ទៃពោះដំបូង នោះសូឡូហ្វូ រ៉ាវែរអូចោណា មានអារម្មណ៍ថាការអធិស្ឋានរបស់ពួកគេបានទទួលចម្លើយមួយឆ្នាំក្រោយមក នៅពេលពរពោះលើកទីពីរ ។ គាត់និងភរិយារបស់គាត់ឈ្មោះ ហារី ម៉ាទីន ពិចារណាពីកំណើតរបស់កូនស្រីខ្លួនថាជាពរជ័យមួយដ៏មហិមាបំផុត ។ សូឡូហ្វូពន្យល់ថា « ដោយសារយើងបានសុំព្រះ ហើយទ្រង់បានប្រទាននាងមកឲ្យយើង នោះយើងបានដាក់ឈ្មោះមួយដល់នាងដែលជាភាសាម៉ាឡាកាស៊ីមានន័យថា ‹ ចម្លើយរបស់ព្រះ › » ។

សូឡូហ្វូ ជាយុវមជ្ឈិមវ័យមកពីប្រទេសម៉ាដាហ្គាស្ការ ដែលយល់ដឹងថាព្រះឆ្លើយតបការអធិស្ឋាន ហើយប្រទានពរដល់ពួកអ្នកស្មោះត្រង់នៅចំគ្រាដែលត្រូវការ ។ សូឡូហ្វូនិយាយថា « ជីវិតនេះពុំងាយស្រួលឡើយ ហើយនៅពេលមនុស្សពុំបាននូវអ្វីដែលពួកគេចង់បានទេ នោះមនុស្សមួយចំនួនចាប់ផ្ដើមសួរថា ‹ ហេតុអ្វីរឿងនេះកើតឡើងចំពោះខ្ញុំ ? › ពួកគេអាចចាកចេញពីសាសនាចក្រ ឬ មានចម្ងល់នឹងជំនឿរបស់ខ្លួនលើព្រះ ។ ប៉ុន្តែនៅពេលរស់នៅតាមដំណឹងល្អ ហើយអានព្រះគម្ពីរនោះគឺមានភាពងាយស្រួលជាង ។ នៅពេលយើងពិតជារស់នៅតាមដំណឹងល្អ នោះអ្នកពិតជាអាចឃើញពរជ័យជាច្រើន » ។

រស់នៅក្នុងប្រទេសមួយដែលមានបញ្ហាយ៉ាងធ្ងន់ធ្ងរដូចជា ភាពកម្សត់ទុរគត៌ ភាពគ្មានស្ថេរភាពនៅក្នុងរដ្ឋាភិបាល ហេដ្ឋារចនាសម្ព័ន្ធខ្សត់ខ្សោយ និងមានគ្រោះធម្មជាតិច្រើន នោះវាបញ្ជាក់យ៉ាងច្បាស់ពីមូលហេតុដែលសូឡូហ្វូនិយាយថាជីវិតនេះវាពុំងាយស្រួលឡើយ ។ ប៉ុន្តែសម្រាប់គាត់ ពរជ័យដែលរស់នៅតាមដំណឹងល្អ គឺធំធេងជាងភាពលំបាកនោះទៅទៀត ។ គាត់និយាយថា « ខ្ញុំពុំអាចរាប់ពរជ័យដែលខ្ញុំបានទទួលឡើយ ដរាបណាខ្ញុំរស់នៅតាមដំណឹងល្អនោះ » ។

ដោយសារសាសនាចក្រទើបតែថ្មីនៅក្នុងប្រទេសម៉ាដាហ្គាស្ការ ( សាខាដំបូងគេត្រូវបានរៀបចំនៅក្នុងឆ្នាំ ១៩៩០ ) សូឡូហ្វូនិយាយថាផ្នែកមួយដ៏លំបាកបំផុតនៃការធ្វើជាសមាជិកនោះគឺជាពាក្យចចាមអារ៉ាមនិង ការយល់ខុសអំពីសាសនាចក្រ ។ សូឡូហ្វូថ្លែងថា គឺដូចនៅក្នុងការនិមិត្តរបស់លីហៃអំពីដើមជីវិតដែរ « មនុស្សពុំឱបក្រសោបយកដំណឹងល្អពេញលេញឡើយ ដោយសារពួកគេមានអារម្មណ៍ខ្មាស់អៀននៅចំពោះមុខមិត្តភក្តិរបស់ខ្លួន ហើយខ្លាចថាគ្រួសាររបស់ពួកគេនឹងបោះបង់គេចោល » ។ គាត់និយាយថាអ្វីដែលធ្វើឲ្យសូឡូហ្វូមានភាពខុសពីពួកគេនោះគឺថា « ខ្ញុំពុំធ្លាប់អៀនខ្មាស់ឡើយ ។ ខ្ញុំរស់នៅតាមដំណឹងល្អ ហើយខ្ញុំតែងតែចង់ចែកចាយវាជាមួយសហការីរបស់ខ្ញុំ ទោះបីជាពួកគេមួយចំនួនពុំចាប់អារម្មណ៍នឹងវាក្ដី » ។ ជារឿយៗគាត់តែងចែកទីបន្ទាល់យ៉ាងសាមញ្ញរបស់គាត់ ដែលធ្វើឲ្យមិត្តរួមការងាររបស់គាត់ដាក់ឈ្មោះហៅក្រៅគាត់ថា « គ្រូគង្វាល » ។

នៅក្នុងចំណោមភាពវឹកវរនៃសេដ្ឋកិច្ច និងនយោបាយ នោះសូឡូហ្វូ និង ម៉ារី ម៉ាទីនពឹងផ្អែកទាំងស្រុងលើពរជ័យនៃសេចក្ដីសញ្ញាព្រះវិហារបរិសុទ្ធរបស់ខ្លួន ( ពួកគេបានរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធយ៉ូហាណែស្ប៊ើកអាហ្វ្រិកខាងត្បូងមួយឆ្នាំក្រោយពីបេសកកម្មរបស់ពួកគេ — ដែលគាត់បម្រើនៅក្នុងប្រទេស អ៊ូហ្គង់ដា ហើយភរិយាគាត់បម្រើនៅក្នុងប្រទេស ម៉ាដាហ្គាស្ការ ) ព្រមទាំងការទុកចិត្តរបស់ពួកគេលើព្រះអម្ចាស់ ។ សូឡូហ្វូពន្យល់ថា « ខ្ញុំមានដំណឹងល្អ ហើយខ្ញុំដាក់ជីវិតរបស់ខ្ញុំនៅក្នុងព្រះហស្តរបស់ព្រះ » ។ គាត់អាចពឹងផ្អែកលើទីបន្ទាល់ដ៏រឹងមាំរបស់ខ្លួន ដោយសារគាត់មានសេចក្ដីជំនឿរួចហើយលើ « ការឆ្លើយតបរបស់ព្រះ » ។ ■

រូបថត ៖ ខាងលើបានផ្ដល់ឲ្យដោយសូឡូហ្វូ រ៉ាវែរអូចោណា ខាងក្រោម © ISTOCK/THINKSTOCK





## សេចក្ដីបន្ថែមអំពីសូឡូហ្វូ

*តើអ្នកចូលចិត្តបរិភោគអ្វីខ្លះ ?*

អាហារដែលយើងបរិភោគនោះគឺបាយ — បាយច្រើនណាស់ ។ អ្វីមួយដែលខ្ញុំ ចូលចិត្តនោះគឺគេហៅថា *វ៉ែវតូតូ* ។ យើងប្រើឧបករណ៍ពិសេសមួយដើម្បី បុកស្លឹកក្ដួចឲ្យបែកជាចំណិតតូចៗ ហើយហូបវាជាមួយបាយ និង សាច់ជ្រូក ។

*តើអ្នកចូលចិត្តធ្វើអ្វីខ្លះនៅពេលទំនេរ ?*

ខ្ញុំចូលចិត្តលេងព្យាណូ ច្រៀង និង អាន ។ ដោយសារប្រធានសាខាបានដឹងថាខ្ញុំចូលចិត្តច្រៀង និង អាចលេងព្យាណូ នៅពេលខ្ញុំចូលរួមសាខានោះគាត់និយាយថា « ហ៊្អ យើងមានអ្នកដឹកនាំក្រុមចម្រៀងហើយ » ហើយខ្ញុំបានស្ម័គ្រចិត្តបម្រើ ។ ពួកគេពុំមានក្រុមចម្រៀងពីមុនឡើយ ប៉ុន្តែខ្ញុំបានចាប់ផ្ដើមបង្រៀនពួកគេ ហើយឥឡូវពួកគេរីករាយនឹងក្រុមចម្រៀងនេះ ។



## ព័ត៌មានលម្អិតអំពីប្រទេសម៉ាដាហ្គាស្ការ

ភាសា ៖ បារាំង ម៉ាឡាកាស៊ី
រដ្ឋធានី ៖ អង់តាណាណារីវ៉ូ

## ចំនួនជាតួលេខ

ប្រជាជន ២២,០០៥,២២២ ( ប៉ាន់ប្រមាណនៅឆ្នាំ ២០១២ )
៨០ភាគរយនៃសត្វដែលមាននៅក្នុងប្រទេសម៉ាដាហ្គាស្ការពុំមាននៅកន្លែងផ្សេងទៀតឡើយនៅលើផែនដីនេះ ។
ជាកោះទីបួនដែលធំបំផុតក្នុងពិភពលោក ។
៦០ភាគរយនៃវ៉ានីឡាត្រូវបាននាំចេញមកពីប្រទេសម៉ាដាហ្គាស្ការ ។

## សាសនាចក្រនៅក្នុងប្រទេសម៉ាដាហ្គាស្ការ

ពួកបរិសុទ្ធថ្ងៃចុងក្រោយ ៩១៩០ នាក់
មាន ៣៧ វួដ និង សាខា
ស្តេក ២
បេសកកម្ម១









**ដោយ អែលឌើរ**
**ឌែល ជី រេនឡាន់**
ក្នុងកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

# ស្ថេរភាពខាងវិញ្ញាណ ៖ ការសង់កប៉ាល់មួយដែលមិនអាចលិចបាន

*យើងត្រូវការមានស្ថេរភាពខាងវិញ្ញាណគ្រប់គ្រាន់ ដើម្បីកាច់ចង្កូតជីវិតរមែងស្លាប់របស់យើងឲ្យបានជោគជ័យ ហើយត្រឡប់ទៅគេហដ្ឋានសួគ៌ាយើងវិញដោយសុវត្ថិភាព ។*



នៅក្នុងដើមសតវត្សរ៍ទី ១៧ ព្រះរាជារបស់ប្រទេសស៊ុយអែដ ឈ្មោះ ហ្គូស្តាវ ទី II អាដូហ្វ បានបញ្ជាឲ្យសង់កប៉ាល់សង្គ្រាមមួយដែលនឹងដាក់ឈ្មោះថា *វ៉ាសា* ។ ការសង់កប៉ាល់នោះតម្រូវឲ្យប្រើធនធានច្រើនណាស់ ជាពិសេសគឺដើមសែន ដែលត្រូវការមកសាងសង់វា ។ ហ្គូស្តាវ អាដូហ្វ បានទតមើលដំណើរការសាងសង់កប៉ាល់នោះយ៉ាងដិតដល់ ដោយមានបំណងដើម្បីប្រាកដថាកប៉ាល់ *វ៉ាសា* នឹងបានសម្រេចទាំងស្រុងតាមការរំពឹងរបស់ទ្រង់ ។

បន្ទាប់ពីការសាងសង់បានចាប់ផ្ដើម ហ្គូស្តាវ អាដូហ្វបានបញ្ជាថា កប៉ាល់ *វ៉ាសា* ត្រូវតែធ្វើឲ្យវែង ។ ដោយសារផ្នែកទទឹងនៃកប៉ាល់បានសង់រួចហើយដោយប្រើឈើសែន នោះព្រះរាជាបានបង្គាប់ឲ្យស្ថាបនិកពង្រីកបណ្ដោយរបស់កប៉ាល់ដោយពុំពង្រីកទទឹងរបស់វាឡើយ ។ ទោះបីជាស្ថាបនិកនោះបានដឹងថាការធ្វើបែបនេះនឹងធ្វើឲ្យការធ្វើដំណើររបស់កប៉ាល់ *វ៉ាសា* ចុះខ្សោយក៏ដោយ ក៏ពួកគេស្ទាក់ស្ទើរនឹងប្រាប់ព្រះរាជានោះអំពីអ្វីដែលពួកគេបានដឹង ដែលទ្រង់មិនចង់ជ្រាបឡើយ ។ ពួកគេបានស្ដាប់តាមការបញ្ជា ។ ហ្គូស្តាវ អាដូហ្វ ក៏ប្រកាសផងដែរថា កប៉ាល់នេះពុំមានជាន់ដាក់កាំភ្លើងធំតាមទម្លាប់ធម្មតាទេ ប៉ុន្តែដាក់កាំភ្លើងធំនៅលើជាន់ទាំងបី ដោយដាក់កាំភ្លើងដែលធ្ងន់ជាងគេបំផុតនៅជាន់លើគេបង្អស់ ។ ជាថ្មីម្ដងទៀត ទោះបីជាវាផ្ទុយនឹងការវិនិច្ឆ័យរបស់ខ្លួនក្ដី ស្ថាបនិកនោះបានគោរពតាមបញ្ជា ។

នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៦២៨កប៉ាល់ *វ៉ាសា* បានចាប់ផ្ដើមធ្វើដំណើរជាលើកដំបូងរបស់ខ្លួន ។ បន្ទាប់ពីកប៉ាល់ *វ៉ាសា* បានចាកចេញពីកំពង់ផែ នោះមានខ្យល់បក់យ៉ាងខ្លាំងលើក្ដោងរបស់វា ហើយកប៉ាល់បានចាប់ផ្ដើមផ្អៀង ។ មិនយូរប៉ុន្មាន « កប៉ាល់នោះបានផ្អៀងទៅស្ដាំ ហើយទឹកបានហូរយ៉ាងគំហុកទៅក្នុងកាំភ្លើង រហូតធ្វើឲ្យកប៉ាល់នោះបានលិចចុះបន្តិចម្ដងៗទៅក្នុងបាតសមុទ្រ លិចទាំងក្ដោង និង ទង់ជាតិនិងអ្វីៗទាំងអស់ » ។[1] ការធ្វើដំណើរដំបូងរបស់កប៉ាល់ *វ៉ាសា* គឺបានចម្ងាយប្រហែល ១២៨០ម៉ែត្រ ។

ព្រះរាជបំណងរបស់ហ្គូស្តាវ អាដូហ្វដើម្បីបង្ហាញពីនិមិត្តសញ្ញានៃព្រះចេស្ដាខ្លាំងក្លារបស់ទ្រង់នោះ បានបំផ្លាញកប៉ាល់ក្ដោងដ៏អស្ចារ្យ ដែលជាកប៉ាល់សង្គ្រាមដ៏ខ្លាំងបំផុតនៅសម័យនោះ ។ ភាពស្ទាក់ស្ទើរមិនហ៊ានបើកមាត់និយាយរបស់ស្ថាបនិកសង់កប៉ាល់នោះ — គឺភាពភ័យខ្លាចរបស់ពួកគេចំពោះការមិនសព្វព្រះទ័យរបស់ព្រះរាជា — បានធ្វើឲ្យព្រះរាជាដកខ្លួនចេញពីចំណេះដឹង និង ការយល់ដឹងរបស់ពួកគេ ។ ទាំងអស់គ្នាមានការពាក់ព័ន្ធនឹងការខ្វះនូវការមើលឃើញពីគោលដៅនៃគម្រោងនោះ ៖ ដើម្បីការពារប្រជាជនស៊ុយអែដ និង បំពេញគោលដៅជាអន្តរជាតិរបស់វា ។ កប៉ាល់ដែលព្យាយាមប្រឆាំងនឹងច្បាប់នៃរូបកាយនេះគឺជាទូកសាមញ្ញមួយដែលនឹងមិនអណ្ដែតលើទឹកឡើយ ។





សម្រាប់ពួកយើងដើម្បីកាច់ចង្កូតជីវិតរមែងស្លាប់របស់យើងឲ្យបានជោគជ័យ យើងត្រូវការស្ថេរភាពខាងវិញ្ញាណគ្រប់គ្រាន់ ដើម្បីទប់ទល់នឹងខ្យល់បក់បោក ធ្វើការកាច់ចង្កូតដែលចាំបាច់ ហើយត្រឡប់ទៅកាន់ផ្ទះរបស់ព្រះវរបិតាសួគ៌យើងវិញដោយសុវត្ថិភាព ។ មានរឿងជាច្រើនដែលយើងអាចធ្វើដើម្បីបង្កើនស្ថេរភាពខាងវិញ្ញាណរបស់យើង ។ ខ្ញុំនឹងប្រាប់នូវចំណុចបួន ។

## គោរពតាមព្រះបញ្ញត្តិរបស់ព្រះ

ទីមួយគឺការគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ។ គឺដូចជាកប៉ាល់ *វ៉ាសា* ដែលត្រូវចុះចូលនឹងក្រឹត្យវិន័យនៃរូបកាយ នោះយើងទាំងអស់គ្នាត្រូវចុះចូលទៅនឹងក្រឹត្យវិន័យខាងវិញ្ញាណផងដែរ ។ គ្មាននរណាម្នាក់អាចជៀសផុតបានឡើយ ។ យើងត្រូវតែគោរពធ្វើតាមក្រឹត្យវិន័យខាងវិញ្ញាណទាំងនេះ ដែលយើងហៅថាបទបញ្ញត្តិរបស់ព្រះ ។

ដោយធ្វើតាមក្រឹត្យវិន័យខាងរូបកាយនៅក្នុងការសង់កប៉ាល់ អាចមានអារម្មណ៍ថាមានភាពតានតឹងចំពោះហ្គូស្តាវ ប៉ុន្តែកប៉ាល់ *វ៉ាសា* នឹងពុំលិចពីមុនបេសកកម្មរបស់វាចាប់ផ្តើមឡើយ ប្រសិនបើវាបានគោរពតាមក្រឹត្យវិន័យទាំងនេះ ។ ផ្ទុយទៅវិញ វាមានសេរីភាព និង ភាពអាចបត់បែនបានដើម្បីសម្រេចបាននូវអ្វីដែលវាត្រូវធ្វើ ។

ដូចគ្នានេះផងដែរ ការគោរពតាមក្រឹត្យវិន័យរបស់ព្រះ រក្សានូវសេរីភាព ភាពអាចបត់បែន និង សមត្ថភាពរបស់យើងដើម្បីសម្រេចបាននូវសក្តានុពលរបស់ខ្លួន ។ ព្រះបញ្ញត្តិពុំមែនដើម្បីគាបសង្កត់យើងឡើយ ។ ផ្ទុយទៅវិញ ការគោរពប្រតិបត្តិនាំឲ្យបង្កើតនូវស្ថេរភាពខាងវិញ្ញាណ ហើយមានសុភមង្គលយូរអង្វែរ ។

ការគោរពប្រតិបត្តិគឺជាជម្រើសយើង ។ ព្រះយេស៊ូវមានបន្ទូលថា « មើលចុះ យើងបានប្រទានបញ្ញត្តិទាំងឡាយដល់អ្នករាល់គ្នា ដូច្នេះចូរធ្វើតាមបញ្ញត្តិទាំងឡាយរបស់យើង » ( នីហ្វៃទី ៣ ១៥:១០ ) ។ វាគឺសាមញ្ញណាស់ ។ ចូរធ្វើការសម្រេចចិត្តចុះ ។ សូមសម្រេចចិត្តនៅពេលនេះដើម្បីគោរពប្រតិបត្តិតាមដោយឥតលំអៀង ។ គ្មានអ្វីនឹងអាចបង្កើនស្ថេរភាពខាងវិញ្ញាណបន្ថែមទៀតឡើយ ។ គ្មានអ្វីនឹងផ្តល់សេរីភាពដ៏អស្ចារ្យដល់យើង ឲ្យសម្រេចបាននូវបេសកកម្មនៃជីវិតរបស់យើងឡើយ ។

## ស្តាប់តាមការទូន្មាន និង បន្តរៀនពេញមួយជីវិត

ទីពីរ យើងត្រូវការផ្តោតចិត្តទុកដាក់ ហើយស្តាប់តាមការទូន្មានមកពីប្រភពដែលគួរទុកចិត្ត ហើយប្តេជ្ញាចិត្តដោយខ្លួនយើង ដើម្បីបន្តរៀនពេញមួយជីវិត ។

គ្រោះថ្នាក់មួយនៃការទទួលបានចំណេះដឹងគឺជាអំនួតដែលអាចកើតឡើងនៅពេលយើងគិតថាយើងចេះច្រើនហើយ ថាគ្មានអ្វីទៀតត្រូវរៀនឡើយ ។ យើងបានឃើញការណ៍ទាំងនេះនៅក្នុងមនុស្សជាច្រើន ដែលពឹងផ្អែកយ៉ាងខ្លាំងលើប្រាជ្ញាផ្ទាល់របស់ខ្លួន ។ វាពិតជាលំបាកដើម្បីបង្រៀនដល់អ្នកដែលគិតថាខ្លួនឯងចេះអ្វីៗគ្រប់យ៉ាងទាំងអស់ ។

ដោយដឹងពីការណ៍នេះ និង មានបំណងបន្តរៀនពេញមួយជីវិតនោះប្រធាន ហិនរី ប៊ី អាវិង ជាទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ថា « ខ្ញុំនៅតែមានអ្វីជាច្រើនដើម្បីរៀន ។ មនុស្សគ្រប់គ្នាអាចបង្រៀនខ្ញុំនូវអ្វីជាច្រើន » ។[២] នៅពេលគាត់បានផ្តល់ការហៅខ្ញុំឲ្យធ្វើជាអ្នកមានសិទ្ធិអំណាចទូទៅ ប្រធាន អាវិងបានបង្រៀនខ្ញុំនូវមេរៀនសំខាន់មួយ ។ លោកបានមានប្រសាសន៍ថា នៅពេលលោកស្តាប់នរណាម្នាក់ប្រាប់រឿងមួយដែលលោកធ្លាប់បានស្តាប់ពីមុន ឬ ប្រាប់ខគម្ពីរដែលគាត់ស្គាល់ច្បាស់ហើយ នោះគាត់សួរខ្លួនឯងថា « ហេតុអ្វីបានជាព្រះអម្ចាស់សង្កត់ធ្ងន់ពីចំណុចនេះដល់ខ្ញុំ ? » និង « តើខ្ញុំពុំទាន់បានរៀនអ្វីខ្លះពីរឿង ឬ ខគម្ពីរនោះ ? » ប្រសិនបើយើងចង់បង្កើនស្ថេរភាពខាងវិញ្ញាណរបស់យើង នោះយើងនឹងមានឆន្ទៈដើម្បីរៀន ហើយបន្ទាបខ្លួនគ្រប់គ្រាន់ដើម្បីទទួលយកការណែនាំពុំថាយើងមានអាយុ ឬ បទពិសោធន៍ប៉ុណ្ណានោះឡើយ ។

វាពិតជាជម្រើសរបស់យើង ។ យើងអាចស្តាប់ ហើយស្តាប់តាមការទូន្មានដែលបានផ្តល់ដល់យើងដោយអ្នកដឹកនាំសាសនាចក្រ ជាពិសេសអស់អ្នកដែលយើងគាំទ្រថា ព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ តាមរយៈឪពុកម្តាយ និង តាមរយៈមិត្តភក្តិដែលទុកចិត្ត — ឬក៏មិនស្តាប់តាម ។ យើងអាចព្យាយាមដើម្បីបន្តរៀនពេញមួយជីវិតនេះ — ឬក៏មិនចង់រៀន ។ យើងអាចបង្កើនស្ថេរភាពខាងវិញ្ញាណរបស់យើង — ឬមិនបង្កើន ។ ប្រសិនបើយើងពុំបង្កើនស្ថេរភាពខាងវិញ្ញាណរបស់យើងទេ នោះយើងនឹងក្លាយដូចជាកប៉ាល់ *វ៉ាសា* — គឺជាកប៉ាល់ដែលនឹងមិនអណ្តែតទឹកឡើយ ។









រូប និង រូបថតនៃកប៉ាល់ © LUBLUBACHKA/THINKSTOCK, MICHELEBOLERO/THINKSTOCK, DAVID HARDING/THINKSTOCK

## បម្រើអ្នកដទៃ

ទីបី កិច្ចខិតខំរបស់យើងជួយដល់មនុស្សដទៃ ការខ្វល់ខ្វាយពីមនុស្សដទៃ និងការបម្រើមនុស្សដទៃបង្កើនស្ថេរភាពខាងវិញ្ញាណរបស់យើង ។

ភាពអស់កល្បជានិច្ចស្ថិតនៅយ៉ាងច្បាស់ នៅពេលយើងផ្ដោតលើមនុស្សដទៃ នៅពេលយើងព្យាយាមជួយដល់កូនចៅរបស់ព្រះវរបិតាសួគ៌ ។ ខ្ញុំបានឃើញថាវាកាន់តែងាយស្រួលជាង ដើម្បីទទួលការបំផុសគំនិត នៅពេលខ្ញុំកំពុងអធិស្ឋានដើម្បីស្វែងរកបៀបដែលខ្ញុំអាចជួយនរណាម្នាក់ ជាងនៅពេលខ្ញុំអធិស្ឋានយ៉ាងសាមញ្ញសម្រាប់ខ្លួនខ្ញុំ ។

យើងអាចជឿថានៅពេលណាមួយនាគ្រាខាងមុខ នោះយើងនឹងមានស្ថានភាពដ៏ល្អប្រសើរជាងនេះដើម្បីជួយមនុស្សដទៃ ។ តាមពិតទៅ នេះគឺជាពេលវេលានោះហើយ ។ យើងនឹងខុស ប្រសិនបើយើងគិតថាវានឹងកាន់តែងាយស្រួល នៅពេលយើងមានពេលច្រើន លុយច្រើន ឬ មានអ្វីៗផ្សេងទៀតជាច្រើនដើម្បីបម្រើមនុស្សដទៃ ។ ដោយពុំគិតពីកាលៈទេសៈណាឡើយ នោះយើងមានជម្រើស ។ តើយើងនឹងជួយមនុស្សដទៃ ឬ ក៏អត់ជួយ ? យើងបានបរាជ័យនូវការសាកល្បងដ៏សំខាន់នៃជីវិតរមែងស្លាប់នេះ ប្រសិនបើយើងពុំជ្រើសរើសដើម្បីជួយដល់អស់អ្នកដែលត្រូវការជំនួយនោះ ។ ហើយប្រសិនបើយើងជួយ នោះយើងបង្កើនស្ថេរភាពខាងវិញ្ញាណផ្ទាល់របស់យើង ។

## ធ្វើឲ្យព្រះយេស៊ូវគ្រីស្ទក្លាយជាគ្រឹះរបស់យើង

ទីបួន និងជាទីបញ្ចប់ ហើយជាចំណុចសំខាន់បំផុត ស្ថេរភាពខាងវិញ្ញាណរបស់យើងកើនឡើងនៅក្នុងចំណែកនៃកម្រិតដែលយើងស្ថាបនាព្រះយេស៊ូវគ្រីស្ទជាគ្រឹះរបស់យើង ។

ប្រសិនបើគ្មានព្រះគ្រីស្ទទេ យើងនឹងត្រូវបានបោកបក់ដូចជានាវាដែលនៅលើទឹករលកដែរ ។ យើងគ្មានអំណាចដោយសារយើងគ្មានក្ដោង ។ យើងគ្មានស្ថេរភាពឡើយ ជាពិសេសនៅក្នុងគ្រានៃព្យុះដោយសារយើងគ្មានយុថ្កាឡើយ ។ យើងគ្មានទិសដៅ ឬ គោលបំណងឡើយ ដោយសារយើងគ្មានចង្កូតកាច់នោះឡើយ ។ យើងត្រូវធ្វើឲ្យព្រះគ្រីស្ទក្លាយជាគ្រឹះរបស់យើង ។

ដើម្បីប្រឈមមុខ យកឈ្នះ និង រៀបចំខ្លួនជាស្រេច សម្រាប់ខ្យល់ព្យុះនៃជីវិត នោះយើងត្រូវតែគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ចេះបន្ទាបខ្លួន មានឆន្ទៈ ហើយប្ដេជ្ញាចិត្តបន្តរៀនពេញមួយជីវិត បម្រើមនុស្សដទៃ ហើយស្ថាបនាព្រះយេស៊ូវគ្រីស្ទធ្វើជាគ្រឹះនៃជីវិតរបស់យើង ។ នៅពេលយើងធ្វើបែបនោះ យើងបង្កើនស្ថេរភាពខាងវិញ្ញាណរបស់យើង ។ មិនដូចជាកប៉ាល់ *វ៉ាសា* ឡើយ នោះយើងនឹងអាចត្រឡប់ទៅច្រាំងវិញដោយសុវត្ថិភាព ដោយបំពេញនូវជោគវាសនារបស់យើង ។ ■

*ដកស្រង់ចេញពីការប្រជុំធម្មនិដ្ឋាននៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ធ្វើឡើងនៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៤ ។ ចំពោះអត្ថបទទាំងមូលជាភាសាអង់គ្លេសសូមចូលទៅកាន់គេហទំព័រ speeches.byu.edu*។

កំណត់ចំណាំ

1. លិខិតមកពីក្រុមប្រឹក្សា នៃព្រះរាជាណាចក្រស៊ុយអែដទៅដល់ព្រះរាជា ហ្គូស្តាវទី II អាដូហ្វ ការបកប្រែត្រូវបានដកស្រង់នៅក្នុង រីឆាដ អូ ម៉ាសុន « The *Vasa* Capsizes » virtualschool.edu/mon/CaseStudies/Vasa/vasa.html ។ នៅមានដំណើររឿងជាច្រើនអំពីកប៉ាល់ *វ៉ាសា* ឧទាហរណ៍សូមមើល vasamuseet.se/en សម្រាប់ប្រវត្តិនៃរឿងនេះ និង តំណភ្ជាប់ដទៃទៀត ។
2. ហិនរី ប៊ី អាវិង នៅក្នុង រ៉ូបឺត អិល អ៊ីតុន និង ហែនរី ជេ អាវិង *I Will Lead You Along ៖ The Life of Henry B. Eyring* ( ឆ្នាំ ២០១៣ ) ទំព័រទី ៤០៩ ។

# រៀនលេងទំនុកតម្កើងមួយបទ *ក្នុងរយៈពេល ១០នាទី !*

**បានចងក្រង និង កែសម្រួលដោយ ដានីយ៉ែល ខាធើរ**
ផ្នែកតន្ត្រី និង សិល្បៈវប្បធម៌សាសនាចក្រ

ប្រសិនបើអ្នកពុំធ្លាប់លេងព្យាណូពីមុន ប៉ុន្តែតែងតែមានចិត្តចង់លេងនោះ នេះគឺជាឱកាសរបស់អ្នកហើយ ។ អ្វីដែលអ្នកត្រូវការនោះគឺព្យាណូ ។ ប្រសិនបើអ្នកគ្មានព្យាណូនៅផ្ទះទេនោះ អ្នកអាចយកអត្ថបទនេះទៅជាមួយអ្នកនៅកន្លែងណាដែលមានព្យាណូដើម្បីចាប់ផ្ដើមការរៀន ។

មេរៀននេះមានភាពសាមញ្ញ ហើយងាយស្រួលដែលអ្នកនឹងអាចលេងទំនុកតម្កើងមួយបានពេលរៀនមេរៀននេះចប់ ។ តាមពិតទៅអ្នកអាចលេងទំនុកបទនៃទំនុកតម្កើងនៅក្នុងមេរៀននេះបានក្នុងរយៈពេល ១០នាទី !

ត្រៀមខ្លួនហើយឬនៅ ? តោះសូមចាប់ផ្ដើម !



រូបគំនូរដោយ ជេម៉ស ហាបឺន

## ត្រៀមខ្លួនដើម្បីលេងព្យាណូ

១. នៅពេលអ្នកអង្គុយនៅតុព្យាណូ ហើយដាក់ម្រាមដៃរបស់លើខ្ទង់ចុច សូមរំកិលកៅអីអង្គុយឲ្យឆ្ងាយល្មម ប្រយោជន៍ឲ្យកែងដៃរបស់អ្នករៀងកោងបន្តិច ។
២. អង្គុយនៅចំកណ្ដាលកៅអី នៅឲ្យចំកណ្ដាលព្យាណូ ។
៣. អង្គុយឲ្យត្រង់ខ្លួននៅលើគែមមុខនៃកៅអី ហើយឈ្ងោកទៅមុខ ។
៤. ដាក់ជើងរបស់អ្នកនៅលើកម្រាល ។
៥. អង្គុយឲ្យស្រួល រក្សាជំហរខ្លួន ។
៦. សូមប្រាកដថាមានពន្លឺគ្រប់គ្រាន់ល្មមសម្រាប់អ្នកមើលឃើញអក្សរភ្លេង និងខ្ទង់ព្យាណូ ។



៧. សូមឈរ ។ សូមដាក់ដៃរបស់អ្នក ចុះស្របដងខ្លួនទាំងសងខាង ហើយសំយ៉ុងវាចុះឲ្យស្រួល ។ សូមកត់សម្គាល់ពីភាពកោងរបស់ដៃអ្នក ដូចជាអ្នកកំពុងតែកាន់បាល់ ។ នៅពេលអ្នកអង្គុយម្ដងទៀត សូមដាក់ម្រាមដៃរបស់អ្នកលើខ្ទង់ព្យាណូ ដោយទុកវាឲ្យនៅកោងតាមធម្មជាតិ ។

៨. សូមដាក់ដៃរបស់អ្នកលើខ្ទង់ព្យាណូ ដោយឲ្យម្រាមដៃរបស់អ្នកប៉ះក្បែរចំណុចកណ្ដាលនៃតំបន់ដ៏ធំនៅលើខ្ទង់ពណ៌ស ។ សូមដាក់បាតដៃរបស់អ្នកលើខ្ទង់ព្យាណូ ប៉ុន្តែកុំសង្កត់វាលើខ្ទង់ព្យាណូ ឬលើបន្ទះឈើខាងក្រោមខ្ទង់នោះឡើយ ។

៩. សូមចុចខ្ទង់ព្យាណូដោយចុងម្រាមដៃរបស់អ្នកគឺនៅពីក្រោមចុងម្រាមរបស់អ្នក ។ សូមរក្សាម្រាមដៃនិមួយៗឲ្យនៅកោង ដោយលើកវាឡើងពីក្រញ៉ូវដៃលើខ្នងដៃរបស់អ្នក ។ នៅពេលអ្នកចុចខ្ទង់ព្យាណូ សូមរក្សាសន្លាក់ម្រាមដៃរបស់អ្នកឲ្យកោង ។




**ការលេងដោយប្រើលេខនៃម្រាមដៃ**

ដើម្បីជួយអ្នកឲ្យដាក់ម្រាមដៃត្រឹមត្រូវលើខ្ទង់និមួយៗ នោះម្រាមដៃត្រូវបានដាក់លេខឲ្យដូចដែលបានបង្ហាញខាងក្រោមនេះ ។ លេខនៃម្រាមដៃត្រូវបានសរសេរនៅជាប់នឹងអក្សរភ្លេងនៅលើទំព័រនេះ ។

សូមដាក់ដៃរបស់អ្នកពីលើក្រុមមួយណាក៏បានដែលមានខ្ទង់ប្រាំ ដោយដាក់ម្រាមដៃមួយលើខ្ទង់មួយនៃព្យាណូ ។ សូមអនុវត្តលេខនៃម្រាមដៃដោយលេងខ្ទង់ព្យាណូជាមួយនឹងម្រាមដៃត្រឹមត្រូវដូចបានបង្ហាញ ។ អក្សរភ្លេងដែលមានទងឡើងទៅលើគឺសម្រាប់ប្រើដៃស្ដាំលេង ។ អក្សរភ្លេងដែលមានទងចុះក្រោមគឺសម្រាប់ប្រើដៃឆ្វេងលេង ។




**លេងបទ « មានភ្នំខៀវមួយនៅដ៏សែនឆ្ងាយ »**

ដាក់ដៃរបស់អ្នកនៅលើខ្ទង់ព្យាណូដូចបង្ហាញខាងក្រោម ។

សូមប្រើខ្ទង់ព្យាណូដែលមានពីរខ្ទង់ និង ខ្ទង់ព្យាណូខ្មៅបី ដើម្បីជួយអ្នកឲ្យរកឃើញនូវទីតាំងត្រឹមត្រូវ ។

សូមលេងទំនុកតម្កើងនេះ ដោយលេងតាមលេខនៃម្រាមដៃដូចដែលបានបង្ហាញ ។ អក្សរភ្លេងដែលមានទងឡើងទៅលើគឺសម្រាប់ប្រើដៃស្ដាំលេង ហើយអក្សរភ្លេងដែលមានទងចុះក្រោមគឺសម្រាប់ប្រើដៃឆ្វេងលេង ។ សូមអនុវត្តទំនុកតម្កើងនេះរហូតដល់អ្នកចេះលេងវា ។ សូមប្រើគោលការណ៍នានានៃបច្ចេកទេសដាក់ម្រាមដៃឲ្យបានល្អដែលមានរៀបរាប់នៅបញ្ជីចំណុចទាំងប្រាំបួន ។

ឥឡូវនេះអ្នកត្រូវបានណែនាំឲ្យលេងព្យាណូ ហើយបានរៀននូវទំនុកតម្កើងដ៏សាមញ្ញ ។ ដើម្បីលេងទំនុកតម្កើងផ្សេងទៀត អ្នកត្រូវតែរៀនពីគោលការណ៍គ្រឹះមួយចំនួនអំពីចង្វាក់ សាច់ភ្លេង និង អក្សរភ្លេង ។

នេះគឺជាផ្នែកដ៏សំខាន់បំផុត ៖ មេរៀនដែលអ្នកទើបតែរៀននេះគឺជាមេរៀនដំបូងនៅក្នុងវគ្គសិក្សាព្យាណូរបស់សាសនចក្រ ដែលមានជាប្រាំមួយភាសាមកពីស្ថាប័នចែកចាយសាសនាចក្រ ។[1] ភាពងាយស្រួលដើម្បីធ្វើតាមផែនការនៃសេចក្ដីណែនាំជួយអ្នកឲ្យរៀនដោយខ្លួនឯង ឬ ជាក្រុម ។ អ្នកអាចប្រមូលក្រុមគ្រួសារទាំងមូលរបស់អ្នកឲ្យរៀនលេងព្យាណូទាំងអស់គ្នានៅក្នុងសកម្មភាពរាត្រីជួបជុំក្រុមគ្រួសារ ។ វគ្គសិក្សានេះអាចបញ្ចប់ក្នុងរយៈពេលប្រាំមួយសប្ដាហ៍ ។

ការសិក្សាជាច្រើនបង្ហាញថា ការរៀនតន្ត្រីដោយខ្លួនឯងជួយកែលម្អការផ្ដោតចិត្តទុកដាក់របស់សិស្ស មានការអប់រំដ៏ល្អឧត្ដុងឧត្ដម និង មានជំនាញចេះគិតគូរ ។[2]

តាមរយៈការរៀនជំនាញតន្ត្រី នោះយើងអភិវឌ្ឍទេពកោសល្យដែលព្រះអម្ចាស់បានប្រទានដល់យើង បង្កើនចំណេះដឹងរបស់យើង ហើយរៀនពីរបៀបផ្សេងៗជាច្រើនដែលយើងអាចប្រើចំណេះ និង ទេពកោសល្យរបស់យើងដើម្បីស្ថាបនានគររបស់ទ្រង់ ។ ■




**កំណត់ចំណាំ**

១. ដើម្បីបញ្ជាទិញកញ្ចប់វគ្គសិក្សាព្យាណូ សូមចូលទៅគេហទំព័រ store.lds.org ។

២. សូមមើល ឡារ៉ាលើរីស ប្រោន « The Benefits of Music Education » pbs.org ជេសីការ វេឡាស្កូ « How the Arts Can Help Students Excel » the Science of Learning Blog ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ scilearn.com/blog/how-arts-help-students-excel « Music Helps Children Learn Maths » *The Telegraph* ថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០១២ telegraph.co.uk ។

# បានតាំងចិត្តដើម្បី **ឈប់**

*ជំនាញលេងព្យាណូរបស់ខ្ញុំពុំបានប្រសើរឡើងសោះទោះបីបន្ទាប់ពីអនុវត្តអស់ជាច្រើនឆ្នាំក្តី ។ ឪពុកម្តាយខ្ញុំបានប្រាប់ខ្ញុំថាខ្ញុំអាចឈប់បានប៉ុន្តែមានលក្ខខណ្ឌមួយ ៖ ខ្ញុំត្រូវតែរៀនឲ្យបាន៥០បទនៃបទទំនុកតម្កើង ។*

ដោយ ហ្វែតជិន ប្លាកបើន

ខ្ញុំខឹងយ៉ាងខ្លាំង ហើយបានរត់ចូលទៅក្នុងផ្ទះរបស់ខ្ញុំ ទាំងយំយ៉ាងខ្លាំង បន្ទាប់ពីការខកចិត្តមួយទៀតជាមួយនឹងការរៀនព្យាណូ ។ វាគឺជាឆ្នាំទីបួននៃការរៀនលេងព្យាណូរបស់ខ្ញុំ ហើយខ្ញុំ អាចលេងបទចម្រៀងកុមារតែបទស្រួលៗប៉ុណ្ណោះ ។ គ្រូបង្រៀនរបស់ខ្ញុំបានព្យាយាមស្វែងរកពាក្យវិជ្ជមានដើម្បីនិយាយអំពី ការលេងព្យាណូដ៏អន់របស់ខ្ញុំ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍មិនល្អសោះ ។ ឪពុកម្តាយខ្ញុំបានចំណាយប្រាក់សម្រាប់ការរៀនព្យាណូដែលខ្ញុំមិនចង់រៀន ហើយពុំសង្ឃឹមចង់លេងឡើយ ។

ខ្ញុំចង់ឲ្យឪពុកម្តាយរបស់ខ្ញុំប្រាប់ខ្ញុំឲ្យឈប់លេង ។ ខ្ញុំបានអង្វរ ថា « សូមមេត្តាឲ្យកូនឈប់លេងទៅ » ។ « កូននឹងធ្វើអ្វីគ្រប់យ៉ាង ។ តើធ្វើដូចម្តេចទើបពុកម៉ែឲ្យខ្ញុំឈប់ ? »

បន្ទាប់ពីពិភាក្សាវាជាមួយពួកគាត់មក ពួកគាត់បាននិយាយថា « ប្រសិនបើកូនរៀនចេះ៥០បទនៃបទទំនុកតម្កើង នោះពុកម៉ែនឹងអនុញ្ញាតឲ្យកូនឈប់ » ។

ខ្ញុំបានចាប់ផ្តើមអនុវត្តវាភ្លាម ។ ខ្ញុំចង់ឈប់លេងយ៉ាងខ្លាំង ដូច្នោះខ្ញុំបានប្តេជ្ញាចិត្តចំណាយពេលបន្ថែមទៀតលេងព្យាណូ ។ ទំនុកតម្កើងទីមួយ « យើងអរគុណទ្រង់ចំពោះព្យាការី » ( *ទំនុកតម្កើង* លេខ ១០ ) ចំណាយពេលជិតមួយខែទើបអាចលេងបានស្ទាត់ ។ ខ្ញុំនៅតែមានបំណងឈប់លេង ដូច្នោះខ្ញុំបានបន្តហាត់លេងវារហូត ។

មានរឿងមួយគួរឲ្យចាប់អារម្មណ៍បានកើតឡើង ៖ ទំនុកតម្កើងនានាបានធ្វើឲ្យខ្ញុំលេងស្ទាត់យ៉ាងងាយស្រួល ។ ខ្ញុំមានអារម្មណ៍រីករាយខ្លាំងជាងមុនពេញមួយសប្តាហ៍ ។ ខ្ញុំបានឃើញថាខ្លួនខ្ញុំបានច្រៀងរហឹមៗនូវទំនុកតម្កើងនានាអំឡុងពេលថ្ងៃ ហើយច្រៀងវាយ៉ាងឮៗនៅក្នុងការប្រជុំសាក្រាម៉ង់ ។

ទីបំផុត ខ្ញុំបានឈប់តាមដានថាខ្ញុំចេះបានប៉ុន្មានបទហើយ ។ នៅពេលខ្ញុំបានលេងព្យាណូកាន់តែស្ទាត់ជំនាញ ខ្ញុំបានដឹងថាខ្ញុំអាចលេងទំនុកតម្កើងថ្មីមួយស្ទើរតែបានល្អឥតខ្ចោះក្នុងរយៈពេលតិចជាង ៣០នាទី ។

ទីបំផុតនៅពេលខ្ញុំបានបានបូកសរុបបទទាំងនោះចូលគ្នា នោះខ្ញុំបានដឹងថាវាមានច្រើនជាង៥០បទទៅទៀត ។ ហើយគ្មានផ្លូវទេដែលខ្ញុំនឹងឈប់លេងព្យាណូនោះ ។ ខ្ញុំប្រែជាមានទំនុកចិត្តកាន់តែច្រើនឡើងៗនៅក្នុងសមត្ថភាពរបស់ខ្ញុំដើម្បីលេង ហើយមានអារម្មណ៍ពីអំណាចនៃទំនុកតម្កើងនៅក្នុងជីវិតរបស់ខ្ញុំ ។

ទំនុកតម្កើងគឺដូចជាព្រះគម្ពីរដែរ វាប្រាប់ពីសេចក្តីពិត ។ នៅពេលខ្ញុំលេងបទទំនុកតម្កើង នោះខ្ញុំមានអារម្មណ៍ថាខ្ញុំកំពុងមុជខ្លួនរបស់ខ្ញុំទាំងស្រុងទៅក្នុងព្រះគម្ពីរ ។ ការរៀនពីរបៀបលេងទំនុកតម្កើងបានជួយខ្ញុំដើម្បីស្តាបនាទីបន្ទាល់ និង រៀនពីសេចក្តីពិត ។ ខ្ញុំឃើញថា ខ្លួនខ្ញុំបានបណ្តែតអារម្មណ៍ទៅតាមពាក្យពេចន៍នានានៃទំនុកតម្កើងផ្សេងៗនោះ ជួយខ្ញុំពេញមួយជីវិតខ្ញុំ ។ ការលេងព្យាណូបានពង្រឹងទីបន្ទាល់របស់ខ្ញុំ ហើយបានផ្តល់ឱកាសនានាដល់ខ្ញុំទោះជាខ្ញុំទៅទីណាក៏ដោយ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋនូវ យ៉ោក ស.រ.អា. ។*



# ការភ័យរន្ធត់ ភាពទុក្ខព្រួយ និង ផែនការរបស់ព្រះ

*តាមរយៈបទពិសោធន៍នៃ **ភាពហិចហោចដ៏ខ្លាំងបំផុត** នៃជីវិតរបស់ខ្ញុំ ឥឡូវនេះខ្ញុំដឹងថា **ព្រះវរបិតាសួគ៌បានគង់នៅជាមួយខ្ញុំ** គ្រប់ពេលទាំងអស់ ។*

ដោយ ប៉ោឡា កាដូពី

កាលពីព្រឹកព្រលឹមនៅក្នុងឆ្នាំ ២០០៨ នៅពេលម្ដាយរបស់ខ្ញុំបានដាស់ខ្ញុំឲ្យក្រោកឡើងដើម្បីទៅសាលារៀន ។ ខ្ញុំមានក្ដីរីករាយណាស់នាព្រឹកនោះ ប៉ុន្តែខ្ញុំពុំដឹងថាវាបានប្រែទៅជាថ្ងៃដ៏អាក្រក់បំផុតនៅក្នុងជីវិតរបស់ខ្ញុំ ឬ ជាពេលចុងក្រោយដែលខ្ញុំបាននៅជាមួយម្ដាយខ្ញុំឡើយ ។ ខ្ញុំពុំទាន់បានរៀនចប់ម៉ោងឡើយនៅថ្ងៃនោះ ដោយសារមិត្តរបស់គ្រួសារយើងបានមកទទួលខ្ញុំពីសាលា ហើយប្រាប់ខ្ញុំថាម្ដាយរបស់ខ្ញុំបានសម្លាប់ខ្លួន ។ ខ្ញុំមានអាយុតែ ១២ឆ្នាំប៉ុណ្ណោះ ។

ខ្ញុំបានគិតថា « តើខ្ញុំអាចរស់នៅដោយគ្មានម្ដាយខ្ញុំយ៉ាងដូចម្ដេច ? » គាត់គឺជាមិត្តដ៏ល្អបំផុតរបស់ខ្ញុំ ។

ខ្ញុំបានសោកសៅអស់ពេល ជាច្រើនខែ ។ ខ្ញុំពុំចង់ទៅសាលារៀនទេ ដោយសារក្មេងដទៃទៀតបានប្រព្រឹត្តដាក់ខ្ញុំខុសពីមុន ហើយមានអារម្មណ៍សោកស្ដាយចំពោះខ្ញុំ ។ ខ្ញុំពុំដឹងអ្វីដែលខ្ញុំគួរតែធ្វើឡើយ ខ្ញុំគ្រាន់តែបានដឹងថា ខ្ញុំត្រូវតែមានចិត្តរឹងមាំសម្រាប់មនុស្សគ្រប់គ្នា ។

នាថ្ងៃមួយ ប្រាំ ឬ ប្រាំមួយខែ បន្ទាប់ពីមរណភាពរបស់ម្ដាយខ្ញុំ នោះខ្ញុំបាននៅតែម្នាក់ឯងនៅក្នុងបន្ទប់ខ្ញុំក្បែរបង្អួច ទាំងយំ ដោយព្យាយាមដើម្បីយល់ពីគោលបំណងរបស់ខ្ញុំនៅលើផែនដីនេះ ។ ភ្លាមនោះខ្ញុំបានស្ដាប់ឮសំឡេងមួយនៅក្នុងចិត្តខ្ញុំ ៖ « អ្នកគឺជាបុត្រីរបស់យើង យើងនឹងមិនឲ្យអ្នករងទុក្ខឡើយ » ។ ខ្ញុំដឹងថា នោះជាសំឡេងរបស់ព្រះ ។ ប៉ុន្តែខ្ញុំមានភាពភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយសារខ្ញុំពុំបានជឿលើទ្រង់ទៀតឡើយ ជាពិសេសចាប់តាំងពីខ្ញុំបានមានអារម្មណ៍ថា គឺ ព្រះជាអ្នកដែលបានឆក់យកជីវិតរបស់ម្ដាយខ្ញុំ ។ ទោះបីជាខ្ញុំពុំដឹងពីអត្ថន័យដែលទ្រង់មានព្រះបន្ទូលក្ដី ខ្ញុំមានអារម្មណ៍សុវត្ថិភាពក្នុងចិត្តខ្ញុំ ។

បីឆ្នាំក្រោយមកខ្ញុំបានទៅទីក្រុង រ៉ូម ប្រទេសអ៊ីតាលី ដើម្បីទៅសួរសុខទុក្ខឪពុកមារបស់ខ្ញុំ ។ គាត់បានប្រាប់ខ្ញុំដដែលអំពីសាសនាចក្រនេះដែលគាត់បានចូលរួម ។ នៅថ្ងៃអាទិត្យមួយ គាត់បាននាំខ្ញុំទៅជាមួយគាត់ ។ ខ្ញុំចាំជានិច្ចពីការដើរទៅតាមទ្វារព្រះវិហារ នាលើកដំបូង ហើយទទួលអារម្មណ៍នៃក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ នៅពេលខ្ញុំបានទៅក្នុងព្រះវិហារ ខ្ញុំមានអារម្មណ៍ថាវាដូចជាផ្ទះរបស់ខ្ញុំអញ្ចឹង ។

ខ្ញុំបានចាប់ផ្ដើមទៅព្រះវិហាររៀងរាល់សប្ដាហ៍ និង ទៅគ្រប់សកម្មភាពទាំងអស់ក្នុងអំឡុងថ្ងៃនៃសប្ដាហ៍ ។ ខ្ញុំចូលចិត្តនៅជាមួយយុវវ័យនៃសាសនាចក្រ ។ ពួកគេធ្វើឲ្យខ្ញុំមានភាពរីករាយជាងមុន ។ ពួកគេបានគិត ហើយជឿនូវរឿងដូចគ្នាដែលខ្ញុំបានជឿ ។ បីខែក្រោយមក វិស្សមកាលរដូវក្ដៅរបស់ខ្ញុំបានចប់ ហើយខ្ញុំត្រូវត្រឡប់ទៅប្រទេសអាល់បានីវិញ ។

នៅពេលខ្ញុំត្រឡប់ទៅផ្ទះវិញ ខ្ញុំបានប្រាប់ឪពុកខ្ញុំពីអារម្មណ៍ដែលខ្ញុំបានមាន និង ក្ដីអំណរយ៉ាងខ្លាំងដែលខ្ញុំមានអំឡុងពេលនោះ ។ គាត់មិនចូលចិត្តវាទេ ។ គាត់បានប្រាប់ខ្ញុំ ថា គាត់ពុំអនុញ្ញាតឲ្យខ្ញុំបន្តទៅព្រះវិហារ ឬ រៀនពីព្រះវិហារនេះទៀតឡើយ ។ ដូច្នេះខ្ញុំត្រូវរង់ចាំដោយអំណត់រយៈពេលបីឆ្នាំទៀតរហូតដល់ខ្ញុំឈានដល់អាយុ ១៨ឆ្នាំ ។ បន្ទាប់មកខ្ញុំអាចសម្រេចចិត្តដោយខ្លួនឯង ហើយទទួលបុណ្យជ្រមុជទឹក ។

អំឡុងពេលនោះខ្ញុំត្រូវបានប្រទានពរ ដោយមានមនុស្សជាច្រើន ដែលបានប្រាប់ខ្ញុំអំពីអ្វីដែលពួកគេបានរៀនរាល់សប្ដាហ៍នៅព្រះវិហារ ។ មានម្នាក់ឈ្មោះស្ទេហ្វានី ។ នាងបានធ្លាប់រស់នៅក្នុងប្រទេសអ៊ីតាលី នៅពេលឪពុកមារបស់ខ្ញុំបានចូលរួមសាសនាចក្រ ប៉ុន្តែនាងបានត្រឡប់ទៅផ្ទះរបស់នាងវិញនៅសហរដ្ឋ ។ ឪពុកមារបស់ខ្ញុំបានគិតថា វាជាការណ៍ល្អសម្រាប់ពួកយើងដើម្បីសរសេរសំបុត្រឲ្យគ្នាទៅវិញទៅមក ដូច្នោះខ្ញុំបានបញ្ជូលនាងធ្វើជាមិត្តរបស់ខ្ញុំលើហ្វេសប៊ុក ។

ទោះបីជាយើងពុំដែលបានជួបគ្នាផ្ទាល់ក្ដី ខ្ញុំមានអំណរគុណជានិច្ចចំពោះនាងដែលបានជួយខ្ញុំឲ្យស្គាល់បនាសេចក្ដីជំនឿរបស់ខ្ញុំ ហើយរៀនបន្ថែមទៀត

អំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ នាងបានសរសេរសំបុត្រមកខ្ញុំស្ទើរតែរាល់សប្ដាហ៍ ហើយបានប្រាប់ខ្ញុំពីអ្វីដែលនាងបានរៀននៅព្រះវិហារ ហើយបានឆ្លើយសំណួរនានារបស់ខ្ញុំ ។ នាងគឺជាមិត្តដ៏ល្អបំផុតរបស់ខ្ញុំ ។

ទីបំផុត បន្ទាប់ពីក្ដីអំណត់ជាច្រើនឆ្នាំក្រោយមក នោះខ្ញុំបានជ្រមុជទឹកគឺតែពីរថ្ងៃប៉ុណ្ណោះបន្ទាប់ពីថ្ងៃកំណើតរបស់ខ្ញុំគម្រប់អាយុ ១៨ឆ្នាំ ។ ហើយមិនយូរប៉ុន្មាន ខ្ញុំនឹងចែករំលែកនូវសុភមង្គលនេះជាមួយម្ដាយខ្ញុំ នូវអារម្មណ៍ដែលខ្ញុំមាននូវថ្ងៃនោះ ដោយសារខ្ញុំនឹងជ្រមុជទឹកឲ្យគាត់ ។ ខ្ញុំដឹងថាគាត់នឹងមានមោទនភាពចំពោះជីវិតដែលខ្ញុំបានជ្រើសយកនេះ ។

ខ្ញុំមានអារម្មណ៍ថាបានទទួលពរពីព្រះវរបិតាសួគ៌ ដោយសារទ្រង់បានគង់នៅជាមួយខ្ញុំ ក្នុងដំណើរជីវិតរបស់ខ្ញុំទាំងមូលតាមរបៀបជាច្រើន ។ ខ្ញុំត្រូវតែចាំ ហើយមានចិត្តអំណត់ដោយសារទ្រង់មានផែនការសម្រាប់ខ្ញុំ ។ ទ្រង់គឺជាអង្គដែលបានប្រទានកម្លាំងដល់ខ្ញុំឲ្យឆ្លងកាត់នូវឧបសគ្គទាំងអស់ដែលខ្ញុំបានជួប ។ ទ្រង់តែងតែគង់នៅជាមួយខ្ញុំហើយជួយខ្ញុំឲ្យកាន់តែរីករាយជានិច្ច ។ ■

*អ្នកនិពន្ធរស់នៅក្នុង ប្រទេសអាល់បានី ។*

រូបគំនូរ ដោយ ជេរ៉េ យើរីដេស





ដោយ អែលឌើរ
ចូសេ អេ តិក្សសៃរ៉ា
នៃពួកចិតសិបនាក់




# ទោះបីជាអ្នក អៀនខ្មាស ក៏ដោយ

*សូមទុកចិត្តលើព្រះអម្ចាស់ ហើយទ្រង់នឹងប្រទានពរដល់អ្នក នៅក្នុងកិច្ចខិតខំរបស់អ្នក ដើម្បីចែកចាយដំណឹងល្អ ។*

កាលខ្ញុំជាប្រធានបេសកកម្មថ្មីនៅក្នុងប្រទេសប្រេស៊ីល ខ្ញុំសម្ភាសអែលឌើរមួយចំនួន ។ ខ្ញុំបានសុំឲ្យអែលឌើរម្នាក់ណែនាំខ្លួនឲ្យខ្ញុំស្គាល់ ។

គាត់បានពោលថា « ខ្ញុំមានការអៀនខ្មាសណាស់ » ។ គាត់បានបារម្ភថា ភាពអៀនខ្មាសរបស់ខ្លួន រារាំងដល់ការបម្រើរបស់គាត់ ។

ខ្ញុំបានសួរថា « តើអ្នកគិតថា ព្រះអម្ចាស់អាចជួយអ្នកឲ្យក្លាយជាអ្នកផ្សព្វផ្សាយសាសនាល្អឬទេ ?»

« ខ្ញុំជឿថាព្រះអម្ចាស់អាចធ្វើអ្វីៗគ្រប់យ៉ាងបាន »។

« ដូច្នេះសូមឲ្យទ្រង់ជួយដល់អ្នកទៅ ។ តើអ្នកគិតថាអ្នកអាចធ្វើដូច្នោះបានទេ ?

គាត់និយាយថា « ខ្ញុំអាចធ្វើបាន » ។

ខ្ញុំហ៊ានសារភាពថា នៅពេលគាត់បានដើរចេញទៅ នោះខ្ញុំបានគិតថា « មែនហើយ ខ្ញុំសង្ឃឹមថាគាត់អាចធ្វើវាបាន » ។

អស់ពេលជាច្រើនសប្ដាហ៍បានកន្លងផុតទៅ ហើយអ្នកផ្សព្វផ្សាយសាសនាដដែលនេះបានមកសម្ភាសម្ដងទៀត។ ម្ដងនេះដៃគូរបស់អែលឌើរដែលអៀននោះនិយាយថា « ប្រធាន ខ្ញុំពុំដឹងថាប្រធានបានប្រាប់អ្វីដល់គាត់ ប៉ុន្តែគាត់ពិតជាបានផ្លាស់ប្ដូរ ។ គាត់បានប្រែជាពូកែនិយាយជាមួយមនុស្ស » ។ ដូច្នោះហើយខ្ញុំ ទន្ទឹងរង់ចាំជួបគាត់ម្ដងទៀត ។

នៅពេលគាត់បានចូលមកក្នុងការិយាល័យរបស់ខ្ញុំ គាត់បានឱនមុខចុះក្រោម ។

គាត់បានពោលថា « ខ្ញុំមានដំណឹងល្អមួយចំនួន » ។ « ខ្ញុំនៅតែអៀន ប៉ុន្តែខ្ញុំបានសូមព្រះអម្ចាស់ឲ្យជួយខ្ញុំ បន្ទាប់មកខ្ញុំបានបើកមាត់របស់ខ្ញុំ ហើយបានចាប់ផ្ដើមនិយាយ ។ តើប្រធានដឹងទេ ? ឥឡូវខ្ញុំធ្វើបែបនេះគ្រប់ពេល ។ ខ្ញុំថែមទាំងពុំចាំពីអ្វីដែលខ្ញុំនិយាយនោះផង ។ រឿងដ៏អស្ចារ្យនោះគឺថាមនុស្សចូលចិត្តវា ។ ពួកគេទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។ ពួកគេនិយាយមកកាន់ខ្ញុំ និង អ្វីដែលខ្ញុំត្រូវតែប្រាប់ពួកគេ » ។

ខ្ញុំមានភាពអស្ចារ្យ ដោយឃើញអ្នកផ្សព្វផ្សាយសាសនារូបនេះបានផ្លាស់ប្រែ នៅពេលគាត់បានដាក់ទីទុកចិត្តរបស់ខ្លួនលើព្រះអម្ចាស់ ។ គាត់បានក្លាយជាឧបករណ៍ដ៏អស្ចារ្យមួយនៅក្នុងការនាំសុភមង្គលដល់មនុស្សជាច្រើននាក់ ។

« ខ្ញុំនៅតែអៀន ប៉ុន្តែខ្ញុំបានសូមព្រះអម្ចាស់ឲ្យជួយខ្ញុំ » ។



## ការយកឈ្នះលើភាពភ័យខ្លាច

នៅពេលយើងចែកចាយដំណឹងល្អ ពេលខ្លះយើងមានអារម្មណ៍ភិតភ័យ ។ ប៉ុន្តែដូចអ្វីដែលអ្នកផ្សព្វផ្សាយសាសនាដ៏អៀនខ្មាសនេះបានបង្ហាញ ព្រះអម្ចាស់នឹងដឹកនាំយើង ប្រសិនបើយើងទុកចិត្តលើទ្រង់ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងជួយយើងឲ្យដឹងពីអ្វីដែលត្រូវនិយាយ ( សូមមើល នីហ្វៃទី ២ ៣២:២–៣) ហើយនៅពេលមនុស្សមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ នោះពួកគេតែងតែឆ្លើយតបក្នុងរបៀបមួយយ៉ាងវិជ្ជមាន ។ មនុស្សជាច្រើនប្រែជាចាប់អារម្មណ៍ដោយសារអ្វីដែលយើងជឿ និង ចង់ដឹងបន្ថែមទៀត ។

## សេចក្ដីអំណរដ៏ធំមហិមា

ខ្ញុំមានទីបន្ទាល់ថា ព្រះវរបិតាសួគ៌នឹងដឹកនាំយើងនៅក្នុងកិច្ចខិតខំរបស់យើង ដើម្បីចែកចាយដំណឹងល្អ ហើយនៅក្នុងដំណើរការនោះ យើងនឹងមានសេចក្ដីអំណរដ៏ធំមហិមា ។ តាមពិតទៅ សេចក្ដីអំណរនោះនឹងនៅជាមួយយើង ពុំគ្រាន់តែក្នុងពេលបច្ចុប្បន្ននេះឡើយ ប៉ុន្តែថែមទាំងនៅក្នុងជីវិតខាងមុខផងដែរ ។ ( សូមមើល គ. និង ស. ១៨:១៦) ។ វាជាហេតុផលមួយដ៏ល្អដើម្បីឈានជើងចេញពីស្ថានភាពសុខស្រួលរបស់អ្នក ហើយធ្វើអ្វីមួយ ទោះបីជាអ្នកអៀនខ្មាសក៏ដោយ ។ ■

## សេចក្ដីភ័យខ្លាចបីយ៉ាងដែលអ្នកអាចយកឈ្នះបាន

ក្រៅពីភាពអៀនខ្មាស ខ្ញុំដឹងពីសេចក្ដីភ័យខ្លាចបីយ៉ាងទៀត ដែលបណ្ដាលឲ្យពួកយើងនិយាយថា « ខ្ញុំភ័យខ្លាចថា ប្រសិនបើខ្ញុំនិយាយអំពីដំណឹងល្អ នោះខ្ញុំនឹងបាត់បង់មិត្តភក្ដិហើយ » ។ មានអំណរគុណណាស់ដោយមានសេចក្ដីជំនឿ នោះសេចក្ដីខ្លាចទាំងនោះអាចយកឈ្នះបាន ។

**១. ខ្ញុំពុំដឹងគ្រប់គ្រាន់ឡើយ ។**

ប្រសិនបើអ្នកខ្វះចំណេះដឹងអំពីដំណឹងល្អ នោះអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងអាចជួយអ្នកបាន ។ ពួកគេអាចបង្រៀនយើងអំពី សារលិខិតនៃការស្ដារឡើងវិញ ជួយពង្រឹងសេចក្ដីជំនឿរបស់យើងលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយជួយពួកយើងយល់ពីការប្រែចិត្ត និង របៀបដើម្បីអនុវត្តវានៅក្នុងជីវិតរបស់យើង និង មូលហេតុដែលបុណ្យជ្រមុជទឹក ព្រមទាំងព្រះវិញ្ញាណបរិសុទ្ធមានសារៈសំខាន់ ។ ប្រភពនៃចំណេះដឹងដ៏អស្ចារ្យមួយទៀតនោះគឺ *ប្រកាសដំណឹងល្អរបស់យើង* ។ ខ្ញុំចង់លើកទឹកចិត្តយុវជន និង យុវនារីគ្រប់រូបឲ្យមានសៀវភៅនេះមួយក្បាល ហើយសិក្សាវារៀងរាល់ថ្ងៃជាមួយព្រះគម្ពីរ ។

**២. ខ្ញុំពុំធ្លាប់បានធ្វើបែបនេះពីមុនទេ ។**

ប្រសិនបើអ្នកខ្វះបទពិសោធន៍ សូមអនុវត្តជាមួយអ្នកពួកផ្សព្វផ្សាយសាសនា ! ពួកគេអាចជួយអ្នកដឹងអ្វីដែលត្រូវនិយាយ ឬពុំនិយាយនៅក្នុងស្ថានភាពត្រឹមត្រូវមួយ ។ នៅពេលអ្នកចំណាយពេលជាមួយពួកអ្នកផ្សព្វផ្សាយ នោះអ្នកនឹងមានអារម្មណ៍នៃសេចក្ដីស្រឡាញ់ ដែលពួកគេមានចំពោះដំណឹងល្អ និង ចំពោះបងប្អូនរបស់ពួកគេ ។ ពួកគេបានរកឃើញសេចក្ដីក្លាហានដើម្បីចែកចាយដំណឹងល្អ ពួកគេអាចជួយអ្នកឲ្យធ្វើកិច្ចការនេះផងដែរ ។

**៣. ខ្ញុំខ្លាចមិនហ៊ានចែកចាយ ។**

នៅពេលយើងចែកចាយទីបន្ទាល់របស់យើង នោះយើងជួយមិត្តភក្ដិរបស់យើងឲ្យមើលឃើញអ្វីៗបានប្រសើរជាង ហើយពួកគេចាប់ផ្ដើមគោរពយើង ហើយស្រឡាញ់យើងក្នុងរបៀបថ្មីមួយ ។ ការណ៍នេះកើតឡើងស្ទើរតែរៀងរាល់ពេល ។ យុវវ័យជាច្រើននិយាយថា « ខ្ញុំភ័យខ្លាចជាខ្លាំង ប៉ុន្តែនៅពេលខ្ញុំបាននិយាយដោយស្មោះត្រង់ នោះមិត្តភក្ដិរបស់ខ្ញុំបានចាប់ផ្ដើមទុកចិត្តខ្ញុំ ហើយសួរសំណួរខ្ញុំបន្ថែមទៀត » ។ យើងពុំគួរគប្បីភ័យខ្លាចអំពីការចែកចាយអ្វីដែលយើងមានឡើយ ។ ការណ៍នេះពិសិដ្ឋដោយសារវាកើតមកពីព្រះ ។ ហើយតើមានរបៀបណាទៅដែលល្អជាងនេះ ដើម្បីចែកចាយសេចក្ដីស្រឡាញ់ចំពោះមិត្តភក្ដិរបស់យើងដោយចែកចាយពួកគេនូវអ្វីដែលយើងដឹងថាជាការពិតនោះ ?

# ទីកន្លែងរបស់យើង



## សូមទៀងត្រង់នៅក្នុងគ្រប់ការណ៍ទាំងអស់

អាលីវសឺ អេច ចាលីស្ហ ម៉ិកសឺកូ

រៀងរាល់ពេលចាប់ផ្ដើមបវេនសកាលម្ដងៗ យើងតែងទទួលបាននូវការផ្ដល់ជូនដោយឥតគិតថ្លៃមួយកញ្ចប់ដែលមានដូចជា សៀវភៅសរសេរ របៀបវារៈ និង ឯកសារគំរូផ្សេងៗទៀត ។ មានឆ្នាំមួយនោះខ្ញុំបានតម្រង់ជួរដើម្បីទទួលបានការផ្ដល់ជូននោះ ហើយបានដឹងថាឯកសារគំរូ ដែលខ្ញុំបានទទួលនោះគឺពិតជាមានប្រយោជន៍យ៉ាងពិសេសចំពោះខ្ញុំ ។

នៅចុងបញ្ចប់នៃថ្ងៃនោះខ្ញុំបានឃើញថាពួកគេបានឲ្យឯកសារគំរូពីរពីឯកសារតែមួយដែលដូចគ្នា ។ វាមានភាពងាយស្រួលដើម្បីតម្រង់ជួរម្ដងទៀត ហើយយកឯកសារមួយទៀត ហើយខ្ញុំបានសម្រេចចិត្តធ្វើបែបនោះ ។ ក្រោយពីនោះមកដោយសារវាឥតគិតថ្លៃនោះ ខ្ញុំពិតជាត្រូវការឯកសារនោះណាស់ ។

ខ្ញុំបានឈប់មួយសន្ទុះនៅបន្ទប់ទឹក ជាកន្លែងដែលខ្ញុំបានឃើញទូរសព្ទដៃមួយដែលយុវនារីមួយចំនួនបានភ្លេចនៅទីនោះដោយចៃដន្យ ។ ទូរសព្ទនោះវាជាម៉ូតដែលទើបនឹងចេញថ្មី ហើយខ្ញុំទើបតែបាត់ទូរសព្ទរបស់ខ្លួនកាលពីសប្ដាហ៍មុន ។ ប៉ុន្តែខ្ញុំមិនបានគិតចង់រកវាឡើយ ។ ខ្ញុំនិយាយដាក់ខ្លួនឯងថា « នោះគឺលួចហើយ »។

បន្ទាប់មក នៅតាមផ្លូវទៅយកឯកសារដែលឥតគិតថ្លៃនោះ ខ្ញុំបានដឹងថាវាគ្មានភាពស្មោះត្រង់ទេបើខ្ញុំយកទូរសព្ទនេះ ដោយសារខ្ញុំត្រូវតែកុហក ហើយខ្ញុំពុំទាន់មានទូរសព្ទថ្មីបែបនេះពីមុនមកឡើយ ។

ខ្ញុំមានអំណរគុណចំពោះបទពិសោធន៍តូចតាចនេះ ដែលបានបង្រៀនខ្ញុំនូវមេរៀនដ៏អស្ចារ្យ ។ ខ្ញុំបានដាក់ទូរសព្ទទុកវិញ ហើយបានទៅផ្ទះជាមួយតែសៀវភៅសរសេរ របៀបវារៈ និងឯកសារគំរូប៉ុណ្ណោះ ដោយអារម្មណ៍ដ៏ល្អចំពោះការនៅស្មោះពិតនៅក្នុងគ្រប់ការណ៍ទាំងអស់ ទោះវាជារឿងតូចតាចក្ដី ។ ■

## មានពរហើយចំពោះការគោរពតាមក្រឹត្យវិន័យដង្វាយមួយភាគក្នុងដប់

សាប្រីណា ធី ទីក្រុង សៅប៉ូឡូ ប្រទេសប្រេស៊ីល

កាលខ្ញុំនៅតូច ឪពុករបស់ខ្ញុំ និង ខ្ញុំបានហែលឆ្លងកាត់នូវការសាកល្បងផ្នែកហិរញ្ញវត្ថុយ៉ាងច្រើន រហូតដល់ខ្ញុំអាយុ១០ឆ្នាំ ។ ឪពុករបស់ខ្ញុំពុំអាចរកការងារផ្សេងធ្វើបានឡើយ ដូច្នោះគាត់បានធ្វើជាអ្នកលក់ដូរនៅតាមចិញ្ចើមថ្នល់ ហើយរកបានប្រាក់កម្រៃតិចតួចបំផុត ។ ម្ដាយរបស់ខ្ញុំបាននៅផ្ទះដើម្បីមើលថែខ្ញុំ និង ប្អូនប្រុសរបស់ខ្ញុំ ។

ប៉ុន្តែទោះបីជាបានហែលឆ្លងកាត់នូវការលំបាកជាច្រើនក្តី យើងមានទីបន្ទាល់អំពីការថ្វាយដង្វាយមួយភាគក្នុងដប់ និង ដង្វាយផ្សេងៗទៀត ។ យើងបានថ្វាយដង្វាយមួយភាគក្នុងដប់របស់យើងយ៉ាងស្មោះត្រង់រៀងរាល់ខែ ហើយពុំដែលខ្វះខាតឡើយ ។ យើងដឹងយ៉ាងប្រាកដថា យើងត្រូវបានប្រទានពរឲ្យជាបន្តបន្ទាប់ ដោយសារតែសេចក្ដីសប្បុរសដែលគ្មានដែនកំណត់របស់ព្រះអម្ចាស់ និង ដោយសារទ្រង់រក្សាការសន្យារបស់ទ្រង់ នៅពេលយើងគោរពប្រតិបត្តិចំពោះព្រះបញ្ញត្តិរបស់ទ្រង់ ។

ទីបំផុតពេលវេលានៃការសាកល្បងបញ្ហាខាងហិរញ្ញវត្ថុរបស់យើងបានចប់ ។ ពរជ័យដែលព្រះអម្ចាស់បានប្រទានដល់ពួកយើងនៅក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះមានភាពអស្ចារ្យណាស់ ។

ខ្ញុំដឹងថា អស់អ្នកណាដែលថ្វាយដង្វាយមួយភាគក្នុងដប់ដោយស្មោះត្រង់ ហើយបង់ដង្វាយរបស់ខ្លួនដោយសេចក្ដីស្រឡាញ់ ដែលមានបំណងដើម្បីប្រទានពរដល់មនុស្សដទៃទៀត នោះគ្មានភាពខ្វះខាតកើតឡើងទៀតឡើយ ហើយមានរឿងកាន់តែអស្ចារ្យបានកើតឡើង ដូចជាខ្ញុំ និង គ្រួសារខ្ញុំផងដែរ ។ ពរជ័យទាំងនោះនឹងកើនឡើង ។ ខ្ញុំដឹងការណ៍នេះ ។ ខ្ញុំបានរស់នៅតាមការណ៍នេះ ។ ■

រូបគំនូរដោយ ដែលរី ម៉ាកអ៊ីស

# តើមើលទៅគួរឲ្យឆ្ងាញ់មែនទេ ?

ចូរមើលម្ដងទៀត ។ សាតាំងចង់ឲ្យយើងប្ដូរយកសេចក្ដីអំណរដ៏ពិតជាមួយនឹងសុភមង្គលក្លែងក្លាយដែលនឹងគ្មានក្ដីសោមនស្សរីករាយឡើយ ។ ចូរកុំបរិភោគវាសូម្បីតែមួយម៉ាត់ឡើយ ។

( សូមមើលឌៀថើរ អេស្វ អុជដូហ្វ « You Can Do It Now » *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៥៦ ) ។



រូបថតដោយឌៅវីឌ ស្តុកប៊ើ

## « ខ្ញុំត្រូវបានគេចំអកឲ្យនៅសាលារៀន ដោយសារខ្ញុំជាពួកអិល.ឌី.អេស. ។ ខ្ញុំដឹងថាខ្ញុំត្រូវការពារជំនឿរបស់ខ្ញុំ ប៉ុន្តែវាពិតជាពិបាកណាស់ ! តើខ្ញុំនឹងមានចិត្តក្លាហានគ្រប់គ្រាន់បានដោយរបៀបណា ?

អ្នកគិតត្រូវហើយ ដែលអ្នកត្រូវតែមានចិត្តក្លាហានដើម្បីដោះស្រាយចំពោះស្ថានភាពបែបនេះ ។ បន្ទាប់ពីអ្វីៗទាំងអស់ ព្រះយេស៊ូវគ្រីស្ទបានបញ្ជាថា « ចូរក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅប្រយោជន៍ឲ្យពន្លឺរបស់អ្នកអាចបានទៅជាបមាណីយដល់សាសន៍នានា » ( គ. និង ស. ១១៥:៥ ) ។ ប៉ុន្តែការមានចិត្តក្លាហានដើម្បីឲ្យពន្លឺរបស់អ្នកបញ្ចាំងចេញទៅ នោះពុំមែនមានន័យថាឲ្យអ្នកនិយាយទាស់នឹងមនុស្សដែលចំអកដល់អ្នកនោះឡើយ ។

ហើយក្នុងករណីនេះ អ្នកអាចឲ្យការប្រឆាំងនេះបំផុសគំនិតអ្នកឲ្យធ្វើបានកាន់តែប្រសើរឡើង ។ នៅពេលអ្នកខិតខំពង្រឹងទីបន្ទាល់របស់អ្នក នោះអ្នកអាចបង្កើននូវភាពក្លាហានមួយបែប ដែលនឹងជួយអ្នកឲ្យហ៊ាននិយាយ ឬ បន្តធ្វើកិច្ចការដែលត្រឹមត្រូវ បើទោះបីជាមនុស្សដទៃចំអកដល់អ្នកក៏ដោយ ។

ការត្រូវបានគេបន្ទុះបង្អាប់អាចជាការអាក់អន់ចិត្ត ប៉ុន្តែសូមចាំថា អ្នកអាចអធិស្ឋានទូលសុំឲ្យបានពេញដោយសេចក្ដីសប្បុរស ប្រយោជន៍ឲ្យមនុស្សដទៃអាចមានអារម្មណ៍ពី សេចក្ដីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទតាមរយៈអ្នក ( សូមមើល ម៉ូរ៉ូណៃ ៧:៤៨ ) ។ ដោយសារគ្រប់ស្ថានភាពទាំងអស់វាផ្សេងៗពីគ្នា នោះចូរសុំនូវការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីដឹងពីរបៀបឆ្លើយតបក្នុងរបៀបមួយដូចជាព្រះគ្រីស្ទនៅក្នុងឧទាហរណ៍និមួយៗ ។

អាស្រ័យលើស្ថានភាពនោះ វាអាចជារឿងដ៏ល្អបំផុតដើម្បីនិយាយដោយផ្ទាល់ជាសម្ងាត់ជាមួយអស់អ្នកដែលបានចំអកដល់អ្នក ឬ គ្រាន់តែកុំខ្វល់ខ្វាយនឹងពាក្យឡកឡឺយដែលមិនសមរម្យនោះ ដោយបន្តរស់នៅតាមជំនឿរបស់អ្នក ។ ប្រសិនបើគ្មាននរណាចាប់អារម្មណ៍ស្ដាប់នូវអ្វីដែលអ្នកនិយាយ គំរូនៃសេចក្ដីសប្បុរស ការអភ័យទោស និង ភាពស្មោះសររបស់អ្នក អាចជាសារលិខិតដ៏ល្អបំផុតដែលអ្នកអាចផ្ដល់ឲ្យបាន ។

### សូមបង្ហាញសេចក្ដីក្លាហានពិត

អស់អ្នកដែលចំអកដល់អ្នក អាចពុំឈប់ដោយងាយៗឡើយ ដោយសារអ្នកមានភាពក្លាហានគ្រប់គ្រាន់ដើម្បីសុំឲ្យពួកគេឈប់ ប៉ុន្តែពួកគេអាចឈប់នៅពេលអ្នកបញ្ចេញនូវសេចក្ដីក្លាហានរបស់ខ្លួន ដោយការរស់នៅតាមអ្វីដែលជាលក្ខណៈរបស់ខ្លួនអ្នក — គឺជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ មុននឹងអ្នកដឹងពីការណ៍នេះ នោះព្រះវរបិតាសួគ៌នឹងជួយអ្នកនូវអ្វីដែលទ្រង់អនុមតិឲ្យអ្នកធ្វើ ដោយសង្ឃឹមថានឹងបើកភ្នែករបស់ពួកគេចំពោះដំណឹងល្អដែលបានស្ដារឡើងវិញនៅក្នុងជីវិតរបស់អ្នក ។

*ប្រាយ យូ អាយុ ១៧ ឆ្នាំ អ៊ីម៉ូ ស្តេត ប្រទេសនីហ្សេរីយ៉ា*

### ស្វែងរកកម្លាំងនៅក្នុងមូលដ្ឋានគ្រឹះ

ការអធិស្ឋាន និង ការតមអាហារគឺសំខាន់ ដោយសារកិច្ចការទាំងនេះនឹងជួយអ្នកឲ្យប្រឈមមុខនឹងការនិយាយចំអក កំប្លែង និង ឧបសគ្គនានានៅសាលារៀន គឺដូចជាព្រះយេស៊ូវគ្រីស្ទបានជួបនឹងការចំអកជាច្រើនកាលទ្រង់គង់នៅលើផែនដីនេះដែរ ។ កិច្ចការទាំងនេះនឹងជួយអ្នកបង្កើនសេចក្ដីស្រឡាញ់ និង ការអត់ធ្មត់កាន់តែច្រើនចំពោះមនុស្សទូទៅ ។

*វ៉លធើរ ស៊ី អាយុ១៥ ឆ្នាំ នៅ ចាអែន ប្រទេស ពេរ៉ូ*



### ចូរទទួលបានការណែនាំតាមរយៈការអធិស្ឋាន

អស់កាលជាយូរមកហើយ ខ្ញុំគឺជាសមាជិកតែម្នាក់ឯងគត់នៅក្នុងសាលារៀនរបស់ខ្ញុំ ។ មិត្តភក្តិជិតស្និទ្ធបំផុតរបស់ខ្ញុំហាក់បីដូចជាយល់ពីខ្ញុំ ប៉ុន្តែមិត្តភក្តិដទៃទៀតក្នុងសាលារៀនបានចំអកដល់ខ្ញុំ ។ ថ្ងៃមួយខ្ញុំបានអធិស្ឋាន ហើយមានអារម្មណ៍ថា ត្រូវពិភាក្សាជាមួយមនុស្សម្នាក់ដែលបានធ្វើឲ្យមនុស្សដទៃទៀតឲ្យចំអកដល់ខ្ញុំ ។ ខ្ញុំបានពន្យល់ថាខ្ញុំគ្មានអារម្មណ៍ខឹងនឹងគាត់ឡើយ ប៉ុន្តែខ្ញុំបានសុំឲ្យគាត់ផ្ដល់នូវការគោរពដែលគាត់ចង់ធ្វើចំពោះខ្ញុំវិញ ។ បន្ទាប់



*ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និង ជាទស្សនវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

ពីស្តាប់ការសន្ទនារបស់យើង គ្រូបង្រៀនម្នាក់របស់យើងតែងតែនិយាយគាំទ្រខ្ញុំនៅពេលគាត់បានឃើញមានរឿងកើតឡើង ។ ខ្ញុំដឹងថា ព្រះអម្ចាស់នឹងគង់នៅជាមួយអ្នក នៅពេលអ្នកនិយាយជាមួយមនុស្សទាំងនោះ ។

*ស្សានែឡា អេស អាយុ ១៤ ឆ្នាំ ផេនប្លាសីនេន ប្រទេសហ្វីលីពីន*

**ស្ថាបនាទីបន្ទាល់របស់អ្នក**

ដំបូង សូមទទួលឲ្យបានទីបន្ទាល់ដ៏ពិតមួយពីសេចក្ដីពិតដែលអ្នកចង់ចែកចាយជាមួយមនុស្សដទៃ ។ បន្ទាប់មកមានចិត្តស្រឡាញ់ចំពោះមនុស្សដែលចំអកដល់អ្នក ហើយកុំឈ្លោះប្រកែកជាមួយពួកគេឡើយ ដោយសារការឈ្លោះប្រកែកគ្នាគឺពុំត្រូវបានគាំទ្រដោយព្រះឡើយ ( សូមមើល នីហ្វៃទី ៣ ១១:២៩ ) ។ អ្វីដែលសំខាន់បំផុតនោះ គឺព្យាយាមឲ្យមានព្រះវិញ្ញាណគង់នៅជាមួយអ្នកជានិច្ច ។ ព្រះវិញ្ញាណនឹងជួយអ្នកឲ្យកាន់តែមានសេចក្ដីស្រឡាញ់ និងភាពក្លាហាន ហើយទ្រង់នឹងធ្វើឲ្យពាក្យសម្ដីរបស់អ្នកពេញដោយអំណាច ។

*ជូលី អេហ្វ អាយុ ១៩ ឆ្នាំ ហេសេ ប្រទេសអាល្លឺម៉ង់*



**ចូរស្រឡាញ់ពួកខ្មាំងសត្រូវរបស់អ្នក**

ខ្ញុំធ្លាប់មានស្ថានភាពស្រដៀងនេះផងដែរ ។ ប្រសិនបើអ្នកមានសេចក្ដីជំនឿ ហើយបន្ទាបខ្លួន នោះអ្នកនឹងត្រូវបានប្រទានពរឲ្យមានកម្លាំង និងសេចក្ដីជំនឿថាអ្នកត្រូវតែ « ស្រឡាញ់ពួកខ្មាំងសត្រូវ ត្រូវឲ្យពរដល់អ្នកណាដែលប្រទេចផ្ដាសាអ្នក . . . ហើយត្រូវអធិស្ឋានសម្រាប់ពួកគេ » ( ម៉ាថាយ ៥:៤៤ ) ។ ខ្ញុំចង់លើកទឹកចិត្តអ្នកឲ្យស្រាវជ្រាវព្រះគម្ពីរដើម្បីរកចម្លើយអំពីរបៀបដើម្បីមានចិត្តរឹងមាំ ។ សូមអធិស្ឋាននៅពេលអ្នកមានអារម្មណ៍ឯកោដោយសេចក្ដីជំនឿរបស់អ្នក ។ រ៉ូម ៨:៣១ ចែងថា « យើងនឹងថ្លែងប្រាប់ពីសេចក្ដីទាំងនេះថាដូចម្ដេច ? ប្រសិនបើជាព្រះកាន់ខាងយើង តើអ្នកណាអាចទាស់នឹងយើងបាន ? » អ្នកមានព្រះគង់នៅខាងអ្នក ! អ្វីគ្រប់យ៉ាងគឺអាចធ្វើទៅបាន ។

*វៀហ្គេន ធី អាយុ១៥ ឆ្នាំ ផ្ញេយូថាយ៍ ស.រ.អា.*



**សូមកុំខ្លាចឡើយ**

សូមនិយាយពីសាសនារបស់អ្នកឲ្យកាន់តែញឹកញាប់ ឬ ធ្វើកិច្ចការនានាដោយចេតនាដើម្បីលើកសាសនារបស់យើងឡើងមកនិយាយ ។ ខ្ញុំបានស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានេះ ហើយខ្ញុំបានសរសេរថា « ខ្ញុំពេញចិត្តធ្វើជាពួកអិល.ឌី.អេស. » នៅលើកាបូបស្ពាយរបស់ខ្ញុំ ។ តាមរយៈការធ្វើបែបនេះ ខ្ញុំបានបើកឱកាសដល់អ្នកផ្សព្វផ្សាយសាសនាជាច្រើន ហើយបង្ហាញមនុស្សទូទៅថាខ្ញុំពុំខ្លាចដើម្បីឲ្យពួកគេដឹងថាខ្ញុំជាពួកអិល.ឌី.អេស. ឡើយ ។ ទោះបីជាអ្នកធ្វើអ្វីក៏ដោយ សូមកុំឲ្យពួកគេមានឥទ្ធិពលលើអ្នកឡើយ ។ សូមអធិស្ឋានសម្រាប់ពួកគេ និង សម្រាប់ខ្លួនឯងផងដែរ ។ មិនយូរប៉ុន្មានអ្នកនឹងឃើញថា ប្រសិនបើអ្នកផ្ដោតចិត្តលើការសង្គ្រោះដល់ព្រលឹងអ្នកដទៃ នោះអ្នកនឹងមិនភ័យខ្លាចឲ្យពួកគេដឹងពីសេចក្ដីពិតនៃដំណឹងល្អរបស់ព្រះវរបិតាយើងឡើយ ។

*សាវ៉ាន់ណា ក៏ អាយុ១៤ ឆ្នាំ ផ្ញេតិចសាស ស.រ.អា.*



**ចិត្តក្លាហាននៃការប្រែចិត្តជឿរបស់យើង**

« ជាញឹកញាប់ វាពិបាកធ្វើអ្វីខុសប្លែកពីគេ ហើយឈរតែម្នាក់ឯងនៅក្នុងហ្វូងមនុស្ស ។ វាធម្មតាទេដែលយើងខ្លាចថាអ្នកដទៃនឹងគិតបែបណា ឬនិយាយបែបណានោះ ។ ការលួងលោមចិត្តគឺមាននៅក្នុងពាក្យនៃគម្ពីរទំនុកតម្កើង ៖ ‹ ព្រះអម្ចាស់ទ្រង់ជាពន្លឺ ហើយជាសេចក្ដីសង្គ្រោះរបស់ខ្ញុំ តើខ្ញុំនឹងត្រូវខ្លាចចំពោះអ្នកណាព្រះអម្ចាស់ទ្រង់ជាទីពឹងពំនាក់នៃជីវិតខ្ញុំ តើត្រូវឲ្យខ្ញុំភ័យចំពោះអ្នកណា ? › [ ទំនុកដំកើង ២៧:១ ] ។ នៅពេលយើងដាក់ព្រះគ្រីស្ទជាអង្គសំខាន់ក្នុងជីវិតរបស់យើង នោះការភ័យខ្លាចនឹងជំនួសដោយចិត្តក្លាហាននៃការប្រែចិត្តជឿរបស់យើង ។

ប្រធាន ថូម៉ាស អេស ម៉នសុន « Be an Example and a Light » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៨៨ ។

## សំណួរបន្ទាប់

« តើខ្ញុំអាចដឹងថា ព្រះកំពុងស្ដាប់ការអធិស្ឋានរបស់ខ្ញុំតាមរបៀបណា ? »

ប្រសិនបើអ្នកមានបំណងចង់ឆ្លើយ សូមផ្ញើចម្លើយរបស់អ្នក និងរូបថតច្បាស់មួយសន្លឹក ត្រឹម ថ្ងៃទី ១ខែ ឧសភា ឆ្នាំ ២០១៦ នៅគេហទំព័រ liahona.lds.org តាមអ៊ីមែលទៅអាស័យដ្ឋាន liahona@ldschurch.org ឬតាមសំបុត្រ ( សូមមើលអាសយដ្ឋាននៅទំព័រទី ៣ ) ។

ព័ត៌មាន និង ការអនុញ្ញាតដូចតទៅនេះត្រូវតែដាក់បញ្ចូលនៅក្នុងអ៊ីម៉ែល ឬ សំបុត្ររបស់អ្នក ៖ ( ១ ) នាម និង គោត្តនាម ( ២ ) ថ្ងៃខែ ឆ្នាំ កំណើត ( ៣ ) វួដ ឬ សាខា ( ៤ ) ស្តេក ឬ មណ្ឌល ( ៥ ) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយ ប្រសិនបើអ្នកអាយុក្រោម ១៨ ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយអ្នក ជាលាយលក្ខណ៍អក្សរ ( អ៊ីមែលអាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ បើវាវែងពេក ឬ មិនសូវច្បាស់លាស់ ។

**ចម្លើយមកពីសាវក**



**ដោយអែលឌើរ**
**ដាវីឌ អេ បែដណា**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# តើពួកសាវកធ្វើអ្វីខ្លះ ?



ពួកសាវកគឺជាអ្នកបម្រើរបស់ព្រះអម្ចាស់ ។ ពួកគេធ្វើដំណើរទៅសួរសុខទុក្ខសមាជិកសាសនាចក្រនៅជុំវិញពិភពលោក ។

គ្រាដំបូងដែលខ្ញុំបានធ្វើដំណើរក្នុងនាមខ្ញុំជាសាវក នោះខ្ញុំបានជួបនឹងបុរសម្នាក់ដែលមានការលំបាកក្នុងការរស់នៅតាមច្បាប់នៃពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។ ខ្ញុំបានប្រាប់គាត់ថា « ព្រះអម្ចាស់បានបញ្ជូនខ្ញុំមកទីនេះ ឲ្យប្រាប់ដល់អ្នកនូវសារលិខិតយ៉ាងសាមញ្ញមួយ ៖ ‹ អ្នកអាចធ្វើតាមវាបាន ។ ខ្ញុំសន្យាថា ព្រះនឹងជួយអ្នកនៅពេលអ្នកប្រឈមមុខនឹងឧបសគ្គនេះ › » ។

តើព្រះអម្ចាស់បញ្ជូនសាវកម្នាក់នៃពួកសាវកដប់ពីរនាក់ឲ្យធ្វើដំណើរចម្ងាយពាក់កណ្ដាលពិភពលោក ដើម្បីគ្រាន់តែជួយមនុស្សម្នាក់ឬ ? ចម្លើយគឺថា *មែនហើយ* ។ ទ្រង់ធ្វើបែបនេះគ្រប់ពេលទាំងអស់ ។ ■

*ដកស្រង់ចេញពីការចាក់ផ្សាយកម្មវិធីជួបមុខគ្នាផ្ទាល់ទូទាំងពិភពលោករបស់អែលឌើរ និង ស៊ីស្ទើរបែដណា ។*

រូបគំនូរដោយ ស្កត គ្រៀ



# សេចក្ដីសុខសាន្តនៅក្នុងដួងចិត្តខ្ញុំ

**ដោយ ខារ៉ុល អេហ្វ ម៉ាកខន់ឃី**
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានយុវនារីទូទៅ

កាលខ្ញុំអាយុប្រាំបី ឆ្នាំ ខ្ញុំបានឃើញព្យាការី ប្រធានដេវីឌ អូ មិកឃេ ( ឆ្នាំ ១៨៧៣–១៩៧០ ) ។ លោកបានមកឧទ្ទិសឆ្លងអគារសាសនាចក្រថ្មីមួយនៅក្នុងក្រុងប៉ាម៉ៃរ៉ា នូវ យ៉ោក ស.រ.អា. ។ គ្រួសាររបស់ខ្ញុំបានទៅពិធីឧទ្ទិសឆ្លងនោះ ។ មានមនុស្សជាច្រើនក៏បានមកដែរ ។ ពួកយើងមានក្ដីរំភើបដើម្បីជួបព្យាការី !

ខ្ញុំនៅតូចមែនទែន ដូច្នោះវាពិបាកឲ្យខ្ញុំមើលឃើញគាត់ដោយបាំងអ្នកដែលឈរជុំវិញលោក ។ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ប្រធានមិកឃេ ។ ខ្ញុំបានឃើញសក់ពណ៌ស និងទឹកមុខដ៏ស្រទន់របស់លោកតែមួយភ្លែតប៉ុណ្ណោះ ។ ខ្ញុំបានគិតថា « ព្យាការីរបស់ព្រះគឺមានលក្ខណៈបែបនេះ » ។ ខ្ញុំបានអានអំពីព្យាការីនៅក្នុងព្រះគម្ពីរ ប៉ុន្តែនេះគឺជាលើកដំបូងដែលខ្ញុំបានឃើញព្យាការី ឬ អ្នកមានសិទ្ធិអំណាចទូទៅផ្ទាល់ភ្នែក ។ ខ្ញុំបានដឹងថាព្យាការីគឺជាមនុស្សពិតប្រាកដ ។ ហើយពួកលោកស្រឡាញ់យើង ! ខ្ញុំតែងចាំពីសេចក្ដីស្រឡាញ់ និង ភាពសុខសាន្តដែលខ្ញុំបានមាននៅថ្ងៃនោះ ។

កាលខ្ញុំអាយុ ១១ឆ្នាំ ខ្ញុំមានបទពិសោធន៍មួយទៀត ដែលបានជួយខ្ញុំឲ្យមានអារម្មណ៍សុខសាន្តនៅក្នុងដួងចិត្តរបស់ខ្ញុំ ។ សន្និសីទស្តេកជិតខិតចូលមកដល់ ហើយខ្ញុំត្រូវច្រៀងនៅក្នុងក្រុមចម្រៀងស្តេក ។ ខ្ញុំរំភើបខ្លាំងណាស់ ! ខ្ញុំបានពាក់អាវ-សយ៉ាងស្អាត ហើយខ្ញុំមានអារម្មណ៍យ៉ាងអស្ចារ្យ ។ ចម្រៀងដែលយើងបានច្រៀងមាននូវពាក្យពេចន៍ដកស្រង់ពី យ៉ូហាន ១៤:២៧ « ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកិយឲ្យទេ ។ កុំឲ្យអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ » ។

ពាក្យពេចន៍ទាំងនោះពិតជាធ្វើឲ្យខ្ញុំរំជួលចិត្តយ៉ាងខ្លាំង ហើយខ្ញុំបានចាំពាក្យទាំងនោះតាំងពីពេលនោះមក ។ នៅពេលខ្ញុំបានច្រៀងនូវពាក្យទាំងនោះ ខ្ញុំបានដឹងថាពាក្យនោះគឺជាការពិត ។ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធប្រាប់ខ្ញុំថា ការធ្វើតាមព្រះយេស៊ូវគ្រីស្ទជួយយើងឲ្យមានអារម្មណ៍សុខសាន្ត ។ ចាប់តាំងពីពេលនោះមក នៅពេលណាដែលខ្ញុំមានឧបសគ្គ ខគម្ពីរនេះបានផុសមកក្នុងគំនិតខ្ញុំ ហើយធ្វើឲ្យខ្ញុំមានភាពសុខសាន្ត ។ សេចក្ដីពិតដែលខ្ញុំបានរៀនកាលខ្ញុំនៅក្មេងបានប្រទានពរដល់ជីវិតរបស់ខ្ញុំទាំងស្រុង ។ ■

គំនូរដោយ អែមី ប៉េតស៍

# ទីបន្ទាល់របស់អ៊ីថាន

ដោយ ឡូរី ហិល្លី

ផ្អែកទៅលើដំណើររឿងពិត

*« សូមស្ដាប់ សូមស្ដាប់ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងខ្សឹបប្រាប់ ។ សូមស្ដាប់ សូមស្ដាប់សំឡេងតូចរហៀង »* ( ចម្រៀងកុមារ ១០៦ ) ។

អីថានបានអង្គុយនៅក្នុងការប្រជុំពេលវេលាចែកចាយ ហើយបានសម្លឹងមើលទៅ សាមមិត្តភក្តិដ៏ជិតស្និទ្ធរបស់គាត់ថ្លែងទីបន្ទាល់របស់ខ្លួន ។ មិត្តភក្តិរបស់គាត់ សារ៉ាកំពុងអង្គុយលើវេទិកា រង់ចាំដល់វេនរបស់នាង ។ សាមបាននិយាយអំពីគម្រោងបម្រើមួយដែលគាត់បានធ្វើ ។ គាត់បាននិយាយថា គាត់មានទីបន្ទាល់អំពីការបម្រើ ។ សារ៉ាបានថ្លែងទីបន្ទាល់របស់នាងអំពីក្រុមគ្រួសារ ។ គ្រូរបស់អ៊ីថានក៏ថ្លែងទីបន្ទាល់របស់គាត់ផងដែរ ។ គាត់បាននិយាយអំពីកិច្ចការព្រះវិហារបរិសុទ្ធ ។ ពួកគេទាំងអស់គ្នាបានថ្លែងថា សាសនាចក្រនេះពិត ។ គ្រប់គ្នាទំនងជាមាននូវទីបន្ទាល់មួយលើកលែងតែអ៊ីថានប៉ុណ្ណោះ ។

*គ្រប់គ្នាទំនងជាមាននូវទីបន្ទាល់មួយលើកលែងតែអ៊ីថានប៉ុណ្ណោះ ។*



« តើខ្ញុំមានទីបន្ទាល់អំពីអ្វីខ្លះ ? » អ៊ីថានបានងឿងឆ្ងល់ ។

គាត់បានគិតពីរយៈពេលពីរបីឆ្នាំមុន នៅពេលគាត់នឹងមិត្តភក្តិរបស់គាត់បានជ្រមុជទឹក ។ គ្រូបង្រៀនថ្នាក់បឋមសិក្សារបស់គាត់ គឺបងស្រីខាលឌើរ បាននិយាយអំពីព្រះវិញ្ញាណបរិសុទ្ធ ។

« ព្រះវិញ្ញាណបរិសុទ្ធអាចធ្វើឲ្យអ្នកមានអារម្មណ៍ខ្ទួលខ្ទាញ់ក្នុងដួងចិត្តរបស់អ្នក ។ គាត់បាននិយាយថា ទ្រង់អាចជួយអ្នកដឹងពីអ្វីដែលពិត » ។ « ហើយនោះគឺជារបៀបដែលអ្នក



ក្បែរគ្រែរបស់ខ្លួនដើម្បីអធិស្ឋាន ។

គាត់បាននិយាយថា « ព្រះវរបិតាសួគ៌ សូមជួយទូលបង្គំឲ្យមានទីបន្ទាល់ផង ។ សូមជួយទូលបង្គំឲ្យដឹងថា សាសនាចក្រនេះពិត ។ ថាយ៉ូសែប ស្ម៊ីធ គឺជាព្យាការី ។ ហើយថាព្រះគម្ពីរមរមនពិត » ។

នៅពាក់កណ្ដាលនៃការអធិស្ឋានរបស់គាត់ អ៊ីថានបានឈប់ ។ គាត់បានគិតមួយសន្ទុះ ។ ក្រោយមកគាត់បានសួរខ្លួនឯងថា « មែនហើយ តើខ្ញុំដឹងអ្វីខ្លះហើយ ? »

ហើយក្រោយមកអារម្មណ៍ស្ងប់ស្ងាត់ សុខសាន្តបានមានលើគាត់ ។ វាមិនមែនជាអារម្មណ៍ដ៏ឆេះខ្វល់ខ្វាញ់ឡើយ ។ ប៉ុន្តែអ៊ីថានបានដឹង ថា នោះគឺជាព្រះវិញ្ញាណបរិសុទ្ធ ។

មានគំនិតមួយផុសឡើងនៅក្នុងចិត្តរបស់អ៊ីថាន ៖ « ខ្ញុំដឹងថាខ្ញុំស្គាល់អារម្មណ៍នេះ » ។ ហើយនៅពេលគាត់បានគិតពីអារម្មណ៍នោះ គាត់បានដឹងថាគាត់ធ្លាប់មានអារម្មណ៍ដ៏សុខសាន្តនេះពីមុនមក ។

នៅពេលគាត់បានអានព្រះគម្ពីរមរមន វាធ្វើឲ្យគាត់មានអារម្មណ៍ល្អនិងត្រឹមត្រូវ ។ ឥឡូវគាត់បានដឹងថា អារម្មណ៍នោះគឺមកពីព្រះវិញ្ញាណបរិសុទ្ធដែលថ្លែងទីបន្ទាល់ដល់គាត់ ។ នៅពេលគាត់បានទៅព្រះវិហារ ហើយវាធ្វើឲ្យគាត់មានអារម្មណ៍ល្អ និងត្រឹមត្រូវនៅទីនោះ នោះគឺជាអារម្មណ៍នៃព្រះវិញ្ញាណបរិសុទ្ធផងដែរ ។ គាត់បានមានទីបន្ទាល់មួយរួចទៅហើយ !

គាត់មិនចាំបាច់ត្រូវដឹងគ្រប់យ៉ាងក្នុងពេលនេះឡើយ ។ ប៉ុន្តែគាត់បានដឹងថាព្រះវិញ្ញាណបរិសុទ្ធគឺពិត ហើយអាចជួយគាត់ឲ្យបន្តស្ដាប់នាទីបន្ទាល់របស់គាត់ ។

អ៊ីថានបានចាប់ផ្ដើមអធិស្ឋានម្ដងទៀត ។ ប៉ុន្តែលើកនេះគឺជាពេលដើម្បីថ្លែងអំណរគុណ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា ។*

ទទួលនូវទីបន្ទាល់មួយអំពីអ្វី ដែលអ្នកជឿ » ។

អ៊ីថានបានព្យាយាមធ្វើនូវអ្វីដែលត្រឹមត្រូវ ប្រយោជន៍ឲ្យគាត់ទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ។ គាត់បានអានព្រះគម្ពីរ ហើយអធិស្ឋាន ។ ប៉ុន្តែគាត់ពុំដែលធ្លាប់មានអារម្មណ៍ខ្វល់ខ្វាញ់ក្នុងចិត្តដូចគេបាននិយាយឡើយ ។ តើការណ៍នេះមានន័យថា គាត់ពុំមានទីបន្ទាល់ឬ ?

សំណួរនេះបានដក់នៅក្នុងចិត្តរបស់អ៊ីថាននៅថ្ងៃបន្ទាប់នោះ ។ គាត់កំពុងគិតអំពីវានៅពេលគាត់ និងសាមលេងជិះកូនក្ដាររំអិលបន្ទាប់ពីមកពីសាលាវិញ ។ គាត់បានឆ្ងល់ពីរបៀបដែលគាត់អាចសួរសាមអំពីទីបន្ទាល់នោះ ។

ទីបំផុតអ៊ីថានបានសួរ « ហេ៎ សាម តើឯងមានការភ័យខ្លាចទេ នៅពេលឯងបានថ្លែងទីបន្ទាល់កាលពីម្សិលមិញនោះ ? »

សាមបានស្ទុះចេញពីកូនក្ដាររំអិល ហើយបានដើរទៅវាលស្មៅ ។ គាត់និយាយពេលកំពុងអង្គុយថា « អត់ខ្លាចទេ » ។ « ខ្ញុំបានចែកចាយទីបន្ទាល់របស់ខ្ញុំនៅពេលយប់ជាមួយគ្រួសារពីមុនខ្ញុំចែកចាយវានៅព្រះវិហារ » ។

អ៊ីថានបានអង្គុយជាមួយគាត់ ហើយបានដាក់កូនក្ដាររំអិលលើភ្លៅរបស់ខ្លួន ។ « ប៉ុន្តែ តើអ្នកបានដឹងថា អ្នកមានទីបន្ទាល់មួយដោយរបៀបណា ? »

« មែនហើយខ្ញុំបានអធិស្ឋាន ហើយខ្ញុំមានអារម្មណ៍ល្អពីវា » ។

អ៊ីថានបានងក់ក្បាលយឺតៗ ហើយយកដៃខ្លួនបង្វិលកង់ ។ ដោយគាត់ចង់មានអារម្មណ៍បែបនោះផងដែរ ។ នាពេលយប់នោះ ជាពេលងងឹត ហើយស្ងាត់ អ៊ីថានបានលុតជង្គង់ចុះ

រូបគំនូរដោយ មេលីស្សា មែនលៃ

# ប្រាក់ពេសូសម្រាប់ ព្រះវរបិតាសួគ៌

ដោយ អែនជេឡា ផេណា ដាលី

*« រក្សាបទបញ្ញត្តិ ។ ព្រោះនាំឲ្យមានសុវត្ថិភាព និង ក្ដីសុខសាន្ត »* ( សៀវភៅចម្រៀងកុមារ ១៤៦ ) ។



អាណាបានទំពាបន្ទះនំថតធីឡាមួយម៉ាត់ចុងក្រោយរបស់ខ្លួន ។ វាទន់ហើយឆ្ងាញ់ ។ អាណាចូលចិត្តបន្ទះនំថតធីឡារបស់ជីដូននាងណាស់ ។ វាជាអាហារពេលព្រឹកដ៏ល្អបំផុត ។

អាណាបានមើលជីដូនអាប៊ុយឡាលាងចាន ។

វាដូចជាព្រឹកធម្មតាផ្សេងទៀតដែរ ។ ប៉ុន្តែមានអ្វីមួយដែលមិនដូចគ្នាឡើយ ។

អាប៊ុយឡាតែងដើរទៅផ្សារដើម្បីទិញអាហារ ។ ប៉ុន្តែថ្ងៃនេះគាត់មិនទៅផ្សារទេ ។ ថ្ងៃនេះគ្មានប្រាក់ទិញអាហារឡើយ ។

« តើយើងនឹងញ៉ាំអ្វីនៅថ្ងៃស្អែក ? » អាណាបានការងឿងឆ្ងល់ ។

ក្រោយមកអាណាបានចាំ ។ នាងបានដឹងពីកន្លែងដែលមានប្រាក់ខ្លះ ! យប់មិញនាងបានឃើញអាប៊ុយឡាបានដាក់ប្រាក់ពេសូមួយចំនួននៅក្នុងអាវ-សតូចមួយ ។

« អាប៊ុយឡា តើលោកយាយភ្លេចហើយមែនទេ ? លោកយាយមានប្រាក់ទិញអាហារ »។

« ប្រាក់អ្វីទៅ ? » អាប៊ុយឡាបានសួរ ។

អាណាបានរត់ទៅយកប្រាក់នោះ ។ នាងបានក្រឡុកកាបូបតូចដែលមានប្រាក់កាក់នោះ ។ *គ្លីង ! គ្លីង !*

អាប៊ុយឡាបានញញឹម ។ « នោះគឺជាដង្វាយមួយភាគក្នុងដប់របស់យើងទេ អាណា ។ នោះគឺជាប្រាក់ *របស់ទ្រង់* ទេ » ។

« ប៉ុន្តែតើយើងនឹងញ៉ាំអ្វីនៅថ្ងៃស្អែក ? » អាណាបានសួរ ។

អាប៊ុយឡាបាននិយាយថា « កុំបារម្ភអី » ។ « យាយជឿថាព្រះវរបិតាសួគ៌នឹងជួយយើង » ។

នៅព្រឹកបន្ទាប់អាប៊ុយឡាបានឲ្យអាណានូវបន្ទះនំថតធីឡាពោតចុងក្រោយបង្អស់ ។ ក្រោយមកគាត់បានអង្គុយចុះលើកៅអី ។ គាត់បានដេរផ្កា

រូបគំនូរដោយ អេរិច ប៊ីស្លី



ពណ៌ក្រហមនៅលើរ៉ូបមួយ ហើយបាននិទានរឿងប្រាប់កាល ពីគាត់នៅក្មេង ។ គាត់មើលទៅមិនបារម្ភសោះ ។

ក្រោយមកអាណាឮសំឡេងគោះទ្វារ ។ នាងបានរត់ទៅបើកទ្វារ ។

« លោកអ៊ុំពេទ្រូ ! »

លោកអ៊ុំពេទ្រូបាននិយាយថា « អ៊ុំមានអារម្មណ៍ថាអ៊ុំគួរតែសួរសុខទុក្ខអ្នកទាំងពីរ » ។ គាត់បានដាក់ថង់បីនៅលើតុ ។ មួយថង់មានម្សៅពោតសម្រាប់ធ្វើបន្ទះនំថតធីឡា ។ មួយថង់ទៀតជាសាច់ ។ មួយថង់ទៀតជាបន្លែស្រស់មកពីផ្សារ ។

អាប៊ុយឡាបាននិយាយថា « អូ៎ កូនប្រុសជាទីស្រឡាញ់របស់ម្ដាយអើយ » ។ « ម្ដាយនឹងចំអិនសម្លសាច់ប្រហិតយ៉ាងឆ្ងាញ់ ! »

លោកអ៊ុំពេទ្រូបាននិយាយថា « សម្លរបស់ម៉ែគឺជាសម្លដែលឆ្ងាញ់ជាងគេបំផុតនៅលើលោកនេះ » ។

អាណាបានសើច ហើយទះដៃ ។

បន្ទាប់មកនាងបានឈប់ ។ មានអ្វីមួយទៀតដែលនាងចង់ដឹង ។ « អាប៊ុយឡា តើលោកយាយបានដឹងថាលោកអ៊ុំពេទ្រូនឹងមកថ្ងៃនេះមែនទេ ? តើនោះជាមូលហេតុដែលលោកយាយពុំបារម្ភឬ ? »

អាប៊ុយឡានិយាយថា « អត់ទេ » ។ នៅពេលដែលយាយថ្វាយដង្វាយមួយភាគក្នុងដប់របស់យាយ យាយមានជំនឿថាព្រះវរបិតាសួគ៌នឹងប្រទានពរជ័យដល់យាយ ។ ហើយទ្រង់ពិតជាបានប្រទានមែន ! »

អាណាបានឱបអាប៊ុយឡា ។ នាងមានអារម្មណ៍ថាជាក្មេងស្រីដែលមានសុភមង្គលបំផុតនៅក្នុងប្រទេសម៉ិកស៊ិក ។ នាង និង អាប៊ុយឡាមានសេចក្ដីជំនឿលើព្រះវរបិតាសួគ៌ ។ ឥឡូវនេះនាងអាចរង់ចាំញ៉ាំសម្លដ៏ឆ្ងាញ់របស់អាប៊ុយឡាបានហើយ ! ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ខារ៉ូឡាញណាខាងជើង ស.រ.អា. ។*

# ការធ្វើតាមពួកព្យាការី និង ពួកសាវក

ដោយ ដេណា កូហ្វាំង





ព្រះហៅព្យាការី និង សាវកដើម្បីបង្រៀនយើងពីអ្វីដែលទ្រង់មានព្រះទ័យចង់ឲ្យដឹង ។ នៅក្នុងព្រះគម្ពីរយើងអាចរៀនអំពីព្យាការីនានាដូចជា ណូអេ នីហ្វៃ និង យ៉ូសែប ស្ម៊ីធ ព្រមទាំងសាវកនានាដូចជាពេត្រុស និង ប៉ុល ។ យើងមានព្យាការី និង សាវកសព្វថ្ងៃនេះ !









ដកស្រង់ចេញពី *THE LORD FULFILLETH ALL HIS WORDS* ដោយ ក្លាក ខេ ផ្រៃ ដកស្រង់ចេញពី *JOSEPH SMITH JR.* ដោយដែនខូត អេ វេហ្គើឡែន ដកស្រង់ចេញពី *NEW TESTAMENT STORIES* ដោយ ប៉ុល ម៉ាន ដកស្រង់ចេញពី *NEPHI AND LEHI DIRECT BUILDING THE SHIP* ដោយ ជើរី ថមសុន រូបគំនូរដោយ ហ្គាស្ស ប្រ៊ូនើរ



## តើ « ព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ » គឺជានរណា ?

**ព្យាការី** និយាយជំនួសព្រះ ។

**អ្នកមើលឆុត** អាចមើលឃើញពីព្រឹត្តិការណ៍កាលពីអតីតកាល បច្ចុប្បន្នកាល និង អនាគតកាល ។

**អ្នកទទួលវិវរណៈ** បើកសម្ដែង ( ឬ បង្ហាញ ) យើងអំពីព្រះឆន្ទៈរបស់ព្រះ ។

- សមាជិកនៃគណៈប្រធានទីមួយគឺជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ ពួកសាវកក៏ដូចគ្នាផងដែរ ។
- មានតែប្រធាននៃសាសនាចក្រប៉ុណ្ណោះ ដែលមានសិទ្ធិអំណាចមកពីព្រះដើម្បីដឹកនាំសាសនាចក្រទាំងមូល ។
- តើមានព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈនៅរស់ប៉ុន្មាននាក់ដែលយើងមានសរុបទាំងអស់នោះ ?

**១២ ១៥ ៣ ១**

## ហេតុអ្វីវាសំខាន់ដើម្បីធ្វើតាមព្យាការី ?



ព្យាការីគឺដូចជាមនុស្សម្នាក់ដែលឃ្លាំមើលពីលើប៉ម ( សូមមើលទំព័រទី ៣៨ផងដែរ ) ។ លោកអាចមើលឃើញពីគ្រោះថ្នាក់ដែលនឹងកើតឡើង ហើយប្រាប់យើងពីរបៀបដើម្បីមានសុវត្ថិភាព ។ លោកជួយយើងឲ្យដើរតាមព្រះយេស៊ូវគ្រីស្ទ ។



## តើព្យាការីរបស់យើងបានប្រាប់ឲ្យយើងធ្វើអ្វីខ្លះ ?

ព្យាការីរបស់យើងសព្វថ្ងៃនេះគឺប្រធាន ថូម៉ាស អេស ម៉នសុន ។ នេះគឺជាចំណុចមួយចំនួនដែលលោកបានស្នើសុំឲ្យយើងធ្វើ ។

- ធ្វើតាមគំរូរបស់ព្រះយេស៊ូវ ហើយស្រឡាញ់មនុស្សគ្រប់គ្នា ។
- ថ្វាយដង្វាយមួយភាគក្នុងដប់ ហើយបរិច្ចាគដល់មូលនិធិសម្រាប់អ្នកផ្សាយសាសនា ។
- កុំមើលខ្សែភាពយន្ត ទូរទស្សន៍ និង ប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតដែលមិនល្អ ។
- សូមដាក់រូបភាពព្រះវិហារបរិសុទ្ធមួយ នៅគ្រប់បន្ទប់ដេកនីមួយៗ ។
- សិក្សាសុន្ទរកថាសន្និសីទទូទៅនានា ។
- ទៅសួរសុខទុក្ខចាស់ជរា ហើយធ្វើជាអ្នកជិតខាងល្អ ។

រើសកិច្ចការមួយមកពីបញ្ជីនេះ ដែលអ្នកអាចធ្វើក្នុងខែនេះ ។ តើអ្នកនឹងធ្វើអ្វីខ្លះ ? ■

# អាលម៉ាបានប្រែចិត្ត

អាលម៉ាគឺជាសង្ឃទុច្ចរិតម្នាក់របស់ស្ដេចណូអេ ។ លោកបានស្ដាប់ព្យាការីអាប៊ីណាដៃបង្រៀនអំពីព្រះបញ្ញត្តិ ។ អាលម៉ាបានដឹងថាលោកគួរតែផ្លាស់ប្ដូរជីវិតរបស់ខ្លួន ហើយធ្វើតាមព្រះជាជាងធ្វើអំពើទុច្ចរិត ។ លោកបានកត់ទុកនូវអ្វីដែលអាប៊ីណាដៃបានបង្រៀន ។ លោកបានចាប់ផ្ដើមបង្រៀនដំណឹងល្អដល់មនុស្សដទៃទៀត ។ ក្រោយមកលោកមានគ្រួសារ ហើយបានដាក់ឈ្មោះកូនប្រុសរបស់លោកម្នាក់ថាអាលម៉ា ។



ខ្ញុំបានកំពុងលេងជាអ្នកចាំទី ហើយខ្ញុំលេងបានល្អ ណាស់ ។ ក្រោយមកខ្ញុំបានចាំថា ខ្ញុំត្រូវតែប្រែចិត្តចំពោះការនិយាយមិនល្អកាលពីម្សិលមិញ ។ ខ្ញុំគួរតែប្រែចិត្ត ប៉ុន្តែខ្ញុំកំពុងតែប្រកួតបាល់ ។ ក្រោយមកខ្ញុំបានចងចាំពីរឿងមួយ ។ អ្នកអាចអធិស្ឋានទោះអ្នកនៅទីណាក៏ដោយ ! បន្ទាប់ពីខ្ញុំបានអធិស្ឋាន ខ្ញុំមានអារម្មណ៍ល្អថាខ្ញុំបានប្រែចិត្ត ។

**ភីធើរ ជី អាយុ៨ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អ.**



*ដាម៉ែន ប៊ី អាយុ៨ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អ.*

រូបគំនូរ ដោយ ម៉ាអេខ បើកស្ទ័រ

កាត់ បត់ ហើយរក្សាកាតសំណូមពរនេះ !




## ខ្ញុំអាចប្រែចិត្តបាន !

- ☐ សូមទន្ទេញ ម៉ូសាយ ១៨:៩ ។
- ☐ សូមសរសេរ ឬ គូសអ្វីមួយដែលព្យាការីបានមានប្រសាសន៍នៅក្នុងសន្និសីទទូទៅ ។
- ☐ សូមរើសយករបៀបមួយដែលអ្នកអាចផ្លាស់ប្ដូរឲ្យបានកាន់តែប្រសើរឡើង ។ សូមព្យាយាមធ្វើវានៅក្នុងខែនេះ ។
- ☐ ខ្ញុំសំណូមពរដល់ខ្លួនឯងដើម្បី . . .

______________________

ខ្ញុំអាចអានព្រះគម្ពីរមរមន

## ខគម្ពីរសម្រាប់ខែនេះ

បន្ទាប់ពីអ្នកអានវគ្គបទគម្ពីររួចសូមផាត់ពណ៌លើផ្នែកមាន ចុះលេខត្រូវគ្នាអំពីទឹកមរមន !

**១** ម៉ូសាយ ២១:១៤–១៦, ៣២–៣៥

**២** ម៉ូសាយ ២២:២, ១០–១៦

**៣** ម៉ូសាយ ២៤:៨, ១០–១៤

**៤** ម៉ូសាយ ២៧:៨, ១១, ១៨–២៤

**៥** ម៉ូសាយ ២៧:៣០–៣៧

**៦** ម៉ូសាយ ២៨:៣, ៥–១៥, ២០

**៧** អាលម៉ា ៨:១១–១៦, ១៨–២៧

**៨** អាលម៉ា ១១:៣៨–៤៦





## ទឹកមរមន

អាលម៉ាបានលាក់ខ្លួនពីស្ដេចណូអេដ៏ទុច្ចរិតនាកន្លែងសុខសាន្តមួយដែលហៅថាទឹកមរមន ។ មនុស្សជាច្រើនបានមកស្ដាប់អាលម៉ាបង្រៀនដំណឹងល្អ ។ ពួកគេចង់ជ្រមុជទឹក ។ នៅពេលអាលម៉ាបានជ្រមុជទឹកពួកគេ នោះពួកប្រជាជនបានធ្វើសេចក្ដីសន្យា ឬ សេចក្ដីសញ្ញាដូចគ្នាដែលយើងធ្វើនៅពេលយើងជ្រមុជទឹក ។ អ្នកអាចអានបន្ថែមអំពីអំពីការសន្យាទាំងនេះនៅទំព័របន្ទាប់ ។ ■

រូបគំនូរដោយ ម៉ារេខ ប៊ើកស្ទ្រុំ *THE CONVERSION OF ALMA* ដោយ អាណុល ហ្វ្រីប៊ើក

# អាលម៉ាជ្រមុជទឹកមនុស្សជាច្រើននាក់



អាប៊ីណាដៃគឺជាព្យាការី ។ លោកបានបង្រៀនមនុស្សឲ្យជឿលើព្រះយេស៊ូវ ហើយឈប់ធ្វើទង្វើអាក្រក់ ។ ស្ដេចទុច្ចរិតមួយអង្គឈ្មោះណូអេ បានខ្ញាល់នឹងអ័ប៊ីណាដៃ ។ ណូអេមិនចង់ប្រែចិត្តឡើយ ។



បុរសម្នាក់ឈ្មោះអាលម៉ាបានជឿលើអ័ប៊ីណាដៃ ។ លោកបានរត់គេចខ្លួន ហើយលាក់ខ្លួនពីស្ដេចដែលខ្ញាល់នោះ ។ លោកមានអារម្មណ៍សោកស្ដាយចំពោះទង្វើដែលធ្វើខុស ហើយលោកបានប្រែចិត្ត គឺដូចជាអ្វីដែលអាប៊ីណាដៃបានបង្រៀន ។

រូបគំនូរដោយ អាប៊្រីល ស្កត



មនុស្សជាច្រើនបានមក
ស្ដាប់អាលម៉ាបង្រៀនអំពី
ព្រះយេស៊ូវគ្រីស្ទ ។ អាលម៉ាបានបង្រៀន
ថា ប្រសិនបើពួកគេបានប្រែចិត្ត ហើយធ្វើតាម
ព្រះយេស៊ូវ នោះពួកគេអាចជ្រមុជទឹកបាន ។

ប្រជាជនបានទះដៃដោយក្ដីអំណរ ។
ពួកគេបានសន្យាដើម្បីលួងលោមអ្នក
ដទៃ ។ ពួកគេបានសន្យាថាស្រឡាញ់ព្រះ
និងប្រាប់អ្នកដទៃទៀតអំពីទ្រង់ ។ ពួកគេ
ត្រៀមខ្លួនជាស្រេចដើម្បីទទួលពិធីបុណ្យ
ជ្រមុជទឹក ។





អាលម៉ាបានជ្រមុជទឹកប្រជាជនម្នាក់ម្ដងៗ ។ ពួកគេមានក្ដីរីករាយណាស់ដែលបានធ្វើជាសមាជិកនៃសាសនាចក្ររបស់ព្រះយេស៊ូវ ។

នៅពេលយើងជ្រមុជទឹក យើងធ្វើសេចក្ដីសន្យាដូចគ្នាដែលប្រជាជនរបស់អាលម៉ាបានធ្វើផងដែរ ។ ហើយយើងក្លាយជាសមាជិកសាសនាចក្ររបស់ព្រះយេស៊ូវផងដែរ ! ■

*ចេញមកពី ម៉ូសាយ ១៦–១៨ ។*

# ថ្ងៃឈប់សម្រាកជាថ្ងៃដ៏ពិសេសមួយ



រូបគំនូរដោយ អាប៊ើល ស្តុត



ដោយប្រធាន ចច យូ ឃែណុន
( ឆ្នាំ ១៨២៧–១៩០១ )
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

# ស្វែងរកអំណោយទានខាងវិញ្ញាណ

*តើមានអ្នកគ្រប់គ្នាប៉ុន្មាននាក់ដែលស្វែងរកអំណោយទានទាំងនេះ ដែលព្រះបានសន្យាប្រទានឲ្យអ្នក ?*

បុរស និង ស្ត្រីគ្រប់រូបនៅក្នុងសាសនាចក្រនៃព្រះគ្រីស្ទ អាចមានអំណោយទាននៃព្រះវិញ្ញាណរបស់ព្រះ ដែលបានបានចែករំលែកដល់ពួកគេស្រប តាមសេចក្ដីជំនឿរបស់ពួកគេ និង តាមព្រះរាជបំណងរបស់ព្រះ ។ . . .

តើមានអ្នកគ្រប់គ្នាប៉ុន្មាននាក់ . . . ដែលស្វែងរកអំណោយទានទាំងនេះ ដែលព្រះបានសន្យាប្រទានឲ្យអ្នក ? តើមានអ្នកគ្រប់គ្នាប៉ុន្មាននាក់ ដែលនៅពេលអ្នកឱនក្បាលនៅចំពោះព្រះវរបិតាសួគ៌ នៅក្នុងរង្វង់គ្រួសារអ្នក ឬ នៅក្នុងកន្លែងសម្ងាត់របស់អ្នក ដោយទូលសុំអំណោយទានទាំងនេះត្រូវបានប្រទានដល់អ្នកទេ ? តើមានអ្នកគ្រប់គ្នាប៉ុន្មាននាក់ដែលទូលសូមព្រះវរបិតា នៅក្នុងព្រះនាមនៃព្រះយេស៊ូវ ដើម្បីបង្ហាញព្រះអង្គទ្រង់ដល់អ្នក តាមរយៈអំណាច និង អំណោយទានទាំងនេះ ? ឬ តើអ្នកបានបន្តជីវិតពីមួយថ្ងៃទៅមួយថ្ងៃ ដូចជាទ្វារដែលបើកចុះឡើង ដោយសារត្រចៀកវា ដោយគ្មានគោលដៅអ្វី ដោយពុំអនុវត្តសេចក្ដីជំនឿសោះ ដោយចង់ជ្រមុជទឹក ហើយក្លាយជាសមាជិកនៃសាសនាចក្រ ហើយសម្រាកនៅក្នុងទីនោះ ដោយគិតថាសេចក្ដីសង្គ្រោះរបស់អ្នកត្រូវបានធានា ហើយដោយសារតែអ្នកបានជ្រមុជទឹកហើយឬ ? . . .



. . . ខ្ញុំដឹងថាព្រះមានព្រះឆន្ទៈដើម្បីព្យាបាលអ្នកឈឺ ថាទ្រង់មានព្រះឆន្ទៈដើម្បីប្រទានអំណោយទាននៃការចេះសង្កេតនៃវិញ្ញាណ អំណោយទានឲ្យមានពាក្យសម្ដីនៃប្រាជ្ញាវាងវៃ នៃចំណេះដឹង និង នៃការព្យាករណ៍ និង អំណោយទានដទៃទៀតដែលចាំបាច់ ។ ប្រសិនបើពួកយើងណាម្នាក់ពុំល្អឥតខ្ចោះនោះ វាគឺជាកាតព្វកិច្ចរបស់យើងដើម្បីអធិស្ឋានសុំនូវអំណោយទាននោះដែលនឹងធ្វើឲ្យយើងបានល្អឥតខ្ចោះ ។ តើខ្ញុំគ្មានភាពល្អឥតខ្ចោះឬ ? ខ្ញុំគ្មានភាពល្អឥតខ្ចោះច្រើនណាស់ ។ តើកាតព្វកិច្ចរបស់ខ្ញុំមានអ្វីខ្លះ ? អធិស្ឋានទៅព្រះដើម្បីប្រទានអំណោយទាននោះ ដែលនឹងកែតម្រូវភាពមិនល្អឥតខ្ចោះទាំងនោះ ។ ប្រសិនបើខ្ញុំជាមនុស្សដែលមានកំហឹងម្នាក់ វាជាកាតព្វកិច្ចរបស់ខ្ញុំ ដើម្បីអធិស្ឋានទូលសុំនូវសេចក្ដីសប្បុរស ដែលមានចិត្តអត់ធ្មត់ ហើយក៏ចិត្តល្អ ។ តើខ្ញុំជាមនុស្សច្រណែនឈ្នានីសគេដែរឬទេ ? វាជាកាតព្វកិច្ចរបស់ខ្ញុំ ដើម្បីស្វែងរកសេចក្ដីសប្បុរស ដែលជាសេចក្ដីមិនច្រណែន ។ ដូច្នោះវាគឺជាអំណោយទានទាំងអស់នៃដំណឹងល្អ ។ អំណោយទានទាំងនោះ គឺសម្រាប់គោលបំណងនេះ ។ គ្មាននរណាម្នាក់គួរតែនិយាយថា « អូ ខ្ញុំពុំអាចផ្លាស់ប្ដូរបានទេ នេះជាទម្លាប់របស់ខ្ញុំ » ។ គាត់ពុំត្រូវបានធ្វើឲ្យឃើញថាត្រូវនៅក្នុងកិច្ចការនោះឡើយ ដ្បិតហេតុផលដែលថាព្រះបានសន្យា ប្រទានកម្លាំងដើម្បីកែតម្រូវកិច្ចការទាំងនេះ ហើយប្រទានអំណោយទានដែលនឹងលះបង់ការណ៍ទាំងនោះចេញ ។ ប្រសិនបើនរណាម្នាក់ខ្វះប្រាជ្ញា វាជាកាតព្វកិច្ចរបស់គាត់ដើម្បីសុំដល់ព្រះឲ្យប្រទានប្រាជ្ញាដល់គាត់ ។ ការណ៍នេះគឺវាដូចនឹងការណ៍ផ្សេងៗទៀត ។ វាគឺជាការរៀបចំរបស់ព្រះចំពោះសាសនាចក្ររបស់ទ្រង់ ។ ទ្រង់មានព្រះទ័យចង់ឲ្យពួកបរិសុទ្ធទ្រង់បានល្អឥតខ្ចោះនៅក្នុងសេចក្ដីពិត ។ ដោយហេតុតែគោលបំណងនេះ ទ្រង់បានប្រទាននូវអំណោយទានទាំងនេះ ហើយប្រទានដល់ពួកអ្នកដែលស្វែងរកទ្រង់ ដើម្បីឲ្យពួកគេអាចក្លាយជាមនុស្សល្អឥតខ្ចោះនៅលើផ្ទៃផែនដីនេះ ទោះបើមានភាពទន់ខ្សោយក្ដី ដោយសារព្រះបានសន្យាថាប្រទានអំណោយទានដែលចាំបាច់សម្រាប់ភាពល្អឥតខ្ចោះរបស់ពួកគេ ។ ■

*ដកស្រង់ចេញពី* The Latter-day Saints Millennial Star *ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៨៩៤ ទំព័រ ២៥៨–៦១ ការដាក់វណ្ណយុត្តិ និង សរសេរជាអក្សរពុម្ពត្រូវបានធ្វើឡើងតាមបទដ្ឋាន ។*

រូបថត © ISTOCK/THINKSTOCK

# ការយល់ដឹង



**តើសេចក្ដីជំនឿតាំងពីក្មេងមក អាចរីកចម្រើនទៅជាចំណេះដឹង និង ទីបន្ទាល់មួយបានយ៉ាងដូចម្ដេច ?**

« ខ្ញុំជឿទៅលើព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទជានិច្ច ។ ខ្ញុំស្រឡាញ់ពួកទ្រង់ តាំងពីខ្ញុំបានរៀនពីពួកទ្រង់ពេលលុតជង្គង់ជិតម្ដាយដ៏ល្អរបស់ខ្ញុំ ពេលអានគម្ពីរ និងអានរឿងនានានៃដំណឹងល្អ ។ ឥឡូវនេះជំនឿតាំងពីក្មេងរបស់ខ្ញុំនោះបានរីកចម្រើនក្លាយទៅជាចំណេះដឹង និង ទីបន្ទាល់អំពីក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ ដែលស្ដាប់ និង ឆ្លើយការអធិស្ឋានរបស់យើង » ។

**អែលឌើរ រ៉ូណល អេ រ៉ាសបាន** នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « I Stand All Amazed » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៩០ ។

# មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់យុវមជ្ឈិមវ័យ



### ការទទួលស្គាល់ ភាពក្លែងបន្លំរបស់សាតាំង

ទំព័រ ៤៤

មានគន្លឹះមួយដើម្បីប្រាប់ពីភាពខុសគ្នារវាងការកុហករបស់សាតាំង និង សេចក្ដីពិតរបស់ព្រះអម្ចាស់ ។

## សម្រាប់យុវវ័យ

ទំព័រ ៦០

ទោះបីជាអ្នក

### អៀនខ្មាសក៏ដោយ

តើអ្នកធ្លាប់មានអារម្មណ៍ថាអៀនខ្មាស ឬ ភ័យខ្លាចដើម្បីចែកចាយដំណឹងល្អដែរឬទេ ? នេះជារបៀបបីយ៉ាង ។



## សម្រាប់កុមារ



### ការធ្វើតាមពួកព្យាការី និង ពួកសាវក

ទំព័រ ៧២

តើចំណុចណាមួយដែលអ្នកអាចធ្វើនៅក្នុងខែនេះ ដើម្បីធ្វើតាមប្រធាន ថូម៉ាស អេស ម៉នសុន ?

CAMBODIAN
4 02132 84258 7

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ